រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍

## លទ្ធផលនៃវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើកទី១ (២០២១-២០២៤) ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០"



ខែមីនា ឆ្នាំ២០២៥

# មាតិកា


**មាតិកា** .......... i

I. **សេចក្តីផ្តើម** .......... ១

II. **សមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** .......... ៤

III. **អំពីការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ** .......... ៧

**ក. ដំណើរការ និងគោលការណ៍នៃការរៀបចំវេទិកា** .......... ៧

**ខ. លទ្ធផលនៃការរៀបចំវេទិកា** .......... ៩

ខ.១. ការរៀបចំកិច្ចការនានាគាំទ្រដល់ការរៀបចំវេទិកា .......... ៩

ខ.២. ការរៀបចំវេទិកានៅថ្នាក់ក្រោមជាតិ .......... ១០

ខ.២.១. ការរៀបចំកិច្ចប្រជុំ និងកិច្ចការនានានៅថ្នាក់ឃុំ សង្កាត់ .......... ១០

ខ.២.២. ការរៀបចំកិច្ចប្រជុំ និងកិច្ចការនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ .......... ១២

ខ.២.៣. ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត .......... ១៤

ខ.៣. ការរៀបចំកិច្ចប្រជុំអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. និងកិច្ចប្រជុំ គ.ជ.អ.ប. .. ១៨

ខ.៣.១. កិច្ចប្រជុំរបស់អនុគណៈកម្មាធិការមុខងារនិងធនធាន .......... ១៩

ខ.៣.២. កិច្ចប្រជុំរបស់អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ .... ២០

ខ.៣.៣. កិច្ចប្រជុំរបស់អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ .......... ២០

ខ.៣.៤. កិច្ចប្រជុំ គ.ជ.អ.ប. .......... ២១

**គ. ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ** .......... ២៤

IV. **និសដៅបន្ត** .......... ៣២

V. **សេចក្តីសន្និដ្ឋាន** .......... ៣៣

**ឯកសារភ្ជាប់ និងឧបសម្ព័ន្ធនានា**

## I. សេចក្តីផ្តើម

បន្ទាប់ពីសម្រេចបាននូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង តាមរយៈ **គោលនយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល ដោយសម្រេចបានសមិទ្ធផលធំៗលើគ្រប់វិស័យ។ ផ្អែកលើមូលដ្ឋាននៃសមិទ្ធផលដែលសម្រេចបាននារយៈពេល១៨ខែកន្លងមកនេះ រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧នៃរដ្ឋសភា ដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ដែលស្នូលនៃយុទ្ធសាស្ត្របញ្ចកោណគឺ ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច។

"កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ" ឬហៅម្យ៉ាងទៀតថា "កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ" គឺជាកំណែទម្រង់ស្នូលដ៏សំខាន់មួយក្នុងចំណោមកំណែទម្រង់ស្នូលនានា ជាអាទិ៍ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលបំណងបង្កើតវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋាន លើកកម្ពស់អភិបាលកិច្ចល្អលើការអនុវត្តមុខងារ ការចាត់ចែង និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព សំដៅលើកកម្ពស់គុណភាពសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាន លើកស្ទួយគុណភាពជីវិតរបស់ប្រជាពលរដ្ឋ និងចូលរួមកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងសមធម៌សង្គម។

ការធ្វើវិមជ្ឈការនៅកម្ពុជាបានចាប់ផ្តើមដំបូងជាប្រវត្តិសាស្ត្រនាឆ្នាំ២០០២ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

កំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់នេះបានរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន រួមទាំងប្រព័ន្ធកសាងផែនការអភិវឌ្ឍដែលមានការចូលរួមពីប្រជាពលរដ្ឋ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ នីតិវិធីនៃការគ្រប់គ្រងនិងចាត់ចែងកិច្ចការរដ្ឋបាល ការផ្តល់សេវាសាធារណៈ សេវាសង្គម ការរៀបចំវេទិកាសាធារណៈ ការងារគណនេយ្យភាពសង្គម ការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានានៅមូលដ្ឋាន និងនីតិវិធីបំពេញការងារផ្សេងៗទៀត ដោយឈរលើគោលការណ៍គ្រឹះនៃអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ផ្អែកលើភាពជោគជ័យនៃកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាពនៃកំណែទម្រង់នេះទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត តាមរយៈការរៀបចំក្របខ័ណ្ឌ

យុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៥) ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨) ព្រមទាំងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនាឆ្នាំ២០០៩។

ការពង្រីកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាការធ្វើកំណែទម្រង់កាន់តែមានភាពស៊ីជម្រៅ ដែលមានលក្ខណៈសាំញ៉ាំ និងស្មុគស្មាញជាងការធ្វើកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ ហើយមានផលប៉ះពាល់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងទៅលើក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ទាំងទៅលើរចនាសម្ព័ន្ធគ្រប់គ្រង មុខងារ សិទ្ធិអំណាច និងទាំងទៅលើធនធាន (ធនធានមនុស្ស ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ដើម្បីធានាឱ្យការពង្រីកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងដំណាក់កាលនេះឱ្យទទួលបានជោគជ័យ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាផែនការរយៈពេលវែង ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តកំណែទម្រង់នេះទៅតាមដំណាក់កាលនីមួយៗ។

ទន្ទឹមគ្នានេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ក៏ត្រូវបានបង្កើតឡើងក្រោមការដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** និងបន្តដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំសម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះស្របតាមកម្មវិធីជាតិដំណាក់កាលនីមួយៗ។

រហូតមកដល់បច្ចុប្បន្ននេះ គ.ជ.អ.ប. បានដឹកនាំ សម្របសម្រួលរៀបចំ និងអនុវត្តបញ្ចប់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំដំណាក់កាលទី១ (២០១០-២០២០) ប្រកបដោយជោគជ័យ ព្រមទាំងបានបន្តរៀបចំ និងកំពុងដឹកនាំសម្របសម្រួលអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី២(២០២១-២០៣០)។ ចក្ខុវិស័យនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២នេះ គឺ **"ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម ដែលជាការរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ សំដៅប្រែក្លាយកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០"**។

ផ្អែកតាមបទពិសោធន៍នៅបណ្តាប្រទេសនានា និងបទពិសោធន៍ជាក់ស្តែងនៅកម្ពុជា ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកិច្ចការដែលមានភាពស្មុគស្មាញ និងសាំញ៉ាំដែលទាមទារឱ្យមានការពិនិត្យ វាយតម្លៃ និងពិភាក្សា ពិគ្រោះយោបល់គ្នាឱ្យបានទូលំទូលាយពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាឱ្យមានភាពស្រុះស្រួលឯកភាពគ្នាក្នុងចំណោមភាគីពាក់ព័ន្ធនៃស្ថាប័នរដ្ឋ ស្ថាប័នមិនមែនរដ្ឋ ផ្នែកឯកជន និងសាធារណជនជាទូទៅក្នុងការជំរុញឱ្យដំណើរការកែទម្រង់នេះអាចបោះជំហានទៅមុខប្រកបដោយភាពវិជ្ជមាន មានការចូលរួម ការគាំទ្រ និងការទទួលខុសត្រូវប្រកបដោយភាពម្ចាស់ការក្នុងការរួមគ្នាពង្រឹងអភិបាលកិច្ចនៅមូលដ្ឋានឱ្យកាន់តែល្អប្រសើរស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

អាស្រ័យហេតុនេះ ក្នុងរយៈពេលប្រមាណជាង២ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់យកវិធីសាស្ត្រនៃការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដោយភាពប្រយ័ត្នប្រយែងខ្ពស់ តាមជំហានៗ មានសនិទានភាព មានផែនការច្បាស់លាស់ មានការសម្របសម្រួល ការពិគ្រោះយោបល់ និងមានការឯកភាពគ្នា ស្របតាមអភិក្រម "**អនុវត្តផង ដកស្រង់បទពិសោធន៍ផង**"។

កំណែទម្រង់នេះមានការវិវត្តកាន់តែស៊ីជម្រៅពីមួយដំណាក់កាលទៅមួយដំណាក់កាល ដែលចាំបាច់តម្រូវឱ្យមានចូលរួមកាន់តែសកម្ម និងការពិគ្រោះយោបល់កាន់តែទូលំទូលាយក្នុងចំណោមអ្នកពាក់ព័ន្ធនានាសម្រាប់ជាមូលដ្ឋានក្នុងការពង្រឹង និងពង្រីកការអនុវត្តកម្មវិធីកំណែទម្រង់នេះឱ្យកាន់តែមានប្រសិទ្ធភាព សំដៅរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានភាពធន់ ម្ចាស់ការ មានសមត្ថភាព លទ្ធភាព ភាពស្អាតស្អំ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែចំទិសដៅ ឆាប់រហ័ស និងកាន់តែមានគុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧នៃរដ្ឋសភា បានបន្តតម្កល់ឆន្ទៈបន្តជំរុញ និងពង្រឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជាកំណែទម្រង់ស្នូលផ្នែកអភិបាលកិច្ច គឺជាកិច្ចការដ៏មានសារៈសំខាន់ក្នុងការចូលរួមបង្កើនល្បឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ដូចបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

អាស្រ័យហេតុនេះ ក្រោមគំនិតផ្តួចផ្តើមប្រកបដោយភាពឈ្លាសវៃ និងទស្សនៈវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧នៃរដ្ឋសភាបានសម្រេចឱ្យរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិក្រោមប្រធានបទស្តីពី "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**" ក្នុងគោលបំណងពិគ្រោះពិភាក្សា និងរួមគ្នាវាយតម្លៃលើវឌ្ឍនភាព និងបញ្ហាប្រឈមជាគន្លឹះ ដើម្បីធានាឱ្យរាជរដ្ឋាភិបាលមានមូលដ្ឋានកាន់តែច្បាស់ និងជាក់លាក់ក្នុងការកំណត់ និងដាក់

ចេញការតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់សម្រួចការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព។

## II. សមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងរយៈពេលជាង២២ឆ្នាំនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានកសាងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានភាពធន់ ខ្លាំង និងវៃឆ្លាតក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ធនធាន និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ជារួម គិតមកដល់ពេលនេះ ដោយមានការចូលរួមគាំទ្រពីកំណែទម្រង់គន្លឹះ និងកំណែទម្រង់តាមវិស័យនានា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាបានជំរុញឱ្យការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

– រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតថ្នាក់ត្រូវបានរៀបចំឡើង និងកែសម្រួលជាបន្តបន្ទាប់ឱ្យកាន់តែមានភាពធន់មាំ មានសមត្ថភាព និងលទ្ធភាពក្នុងការគ្រប់គ្រង ការចាត់ចែង ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ក្នុងនោះរួមមាន ការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោតជាសកល និងអសកលស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការរៀបចំ និងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធគ្រប់គ្រងតាមគោលការណ៍អភិបាលកិច្ចមូលដ្ឋាន ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ដែលមានការចូលរួមពីប្រជាពលរដ្ឋ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ នាឆ្នាំ២០២០កន្លងមកនេះ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ត្រូវបានកែសម្រួលឡើងវិញ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នចំនួន២០ចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាពដែលអាចម្ចាស់ការក្នុងការដឹកនាំ គ្រប់គ្រង ចាត់ចែងមុខងារ និងការប្រើប្រាស់ធនធានរបស់ខ្លួន ព្រមទាំងមានសមត្ថភាពក្នុងការដឹកនាំ សម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍនានាដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

– ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលបានផ្ទេរមុខងារសំខាន់ៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះរួមមាន មុខងារក្នុងវិស័យសង្គមកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ការផ្តល់សេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះ និងមុខងារក្នុងវិស័យសុខាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល រួមមានមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព

ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស។ ទន្ទឹមនោះ តាមរយៈការធ្វើសមាហរណកម្ម ការិយាល័យជំនាញទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មុខងារចំនួន**៥៩ក្នុងវិស័យទាំង២០**ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសផងដែរ។ មុខងារដែលបានផ្ទេរទាំងនេះពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាអាទិ៍ មុខងារក្នុងវិស័យអប់រំ កសិកម្ម អនាម័យ បរិស្ថាន សង្គមកិច្ច ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមូលដ្ឋាន ដូចជា ផ្លូវជនបទ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ សាលារៀនជាដើម។ ក្រៅពីនេះ មុខងារផ្តល់សេវារដ្ឋបាលមួយចំនួនក៏ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវារដ្ឋបាលទាំងនេះជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែមួយនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ។ តាមរយៈការផ្ទេរមុខងារទាំងនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលទ្ធភាព និងសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ ព្រមទាំងអាចដោះស្រាយសំណូមពរ និងបញ្ហាប្រឈមនានានៅតាមមូលដ្ឋានបានឆាប់រហ័ស និងទាន់ពេលវេលា ជាពិសេសការគ្រប់គ្រង និងការចាត់វិធានការទប់ស្កាត់ ថែទាំ និងព្យាបាលអ្នកជំងឺក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ១៩ក្នុងរយៈពេលកន្លងមកនេះ និងការជួយសង្គ្រោះប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។

– ប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំ និងកែសម្រួលជាបន្តបន្ទាប់ ដោយបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួន តាំងពីដំណាក់កាលនៃការប្រឡងជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្តូរកន្លែងធ្វើការ ការដាក់ពិន័យ ការបណ្តេញចេញ ការដាក់ឱ្យចូលនិវត្តន៍ និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិក លើកលែងតែការជ្រើសរើស ការបណ្តុះបណ្តាលគ្រូបង្រៀន និងគ្រូពេទ្យ។ ស្របពេលជាមួយនឹងការផ្ទេរមុខងារ បុគ្គលិករដ្ឋបាល និងបុគ្គលិកជំនាញប្រមាណ**១០ម៉ឺននាក់**ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះបុគ្គលិកក្រសួងមហាផ្ទៃចំនួន**ជាង៧.៥០០នាក់** បុគ្គលិកសុខាភិបាលចំនួន**ជាង២០.០០០នាក់** បុគ្គលិកអប់រំចំនួនប្រមាណ**ជាង៧០.០០០នាក់** និងបុគ្គលិកជំនាញបច្ចេកទេសពីក្រសួង ស្ថាប័នតាមវិស័យនានាចំនួនប្រមាណ៨.០០០នាក់។

– ពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានបង្កើត និងដាក់ឱ្យប្រតិបត្តិការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក និងការបង្កើតប្រភពចំណូលនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងប្រព័ន្ធរៀបចំ និងអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ រាជរដ្ឋាភិបាលបាន (១).បង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ដែលជាប្រព័ន្ធផ្ទេរធនធានថវិកាពីថវិកាជាតិទៅឱ្យឃុំ សង្កាត់ក្នុងអត្រា២%នៃ

ចំណូលចរន្តថវិកាជាតិក្នុងឆ្នាំ២០០៣ និងបានបង្កើនដល់៣,៥%ក្នុងឆ្នាំ២០២៥ ព្រមទាំងបានផ្ទេរធនធានបន្ថែមពីថវិកាជាតិជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយផ្នែកអភិវឌ្ឍមូលដ្ឋានក្នុងអត្រាប្រចាំឆ្នាំ១% ចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០២៥ (២).បង្កើតមូលនិធិក្រុង ស្រុកដែលជាប្រព័ន្ធផ្ទេរធនធានថវិកាពីថវិកាជាតិទៅក្រុង ស្រុក ក្នុងអត្រា០,៨% នៃចំណូលចរន្តថវិកាជាតិក្នុងឆ្នាំ២០១៣ និងបានបង្កើនដល់១,៦% ក្នុងឆ្នាំ២០២៥។ ទន្ទឹមនេះ ក៏បានផ្ទេរធនធានថវិកាពីប្រភពនានាបន្ថែមទៀតទៅឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធ្វើឱ្យថវិកាថ្នាក់ក្រោមជាតិមានការកើនឡើងពី**១០៥.៦៨៧លានរៀល** ប្រហាក់ប្រហែលនឹង**២៧,១០លានដុល្លារអាមេរិក**នៅឆ្នាំ២០០២ ដល់**៧.១៩៤ប៊ីលានរៀល** ប្រហាក់ប្រហែលនឹង**១.៧៥៥លានដុល្លារអាមេរិក** នៅឆ្នាំ២០២៥។ បើគិតចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលការផ្ទេរថវិកាសរុបប្រមាណ **៤៣.៦៤១ប៊ីលានរៀល** ប្រហាក់ប្រហែលនឹង **១០.៥៨០លានដុល្លារអាមេរិក**។

– ប្រព័ន្ធកសាងផែនការ គឺជាប្រព័ន្ធអភិបាលកិច្ចដ៏សំខាន់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ធ្វើសេចក្តីសម្រេចចិត្តតាមបែបប្រជាធិបតេយ្យរបស់ក្រុមប្រឹក្សាក្នុងការកំណត់ចក្ខុវិស័យ គោលដៅក្របខ័ណ្ឌអភិវឌ្ឍន៍ដែលក្រុមប្រឹក្សាចង់ឱ្យសម្រេចបាននៅក្នុងអាណត្តិរបស់ខ្លួន។ ច្បាប់រៀបចំអង្គការ បានតម្រូវឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានកាតព្វកិច្ចរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីធ្វើជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការជំរុញដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាននីមួយៗ។ ដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំដាក់ឱ្យអនុវត្ត និងកែលម្អជាបណ្តើរៗ ដើម្បីធានាឱ្យមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈផ្សេងៗគ្នានៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិផង ព្រមទាំងឱ្យមានប្រសិទ្ធភាពក្នុងការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋផង សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានកែលម្អ និងធ្វើទំនើបកម្មនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យជាមូលដ្ឋានបម្រើឱ្យការវិភាគ ការកំណត់បញ្ហា និងការកំណត់តម្រូវការអភិវឌ្ឍតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីធានាដល់ការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានភាពសុក្រឹតក្នុងការឆ្លើយតប និងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

– ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក៏ត្រូវបានលើកកម្ពស់ និងមានលក្ខណៈកាន់តែឆ្លើយតបតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងជីវភាពរស់នៅប្រចាំថ្ងៃតាមមូលដ្ឋាននីមួយៗ ដែលក្នុងមួយឆ្នាំៗ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសេវាកម្មប្រមាណជាង**២.០០០គម្រោង**។ ការផ្តល់សេវាសាធារណៈក៏ត្រូវបានកែលម្អ និងធ្វើទំនើបកម្មជាបណ្តើរៗ ដើម្បីបង្កភាពងាយស្រួល និងឆាប់រហ័សជូនប្រជាពលរដ្ឋ។ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវបានរៀបចំបង្កើតឡើង

និងបន្តពង្រឹង ពង្រីកឱ្យដំណើរការយ៉ាងសកម្មនៅទូទាំងប្រទេស ដោយបានបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់នានា ដែលរួមមានសេវារដ្ឋបាលប្រមាណជាង**៨០០ប្រភេទ** ក្នុងវិស័យចំនួន១៤។ ការិយាល័យប្រជាពលរដ្ឋ(Ombudsman)ក៏ត្រូវបានពង្រឹង និងពង្រីកឱ្យមានដំណើរការនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ការិយាល័យប្រជាពលរដ្ឋគឺជាយន្តការអព្យាក្រឹត្យមួយរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតួនាទីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការបំពេញការងារ និងការផ្តល់សេវានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់គុណភាពសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ទន្ទឹមនេះ ការងារគណនេយ្យភាពសង្គម ក៏ត្រូវបានដំណើរការយ៉ាងល្អប្រសើរនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់ ដែលតាមរយៈការងារគណនេយ្យភាពសង្គមនេះ បានផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវព័ត៌មាន និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានានៅមូលដ្ឋាន ការចូលរួមក្នុងការអនុវត្តដោយផ្ទាល់ក្នុងដំណើរការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងការចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើដំណើរការនៃការផ្តល់សេវាសាធារណៈ និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## III. អំពីការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ក. ដំណើរការ និងគោលការណ៍នៃការរៀបចំវេទិកា

វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ត្រូវបានរៀបចំឡើងក្រោមគំនិតផ្តួចផ្តើមដ៏ឈ្លាសវៃ និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ផ្អែកលើគំនិតផ្តួចផ្តើមនេះ រាជរដ្ឋាភិបាល និងគ.ជ.អ.ប. បានរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានសម្រាប់ការរៀបចំវេទិកា រួមមានដូចខាងក្រោម៖

– សេចក្តីជូនដំណឹងលេខ១៧៤ សជណ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំការពិនិត្យ សម្រេចលើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ការរៀបចំវេទិការវាងរាជរដ្ឋាភិបាលនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

– សេចក្តីណែនាំលេខ ០១៥ សសរ/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់គ.ជ.អ.ប. ស្តីពីដំណើរការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

– សេចក្តីសម្រេចលេខ ០១៤ សសរ/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់គ.ជ.អ.ប. ស្តីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់រៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

វេទិកានេះត្រូវរៀបចំរៀងរាល់៣ឆ្នាំម្តង ដោយចាប់ផ្តើមអនុវត្តដំបូងពីឆ្នាំ២០២៤នេះទៅ។ ការរៀបចំវេទិកានេះ ត្រូវអនុវត្តតាមជំហានសំខាន់ៗចំនួនបីគឺ៖

**ជំហានទី១៖** រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់នឹងរៀបចំវេទិកានៅតាមរដ្ឋបាលសាមីនីមួយៗ ដើម្បីបូកសរុបលទ្ធផលនៃការបំពេញការងារ និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងពិនិត្យ ពិភាក្សាទៅលើវឌ្ឍនភាព និងបញ្ហាប្រឈម ព្រមទាំងកំណត់នូវវិធានការចាំបាច់នានាសម្រាប់ដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរនានាដែលរដ្ឋបាលរបស់ខ្លួនបានជួបប្រទះដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ។ ចំពោះបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣ថ្នាក់ពុំអាចដោះស្រាយបាន ត្រូវលើកស្នើមករដ្ឋបាលថ្នាក់លើជាបន្តបន្ទាប់ និងមករាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា ដើម្បីពិនិត្យ និងដោះស្រាយ។

**ជំហានទី២៖** ការរៀបចំកិច្ចប្រជុំអនុគណៈកម្មាធិការនានានៃគ.ជ.អ.ប. និងកិច្ចប្រជុំ គ.ជ.អ.ប. ដើម្បីវាយតម្លៃ ពិនិត្យ ពិភាក្សាលើបញ្ហាប្រឈមនិងសំណើសំណូមពរ ដែលបានស្នើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់វិធានការដោះស្រាយបញ្ហាប្រឈមទាំងនោះ ព្រមទាំងកំណត់បញ្ហាប្រឈមជាគន្លឹះ និងសំណើដំណោះស្រាយនានាដែលត្រូវលើកអនុសាសន៍ដាក់ជូនប្រមុខរាជរដ្ឋាភិបាលដាក់ចេញនូវគោលការណ៍តម្រង់ទិសសម្រាប់ការដោះស្រាយបញ្ហាប្រឈមជាគន្លឹះទាំងនោះនៅក្នុងវេទិកានៅថ្នាក់ជាតិ។

**ជំហានទី៣៖** ការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីវាយតម្លៃលើវឌ្ឍនភាព និងបញ្ហាប្រឈមជាគន្លឹះ ព្រមទាំងការដាក់ចេញវិធានការដោះស្រាយ និងការតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់សម្រួចការរៀបចំ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការចូលរួមសម្រេចគោលបំណងនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ក្នុងឆ្នាំ២០២៤នេះ វេទិកាផ្តោតលើប្រធានបទសំខាន់ៗ**ចំនួន៧** ដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន៖

១. ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២. ស្ថានភាពនៃការផ្ទេរមុខងារ និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ស្ថានភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការគ្រប់គ្រង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយស្ថាប័នថ្នាក់ជាតិ និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ

៦. ការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន និង

៧. ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ ការធ្វើអធិការកិច្ច និងសវនកម្មមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២. លទ្ធផលនៃការរៀបចំវេទិកា

### ២.១. ការរៀបចំកិច្ចការនានាគាំទ្រដល់ការរៀបចំវេទិកា

បន្ទាប់ពីការដាក់ចេញនូវសេចក្ដីណែនាំ និងក្របខ័ណ្ឌពេលវេលានៃកិច្ចដំណើរការវេទិកា គ.ជ.អ.ប. បានរៀបចំចាត់ចែងកិច្ចការចាំបាច់នានា និងផ្ដល់ការគាំទ្រដល់ការអនុវត្ត រួមមានដូចខាងក្រោម៖

– បានរៀបចំពិធីផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវសេចក្ដីណែនាំស្ដីពីដំណើរការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផែនការសកម្មភាពសម្រាប់អនុវត្តវេទិកានេះជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ដែលមានអ្នកចូលរួមសរុប**ប្រមាណ ១១០រូប** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**។ ក្នុងពិធីផ្សព្វផ្សាយនេះ គ.ជ.អ.ប. ក៏បានណែនាំឱ្យរដ្ឋបាលរាជធានី ខេត្តនីមួយៗ រៀបចំបង្កើតក្រុមការងារបច្ចេកទេសនៅថ្នាក់រាជធានី ខេត្តនីមួយៗដែលមានអភិបាលរង១រូប ជាប្រធានក្រុមការងារ ដើម្បីសម្របសម្រួលរៀបចំកិច្ចប្រជុំ និងវេទិកានៅថ្នាក់ក្រោមជាតិ។

– បានរៀបចំបង្កើតក្រុមការងារអន្តរក្រសួងជាសេនាធិការ ដើម្បីគាំទ្រ តាមដាន និងត្រួតពិនិត្យដំណើរការរៀបចំវេទិកានេះ (សេចក្ដីសម្រេចលេខ០២៩ សសរ/គ.ជ.អ.ប. ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤)។ ក្រុមការងារអន្តរក្រសួងនេះ ដឹកនាំសម្របសម្រួលដោយ **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប.** និងមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ ក្រសួងកិច្ចការនារី សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន គ.ជ.អ.ប. **សរុបចំនួន ៣១រូប**។ ជាមួយគ្នានេះ គ.ជ.អ.ប. ក៏បានបង្កើតឡើងនូវក្រុមការងារប្រចាំការជាសេនាធិការឱ្យក្រុមការងារអន្តរក្រសួងក្នុងការជួយគាំទ្រ តាមដាន និងត្រួតពិនិត្យជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមការងារប្រចាំការនេះមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. មានសរុបចំនួន **៥ក្រុម** ដែលក្នុង១ក្រុមទទួលខុសត្រូវលើរដ្ឋបាលរាជធានី ខេត្តចំនួន៥។

– លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំវគ្គបណ្ដុះបណ្ដាលដល់ក្រុមការងារបច្ចេកទេសនៅថ្នាក់រាជធានី ខេត្តនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ អំពីខ្លឹមសារសំខាន់ៗពាក់ព័ន្ធនឹងគោលការណ៍ បែបបទ និងនីតិវិធីនៃដំណើរការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផែនការសកម្មភាពឆ្នាំ២០២៤ ដែលមានអ្នកចូលរួម**សរុបប្រមាណ ៨០រូប**។ បន្ទាប់ពីវគ្គបណ្ដុះបណ្ដាលនេះ រដ្ឋបាលរាជធានី ខេត្តទាំង២៥ បានរៀបចំវគ្គបណ្ដុះបណ្ដាល និងផ្សព្វផ្សាយដល់គ្រប់រដ្ឋបាលឃុំ សង្កាត់ ក្រុង

ស្រុក ខណ្ឌ និងមន្ទីរ អង្គភាពពាក់ព័ន្ធដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចាប់ពីសប្ដាហ៍ទី៤ ខែមេសា រហូតបានចប់សព្វគ្រប់ត្រឹមចុងខែឧសភា ឆ្នាំ២០២៤។

– ក្រុមការងារបច្ចេកទេសអន្តរក្រសួងគាំទ្រដំណើរការនៃការរៀបចំវេទិកានេះ បានរៀបចំកិច្ចប្រជុំនាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីត្រួតពិនិត្យអំពីស្ថានភាព និងវឌ្ឍនភាពសំខាន់ៗនៃដំណើរការរៀបចំវេទិកានេះដែលបាន និងកំពុងអនុវត្តជាបណ្ដើរៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពិនិត្យ ពិភាក្សាអំពីផែនការសកម្មភាពរបស់ក្រុមការងារអន្តរក្រសួងក្នុងការគាំទ្រដល់ការរៀបចំកិច្ចប្រជុំ និងកិច្ចការចាំបាច់នានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ក្នុងកិច្ចការគាំទ្រដល់ការរៀបចំកិច្ចប្រជុំ និងវេទិកានៅថ្នាក់ក្រោមជាតិ ក្រុមការងារអន្តរក្រសួង និងលេខាធិការដ្ឋានគ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់ទាំងការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ (**ZOOM**) ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងារ និងផ្ដល់ការគាំទ្រ ណែនាំ និងតម្រង់ទិសដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីខ្លឹមសារ ប្រធានបទ និងដំណើរការនៃការរៀបចំវេទិកានេះ ព្រមទាំងសម្របសម្រួលដោះស្រាយបញ្ហានានាក្នុងដំណើរការរៀបចំវេទិកានេះ។ ក្រៅពីការបណ្ដុះបណ្ដាល និងតម្រង់ទិស ក្រុមការងារអន្តរក្រសួង និងលេខាធិការដ្ឋានគ.ជ.អ.ប. ក៏បានចុះសង្កេតដោយផ្ទាល់ និងគាំទ្រដំណើរការរៀបចំកិច្ចប្រជុំ និងវេទិកានៅតាមរាជធានី ខេត្តចំនួន ១៨ រួមមានរាជធានីភ្នំពេញ ខេត្តក្រចេះ បន្ទាយមានជ័យ ត្បូងឃ្មុំ កំពង់ឆ្នាំង ព្រះសីហនុ កំពង់ស្ពឺ ឧត្តរមានជ័យ ព្រះវិហារ កណ្ដាល មណ្ឌលគិរី ព្រៃវែង ប៉ៃលិន ពោធិ៍សាត់ តាកែវ សៀមរាប និងខេត្តបាត់ដំបង។

### ២.២. ការរៀបចំវេទិកានៅថ្នាក់ក្រោមជាតិ

#### ២.២.១. ការរៀបចំកិច្ចប្រជុំ និងកិច្ចការនានានៅថ្នាក់ឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ទាំង១.៦៥២ បានចាត់ចែងរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពការងាររយៈពេល៣ឆ្នាំ (២០២១-២០២៣) របស់រដ្ឋបាលឃុំ សង្កាត់សាមីនីមួយៗ ព្រមទាំងបានរៀបចំកិច្ចប្រជុំចាប់ពី**សប្ដាហ៍ទី៤ ខែឧសភា** រហូតដល់**សប្ដាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤** ក្រោមការដឹកនាំសម្របសម្រួលដោយមេឃុំ/ចៅសង្កាត់នីមួយៗ ដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការនានានៃឃុំ សង្កាត់ ថ្នាក់ដឹកនាំភូមិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងតំណាងសហគមន៍ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ឃុំ សង្កាត់នីមួយៗ ដើម្បីរួមគ្នាពិនិត្យ វាយតម្លៃទៅលើវឌ្ឍនភាពនៃការបំពេញការងារកន្លងមក និងពិភាក្សាទៅលើបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលបានលើកឡើង។ ក្នុងកិច្ចប្រជុំនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗបានកំណត់វិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរនានាក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន និងបានកំណត់បញ្ហាប្រឈម និងសំណើសំណូមពរដែលរដ្ឋបាលឃុំ សង្កាត់មិនអាចដោះស្រាយបាន ដើម្បីស្នើមករដ្ឋបាលក្រុង ស្រុក ខណ្ឌជួយពិនិត្យ និងដោះស្រាយ។

ផ្អែកតាមរបាយការណ៍របស់រដ្ឋបាលឃុំ សង្កាត់ បានបង្ហាញឱ្យឃើញថា តាមរយៈការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានរៀបចំឱ្យស្ថាប័នរដ្ឋបាលឃុំ សង្កាត់មានរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ មានមុខងារ ការទទួលខុសត្រូវ និងធនធានច្បាស់លាស់ និងកាន់តែច្រើនសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានកាន់តែមានភាពល្អប្រសើរឡើង។ ផ្អែកលើមូលដ្ឋាននេះ រដ្ឋបាលឃុំ សង្កាត់បានអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនទៅតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ តាមរយៈការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានការចូលរួមផ្តល់យោបល់ពីប្រជាពលរដ្ឋ ការកៀរគរធនធានពីអ្នកពាក់ព័ន្ធនានា ការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការដោះស្រាយបញ្ហាប្រឈមនិងសំណើសំណូមពរនានាបានទាន់ពេលវេលា។ ក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះ រដ្ឋបាលឃុំ សង្កាត់ទទួលបានធនធានថវិកាពីថ្នាក់ជាតិសរុបចំនួន**២.៥៣២ប៊ីលានរៀល** ស្មើនឹង **៦២០លានដុល្លារអាមេរិក**។ ផ្អែកលើមុខងារ និងធនធានថវិកាដែលទទួលបានពីថ្នាក់ជាតិ និងការកៀរគរពីប្រភពស្របច្បាប់ផ្សេងទៀត ក្នុងរយៈពេល៣ឆ្នាំ (២០២១-២០២៣) កន្លងមកនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗបានខិតខំបំពេញមុខងារ និងការទទួលខុសត្រូវរបស់ខ្លួន ដោយសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម រួមមាន៖

- រដ្ឋបាលឃុំ សង្កាត់បានផ្សព្វផ្សាយអំពីគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពនៅក្នុងមូលដ្ឋានរបស់ខ្លួនបានចំនួន **៣៤៥.២៥៩លើក** ក្នុងមួយលើកៗមានអ្នកចូលរួមប្រមាណពី **៤០-៥០នាក់** និងបានចូលរួមបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានចំនួន **១៤.០៦១ករណី**។

- រដ្ឋបាលឃុំ សង្កាត់បានផ្តល់សេវាសង្គម រួមមានដូចជាការផ្តល់ប័ណ្ណគ្រួសារក្រីក្រ ការឧបត្ថម្ភជនមានពិការភាព ប្រជាពលរដ្ឋក្រីក្រ គ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ ការគាំពារនិងថែទាំកុមារនិងស្ត្រីរងគ្រោះនិងងាយរងគ្រោះ ការជួយឧបត្ថម្ភប្រជាពលរដ្ឋក្នុងអំឡុងការរីករាលដាលជំងឺកូវីដ១៩ ការឧបត្ថម្ភប្រជាជនសម្រាកព្យាបាលនៅមន្ទីរពេទ្យ ការចែកសម្ភារៈសិក្សា ការផ្តល់រង្វាន់ដល់សិស្សពូកែ ការផ្តល់សម្ភារបង្គន់អនាម័យជូនគ្រួសារក្រីក្រ ជាដើម ដោយប្រើប្រាស់ថវិកាប្រមាណ **៣៧.៥៦៩,៨លានរៀល** ស្មើនឹង **៩លានដុល្លារ**។ រដ្ឋបាលឃុំ សង្កាត់ក៏បានចាត់ចែងផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយបានចំនួន **៣.២៥០.៩៧៤សេវា** និងចុះបញ្ជីអត្រានុកូលដ្ឋានបានចំនួន **៤.៤២៥.៣៩១សេវា**។

- រដ្ឋបាលឃុំ សង្កាត់បានសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងដែនសមត្ថកិច្ចរបស់ឃុំ សង្កាត់នីមួយៗ ក្នុងនោះការសាងសង់ និងជួសជុលផ្លូវលំជនបទបានចំនួន **៧.៣០៩គ.ម** ផ្លូវបេតុងបានចំនួន **១.៩៤២គ.ម** ផ្លូវក្រាលកៅស៊ូបានចំនួន **៣៩គ.ម** ប្រព័ន្ធទឹកកខ្វក់បានចំនួន **២២៨គ.ម** **និង១.៤៦៦កន្លែង** រួមទាំងការសាងសង់ប្រព័ន្ធធារាសាស្ត្រ ស្តារប្រឡាយបានចំនួន **១.៣២៥គ.ម**

ការសាងសង់ស្ថានីយបូមទឹក អណ្តូងស្នប់ ស្រះស្តុកទឹកបានចំនួន **២៦៤កន្លែង** និងស្ពានបានចំនួន **៣៨កន្លែង** ព្រមទាំងសាងសង់អគារសាលាបឋមសិក្សា និងសាលាមត្តេយ្យសិក្សាបានចំនួន**១១៩ខ្នង**។

– រដ្ឋបាលឃុំ សង្កាត់នីមួយៗបានរៀបចំឱ្យមានយន្តការនៃការផ្តល់ទទួលព័ត៌មាន និងឆ្លើយតបមតិយោបល់ ឬបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ ព្រមទាំងការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋាន ដែលជាលទ្ធផលឃុំ សង្កាត់បានផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋបានចំនួន**៧០.៦៧៥លើក** (តាមរយៈវេទិកាសាធារណៈ ទូរទស្សន៍ វិទ្យុ ក្តារព័ត៌មាន ព្រឹត្តិបត្តិព័ត៌មាន បណ្តាញសង្គម និងយន្តការគណនេយ្យភាពសង្គម) និងទទួលពាក្យបណ្តឹង សំណើសំណូមពររបស់ប្រជាពលរដ្ឋចំនួន **១០៨.០២១ករណី** ក្នុងនោះ សម្រុះសម្រួលដោះស្រាយបានចំនួន **១០០.២៤៣ករណី** (៩៣%) កំពុងដោះស្រាយចំនួន **៧៩៥ករណី** (០,៧%) និងបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធចំនួន **៦.៩៨៣ករណី** (៦,៣%)។

ជារួម ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំនៅថ្នាក់ឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសបានលើកឡើងនូវបញ្ហាប្រឈម និងសំណើសំណូមពរសរុបចំនួន**៥២** ក្នុងនោះដោះស្រាយដោយឃុំ សង្កាត់ផ្ទាល់ចំនួន **១៥** ដោះស្រាយដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន **៨** ដោះស្រាយដោយរដ្ឋបាលរាជធានី ខេត្តចំនួន**១៧** និងបានស្នើមកថ្នាក់ជាតិចំនួន **១២** ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១ នៃរបាយការណ៍នេះ។

### ៩.២.២. ការរៀបចំកិច្ចប្រជុំ និងកិច្ចការនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីទទួលបានរបាយការណ៍ពីរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង២០៩ បានរៀបចំបូកសរុបរបាយការណ៍របស់ឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារ៣ឆ្នាំ (២០២១-២០២៣) និងបញ្ហាប្រឈមរបស់ខ្លួនផងដែរ។ ផ្អែកលើរបាយការណ៍នេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗបានរៀបចំកិច្ចប្រជុំចាប់ពីសប្តាហ៍ទី១ខែមិថុនា រហូតដល់សប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០២៤។ កិច្ចប្រជុំនេះ ដឹកនាំសម្របសម្រួលដោយប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌ និងមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គណៈអភិបាល ប្រធានគណៈកម្មាធិការនានា នាយករដ្ឋបាលនិងមន្ត្រីចំណុះរដ្ឋបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដើម្បីរួមគ្នាពិនិត្យពិភាក្សាទៅលើវឌ្ឍនភាពការងារ និងខិតខំដោះស្រាយបញ្ហានានាដែលស្នើឡើងដោយរដ្ឋបាលឃុំ សង្កាត់ផង និងដោះស្រាយបញ្ហានានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗផង ព្រមទាំងកំណត់នូវបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌមិនអាចដោះស្រាយបាន ដើម្បីស្នើមករដ្ឋបាលរាជធានី ខេត្តជួយដោះស្រាយ។

ផ្អែកតាមរបាយការណ៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌបានបង្ហាញឱ្យឃើញថា តាមរយៈការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានរៀបចំឱ្យស្ថាប័នរដ្ឋបាលក្រុង ស្រុក ខណ្ឌមានរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព មានសិទ្ធិអំណាច មុខងារ ការទទួលខុសត្រូវ និងធនធានកាន់តែច្រើនសម្រាប់ផ្តល់សេវាសាធារណៈ និងការ

អភិវឌ្ឍមូលដ្ឋាន។ ជារួម ក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះ រដ្ឋបាលក្រុង ស្រុក ទទួលបានធនធានថវិកាសរុបចំនួន **១.៧០០ប៊ីលានរៀល** ស្មើនឹង **៤១៧លានដុល្លារអាមេរិក**។ ផ្អែកលើមូលដ្ឋាននេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានទៅតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានការចូលរួមផ្តល់យោបល់ពីប្រជាពលរដ្ឋ ការកៀរគរធនធានពីប្រភពស្របច្បាប់នានា ការផ្តល់សេវា និងការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរនានាបានទាន់ពេលវេលា។ ផ្អែកលើមុខងារ និងធនធានថវិកាដែលទទួលបានពីថ្នាក់ជាតិ និងការកៀរគរពីប្រភពស្របច្បាប់ផ្សេងទៀត និងតាមរយៈផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួនក្នុងរយៈពេល៣ឆ្នាំ (២០២១-២០២៣) កន្លងមកនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌបានបំពេញមុខងារ និងការទទួលខុសត្រូវរបស់ខ្លួន ដោយសម្រេចបានសមិទ្ធផលជាច្រើនក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម រួមមាន៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្សព្វផ្សាយពីការងារសន្តិសុខ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនបានចំនួន **៣៧០.៦២៣លើក** ដោយមានអ្នកចូលរួមចន្លោះពី**៤០-៥០នាក់** និងបានបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានចំនួន**២៥.១២៥ករណី**។

- រដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាត់ចែងផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយបានចំនួន **៥.១៧៨.២៣០សេវា** និងចុះបញ្ជីអត្រានុកូលដ្ឋានបានចំនួន **៦.១៨០.៧៩២សេវា**។ ជាមួយគ្នានេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏បានផ្តល់សេវាសង្គម រួមមានដូចជាការឧបត្ថម្ភជនមានពិការភាព ប្រជាពលរដ្ឋក្រីក្រ គ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ ការគាំពារដល់ស្ត្រីនិងកុមារ ការជួយឧបត្ថម្ភប្រជាពលរដ្ឋក្នុងអំឡុងការរីករាលដាលជំងឺកូវីដ១៩ ការឧបត្ថម្ភប្រជាជនសម្រាកព្យាបាលនៅមន្ទីរពេទ្យ ការផ្តល់សម្ភារៈបង្គន់អនាម័យជូនគ្រួសារក្រីក្រជាដើម ដោយប្រើប្រាស់ថវិកាប្រមាណ **៧.១៩៧លានរៀល** ស្មើនឹង **១,៨លានដុល្លារអាមេរិក**។

- រដ្ឋបាលក្រុង ស្រុក ខណ្ឌបានសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះការសាងសាង់ ជួសជុល និងថែទាំផ្លូវលំជនបទចំនួន **៦៣គ.ម** ផ្លូវបេតុងចំនួន **២៤៦គ.ម** ផ្លូវក្រាលកៅស៊ូចំនួន **៦១១គ.ម** ប្រព័ន្ធទឹកកខ្វក់ចំនួន **៤៤០គ.ម** រួមទាំងការសាងសង់ប្រព័ន្ធធារាសាស្ត្រ ស្តារប្រឡាយចំនួន **៧១គ.ម** ការសាងសង់ស្ថានីយបូមទឹក អណ្តូងស្នប់ ស្រះស្តុកទឹកចំនួន **៧៦កន្លែង** និងស្ពានបានចំនួន **៦០កន្លែង** និងរៀបចំកែលម្អសួនចំនួន **១២គ.មការ៉េ និង២១កន្លែង** ព្រមទាំងសាងសង់អគារសាលាបឋមសិក្សា និងមត្តេយ្យសិក្សាចំនួន **១ខ្នង**។

- រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗបានរៀបចំឱ្យមានយន្តការនៃការផ្តល់ទទួលព័ត៌មាន និងឆ្លើយតបមតិយោបល់ ឬបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ (ការិយាល័យប្រជាពលរដ្ឋ និងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន) ព្រមទាំងការសម្រុះសម្រួលដោះស្រាយបណ្តឹងដែលជាលទ្ធផល

ក្រុង ស្រុក ខណ្ឌបានផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋចំនួន **៣៩៧.៦០៤លើក** (តាមរយៈវេទិកាសាធារណៈ ទូរទស្សន៍ វិទ្យុ ក្ដារព័ត៌មាន ព្រឹត្តិបត្តិព័ត៌មាន បណ្ដាញសង្គម និងយន្តការគណនេយ្យភាពសង្គម) និងទទួលពាក្យបណ្ដឹង សំណើសំណូមពររបស់ប្រជាពលរដ្ឋចំនួន **១៩.៥៨៣ករណី** ក្នុងនោះសម្រុះសម្រួល ដោះស្រាយបានចំនួន **១៦.៣១៧ករណី** (៨៣%) កំពុងដោះស្រាយចំនួន **៦១៤ករណី** (៣%) និងបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ **២.៦៥២ករណី** (១៤%)។

ជារួម ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ រដ្ឋបាលក្រុង ស្រុក ខណ្ឌបានលើកឡើងនូវបញ្ហាប្រឈម និងសំណើសំណូមពរសរុបចំនួន **១០៣** ក្នុងនោះរដ្ឋបាលក្រុង ស្រុក ខណ្ឌបានដោះស្រាយសរុបចំនួន **៥០** ដោះស្រាយដោយរដ្ឋបាលរាជធានី ខេត្តចំនួន **៣៥** និងស្នើមករដ្ឋបាលថ្នាក់ជាតិដោះស្រាយចំនួន **១៨** ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

### ៩.២.៣. ការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្ត

ដោយហេតុថា ឆ្នាំ២០២៤នេះគឺជាឆ្នាំដំបូងនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ អាស្រ័យហេតុនេះ គ.ជ.អ.ប.បានសម្របសម្រួលជ្រើសរើសយករដ្ឋបាលខេត្តកំពតគឺជាខេត្តដែលត្រូវរៀបចំវេទិកាថ្នាក់ខេត្តស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមុនគេ ដើម្បីដកស្រង់មេរៀន និងបទពិសោធន៍នៃការរៀបចំវេទិកានៅថ្នាក់រាជធានី ខេត្តសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំវេទិកានៅតាមរាជធានី ខេត្តសាមីនីមួយៗ។ វេទិកានៅខេត្តកំពតនេះ បានប្រព្រឹត្តទៅនា**ថ្ងៃទី២៥-២៦ ខែកញ្ញា ឆ្នាំ២០២៤** ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនៅខេត្តកំពត និងមានការចូលរួមសង្កេតដោយផ្ទាល់ពីក្រុមការងារអន្តរក្រសួង ប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្តទាំង២៥ ព្រមទាំងមន្ត្រីបច្ចេកទេសសំខាន់ៗ។

ផ្អែកលើមេរៀនបទពិសោធន៍នៃការរៀបចំវេទិកានៅខេត្តកំពត រដ្ឋបាលរាជធានី ខេត្តទាំង២៤ បានរៀបចំបូកសរុបរបាយការណ៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារ៣ឆ្នាំ (២០២១-២០២៣) និងបញ្ហាប្រឈមរបស់ខ្លួនផងដែរ ព្រមទាំងបានរៀបចំវេទិកាស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្តរបស់ខ្លួន ចាប់ពីខែតុលារហូតចប់សព្វគ្រប់នៅខែវិច្ឆិកា ឆ្នាំ២០២៤។ វេទិកានៅថ្នាក់រាជធានី ខេត្តដឹកនាំសម្របសម្រួលដោយប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គណៈអភិបាល ប្រធានគណៈកម្មាធិការនានា នាយករដ្ឋបាលនិងមន្ត្រីចំណុះរដ្ឋបាលរាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញនានាជុំវិញរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សានិងអភិបាលក្រុង ស្រុក ខណ្ឌទាំងអស់និងមន្ត្រីពាក់ព័ន្ធ មេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ វេទិកានៅថ្នាក់រាជធានី ខេត្តប្រព្រឹត្តទៅរយៈពេល១ថ្ងៃកន្លះ ដោយមានបទអន្តរាគមន៍របស់ស្ថាប័ន/អង្គភាពពាក់ព័ន្ធមួយចំនួនទៅលើប្រធានបទសំខាន់ៗ (មេរៀន បទពិសោធន៍ គំនិតផ្ដួចផ្ដើម បញ្ហាប្រឈម និងវិធានការដោះស្រាយ) រួមមានដូចជា៖

១. ការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព
២. ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍
៣. ការអនុវត្តការងារគណនេយ្យភាពសង្គម
៤. ការគ្រប់គ្រងអនាម័យ និងបរិស្ថាន
៥. ការជំរុញ និងលើកកម្ពស់ទេសចរណ៍សហគមន៍ធម្មជាតិ
៦. ការផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយតាមប្រព័ន្ធឌីជីថល
៧. ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
៨. ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋាន
៩. ភាពជាដៃគូរវាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើការអភិវឌ្ឍមូលដ្ឋាន
១០.ការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរ
១១. ការគ្រប់គ្រង និងអនុវត្តមុខងារវិស័យសុខាភិបាល និងវិស័យសង្គមកិច្ចដែលបានផ្ទេរ ជាដើម។

ជាមួយគ្នានេះ វេទិកាថ្នាក់រាជធានី ខេត្តក៏បានពិនិត្យ ពិភាក្សា និងដាក់ចេញនូវវិធានការដោះស្រាយទៅតាមបញ្ហាប្រឈម និងសំណើសំណូមពរនីមួយៗ ព្រមទាំងបានកំណត់នូវបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលថ្នាក់រាជធានី ខេត្តមិនអាចដោះស្រាយបាន ដើម្បីស្នើសុំរដ្ឋបាលថ្នាក់ជាតិជួយដោះស្រាយ។

ផ្អែកតាមរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្តបានបង្ហាញឱ្យឃើញថា តាមរយៈការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលរាជធានី ខេត្តត្រូវបានរៀបចំឱ្យមានរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ មានសិទ្ធិអំណាច មុខងារកាន់តែច្បាស់លាស់ និងធនធានកាន់តែច្រើនឡើងសម្រាប់ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែមានភាពល្អប្រសើរ។ ផ្អែកលើមូលដ្ឋាននេះ រដ្ឋបាលរាជធានី ខេត្តបានថែរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ព្រមទាំងជំរុញការអភិវឌ្ឍមូលដ្ឋាន ផ្អែកទៅតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន។ ជារួមក្នុងរយៈពេល៣ឆ្នាំ (២០២១-២០២៣) កន្លងមកនេះ រដ្ឋបាលរាជធានី ខេត្តបានបំពេញមុខងារ និងការទទួលខុសត្រូវរបស់ខ្លួនដោយសម្រេចបានសមិទ្ធផលជាច្រើនក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម រួមមាន៖

- រដ្ឋបាលរាជធានី ខេត្តបានផ្សព្វផ្សាយពីការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនចំនួន **៤៧៥.៨១៣លើក** ក្នុងមួយលើកៗមានអ្នកចូលរួមចន្លោះពី **៤០-៥០នាក់** និងបានចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាចំនួន **៤០.១៦៣ករណី**។
- រដ្ឋបាលរាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយបានចំនួន **១.៦៩៦.៨៨៥សេវា**។ ជាមួយគ្នានេះ រដ្ឋបាលរាជធានី ខេត្តក៏បានផ្តល់សេវាសង្គម រួមមានដូចជា

ការគ្រប់គ្រងនិងការចាត់ចែងមណ្ឌលថែទាំកុមាររដ្ឋ ការឧបត្ថម្ភគាំពារដល់ជនមានពិការភាព គ្រួសារក្រីក្រ គ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ និងជំងឺកាចសាហាវនានា ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ កិច្ចការគាំពារដល់ស្ត្រីនិងកុមារ ការងារអប់រំ សុខាភិបាល និងកិច្ចការសង្គមកិច្ចផ្សេងៗទៀត ដោយប្រើប្រាស់ថវិកាប្រមាណ **១.០៣៨.៦៩៨លានរៀល** ស្មើនឹង **២៥៣លានដុល្លារអាមេរិក**។

- រដ្ឋបាលរាជធានី ខេត្តបានសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្តនីមួយៗ ក្នុងនោះការសាងសាង់ និងជួសជុលផ្លូវលំជនបទចំនួន **១.១៤២គ.ម** ផ្លូវបេតុងចំនួន **៥៦១គ.ម** ផ្លូវក្រាលកៅស៊ូចំនួន **៣៦៣គ.ម** ប្រព័ន្ធទឹកកខ្វក់បានចំនួន **៦៤៥គ.ម** រួមទាំងការសាងសង់ប្រព័ន្ធធារាសាស្ត្រ ស្ពារប្រឡាយចំនួន **១៥៣គ.ម** ការសាងសង់ស្ថានីយបូមទឹក អណ្តូងស្នប់ ស្រះស្តុកទឹកបានចំនួន **៥៥កន្លែង** និងស្ពានចំនួន **៣១កន្លែង** និងរៀបចំកែលម្អសួនចំនួន**១០០គ.មការ៉េ** និង**៤០កន្លែង** ព្រមទាំងសាងសង់អគារសាលាបឋមសិក្សា និងសាលាមត្តេយ្យសិក្សាបានចំនួន **២៤ខ្នង**។

- រដ្ឋបាលរាជធានី ខេត្តបានរៀបចំឱ្យមានយន្តការនៃការផ្តល់ទទួលព័ត៌មាន និងឆ្លើយតបមតិយោបល់ ឬបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ (ការិយាល័យប្រជាពលរដ្ឋ និងទីចាត់ការអន្តរវិស័យ/ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស) ព្រមទាំងការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា ដែលជាលទ្ធផលរាជធានី ខេត្តបានផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋចំនួន **៥៥៧.៧៦៥លើក** (តាមរយៈវេទិកាសាធារណៈ ទូរទស្សន៍ វិទ្យុ ក្តារព័ត៌មាន ព្រឹត្តិបត្តិព័ត៌មាន និងបណ្តាញសង្គម) និងទទួលពាក្យបណ្តឹង សំណើសំណូមពររបស់ប្រជាពលរដ្ឋចំនួន **១០.០៧០ករណី** ក្នុងនោះសម្រុះសម្រួលដោះស្រាយបានចំនួន **៦.៦១៨ករណី** (៦៦%) កំពុងដោះស្រាយចំនួន **១.៦២២ករណី** (១៦%) និងបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធចំនួន **១.៨៣០ករណី** (១៨%)។

តារាងសង្ខេបអំពីលទ្ធផលសំខាន់ៗនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២១-២០២៣)៖

| ល.រ | សមិទ្ធផលចម្បងៗ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | បូកសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| ក. ការផ្តល់សេវាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សេវារដ្ឋបាល និងសេវាសង្គម | | | | | | |
| ១ | ការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើស | 40.163 ករណី | 25.125 ករណី | 14.061 ករណី | 79.349 ករណី | បទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន ក្មេងទំនើង ជួញដូរមនុស្ស ល្បែងស៊ីសង សេដ្ឋកិច្ច... |
| ២ | ការផ្សព្វផ្សាយពីការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 475.813 លើក | 370.623 លើក | 345.259 លើក | 1.191.695 លើក | គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ផលប៉ះពាល់គ្រឿងញៀន ច្បាប់ចរាចរណ៍... |
| ៣ | សេវារដ្ឋបាល | 1.696.885 សេវា | 5.178.230 សេវា | 3.250.974 សេវា | 10.126.089 សេវា | នីត្យានុកូលកម្ម សុខាភិបាល ទេសចរណ៍ សាធារណការ ឧស្សាហកម្ម រ៉ែ ដីធ្លី សំណង់... |
| ៤ | ការចុះបញ្ជីអត្រានុកូលដ្ឋាន | | 6.180.792 សន្លឹក | 4.425.391 សន្លឹក | 10.605.583 សន្លឹក | សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន |
| ៥ | សេវាសង្គម | 253 លានដុល្លា | 1.8 លានដុល្លា | 9 លានដុល្លា | 263.8 លានដុល្លា | ការជួយជនមានពិការភាព ប្រជាពលរដ្ឋក្រីក្រ ស្ត្រីរងគ្រោះ កូវីដ១៩ អនាម័យ អប់រំ សុខាភិបាល គ្រោះមហន្តរាយ អាហារូបត្ថម្ភ... |

| ល.រ | សមិទ្ធផលចម្បងៗ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | សរុប |
|---|---|---|---|---|---|
| ខ. ការអភិវឌ្ឍមូលដ្ឋាន (ការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា) | | | | | |
| ១ | សាងសង់ ជួសជុលផ្លូវជនបទ | 1.142 គ.ម | 63 គ.ម & 7ខ្សែ | 7.309 គ.ម & 1.014ខ្សែ | 8.514 គ.ម & 1.021ខ្សែ |
| ២ | សាងសង់ និងជួសជុលផ្លូវបេតុង | 561 គ.ម | 246 គ.ម & 64ខ្សែ | 1.942 គ.ម & 263ខ្សែ | 2.749 គ.ម & 327ខ្សែ |
| ៣ | សាងសង់ និងជួសជុលផ្លូវក្រាលកៅស៊ូ | 363 គ.ម | 611 គ.ម & 32ខ្សែ | 39 គ.ម | 1.013 គ.ម & 32ខ្សែ |
| ៤ | ការសាងសង់ ជួសជុលប្រព័ន្ធទឹកកខ្វក់ | 645 គ.ម & 389កន្លែង | 440 គ.ម & 268កន្លែង | 228គ.ម & 1.466 កន្លែង | 1.313 គ.ម & 2.123កន្លែង |
| ៥ | ការសាងសង់ប្រព័ន្ធធារាសាស្ត្រ ស្ពាន ប្រឡាយ អណ្ដូងស្នប់ ស្រះស្តុកទឹក ... | 153 គ.ម & 55កន្លែង | 71 គ.ម & 76កន្លែង | 1.325 គ.ម & 264កន្លែង | 1.549 គ.ម & 144 ខ្នង |
| ៦ | ជួសជុល និងស្ថាបនាស្ពាន | 31 កន្លែង | 60កន្លែង | 38 កន្លែង | 129 កន្លែង |
| ៧ | រៀបចំកែលម្អសួន | 100 គ.ម២ & 40កន្លែង | 12 គ.ម២ & 21កន្លែង | គ្មាន | 112 គ.ម២ & 61កន្លែង |
| ៨ | សាងសង់សាលារៀន | 24ខ្នង | 1ខ្នង | 119 ខ្នង | 144 ខ្នង |

| ល.រ | សមិទ្ធផលចម្បងៗ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | សរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| គ. ការងារគណនេយ្យភាពចំពោះប្រជាពលរដ្ឋ | | | | | | |
| ១ | ការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ | 557.765 លើក | 397.604 លើក | 70.675 លើក | 1.026.044 លើក | ការផ្ដល់ព័ត៌មានតាមទូរទស្សន៍ វិទ្យុ ក្ដារព័ត៌មាន ព្រឹត្តិបត្តិព័ត៌មាន ទស្សនាវដ្ដី និងបណ្ដាញសង្គម |
| ២ | ទទួលពាក្យបណ្ដឹង សំណើសំណូមពររបស់ប្រជាពលរដ្ឋ | 10.070 ករណី | 19.583 ករណី | 108.021 ករណី | 137.674 ករណី | |
| ៣ | បានសម្រុះសម្រួល ដោះស្រាយដោយរដ្ឋបាលនីមួយៗ | 6.618 ករណី (66%) | 16.317 ករណី (83%) | 100.243 ករណី (93%) | 123.178 ករណី (89%) | |
| ៤ | កំពុងដោះស្រាយ | 1.622 ករណី (16%) | 614 ករណី (3%) | 795 ករណី (0,7%) | 3.031 ករណី (2%) | |
| ៥ | ករណីបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | 1.830 ករណី (18%) | 2.652 ករណី (14%) | 6.983 ករណី (6,3%) | 11.465 ករណី (9%) | |

ជាមួយគ្នានេះ រដ្ឋបាលរាជធានី ខេត្តក៏បានលើកឡើងនូវបញ្ហាប្រឈម និងសំណើសំណូមពរសរុបចំនួន**៤២** ក្នុងនោះដោះស្រាយដោយរាជធានី ខេត្តបានចំនួន**១៩** និងស្នើថ្នាក់ជាតិដោះស្រាយចំនួន**២៣** ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣ នៃរបាយការណ៍នេះ។

| ល.រ | រដ្ឋបាលថ្នាក់ក្រោមជាតិ | ចំនួនបញ្ហាប្រឈម សំណើសំណូមពរ | | |
|---|---|---|---|---|
| | | សរុប | ដោះស្រាយដោយ រដ្ឋបាលថ្នាក់ក្រោមជាតិ | ស្នើមកថ្នាក់ជាតិ |
| ១ | រដ្ឋបាលឃុំ សង្កាត់ | 52 | 40 (ឃុំ =15, ស្រុក =8, ខេត្ត =17) | 12 |
| ២ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | 103 | 85 (ស្រុក =50, ខេត្ត =35) | 18 |
| ៣ | រដ្ឋបាលរាជធានី ខេត្ត | 42 | 19 | 23 |
| សរុប | | 197 | 144 | 53 |

## ២.៣. ការរៀបចំកិច្ចប្រជុំអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. និងកិច្ចប្រជុំ គ.ជ.អ.ប.

រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិតនៅទូទាំងប្រទេសបានបញ្ចប់ការរៀបចំកិច្ចប្រជុំ និងកិច្ចការចាំបាច់នានារបស់ខ្លួនរួចរាល់ និងបានបញ្ជូននូវរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំវេទិកានៅថ្នាក់ក្រោមជាតិមកលេខាធិការដ្ឋានគ.ជ.អ.ប. ក្នុងអំឡុងខែធ្នូ ឆ្នាំ២០២៤។ ផ្អែកតាមរបាយការណ៍របស់រាជធានី ខេត្ត លេខាធិការដ្ឋានគ.ជ.អ.ប. បានធ្វើការបូកសរុបនូវរបាយការណ៍លទ្ធផលនៃការរៀបចំវេទិកានេះ និងបញ្ជីបញ្ហាប្រឈម សំណើសំណូមពរនានាដែលលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត។ ជារួម បញ្ជីបញ្ហាប្រឈមនិងសំណើសំណូមពរដែលស្នើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិមានសរុបចំនួន**៥៣** ក្នុងនោះបញ្ហាប្រឈមនិងសំណើសំណូមពរដែលស្នើដោយរដ្ឋបាលឃុំ សង្កាត់មានចំនួន**១២** បញ្ហាប្រឈមនិងសំណើសំណូមពរដែលស្នើដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន**១៨** និងបញ្ហាប្រឈមនិងសំណើសំណូមពរដែលស្នើដោយរដ្ឋបាលរាជធានី ខេត្តមានចំនួន**២៣**។ ក្នុងចំណោមបញ្ហាប្រឈម និងសំណើសំណូមពរទាំង៥៣នេះ គឺពាក់ព័ន្ធនឹង៖

| ល.រ | ប្រធានបទ | ចំនួនបញ្ហាប្រឈម/សំណើសំណូមពរ | | | សរុប |
|---|---|---|---|---|---|
| | | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត | |
| ១ | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 3 | 2 | 2 | 7 |
| ២ | ការផ្ទេរ និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 2 | 3 | 4 | 9 |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | 2 | 3 | 5 | 10 |
| ៤ | ការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | 1 | 4 | 6 | 11 |
| ៥ | ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ | 1 | - | 1 | 2 |
| ៦ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | 1 | 4 | 1 | 6 |
| ៧ | ការគាំទ្រ ការត្រួតពិនិត្យ ការវាយតម្លៃ អធិការកិច្ចលើរដ្ឋបាលថ្នាក់ក្រោមជាតិ | 1 | 1 | 1 | 3 |
| ៨ | ផ្សេងៗ | 1 | 1 | 3 | 5 |
| **សរុប** | | 12 | 18 | 23 | 53 |

ទន្ទឹមនឹងនេះ ដើម្បីធានាបាននូវភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងការប្រមូលធាតុចូលបន្ថែមពីក្រសួង ស្ថាប័ននៅថ្នាក់ជាតិមុននឹងឈានទៅរៀបចំកិច្ចប្រជុំអនុគណៈកម្មាធិការនីមួយៗនៃ គ.ជ.អ.ប. កិច្ចប្រជុំក្រុមការងារអន្តរក្រសួង និងកិច្ចប្រជុំជាមួយអង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃក៏ត្រូវបានរៀបចំឡើង ដើម្បីពិនិត្យ និងផ្តល់យោបល់លើបញ្ជីបញ្ហាប្រឈម និងសំណើសំណូមពរ និង

សំណើដំណោះស្រាយ កាលពីថ្ងៃទី២៤ និងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤ ក្រោមការដឹកនាំរបស់ **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប.។** ផ្អែកតាមស្មារតីនៃកិច្ចប្រជុំ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានរៀបចំបញ្ចប់បញ្ជីបញ្ហាប្រឈម និងសំណើសំណូមពរដោយបានបែងចែកទៅតាមតួនាទី ភារកិច្ចរបស់អនុគណៈកម្មាធិការនីមួយៗនៃ គ.ជ.អ.ប. ដើម្បីរៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សា និងលើកយោបល់ជូន គ.ជ.អ.ប. ក្នុងនោះរួមមាន បញ្ហាប្រឈមនិងសំណើសំណូមពរដែលពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់អនុគណៈកម្មាធិការមុខងារនិងធនធាន**ចំនួន ៣០** អនុគណៈកម្មាធិការកិច្ចការសារពើពន្ធនិងហិរញ្ញវត្ថុ**ចំនួន ២១** និងអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**៧**។

### ខ.៣.១. កិច្ចប្រជុំរបស់អនុគណៈកម្មាធិការមុខងារ និងធនធាន

នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ អនុគណៈកម្មាធិការមុខងារ និងធនធាននៃគ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគ.ជ.អ.ប. និងជាប្រធានអនុគណៈកម្មាធិការមុខងារ និងធនធាន** ដោយមានការចូលរួមពីសមាជិក សមាជិកានៃអនុគណៈកម្មាធិការនេះ ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន។ កិច្ចប្រជុំនេះ មានគោលបំណងពិនិត្យ ពិភាក្សា និងកំណត់វិធានការដោះស្រាយចំពោះបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលបានលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកំណត់បញ្ហាប្រឈម និងសំណើសំណូមពរដែលក្រសួង ស្ថាប័ននៅថ្នាក់ជាតិកត់សម្គាល់ពាក់ព័ន្ធនឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាលទ្ធផលនៃកិច្ចប្រជុំ អនុគណៈកម្មាធិការមុខងារ និងធនធានបានសម្រេចដូចខាងក្រោម៖

**ទី១៖** ចំពោះបញ្ហាប្រឈម និងសំណើសំណូមពរចំនួន **១៥** ដែលស្នើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដែលមានគោលការណ៍ និងមានគ្រោងជាសកម្មភាពនៅក្នុងផែនការសកម្មភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០២៥រួចហើយទាំងក្នុងកម្មវិធីជាតិដំណាក់កាលទី២ ទាំងក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយបញ្ហានិងសំណើសំណូមពរទាំងនេះក៏ត្រូវបានពិនិត្យ ពិភាក្សា និងឯកភាពគ្នាលើវិធានការដោះស្រាយក្នុងក្របខ័ណ្ឌក្រុមការងារបច្ចេកទេសអន្តរក្រសួងរួចហើយ។ អាស្រ័យហេតុនេះ កិច្ចប្រជុំអនុគណៈកម្មាធិការបានសម្រេចឯកភាពលើដំណោះស្រាយនានាដែលបានលើកឡើងដោយក្រុមការងារបច្ចេកទេសអន្តរក្រសួង។

**ទី២៖** ដោយឡែក ចំពោះបញ្ហាប្រឈម សំណើសំណូមពរចំនួន**១៥**ផ្សេងទៀត អនុគណៈកម្មាធិការមុខងារនិងធនធានបានលើកយកបញ្ហាទាំងនោះមកពិនិត្យ ពិភាក្សាគ្នាក្នុងកិច្ចប្រជុំ។ បន្ទាប់ពីការផ្តល់មតិយោបល់ពីតំណាងក្រសួង ស្ថាប័ននានា អនុគណៈកម្មាធិការមុខងារនិងធនធានបានសម្រេចលើកអនុសាសន៍ជូន គ.ជ.អ.ប. លើវិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរទាំង១៥នោះ។

តារាងបញ្ហាប្រឈម និងសំណើសំណូមពរទាំង៣០ខាងលើនេះ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៤ នៃរបាយការណ៍នេះ។

### ២.៣.២. កិច្ចប្រជុំរបស់អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយមានការចូលរួមពីសមាជិក សមាជិកានៃអនុគណៈកម្មាធិការនេះ ព្រមទាំងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន។ កិច្ចប្រជុំអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានដំណើរការដោយមានការពិនិត្យ ពិភាក្សា និងបានលើកឡើងនូវសំណើដំណោះស្រាយទៅលើបញ្ហាប្រឈម និងសំណើសំណូមពរចំនួន**៧** ពាក់ព័ន្ធនឹង **(១)**.ការខ្វះចំនួនបុគ្គលិកជំនាញ និងខ្វះជំនាញបច្ចេកទេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ **(២)**.ភាពចាំបាច់ក្នុងការកំណត់ឱ្យមានមុខតំណែងវិជ្ជាជីវៈច្បាស់លាស់តាមអង្គភាពនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ **(៣)**.ការស្នើសុំឱ្យមានគោលនយោបាយលើកទឹកចិត្តដល់មន្ត្រី បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសស្រុកជនបទដែលនៅតំបន់ឆ្ងាយៗ **(៤)**.ការស្នើសុំពន្លឿនការដាក់ចេញនីតិវិធីសម្រាប់ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យ **(៥)**.ការភ្ជាប់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំជាមួយនឹងរដ្ឋបាលក្រុង ស្រុក **(៦)**.ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្ម និង**(៧)**.ការរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាលទ្ធផល អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានសម្រេចលើកអនុសាសន៍ជូន គ.ជ.អ.ប. លើវិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរទាំង៧ខាងលើនេះ ដូចមានជូនភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធទី៥ នៃរបាយការណ៍នេះ។

### ២.៣.៣. កិច្ចប្រជុំរបស់អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ

អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំនាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានអនុគណៈកម្មាធិការកិច្ចការសារពើពន្ធនិងហិរញ្ញវត្ថុ** ដោយមានការចូលរួមពីសមាជិក សមាជិកានៃអនុគណៈកម្មាធិការនេះ ព្រមទាំងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន។ កិច្ចប្រជុំអនុគណៈកម្មាធិការនេះ បានដំណើរការដោយមានការពិនិត្យ ពិភាក្សាទៅលើបញ្ហាប្រឈម និងសំណើសំណូមពរដែលស្នើដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាលទ្ធផល អនុគណៈកម្មាធិការនេះ បានសម្រេចដូចខាងក្រោម៖

**ទី១៖** ឯកភាពទៅលើសំណើដំណោះស្រាយលើបញ្ហាប្រឈម សំណើសំណូមពរចំនួន **១៧** ដែលបានជជែក ពិភាក្សា និងឯកភាពគ្នារវាងក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.។

**ទី២៖** ចំពោះបញ្ហាប្រឈម សំណើសំណូមពរចំនួន ៤ ផ្សេងទៀត រួមមាន៖ (១).ការផ្តល់ប្រាក់សោធននិវត្តន៍ដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ជាតិ (២).ការផ្តល់ប្រាក់លំហែមាតុភាពជូនសមាជិកក្រុមប្រឹក្សាជាស្ត្រី (៣).ការតំឡើងប្រាក់ឧបត្ថម្ភប្រចាំខែដល់ថ្នាក់ដឹកនាំភូមិ និង(៤).ការតំឡើងអត្រាចូលរួមធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានផ្តល់អនុសាសន៍ដឹកនាំដោយបានលើកឡើងនូវវិធានការដោះស្រាយទៅលើបញ្ហាទាំងនេះ ព្រមទាំងទទួលបានការគាំទ្រការឯកភាពពីសមាជិក សមាជិកានៃកិច្ចប្រជុំដូចមានក្នុងតារាងឧបសម្ព័ន្ធទី៦ នៃរបាយការណ៍នេះ។

### ខ.៣.៤. កិច្ចប្រជុំ គ.ជ.អ.ប.

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានរៀបចំកិច្ចប្រជុំលើកទី២៤ នាថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** ដោយមានការចូលរួមពីសមាជិក សមាជិកានៃគ.ជ.អ.ប ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួន ដើម្បីពិនិត្យ ពិភាក្សា និងកំណត់វិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរដែលស្នើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្អែកលើបញ្ជីបញ្ហាប្រឈម សំណើសំណូមពរ និងមតិយោបល់លើវិធានការដោះស្រាយដែលស្នើឡើងដោយអនុគណៈកម្មាធិការនីមួយៗនៃគ.ជ.អ.ប. អង្គប្រជុំបានកត់សម្គាល់ឃើញថា៖

- ក្នុងចំណោមបញ្ហាប្រឈម និងសំណើសំណូមពរនានាដែលលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ គឺពុំមានបញ្ហាប្រឈមគន្លឹះណាមួយដែលមានផលប៉ះពាល់ដល់ច្បាប់រៀបចំអង្គការ (ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនោះទេ បញ្ហាទាំងនោះពាក់ព័ន្ធទៅនឹងផ្នែកបច្ចេកទេស សមត្ថភាព ធនធាន ការគាំទ្រ ការត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងការរៀបចំ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ រួមទាំងសំណើសំណូមពរមួយចំនួន។

- បញ្ហាប្រឈម និងសំណើសំណូមពរមួយចំនួនត្រូវបានដោះស្រាយរួចរាល់ហើយ បញ្ហាមួយចំនួនកំពុងដោះស្រាយ និងបញ្ហាមួយចំនួនទៀតគឺមានកំណត់ជាសកម្មភាពជាក់លាក់រួចហើយនៅក្នុងផែនការសកម្មភាពឆ្នាំ២០២៥ដែលបានគ្រោងនៅក្នុងកម្មវិធីជាតិដំណាក់កាលទី២ កម្មវិធីកំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល ក៏ដូចជាក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយ

មួយចំនួនទៀតជាសំណើសំណូមពរដែលរដ្ឋបាលថ្នាក់ក្រោមជាតិស្នើឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ ក្នុងចំណោមបញ្ហាប្រឈម និងសំណើសំណូមពរ**ចំនួន៥៣**ដែលស្នើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានស្ថានភាពចំនួន៤ផ្សេងៗពីគ្នាដូចខាងក្រោម ៖

**ទី១.** ជាបញ្ហាប្រឈម សំណើសំណូមពរ**ចំនួន៥** ត្រូវបានដោះស្រាយរួចរាល់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧.១)

**ទី២.** ជាបញ្ហាប្រឈម សំណើសំណូមពរ**ចំនួន១២** ត្រូវបាននិងកំពុងដោះស្រាយដោយក្រសួង ស្ថាប័នពាក់ព័ន្ធ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧.២)

**ទី៣.** ជាបញ្ហាប្រឈម សំណើសំណូមពរ**ចំនួន២៩** ដែលមានគោលការណ៍និងបានគ្រោងជាសកម្មភាពសម្រាប់អនុវត្តរួចហើយក្នុងកម្មវិធីជាតិ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧.៣) និង

**ទី៤.** ជាបញ្ហាប្រឈម សំណើសំណូមពរ**ចំនួន៧** ដែលពុំទាន់មានគ្រោងជាសកម្មភាពនៅក្នុងផែនការ ឬកម្មវិធីណាមួយនៅឡើយ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧.៤)។

ជារួម បញ្ហាប្រឈមសំណើសំណូមពរដែលស្ថិតនៅក្នុងស្ថានភាពទាំង៤ខាងលើនេះ គឺមានការលើកឡើងសំណើដោះស្រាយរួចហើយដោយអនុគណៈកម្មាធិការទាំង៣នៃ គ.ជ.អ.ប.។ បើទោះបីជាមានសំណើជាវិធានការដោះស្រាយហើយក៏ដោយ ក៏មានបញ្ហាប្រឈម និងសំណើសំណូមពរជាគន្លឹះមួយចំនួន ត្រូវស្នើសុំការពិនិត្យ និងសម្រេចដោយប្រមុខរាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ កិច្ចប្រជុំ គ.ជ.អ.ប. បានឯកភាពទៅលើវិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរទាំងនោះ។ ទន្ទឹមនោះ កិច្ចប្រជុំ គ.ជ.អ.ប. ក៏បានពិនិត្យ ពិភាក្សាបន្ថែមលើបញ្ហាប្រឈមគន្លឹះ និងសំណើសំណូមពរដែលមានលក្ខណៈជាយុទ្ធសាស្ត្រមួយចំនួន រួមមាន៖

- ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច និងមុខងាររបស់រដ្ឋបាលខេត្តឱ្យស្របទៅនឹងគោលការណ៍នៃរដ្ឋបាលឯកភាព និងការពិនិត្យមើលឡើងវិញអំពីរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក
- ការបែងចែកមុខងារ និងតួនាទីឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ ព្រៃឈើ ជលផល
- ការខ្វះចំនួនបុគ្គលិកដែលមានជំនាញបច្ចេកទេសជាក់លាក់ និងកង្វះសមត្ថភាពជំនាញសម្រាប់បុគ្គលិកដែលកំពុងបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ក្រុង ស្រុក
- ពាក់ព័ន្ធនឹងការបង្កើនធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការស្នើសុំឱ្យមានប្រាក់សោធននិវត្តន៍សម្រាប់សមាជិកក្រុមប្រឹក្សា និងប្រាក់លំហែមាតុភាពសម្រាប់សមាជិក

ក្រុមប្រឹក្សាជាស្ត្រី និងការបង្កើនប្រាក់ឧបត្ថម្ភដល់ថ្នាក់ដឹកនាំភូមិ

- ការរៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

ជាមួយគ្នានេះ កិច្ចប្រជុំគ.ជ.អ.ប. ក៏បានធ្វើការកត់សម្គាល់ឃើញនូវភាពចាំបាច់ដែលក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវបន្តជំរុញការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ធនធាននានា (ធនធានមនុស្ស ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ) ដែលបានផ្ទេរទៅឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម ស្របតាមច្បាប់ គោលការណ៍ នីតិវិធី និងស្តង់ដាដែលបានកំណត់។ ទន្ទឹមនោះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវពង្រឹងការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់ខ្លួន ក្នុងការលើកកម្ពស់ ប្រសិទ្ធភាពនៃការបំពេញការងារ ដើម្បីធានាដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការ និងសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ។

ជាលទ្ធផលចុងក្រោយនៃកិច្ចប្រជុំ ក្រៅពីការឯកភាពគ្នាទៅលើវិធានការដោះស្រាយនានាដែល បានលើកឡើងដោយអនុគណៈកម្មាធិការនីមួយៗ អង្គប្រជុំក៏បានឯកភាពគ្នាក្នុងការគោរពស្នើសុំ អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុង វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើបញ្ហាប្រឈមជាគន្លឹះ និងសំណើសំណូមពរ ជាយុទ្ធសាស្ត្រមួយចំនួន រួមមានដូចខាងក្រោម៖

**ទី១៖** សំណើសំណូមពរពាក់ព័ន្ធនឹងការពង្រឹង និងការពិនិត្យមើលឡើងវិញលើការរៀបចំរចនា សម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច និងមុខងាររបស់រដ្ឋបាលរាជធានី ខេត្តឱ្យស្របទៅនឹងគោលការណ៍នៃរដ្ឋបាល ឯកភាពដូចដែលបានកំណត់ក្នុងច្បាប់រៀបចំអង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យក្រុមប្រឹក្សារាជធានី ខេត្តអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ព្រមទាំងមានសមត្ថភាពក្នុងការដឹកនាំ សម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់ សេវា និងការអភិវឌ្ឍនានាដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតប ទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងសំណើសំណូមពរពាក់ព័ន្ធនឹងការពិនិត្យមើល ឡើងវិញអំពីរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដើម្បីឱ្យស្របទៅតាមស្ថានភាពជាក់ស្តែង និងចរិតលក្ខណៈជាតំបន់ទីក្រុង ទីប្រជុំជន និងជនបទស្របទៅតាមការវិវឌ្ឍនៃនគរូបនីយកម្ម ប្រជាសាស្ត្រ ភូមិសាស្ត្រ តម្រូវការសេវាទីក្រុងទីប្រជុំជន និងសក្តានុពលសេដ្ឋកិច្ច។

**ទី២៖** បញ្ហាប្រឈមពាក់ព័ន្ធនឹងភាពមិនទាន់មានការបែងចែកមុខងារ និងតួនាទីឱ្យបាន ច្បាស់លាស់រវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង អភិរក្ស និង ការអភិវឌ្ឍតំបន់ការពារធម្មជាតិ ព្រៃឈើ ជលផល ក្នុងន័យលើកកម្ពស់ការទទួលខុសត្រូវប្រកបដោយ ភាពម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចូលរួមបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសធនធាន ធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**ទី៣៖** បញ្ហាពាក់ព័ន្ធនឹងការខ្វះចំនួនបុគ្គលិកដែលមានជំនាញបច្ចេកទេសជាក់លាក់ និងកង្វះសមត្ថភាពជំនាញសម្រាប់បុគ្គលិកដែលកំពុងបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ក្រុង ស្រុក។

**ទី៤៖** សំណើសំណូមពរពាក់ព័ន្ធនឹងការបង្កើនធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលទ្ធភាពក្នុងការផ្តល់សេវាកម្ម និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបបានកាន់តែច្រើនទៅនឹងតម្រូវការជាក់ស្តែង និងជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ជាពិសេសការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាពេលកន្លងមក ព្រមទាំងការស្នើសុំឱ្យមានប្រាក់សោធននិវត្តន៍សម្រាប់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សាជាស្ត្រី និងការបង្កើនប្រាក់ឧបត្ថម្ភដល់ថ្នាក់ដឹកនាំភូមិ។

**ទី៥៖** ភាពចាំបាច់ក្នុងការជំរុញ និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំឱ្យមានផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម ដើម្បីលើកកម្ពស់រៀបចំនគរូបនីយកម្ម និងការអភិវឌ្ឍតាមវិស័យនានាដែលធានាឱ្យការប្រើប្រាស់ធនធានដែលជាសក្តានុពលនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ប្រកបដោយសុវត្ថិភាពផ្នែកបរិស្ថាន សោភ័ណភាព ផាសុកភាព មានរបៀបរៀបរយ មានភាពទាក់ទាញដល់វិនិយោគិន និងមាននិរន្តរភាពនៃការអភិវឌ្ឍ។

### គ. ការរៀបចំវេទិកាវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

វេទិកាវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិលើកទី១ (២០២១-២០២៤) ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ត្រូវបានរៀបចំឡើង**នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

វេទិកានេះត្រូវបានប្រារព្ធធ្វើឡើងនៅ**សណ្ឋាគារសុខាភ្នំពេញ** ដោយមានអ្នកចូលរួមដោយផ្ទាល់សរុបចំនួនប្រមាណ**១.៤០០នាក់** ដែលមានសមាសភាពមកពីតំណាងព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាជិករាជរដ្ឋាភិបាល ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ ជាមួយគ្នានេះ វេទិកាក៏រៀបចំឱ្យមានការចូលរួមតាមប្រព័ន្ធអនឡាញ (ZOOM) ដែលរៀបចំឡើងនៅតាមរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំងអស់ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញនានា និងនៅតាមក្រសួងមួយចំនួន(ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន) សរុបចំនួន**២៣៧គណនី** មានអ្នកចូលរួមសរុបប្រមាណជាង**១០.០០០នាក់**ផងដែរ។

វេទិកាបានប្រព្រឹត្តទៅតាមកម្មវិធីសំខាន់ៗ រួមមាន (១).ការទស្សនាវីដេអូអំពីសមិទ្ធផលសំខាន់ៗនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (២).សុន្ទរកថាបើក និងដឹកនាំអង្គវេទិការបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** (៣).សេចក្តីរាយការណ៍អំពីកិច្ចដំណើរការនៃការរៀបចំវេទិកាស្តីពី**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ដោយ**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ**... **បណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** (៤).បទអន្តរាគមន៍អំពីការអភិវឌ្ឍខេត្ត ដោយ**ឯកឧត្តម ម៉ៅ ធនិន** អភិបាលខេត្តកំពត (៥).បទអន្តរាគមន៍អំពីការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ដោយ**លោក យ៉ាវ សានិន** អភិបាលស្រុកកំពង់ត្របែក ខេត្តព្រៃវែង (៦).បទអន្តរាគមន៍អំពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការផ្តល់សេវាសង្គម ដោយ**លោកស្រី នេត ឆាយា** ចៅសង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី (៧).បទអន្តរាគមន៍របស់លោក Jost Kadel **ភារធារីស្តីទីស្ថានទូតអាល្លឺម៉ង់** តំណាងដៃគូអភិវឌ្ឍន៍ (៨).បទអន្តរាគមន៍របស់ **លោក សុន ពេញ** នាយកប្រតិបត្តិអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តំណាងអង្គការសង្គមស៊ីវិល និង (៩).អនុសាសន៍ដឹកនាំ និងសុន្ទរកថាបិទរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

សេចក្តីរាយការណ៍ និងបទអន្តរាគមន៍នានា មានភ្ជាប់ជាឧបសម្ព័ន្ធទី៨ នៃរបាយការណ៍នេះ។

ជាលទ្ធផល វេទិកានេះបានវាយតម្លៃជារួមថា រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងដើរលើមាគ៌ាដ៏ត្រឹមត្រូវនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយផ្អែកទៅលើបរិបទផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ជាក់ស្តែងរបស់កម្ពុជា និងដោយមានផែនការច្បាស់លាស់ មានដំណាក់កាល មានការសម្របសម្រួល ការពិគ្រោះយោបល់ និងការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយផ្អែកលើអភិក្រម "**ធ្វើផង រៀនសូត្រដកស្រង់បទពិសោធន៍ផង និងកែលម្អផង**"។ ទន្ទឹមនឹងនោះ អង្គវេទិកាក៏បានកត់សម្គាល់ឃើញថា បើទោះបីជាការកែទម្រង់នេះ មានការវិវឌ្ឍជាបន្តបន្ទាប់តាមដំណាក់កាលនីមួយៗក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវរួមគ្នាដោះស្រាយ ដើម្បីបន្តជំរុញ និងពង្រឹងដំណើរការនៃការកែទម្រង់នេះឱ្យកាន់តែមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

អង្គវេទិកា ក្រោមការដឹកនាំរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចដូចខាងក្រោម៖

- ចំពោះបញ្ហាប្រឈម និងសំណូមពរដែលត្រូវដោះស្រាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នដែលបានឯកភាពគ្នាតាមរយៈវេទិកានៅថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំគ.ជ.អ.ប. **រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំឱ្យមានផែនការ និងវិធានការដោះស្រាយបញ្ហាប្រឈមទាំងនោះឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាព ហើយ គ.ជ.អ.ប.ត្រូវសម្របសម្រួល គាំទ្រ**

**តាមដាន ត្រួតពិនិត្យ និងបូកសរុបនូវលទ្ធផលនៃការដោះស្រាយបញ្ហាប្រឈមទាំងនោះ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ជារៀងរាល់ឆ្នាំ និងតាមករណីចាំបាច់។** ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងត្រួតពិនិត្យ និងវាយតម្លៃអំពីលទ្ធផលនៃការដោះស្រាយបញ្ហាប្រឈម និងសំណូមពរទាំងនេះនៅវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបន្ទាប់។

- ចំពោះបញ្ហាប្រឈមដែលនៅសេសសល់ **សម្តេចធិបតី** ផ្តល់គោលការណ៍ណែនាំជាគន្លឹះមួយចំនួនដូចខាងក្រោម៖

<u>**ទី១**</u>- រាជរដ្ឋាភិបាលគាំទ្រទាំងស្រុងចំពោះការស្នើសុំឱ្យមាន**ការពិនិត្យឡើងវិញ ដើម្បីពង្រឹង និងកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចម្ចាស់ការលើការគ្រប់គ្រងមុខងារ ធនធាន និងមានសមត្ថភាពដឹកនាំសម្របសម្រួលសកម្មភាពផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងដែនដីរបស់ខ្លួន សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។ ការពិនិត្យឡើងវិញ ដើម្បីពង្រឹង និងកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច នៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះ មានភាពសមស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០)។ ជាការពិតណាស់ ផ្អែកតាមការវិវឌ្ឍយ៉ាងឆាប់រហ័សទាំងផ្នែកសេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យាព័ត៌មាន ការបម្លាស់ទីរបស់ប្រជាជនមកកាន់តំបន់ទីប្រជុំជន ការកើនឡើងនូវតម្រូវការសេវាសង្គម និងសម្ពាធនៃវិបត្តិជាសាកល បានតម្រូវឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវពិនិត្យ និងកែលម្អស្ថាប័នរដ្ឋបាលសាធារណៈទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ ចំពោះការកែលម្អស្ថាប័នសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានផ្តល់ជាផែនទីបង្ហាញផ្លូវនៅក្នុងកម្មវិធីជាតិដំណាក់កាលទី២រួចហើយ គឺត្រូវបន្តរៀបចំរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- **ចំពោះរដ្ឋបាលខេត្ត៖** ត្រូវរៀបចំក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ ផ្អែកតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលត្រូវមានមុខងារ និងតួនាទីសំខាន់ពាក់ព័ន្ធនឹង៖ (១).ការបំពេញតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន លើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ការលើកកម្ពស់ការអនុវត្តច្បាប់ និងសិទ្ធិមនុស្ស (២).ការគាំទ្របច្ចេកទេស និងអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក និង ឃុំ សង្កាត់ (៣).ការត្រួតពិនិត្យនីត្យានុកូលភាពលើការបំពេញការងាររបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ និង(៤).ការអនុវត្តគម្រោងក្នុងវិស័យសាធារណៈធំៗមួយចំនួនដែលមានលក្ខណៈ បច្ចេកទេសខ្ពស់ មានវិសាលភាពអន្តរក្រុង ស្រុក ហើយដែលរដ្ឋបាលក្រុង ស្រុកពុំមានលទ្ធភាពអនុវត្តបាន។

- **ចំពោះរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់៖** ត្រូវបន្តពង្រឹងឱ្យក្លាយទៅជារដ្ឋបាលមូលដ្ឋានជួរមុខ ដែលមានមុខងារ និងតួនាទីសំខាន់ក្នុងការផ្តល់សេវាជាមូលដ្ឋាន និងចាំបាច់ជូនប្រជាពលរដ្ឋដោយ

ផ្ទាល់នៅតាមមូលដ្ឋាននីមួយៗ។ រដ្ឋបាលមូលដ្ឋានក្រុង ស្រុក និងឃុំ សង្កាត់ទាំងនេះ ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈពិសេសផ្សេងៗគ្នា ស្របតាមទីតាំងភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពលសេដ្ឋកិច្ច និងស្ថានភាពជាក់លាក់រវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ។

- **ចំពោះរដ្ឋបាលរាជធានីភ្នំពេញ៖** ត្រូវរៀបចំឱ្យក្លាយទៅជារដ្ឋបាលដែលមានលក្ខណៈពិសេសដោយឡែក ដែលមានលក្ខណៈខុសពីរដ្ឋបាលខេត្ត ដែលអាចធានាដោះស្រាយបញ្ហាប្រឈមដែលកើតឡើងដោយសារកំណើនប្រជាជននៅក្នុងរាជធានីភ្នំពេញ (បច្ចុប្បន្នមានប្រជាជនប្រមាណជាង២លាននាក់) បញ្ហាពាក់ព័ន្ធនឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ការកកស្ទះចរាចរណ៍ បញ្ហាសំរាមសំណល់រឹងនិងរាវ ការបំពុលបរិស្ថាន ក៏ដូចជា បញ្ហាពាក់ព័ន្ធនឹងការបង្កើតក្រុងរណបនៅតាមតំបន់ជាយក្រុងជាដើម។ ស្នើក្រសួង ស្ថាប័នពាក់ព័ន្ធក្រោមយន្តការ គ.ជ.អ.ប. ពន្លឿនការសិក្សាជម្រើសនានា ដើម្បីកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញឱ្យក្លាយជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន **(Metropolitan)** និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។

**សម្តេចធិបតី** ស្នើឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយលើម៉ូឌែលនៃរដ្ឋបាលដែនដី សម្រាប់ខេត្ត ក្រុង ដែលមានសារៈសំខាន់ធំធេងមកលើសង្គម-សេដ្ឋកិច្ចជាតិទាំងមូល (ឧទាហរណ៍ដូចជា ខេត្តសៀមរាប និងខេត្តព្រះសីហនុ) ដែលកំពុងវិវឌ្ឍឥតឈប់ឈរជារៀងរាល់ថ្ងៃ ដែលចាំបាច់ត្រូវធានាថា ខេត្ត ក្រុង ដែលជាប៉ូលសេដ្ឋកិច្ចជាតិទាំងនេះ ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលឯកភាពមួយដែលមានប្រសិទ្ធភាពខ្ពស់បំផុត ហើយមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងលក្ខណៈពិសេសរបស់ខេត្ត ក្រុងនីមួយៗ។

ការគិតគូរអំពីការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិដូចដែលបានគូសបញ្ជាក់ខាងលើនេះ គឺជាការចាំបាច់ និងមានសារៈសំខាន់ ដោយហេតុថា រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាតួអង្គប្រតិបត្តិករដ៏សំខាន់ដែលនៅកៀកជិតប្រជាពលរដ្ឋ ជាអ្នកប្រែក្លាយគោលនយោបាយថ្នាក់ជាតិឱ្យទៅជាលទ្ធផលជាក់ស្តែងនៅថ្នាក់ក្រោមជាតិ ជាអ្នកដឹងសុខទុក្ខ ដឹងការលំបាក និងយល់ពីតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ហើយក៏ជាអ្នកដែលអាចធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានឆាប់រហ័ស ចំគោលដៅ និងមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។ ដូច្នេះ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋលើការដោះស្រាយបញ្ហាប្រឈមក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្របទៅតាមចរិតលក្ខណៈនៃរដ្ឋបាលនីមួយៗ និងទទួលបានមុខងារ ធនធាន សមត្ថភាព ព្រមទាំងសិទ្ធិអំណាចក្នុងកម្រិតសមស្រប ដើម្បីបម្រើសេវាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងន័យនេះ គ.ជ.អ.ប.ត្រូវបន្តដឹកនាំសម្របសម្រួលរៀបចំការសិក្សាលើជម្រើសសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ, ប្រព័ន្ធអភិបាលកិច្ច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចបានគូសបញ្ជាក់ពី

ខាងដើម ដើម្បីរាជរដ្ឋាភិបាលបន្តរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលមធ្យមទៅរយៈពេលវែង សម្រាប់ពង្រឹងស្ថាប័នសាធារណៈទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានភាពធន់ខ្លាំង រឹងមាំ វៃឆ្លាត និងស្អាតស្អំក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋ។

<u>ទី២</u>- ពាក់ព័ន្ធនឹង**ការខ្វះចំនួនបុគ្គលិក និងខ្វះបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈជាក់លាក់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅរដ្ឋបាលក្រុង ស្រុក**។ ជាការពិតណាស់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានរឹតត្បិតការជ្រើសរើសមន្ត្រីជាទូទៅ លើកលែងតែមន្ត្រីសុខាភិបាល មន្ត្រីអប់រំ ដូចជា គ្រូបង្រៀន និងមន្ត្រីកសិកម្ម។ ដើម្បីពង្រឹងស្ថាប័នសាធារណៈនៅគ្រប់ថ្នាក់ រាជរដ្ឋាភិបាលមានតម្រូវការចាំបាច់ត្រូវធ្វើការពិនិត្យ និងរៀបចំក្របខ័ណ្ឌបុគ្គលិកដែលមានសមត្ថភាពជំនាញវិជ្ជាជីវៈស្របតាមរចនាសម្ព័ន្ធ មុខងារនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងន័យនេះ ដើម្បីដោះស្រាយបញ្ហាខ្វះបុគ្គលិកជំនាញជាក់លាក់បម្រើការងារនៅរដ្ឋបាល ក្រុង ស្រុក ស្នើឱ្យក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. រួសរាន់រៀបចំគោលការណ៍ និងនីតិវិធី ព្រមទាំងផ្តល់ការណែនាំ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ក្នុងការវិភាគ និងកំណត់ឱ្យបានច្បាស់លាស់នូវចំនួនមុខតំណែងវិជ្ជាជីវៈដែលត្រូវការពិតប្រាកដសម្រាប់អនុវត្តមុខងារនៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗ និងត្រូវរៀបចំផែនការស្តីពីតម្រូវការបុគ្គលិកឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការពិនិត្យ សម្រេចពីរាជរដ្ឋាភិបាលតាមនីតិវិធី និងបទដ្ឋានគតិយុត្តជាធរមាន។

ផ្អែកលើផែនការតម្រូវការបុគ្គលិកនេះ ខ្ញុំស្នើក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវគិតគូររៀបចំគោលការណ៍ និងនីតិវិធី ដើម្បីអនុវត្តវិធានការចាំបាច់ចំនួន២ ៖

- **វិធានការទី១៖** សិក្សាលទ្ធភាពផ្តល់គោលនយោបាយលើកទឹកចិត្តក្នុងការផ្ទេរបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈពីមន្ទីរ ក្រសួង ស្ថាប័នឱ្យទៅបម្រើការងារនៅតាមរដ្ឋបាលក្រុង ស្រុក និង

- **វិធានការទី២៖** ផ្តល់ការណែនាំ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការជ្រើសរើសបុគ្គលិកផ្អែកលើកិច្ចព្រមព្រៀងដើម្បីបំពេញមុខតំណែងវិជ្ជាជីវៈដែលត្រូវការចាំបាច់ ដោយឈរលើគោលការណ៍ "**គុណាធិបតេយ្យ តម្លាភាព ត្រឹមត្រូវ និងយុត្តិធម៌**" និងគោលការណ៍ "**រើសឱ្យចំ បំពេញឱ្យត្រូវ និងរក្សាឱ្យនៅ**"។

ទន្ទឹមនឹងវិធានការដោះស្រាយទាំងពីរខាងលើនេះ ជាវិធានការចំពោះមុខ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពង្រឹងការទទួលខុសត្រូវក្នុងការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក ដែលមានស្រាប់នៅនឹងកន្លែង និងត្រូវសហការរៀបចំការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពជំនាញដល់បុគ្គលិកទាំងនោះដើម្បីឱ្យមានសមត្ថភាពស្របតាមតម្រូវការរបស់មូលដ្ឋាននីមួយៗ។

**ទី៣**- ចំពោះសំណើ**បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** មកដល់ពេលនេះ ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើនជាបន្តបន្ទាប់ និងបានកំពុងគិតគូរអំពីយន្តការមួយចំនួនដើម្បីបង្កើនធនធានហិរញ្ញវត្ថុបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាការបង្កើតឡើងនូវមូលនិធិភាតរភាព ជាដើម ដែលជាប្រភពចំណូលបន្ថែមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។ អាស្រ័យហេតុនេះ ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យមើលគោលការណ៍ និងក្របខ័ណ្ឌគតិយុត្តដែលមានស្រាប់ និងត្រូវរៀបចំនីតិវិធីដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព។

ចំពោះការស្នើសុំឱ្យ**មានប្រាក់សោធននិវត្តន៍សម្រាប់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើនប្រាក់ឧបត្ថម្ភដល់ថ្នាក់ដឹកនាំភូមិ** ***សម្តេចធិបតី*** បានផ្តល់ការឯកភាពជាគោលការណ៍លើសំណើនេះ និងស្នើឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រួមមានក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គមជាដើម សិក្សាឱ្យបានល្អិតល្អន់ទាំងទៅលើលទ្ធភាព ក្របខ័ណ្ឌពេលវេលា និងជម្រើសនានាសម្រាប់ការផ្តល់ប្រាក់សោធននិវត្តន៍ដល់សមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងការបង្កើនប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិ។

ចំពោះ**សំណើសុំផ្តល់ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សាជាស្ត្រី** ***សម្តេចធិបតី*** បានផ្តល់ការឯកភាព និងស្នើឱ្យរៀបចំអនុវត្តក្នុង**ឆ្នាំ២០២៥ ឬដើមឆ្នាំ២០២៦**តទៅ។

**ទី៤**- ពាក់ព័ន្ធនឹង**ការរៀបចំផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ***សម្តេចធិបតី*** បានឯកភាព និងគាំទ្រទាំងស្រុង។ ការរៀបចំឱ្យមានផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដី គឺជាកិច្ចការដ៏ចាំបាច់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំឱ្យមាន ដើម្បីធានាដល់ការលើកកម្ពស់ការរៀបចំនគរូបនីយកម្ម និងការអភិវឌ្ឍតាមវិស័យនានា ដោយធានាដល់ការប្រើប្រាស់ធនធាន និងសក្តានុពលដែលមាននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយនិរន្តរភាព សុវត្ថិភាពបរិស្ថាន ប្រកបដោយសោភ័ណភាព ជាសុកភាព របៀបរៀបរយ និងមានភាពទាក់ទាញការវិនិយោគទាំងក្នុង និងក្រៅប្រទេស។ ក្នុងន័យនេះ ស្នើឱ្យគណៈកម្មាធិការអន្តរក្រសួងដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ ត្រូវពន្លឿនកិច្ចដំណើរការរៀបចំផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដីនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យបានកាន់តែឆាប់នៅក្នុងបណ្តាឆ្នាំខាងមុខនេះ។ ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវម្ចាស់ការចូលរួមក្នុងដំណើរការរៀបចំផែនការរៀបចំដែនដី និងប្លង់ប្រើប្រាស់ដីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវពង្រឹងការដឹកនាំសម្របសម្រួលការរៀបចំនគរូបនីយកម្ម និងការអភិវឌ្ឍតាមវិស័យនានា ដោយផ្អែកតាមផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដីដែលបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ជាមួយគ្នានេះ **សម្តេចធិបតី** បានជំរុញឱ្យមានការបែងចែកមុខងារឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិ ព្រៃឈើ ជលផល និងធនធានធម្មជាតិផ្សេងទៀត។ អាស្រ័យហេតុនេះ **សម្តេចធិបតី** ស្នើក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ត្រូវពិភាក្សាពិគ្រោះយោបល់ក្នុងការរៀបចំការបែងចែកមុខងារ និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិ ស្របតាមគោលការណ៍ និងលក្ខខណ្ឌនានាដែលបានកំណត់ដោយច្បាប់ជាធរមាន។

ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការដែលមានស្រាប់ ដែលនោះគឺយន្តការគណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបន្តពង្រឹងការចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដោយត្រូវអនុវត្តការងារនេះជាប្រចាំ។

ក្រៅពីគោលការណ៍ណែនាំគន្លឹះទាំង៤ខាងលើ **សម្តេចធិបតី** បានផ្តល់អនុសាសន៍បន្ថែមលើកិច្ចការសំខាន់មួយចំនួនទៀត ដើម្បីពង្រឹងការអនុវត្តការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដូចខាងក្រោម៖

**ទី១- ភាពចាំបាច់នៃការពង្រឹងកិច្ចសហការគាំទ្រទៅវិញទៅមករវាងកម្មវិធីការកែទម្រង់នានារបស់រាជរដ្ឋាភិបាល។** ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាការកែទម្រង់ស្នូលផ្នែកអភិបាលកិច្ច និងមានលក្ខណៈអន្តរវិស័យ ដែលចាំបាច់ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការកែទម្រង់ស្នូលដទៃទៀត រួមមានជាអាទិ៍ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងការកែទម្រង់តាមវិស័យ។ ក្នុងន័យនេះ ភាពជោគជ័យនៃការកែទម្រង់ទាំងនេះ គឺអាស្រ័យទៅលើការរៀបចំ និងការអនុវត្តប្រកបដោយភាពស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមករវាងកម្មវិធីនៃការកែទម្រង់ស្នូលទាំងនេះ។

**សម្តេចធិបតី** បានលើកឡើងនូវភាពចាំបាច់មួយចំនួនដែលតម្រូវឱ្យមានភាពស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងគាំទ្រគ្នានៃការកែទម្រង់ទាំងនេះដូចតទៅ៖

- ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ផ្តោតទៅលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងការផ្ទេរមុខងារ និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌។ ករណីនេះ ទោះបីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំស្របតាម

គោលការណ៍ដែលបានកំណត់ក៏ដោយ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែពុំទាន់អាចមានសមត្ថភាព និងលទ្ធភាពក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយប្រសិទ្ធភាពបានឡើយ ប្រសិនបើប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធហិរញ្ញវត្ថុតាមបែបវិមជ្ឈការ ពុំត្រូវបានរៀបចំ និងអនុវត្តឱ្យបានស្របគ្នាទៅនឹងការវិវឌ្ឍនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានតែរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងការងារ ប៉ុន្តែពុំមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុសមស្របសម្រាប់អនុវត្តមុខងារ និងតួនាទីក្នុងការផ្តល់សេវា និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាពបានឡើយ។

- ទោះបីជារចនាសម្ព័ន្ធ មុខងារ ប្រព័ន្ធគ្រប់គ្រងការងារ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំដាក់ឱ្យអនុវត្តក៏ដោយ ក៏ប៉ុន្តែប្រសិនបើការផ្តល់សេវាសាធារណៈ បញ្ហាសន្តិសុខសង្គម អំពើពុករលួយ ការប្រើប្រាស់ធនធានសាធារណៈមិនត្រឹមត្រូវ ហើយការដោះស្រាយបណ្តឹងតវ៉ា និងវិវាទនៅមូលដ្ឋានទាំងក្នុងទាំងក្រៅប្រព័ន្ធតុលាការពុំទាន់បានធ្វើឱ្យប្រសើរនោះទេ យើងក៏ពុំអាចធ្វើឱ្យប្រជាជនមានជំនឿជឿជាក់លើប្រព័ន្ធគ្រប់គ្រងសាធារណៈទាំងនៅថ្នាក់ជាតិ និងក្រោមជាតិបានពេញលេញឡើយ។

អាស្រ័យហេតុនេះ ការរៀបចំ និងអនុវត្តកម្មវិធីការកែទម្រង់ស្នូលទាំងនេះ ចាំបាច់ត្រូវតែមានភាពស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា ដើម្បីធានាដល់ការសម្រេចបាននូវគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមគ្នានេះ ការកែទម្រង់តាមវិស័យក៏នឹងត្រូវគាំទ្រ និងសម្របសម្រួលជួយដល់ការកែទម្រង់ស្នូលទាំងនេះ ដើម្បីធានាដល់ការកែលម្អស្ថាប័នសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានភាពស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នាលើគ្រប់វិស័យ និងគ្រប់ស្ថាប័ន ស្របតាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**"។

**<u>ទី២</u>- ការពង្រឹងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារដែលបានផ្ទេរឱ្យ។** ពាក់ព័ន្ធនឹងការងារនេះ **សម្តេចធិបតី** បានគូសរំលេចជូនថា ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាលក្ខខណ្ឌចាំបាច់នៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គិតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានផ្ទេរមុខងារក្នុងវិស័យសំខាន់ៗមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការផ្ទេរមុខងារក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលផងដែរ។ ផ្អែកតាមគោលការណ៍នៃការផ្ទេរមុខងារដែលបានកំណត់ក្នុងច្បាប់ ទោះបីមុខងារ និងធនធានត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ក្រសួង ស្ថាប័ននៅតែមានការទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភា អំពីប្រសិទ្ធភាពនៃការអនុវត្តមុខងារដែលស្ថិតក្នុងវិស័យនៃការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ។ អាស្រ័យហេតុនេះ ក្រសួង ស្ថាប័នត្រូវមានកាតព្វកិច្ចរៀបចំគោលនយោបាយ គោលការណ៍ បទដ្ឋានបច្ចេកទេស នីតិវិធី ស្តង់ដាសេវា ព្រមទាំងផ្តល់ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារដែល

បានផ្ទេរឱ្យទាំងនោះ ឱ្យមានគុណភាព ប្រសិទ្ធភាព គណនេយ្យភាព ស្របតាមស្តង់ដាអប្បបរិមាដែលបានកំណត់។ ក្នុងន័យនេះ **សម្តេចធិបតី** បានស្នើក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបន្តផ្តោតការយកចិត្តទុកដាក់ឱ្យបានច្រើនបន្ថែមទៀតចំពោះកិច្ចការដ៏មានសារៈសំខាន់នេះ។

**ទី៣- ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ត្រូវពង្រឹងការទទួលខុសត្រូវប្រកបដោយភាពម្ចាស់ការ**ក្នុងការអនុវត្តមុខងារ និងការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព តម្លាភាព និងត្រឹមត្រូវ ស្របតាមលក្ខខណ្ឌ គោលការណ៍ នីតិវិធី និងស្តង់ដាដែលបានកំណត់។ នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានភាពរឹងមាំ មានសមត្ថភាព និងការទទួលខុសត្រូវក្នុងភាពម្ចាស់ការបានល្អប្រសើរ រាជរដ្ឋាភិបាលនឹងបន្តផ្ទេរសិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវកាន់តែច្រើនបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ ដើរតួនាទីជាប្រតិបត្តិករលើការផ្តល់សេវាជាមូលដ្ឋាន និងចាំបាច់នានាដោយផ្ទាល់ជូនដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចខ្លួន។ ការផ្ទេរអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាការផ្ទេរផងដែរនូវការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន និងចំពោះមុខរាជរដ្ឋាភិបាល។ ក្នុងន័យនេះ សិទ្ធិអំណាចកាន់តែធំ ការទទួលខុសត្រូវក៏កាន់តែធំ។

**ទី៤-** ស្នើឱ្យ គ.ជ.អ.ប.ពិចារណាអំពីវិធីសាស្ត្រក្នុងការអនុវត្តកិច្ចការកែទម្រង់ខ្លះដែលមានភាពស្មុគស្មាញ ដោយរៀបចំជាគម្រោងអនុវត្តសាកល្បង ហើយដោយផ្អែកលើបទពិសោធន៍ និងជោគជ័យនៃគម្រោងសាកល្បងនេះ ការកែទម្រង់អាចពង្រីកវិសាលភាពទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ។

## IV. ទិសដៅបន្ត

បន្ទាប់ពីការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិលើកទី១ (ឆ្នាំ២០២១-២០២៤) គ.ជ.អ.ប. នឹងបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការចាំបាច់មួយចំនួន ដូចខាងក្រោម៖

១. បូកសរុប និងផ្សព្វផ្សាយលទ្ធផលនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត វិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្ញើជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចាត់ចែងអនុវត្ត។

២. ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗត្រូវលើកយកវិធានការដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរនីមួយៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ទៅដាក់ក្នុងផែនការសកម្មភាព និងថវិកាសម្រាប់ការអនុវត្តឆ្នាំ២០២៥ និងឆ្នាំ២០២៦។

៣. រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំឱ្យមានផែនការ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់សម្រាប់ដោះស្រាយបញ្ហាប្រឈម និងសំណើសំណូមពរនីមួយៗដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទទួលខុសត្រូវដោះស្រាយ។

៤. គ.ជ.អ.ប. នឹងសម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើវឌ្ឍនភាពនៃការដោះស្រាយបញ្ហានីមួយៗដែលបានលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបូកសរុប វាយតម្លៃ និងរាយការណ៍ជូនរាជរដ្ឋាភិបាលជារៀងរាល់ឆ្នាំ និងតាមករណីចាំបាច់។

## V. សេចក្តីសន្និដ្ឋាន

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបាននិងកំពុងអនុវត្តជាង២ទសវត្សរ៍មកនេះ បានរួមចំណែកយ៉ាងសំខាន់ជាមួយនឹងគោលនយោបាយ និងកម្មវិធីកំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់អភិបាលកិច្ច និងប្រជាធិបតេយ្យនៅមូលដ្ឋាន។ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ត្រូវបានរៀបចំឡើងស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ មានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ ធនធាន និងនីតិវិធីបំពេញការងារកាន់តែល្អប្រសើរក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវមុខងារ សិទ្ធិអំណាច និងធនធានកាន់តែច្រើនឡើង និងមានភាពម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ និងធនធានទាំងនោះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយសម្រេចបាននូវសមិទ្ធផលជាច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានាដែលបម្រើឱ្យសេចក្តីត្រូវការនៅមូលដ្ឋាន ការផ្តល់សេវារដ្ឋបាល សេវាសង្គម និងសេវាសាធារណៈផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម ព្រមទាំងចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមបានយ៉ាងល្អប្រសើរ ធ្វើឱ្យប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានរស់នៅប្រកបដោយភាពសុខសាន្ត។ សមិទ្ធផលទាំងនេះ ពិតជាបានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងកាត់បន្ថយភាពក្រីក្រ។

ទន្ទឹមនឹងសមិទ្ធផលខាងលើនេះ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតការយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាទាំងនោះ។ ជារួម បញ្ហាប្រឈមទាំងនោះពុំមានផលប៉ះពាល់ជាអវិជ្ជមានទៅលើក្របខ័ណ្ឌច្បាប់ ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនោះទេ។ បញ្ហាប្រឈមទាំងនោះពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេស សមត្ថភាព ធនធាន ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការរៀបចំ និងការអនុវត្តលិខិតបទដ្ឋានបច្ចេកទេសក្រោមច្បាប់។

ការរៀបចំឱ្យមានវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" គឺជាវេទិកាដ៏ទូលំទូលាយ និងមានសារៈសំខាន់ ដើម្បីរួមគ្នាឆ្លុះបញ្ចាំង វាយតម្លៃទៅលើសមិទ្ធផល និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការដាក់ចេញនូវដំណោះស្រាយសមស្របនានាសម្រាប់រយៈពេលចំពោះមុខ រយៈពេលមធ្យម និងរយៈពេលវែង។ តាមរយៈការរៀបចំវេទិកានេះ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានមើលឃើញអំពីចំណុចខ្លាំង មេរៀនបទពិសោធន៍នៃការអនុវត្ត និងចំណុចខ្សោយដែលចាំបាច់ត្រូវពង្រឹង កែលម្អ និងដោះស្រាយទាំងក្នុងក្របខ័ណ្ឌនៃការរៀបចំ និងដាក់ចេញនូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ ស្តង់ដា និងនីតិវិធីអនុវត្ត ទាំងក្នុងក្របខ័ណ្ឌនៃការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ ការធ្វើអធិការកិច្ច និងសវនកម្មរបស់ថ្នាក់ជាតិទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ និងទាំងក្នុងក្របខ័ណ្ឌនៃការប្រតិបត្តិការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមស្របតាមគោលនយោបាយ ច្បាប់ ស្តង់ដា និងនីតិវិធីដែលបានកំណត់។ ទន្ទឹមនេះ ដោយផ្អែកលើមូលដ្ឋាននៃសមិទ្ធផល និងបញ្ហាប្រឈមជាគន្លឹះដែលបានលើកឡើងតាមរយៈវេទិកាដ៏មានសារៈសំខាន់នេះ រាជរដ្ឋាភិបាលអាចដាក់ចេញនូវគោលការណ៍ណែនាំតម្រង់ទិសផ្អែកគោលនយោបាយសម្រាប់រយៈពេលចំពោះមុខ រយៈពេលមធ្យម និងរយៈពេលវែងនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាដល់ការចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០៕

ថ្ងៃ ពុធ ១១កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

## តារាងឧបសម្ព័ន្ធទី ១

## បញ្ជីបញ្ហាប្រឈម/សំណើសំណូមពរស្នើដោយរដ្ឋបាលឃុំ សង្កាត់ និងដំណោះស្រាយនៅតាមស្ថាប័នមានសមត្ថកិច្ចនីមួយៗ

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | ឃ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| **I.** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលឃុំ សង្កាត់** | | | | |
| ១ | រចនាសម្ព័ន្ធឃុំ (ចំនួនក្រុមប្រឹក្សា គណៈកម្មាធិការ បុគ្គលិក ហិរញ្ញវត្ថុ) មិនទាន់សមស្របទៅនឹងបរិបទនៃការរីកចម្រើន ស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ និងតម្រូវការនៅមូលដ្ឋាននីមួយៗ | | ✓ | ✓ | |
| ២ | – នីតិវិធី និងបែបបទរដ្ឋបាលឃុំ សង្កាត់មានភាពស្មុគស្មាញ គួរធ្វើបច្ចុប្បន្នភាព<br>– ការរៀបចំរបាយការណ៍ លិខិតស្នាម និងកិច្ចការរដ្ឋបាលផ្សេងៗមិនទាន់ឆ្លើយតបទៅនឹងទម្រង់ និងខ្លឹមសារដែលបានណែនាំ<br>– ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅឃុំ សង្កាត់មិនទាន់ទូលំទូលាយ(មនុស្ស និងសេវាអ៊ីនធឺណិត) | ✓ | ✓ | ✓ | ✓ |
| ៣ | – មេឃុំ និងប្រធានក្រុមប្រឹក្សាឃុំជាមនុស្សតែម្នាក់ ដែលធ្វើឱ្យខ្វះការត្រួតពិនិត្យគ្នាទៅវិញទៅមក<br>– ស្នើបន្ថែមឱ្យមានជំទប់ទី៣ ដើម្បីឱ្យជួយការងារប្រចាំថ្ងៃ | | ✓ | ✓ | |
| ៤ | – មិនទាន់មានការកំណត់ច្បាស់លាស់នូវព្រំប្រទល់ឃុំ-ភូមិមួយចំនួនដែលនាំឱ្យពិបាកក្នុងការផ្តល់សេវា និងការងារសន្តិសុខសណ្តាប់ធ្នាប់<br>– ភូមិមួយចំនួននៅតែជាភូមិឧបសម្ព័ន្ធដែលមិនទាន់មានការចុះបញ្ជីទទួលស្គាល់ពីក្រសួងមហាផ្ទៃ | | ✓ | ✓ | ✓ |
| ៥ | – គណៈកម្មាធិការរបស់ឃុំ សង្កាត់មិនសូវដំណើរការ និងមិនទាន់អាចអនុវត្តតួនាទីភារកិច្ចតាមការកំណត់ (មិនមានការគាំទ្រផ្នែកថវិកា ដើម្បីអនុវត្តសកម្មភាព) | ✓ | ✓ | | |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | ឃ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| | – សំណើសុំជួយពង្រឹងរបៀបរបបការងារដល់គណៈកម្មាធិការនានារបស់រដ្ឋបាលឃុំ សង្កាត់ | | | | |
| ៦ | – កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ មិនបានទៀងទាត់តាមប្រតិទិនកំណត់<br>– សមាសភាពពាក់ព័ន្ធមួយចំនួនមិនបានចូលរួមកិច្ចប្រជុំ គ.ក.ន.ក. | ✓ | | | |
| ៧ | – ការរៀបចំ និងការពង្រឹងគណៈបញ្ជាការឯកភាពរបស់ឃុំ សង្កាត់ឱ្យឆ្លើយតបទៅតាមសភាពការណ៍របស់ឃុំ សង្កាត់<br>– គណៈកម្មការលទ្ធកម្មឃុំ សង្កាត់ និងគណៈកម្មការគ្រប់គ្រងគម្រោងឃុំ សង្កាត់មិនទាន់មានភាពជាម្ចាស់ការលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់<br>– កម្មវិធីវិនិយោគមិនបានធ្វើតាមពេលវេលាកំណត់ | ✓ | | | |
| ៨ | ការអនុវត្តនីតិវិធីរដ្ឋបាល និងយន្តការច្រកមានការច្របូកច្របល់គ្នា ដោយហេតុយន្តការច្រកក៏ចុះលេខ ហើយរដ្ឋបាលក៏ចុះលេខ (សៀវភៅផ្សេងគ្នា) | ✓ | ✓ | ✓ | |
| ៩ | – ស្នើសុំកែសម្រួលនីតិវិធីស្តីពីការជ្រើសរើសមេភូមិ អនុភូមិ និងជំនួយការភូមិ<br>– ស្នើសុំកែសម្រួលនីតិវិធីនៃការជ្រើសរើសមេភូមិ ដោយផ្តល់សិទ្ធិជូនប្រជាពលរដ្ឋបោះឆ្នោតចូលរួមបោះឆ្នោតជ្រើសរើសយកមតិភាគច្រើន | | ✓ | ✓ | ✓ |
| ១០ | ស្នើសុំបង្កើតការិយាល័យជំនាញនៅតាមបណ្តាឃុំ សង្កាត់ | | | ✓ | ✓ |
| **II.** | **មុខងាររដ្ឋបាលឃុំ សង្កាត់ (មុខងារជាអាណាត្តិទូទៅ និងមុខងារដែលផ្ទេរ)** | | | | |
| ១ | – ខ្វះលិខិតបទដ្ឋានកំណត់មុខងារជាកាតព្វកិច្ចសម្រាប់រដ្ឋបាលឃុំ សង្កាត់<br>– ស្នើឱ្យមានការបណ្តុះបណ្តាលអំពីមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស | | ✓ | ✓ | ✓ |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | យ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| | – ពុំទាន់មាននីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយ និងសម្របសម្រួលវិវាទមូលដ្ឋាន | | | | |
| ២ | មុខងារខ្លះដែលផ្ទេរមកឱ្យឃុំ ពុំមានភ្ជាប់នូវធនធានហិរញ្ញវត្ថុ និងពុំបានផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសអនុវត្តមុខងារ | | ✓ | ✓ | ✓ |
| ៣ | – នីតិវិធីហិរញ្ញវត្ថុក្នុងការអនុវត្តមុខងារសេវាសង្គមមានភាពស្មុគស្មាញ ហើយការប្រើប្រាស់ថវិកាមានការកំណត់<br>– ស្នើសុំឱ្យមានការកំណត់បញ្ជីឈ្មោះគម្រោងសេវាសង្គម | | ✓ | ✓ | ✓ |
| ៤ | – ខ្វះការគាំទ្រលើដំណើរការមត្តេយ្យសហគមន៍ (សម្ភារ ប្រាក់ឧបត្ថម្ភ អគារ...)<br>– ខ្វះគ្រូបង្រៀនមត្តេយ្យសហគមន៍<br>– ឃុំ សង្កាត់មួយចំនួនមិនទាន់មានមត្តេយ្យសហគមន៍<br>– ស្នើសុំបើកប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ជាប់ស្តង់ដា ២ដងក្នុង១ខែ (បច្ចុប្បន្ន៣ខែបើកម្តង)<br>– គ្រូបង្រៀនមត្តេយ្យសហគមន៍ដែលទទួលប្រាក់បៀវត្សរ៍ពីឃុំ សង្កាត់ ទទួលបានប្រាក់បៀវត្សរ៍ទាប | ✓ | ✓ | ✓ | |
| ៥ | ស្នើសុំឱ្យមានប្រាក់ឧបត្ថម្ភក្រុមទ្រទ្រង់សុខភាពភូមិ | ✓ | ✓ | ✓ | |
| ៦ | សំណើសុំជួយពង្រឹងការត្រួតពិនិត្យ និងគាំទ្រឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម | | | ✓ | |
| ៧ | – ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតរបស់រដ្ឋបាលឃុំ សង្កាត់នៅមានកម្រិត<br>– ករណីបង់ពន្ធអចលនទ្រព្យប្រចាំឆ្នាំ៖ សាខាពន្ធដារខេត្តតែងតែចេញសេចក្តីជូនដំណឹងពីការបង់ពន្ធអចលនទ្រព្យជូនដល់ម្ចាស់អចលនទ្រព្យដែលជាប់ពន្ធ ដោយផ្ញើមកឃុំ សង្កាត់ និងភូមិយកទៅប្រគល់ជូនអ្នកជាប់ពន្ធ។ ករណីនេះ ស្នើសុំឱ្យមន្ត្រីសាខាពន្ធដារខេត្តជាអ្នកកាន់សេចក្តីជូនដំណឹងទៅអ្នកជាប់ពន្ធ ហើយអាជ្ញាធរឃុំ សង្កាត់ជាអ្នកចូលរួមសហការ | ✓ | ✓ | ✓ | |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | យ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| | – ស្នើសុំជួយគាំទ្រធនធាននានាលើការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ | | | | |
| ៨ | – ការចូលរួមរបស់រដ្ឋបាលឃុំក្នុងការរៀបចំសហគមន៍ព្រៃឈើ និងនេសាទនៅមានកម្រិត<br>– រដ្ឋបាលឃុំពុំទាន់មានការទទួលខុសត្រូវ ពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមណ្ឌលសុខភាព គួរផ្ទេរមុខងារទាំងនេះមកឱ្យរដ្ឋបាលឃុំ | ✓ | ✓ | ✓ | |
| **III. ធនធានមនុស្សនៅរដ្ឋបាលឃុំ សង្កាត់** | | | | | |
| ១ | ចំនួន និងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ ស្មៀន ជំនួយការនៅមានកម្រិត (ការងាររដ្ឋបាល នីតិវិធីនៃការផ្តល់សេវាសាធារណៈ ការដោះស្រាយវិវាទ ការរៀបចំគម្រោងថវិកា ជាពិសេសចំណេះដឹងផ្នែកឌីជីថល......) | ✓ | ✓ | ✓ | ✓ |
| ២ | – ស្នើឱ្យមានការកំណត់កម្រិតវប្បធម៌អប្បបរិមា និងលក្ខណសម្បត្តិសម្រាប់ជ្រើសរើសមេភូមិ និងមេឃុំ (មេភូមិគួរមានកម្រិតបឋមភូមិ និងមេឃុំគួរមានកម្រិតទុតិយភូមិ) និងការកំណត់អាណត្តិរបស់មេភូមិ<br>– ស្នើសុំឱ្យមានការកំណត់អាយុ និងកម្រិតវប្បធម៌សម្រាប់បេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាឃុំ សង្កាត់ | | ✓ | ✓ | ✓ |
| ៣ | ការជ្រើសរើសមន្ត្រីកិច្ចសន្យាមិនស្របតាមគោលការណ៍ និងនីតិវិធី | ✓ | ✓ | | |
| ៤ | – ករណីមានការផ្លាស់ប្តូរស្មៀនឃុំ សង្កាត់ ពុំមានការបណ្តុះបណ្តាលតម្រង់ទិសជាមូលដ្ឋានដល់ស្មៀនទាំងនោះ<br>– ការផ្លាស់ប្តូរក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីដែលមិនទាន់មានការយល់ដឹងការងាររបស់ឃុំ សង្កាត់ | | ✓ | ✓ | ✓ |
| ៥ | ការសម្រេចចិត្តលើការតែងតាំង និងការផ្លាស់ប្តូរស្មៀនមានភាពយឺតយ៉ាវ និងស្នើសុំសម្រេចត្រឹមក្រុង ស្រុក ឬខេត្ត | | ✓ | ✓ | |
| ៦ | ស្នើសុំបង្កើនការចូលរួមរបស់ស្ត្រី និងផ្តល់អាទិភាពដល់ស្ត្រីក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនានា | | ✓ | ✓ | |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | យ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| **IV. ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់** | | | | | |
| ១ | ទំហំថវិកាសម្រាប់អភិវឌ្ឍមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន(ស្នើសុំថ្នាក់ជាតិបង្កើនថវិកាមូលនិធិរដ្ឋបាលឃុំ សង្កាត់) | ✓ | ✓ | ✓ | ✓ |
| ២ | សមត្ថភាពមន្ត្រីឃុំនៅមានកម្រិតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | ✓ | ✓ | ✓ | |
| ៣ | ឃុំ សង្កាត់មួយចំនួនមិនទាន់មានអគារធ្វើការតាមស្តង់ដាត្រឹមត្រូវ | | ✓ | ✓ | |
| ៤ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចូលនិវត្តន៍មិនមានប្រាក់សោធននិវត្តន៍ទោះបីគាត់ជាសមាជិក ៣ឬ៤ អាណត្តិ | | | | ✓ |
| ៥ | ស្នើបង្កើនកម្រិតនៃការអនុញ្ញាតថវិកាសម្រាប់ទិញឧបករណ៍ប្រើប្រាស់ដូចជាកុំព្យូទ័រ ម៉ាស៊ីនព្រីនចំនួនមិនលើសពី៥០ម៉ឺនរៀល | | | ✓ | |
| ៦ | – បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ឃុំ សង្កាត់ ដូចជាដីធ្លី (ដីបឹង...) ការគ្រប់គ្រងមិនទាន់បានគ្រប់ជ្រុងជ្រោយ<br>– មិនទាន់បានចុះបញ្ជីដីរដ្ឋ និងធ្វើប័ណ្ណកម្មសិទ្ធិ<br>– ស្នើសុំកែសម្រួលនីតិវិធីជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ | ✓ | ✓ | ✓ | |
| ៧ | – ស្នើសុំតំឡើងប្រាក់ឧបត្ថម្ភមេភូមិ អនុភូមិ សមាជិកភូមិ ឱ្យប្រហាក់ប្រហែលសមាជិកក្រុមប្រឹក្សាឃុំ<br>– ស្នើឱ្យមានការឧបត្ថម្ភជាថវិកា ឬសាំងសម្រាប់ក្រុមប្រឹក្សាចុះបេសកកម្ម | | | ✓ | ✓ |
| ៨ | ស្នើសុំបែងចែកថវិកាឃុំ សង្កាត់តាមស្ថានភាពភូមិសាស្ត្រ(សម្រាប់ឃុំដាច់ស្រយាល គួរមានប្រាក់ប្រតិបត្តិការ ឬបេសកកម្មច្រើនជាងសង្កាត់) | | ✓ | ✓ | |
| ៩ | – នីតិវិធីលទ្ធកម្ម មន្ត្រីសិក្សាគម្រោង និងត្រួតពិនិត្យគម្រោងជាមន្ត្រីតែម្នាក់<br>– ការទូទាត់ និងការជម្រះបញ្ជីឯកសារផ្សេងៗនៅរតនាគារមានភាពយឺតយ៉ាវ | ✓ | | ✓ | |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | យ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| | – ការទម្លាក់ថវិកាមានភាពយឺតយ៉ាវធ្វើឱ្យរដ្ឋបាលឃុំជួបការលំបាកក្នុងការចំណាយលើប្រតិបត្តិការប្រចាំថ្ងៃ<br>– ពុំបានអនុវត្តនីតិវិធីលទ្ធកម្មបានពេញលេញក្នុងការដេញថ្លៃគម្រោងឃុំ សង្កាត់ | | | | |
| ១០ | ការរៀបចំ និងអនុវត្តសេវាសង្គម មិនសូវមានការគាំទ្រ និងមានការលំបាកក្នុងការរៀបចំរបាយការណ៍ទូទាត់ ស្នើកែសម្រួលនីតិវិធីទូទាត់ចំណាយ (ចំណាយជាបុរេប្រទាន)៖<br>– ថវិកាសម្រាប់ប្រជុំ ( សេវាសង្គម )<br>– ថវិកាសម្រាប់ជួសជុល ថែទាំផ្លូវខូច (សំបុកមាន់ លុបក្បាលលូ...) ពន្លឿនការពិនិត្យឯកសារទូទាត់ | | ✓ | ✓ | ✓ |
| **V.** | **ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងរដ្ឋបាលឃុំ សង្កាត់ និងរវាងរដ្ឋបាលឃុំ សង្កាត់និងរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលឃុំ សង្កាត់ជាមួយប្រជាពលរដ្ឋ** | | | | |
| ១ | ប្រព័ន្ធទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលឃុំ សង្កាត់និងរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលខេត្ត និងថ្នាក់ជាតិនៅមានកម្រិត | ✓ | | | |
| ២ | ការធ្វើវេទិកាសាធារណៈនៅតាមឃុំ របស់ថ្នាក់ជាតិ ខេត្ត និងស្រុកពុំបានជាប់លាប់ | ✓ | | | |
| ៣ | ការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលឃុំ សង្កាត់ និងសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍មិនបានទូលំទូលាយ | ✓ | | | |
| ៤ | – ការផ្តល់ព័ត៌មាន ការជូនដំណឹង និងការប្រាស្រ័យទាក់ទងពីរដ្ឋបាលឃុំ សង្កាត់ទៅប្រជាពលរដ្ឋនៅមានកម្រិត<br>– ខ្វះការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការកសាងផែនការ ធ្វើឱ្យការអភិវឌ្ឍពុំឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ គួរកំណត់ ៦០% នៃចំនួនគ្រួសារនៃភូមិនីមួយៗក្នុងកម្មវិធីពិគ្រោះយោបល់ | ✓ | | | |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | យ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| **VI. ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** | | | | | |
| ១ | – សមត្ថភាពរដ្ឋបាលឃុំ សង្កាត់នៅមានកម្រិតនៅក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន និងមានភាពយឺតយ៉ាវ (ជាពិសេសការសរសេរដោយដៃដែលនាំឱ្យខុស និងលុបច្រើនលើក) ស្នើប្រព័ន្ធបច្ចេកវិទ្យាឌីជីថល<br>– រដ្ឋបាលឃុំ សង្កាត់ពុំមានគល់បញ្ជីអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅឃុំ សង្កាត់ដែលនាំឱ្យពិបាកក្នុងការចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ (ស្នើសុំឱ្យមានឯកសារគល់បញ្ជីឆ្នាំចាស់តម្កល់នៅឃុំ សង្កាត់)<br>– មិនអាចកំណត់អត្តសញ្ញាណអ្នកមកធ្វើសំបុត្របញ្ជាក់កំណើតស្នួន<br>– ប្រជាពលរដ្ឋពុំទាន់យល់ដឹងអំពីឯកសារភ្ជាប់សម្រាប់ស្នើសុំសេវាអត្រានុកូលដ្ឋាន ដែលត្រូវមកច្រើនសារ<br>– ស្នើសុំរដ្ឋបាលស្រុកចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ជូនអ្នកដែលបាត់<br>– បែបបទនៃការស្នើសុំកែតម្រូវអត្រានុកូលដ្ឋានឆ្លងឆ្នាំមានភាពស្មុំញ៉ាំច្រើន<br>– ការជំរុញ និងពង្រឹងការណែនាំ និងការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការប្រើប្រាស់សេវាអត្រានុកូលដ្ឋាននៅមានកម្រិត | ✓ | ✓ | ✓ | ✓ |
| ២ | – ប្រជាពលរដ្ឋខ្វះការយល់ដឹងអំពីយន្តការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយនៅឃុំ<br>– សុំស្ថាប័នពាក់ព័ន្ធជួយបង្កើតជាវីឌីអូ ក៏ដូចជាសារសំឡេងផ្សព្វផ្សាយអំពីយន្តការច្រកចេញចូលតែមួយ ដើម្បីជាជំនួយដល់ប្រជាពលរដ្ឋ | ✓ | | | |
| ៣ | – ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព (សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ) ពុំទាន់បានល្អប្រសើរទាំងស្រុងដោយសារខ្វះកម្លាំងនគរបាល<br>– ប្រជាការពារពុំមានប្រាក់ឧបត្ថមក្នុងជួយការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ✓ | ✓ | ✓ | |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | យ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| ៤ | – ករណីខ្លះមានការពង្រីកផ្លូវដែលប៉ះពាល់ទៅដល់ដីឯកជន ប៉ុន្តែមិនមានការបរិច្ចាគដីធ្លី<br>– ការរំលោភដីផ្លូវសាធារណៈរបស់រដ្ឋ ពិបាកក្នុងការដោះស្រាយ | ✓ | | | |
| ៥ | – ចំពោះការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅលើផ្លូវចាស់ ស្នើសុំពុំចាំបាច់ឱ្យមានការសិក្សាដីធ្លី និងបរិស្ថានឡើងវិញ<br>– ឃុំពុំមានបច្ចេកទេស និងជំនាញក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោង | | ✓ | ✓ | |
| ៦ | ស្នើសុំបិទការអនុញ្ញាតឱ្យក្រុមហ៊ុនដេញថ្លៃតែមួយមានសិទ្ធិបំបែកធ្វើជាក្រុមហ៊ុនផ្សេងជាឧបសម្ព័ន្ធសម្រាប់ចូលរួមដេញថ្លៃក្នុងគម្រោងតែមួយដើម្បីបង្ក្រាប់កិច្ចលទ្ធកម្ម | | ✓ | ✓ | |
| ៧ | ក្រសួង ស្ថាប័នមួយចំនួនមិនទទួលយកទម្រង់ឯកសារដែលបានចេញដោយយន្តការច្រកចេញចូលតែមួយ ហើយតម្រូវឱ្យរៀបចំបញ្ជាក់តាមទម្រង់ឯកសារតាមក្រសួង ស្ថាប័នសាមីនោះវិញ | | ✓ | ✓ | |
| ៨ | – ទីកន្លែងសាលាឃុំ សង្កាត់ចង្អៀតពិបាកក្នុងការរៀបចំទីកន្លែងបង្កើតយន្តការច្រកចេញចូលតែមួយខេត្ត<br>– តំបន់ភូមិសាស្ត្រកោះ និងតំបន់ដាច់ស្រយាល ពិបាកក្នុងការផ្តល់សេវានៅតាមយន្តការច្រកចេញចូលតែមួយ និងប្រជាពលរដ្ឋត្រូវចំណាយថវិកា និងពេលវេលាច្រើនមកទទួលសេវា | ✓ | | | |
| ៩ | ប្រជាពលរដ្ឋមកទទួលសេវាពិនិត្យសុខភាពនៅមណ្ឌលសុខភាពនៅមានកម្រិតតិចតួច | ✓ | | | |
| **VII. ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្ម** | | | | | |
| ១ | – យន្តការ និងនីតិវិធីធ្វើអធិការកិច្ច ឬសវនកម្មនៅរដ្ឋបាលឃុំ សង្កាត់មិនទាន់ច្បាស់លាស់<br>– ស្នើស្ថាប័នអធិការកិច្ចជួយពន្យល់បកស្រាយ ឬណែនាំបន្ថែមអំពីចំណុចខ្វះខាតរបស់ឃុំ សង្កាត់<br>– ការធ្វើសវនកម្ម និងអធិការកិច្ចមានច្រើនស្ថាប័ន និងច្រើនដង មកលើរដ្ឋបាលឃុំ សង្កាត់ | | | ✓ | ✓ |

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | | |
|---|---|---|---|---|---|
| | | ឃ/ស | ក/ស/ខ | រ/ខ | ក្រ/ស |
| ២ | – ការគាំទ្រ និងអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក និងខេត្តមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការរបស់ឃុំ សង្កាត់<br>– ស្នើសុំឱ្យរដ្ឋបាលក្រុង ស្រុកបង្កើតក្រុមការងារសម្រាប់ចុះតាមដានត្រួតពិនិត្យ វាយតម្លៃ និងធ្វើការណែនាំដល់មន្ត្រីអនុវត្តការងារនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ឱ្យបាន ១ ឬ២លើកក្នុងមួយឆ្នាំ និងជារៀងរាល់ឆ្នាំ | | ✓ | ✓ | |
| ៣ | ស្នើសុំទីចាត់ការផែនការ និងវិនិយោគ និងរដ្ឋបាលក្រុង ស្រុក ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងវិនិយោគឃុំ សង្កាត់ និងក្រុង ស្រុកឱ្យបានទាន់ពេលវេលា | | ✓ | ✓ | |
| **VIII. បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | | | | | |
| ១ | ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចមួយចំនួនតូចនៅប្រកាន់ទំនៀមទម្លាប់ ពេលស្លាប់ត្រូវដាក់ឯកសារទៅជាមួយសាកសព ដែលនាំឱ្យមានការលំបាកក្នុងការសុំសេវារដ្ឋបាលផ្សេងៗ | ✓ | | | |
| ២ | ស្នើសុំឱ្យមានការធ្វើកែសម្រួលឃុំ សង្កាត់ដែលស្ថិតក្នុងតំបន់ឃ្លាំមើលបរិស្ថាន និងជម្រកព្រៃឈើមកជាតំបន់កសិកម្ម ឬលំនៅដ្ឋាន ដែលបានប្រែក្លាយពីតំបន់ព្រៃឈើទៅជាតំបន់សហគមន៍រួចហើយ | | ✓ | ✓ | |

**កំណត់សម្គាល់÷**

- ឃ/ស៖ ឃុំ សង្កាត់
- ក/ស/ខ៖ ក្រុង ស្រុក ខណ្ឌ
- រ/ខ៖ រាជធានី ខេត្ត
- ក្រ/ស៖ ក្រសួង ស្ថាប័ន

## តារាងឧបសម្ព័ន្ធទី ២

## បញ្ជីបញ្ហាប្រឈម/សំណើសំណូមពរដែលស្នើឡើងដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងដំណោះស្រាយនៅតាមស្ថាប័នមានសមត្ថកិច្ចនីមួយៗ

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | | |
|---|---|---|---|---|
| | | ក/ស/ខ | រ/ខ | ក្រុ/ស |
| **I.** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** | | | |
| ១ | – ប្រព័ន្ធអនុវត្តការងារនៅក្រុង ស្រុក (ការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវា) នៅមិនទាន់មានលក្ខណៈទំនើប ស្នើបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងឯកសារ ដែលប្រកបដោយប្រសិទ្ធភាព បច្ចេកទេស និងសុវត្ថិភាព ដើម្បីរក្សា និងទាញយកបានទាន់ពេលវេលា | | ✓ | ✓ |
| ២ | – ស្នើសុំកែសម្រួលក្របខ័ណ្ឌពេលវេលារៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ដោយឆ្លាស់ឆ្នាំគ្នា (កុំឱ្យអនុវត្តដូចគ្នាក្នុងឆ្នាំតែមួយ) | ✓ | ✓ | |
| ៣ | ស្នើសុំកែសម្រួលពេលវេលារៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាខេត្ត ពីអំឡុងត្រីមាសទី៤ មកក្នុងអំឡុងត្រីមាសទី១ នៃឆ្នាំវិញ | ✓ | ✓ | |
| ៤ | ស្នើសុំកែសម្រួលនីតិវិធីតែងតាំងប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ដោយពុំចាំបាច់លើកសំណើផ្តល់ការឯកភាពពីក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ✓ | ✓ | |
| ៥ | រដ្ឋបាលក្រុង ស្រុកស្នើសុំបង្កើតការិយាល័យអគ្រានុកូលដ្ឋាន | | ✓ | |
| ៦ | ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលចាប់ពីខែមករា បញ្ចប់នៅខែធ្នូ នៅឆ្នាំនីមួយៗ រីឯការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ ចាប់ផ្តើមពីខែមិថុនា និងឱ្យបានរួចរាល់ត្រឹមខែតុលា នៃឆ្នាំនីមួយៗ។ បានសេចក្តីថាដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ពុំមានសង្គតិភាពជាមួយនឹងការរៀបចំថវិកាប្រចាំឆ្នាំ | ✓ | ✓ | |

| | | | | |
|---|---|---|---|---|
| ៧ | ព្រំប្រទល់រដ្ឋបាលក្រុង ស្រុកពុំទាន់មានភាពច្បាស់លាស់ | | ✓ | ✓ |
| ៨ | ស្នើរៀបចំឱ្យមានលក្ខខណ្ឌ និងលក្ខណសម្បត្តិសម្រាប់រៀបចំជារដ្ឋបាលក្រុង ឬជារដ្ឋបាលស្រុក | | | ✓ |
| ៩ | ស្នើសុំឱ្យមានការសិក្សា និងពិនិត្យមើលឡើងវិញលើការរៀបចំរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក ឱ្យស្របទៅតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្ដានុពលសេដ្ឋកិច្ច និងតម្រូវការជាក់ស្ដែង | | | ✓ |
| ១០ | នីតិវិធីនៃការប្រើប្រាស់ត្រាមូលរបស់ការិយាល័យមួយចំនួន ដែលបានធ្វើសមាហរណកម្មទៅឱ្យរដ្ឋបាល ក្រុង ស្រុកមិនមានការឯកភាពគ្នា (ឧ.៖ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ...) | | ✓ | |
| ១១ | កិច្ចប្រជុំគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាពុំទាន់បានទៀងទាត់ | ✓ | | |
| ១២ | យន្តការទំនាក់ទំនង និងទីតាំងផ្ដល់ព័ត៌មានតាមរយៈការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ មិនទាន់បង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋ ឬសាធារណជន ក្នុងការទំនាក់ទំនងការងារ ដូចជា ការសួរនាំព័ត៌មាន ការដាក់លិខិតស្នើសុំ ឬបណ្ដឹងផ្សេងៗនៅឡើយ | ✓ | ✓ | |
| ១៣ | ការិយាល័យ អង្គភាពភាគច្រើនមិនមានរៀបចំផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ឆ្លើយតបនឹងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលនៅឡើយ | ✓ | | |
| ១៤ | ក្រៅពីការរៀបចំវេទិកាសាធារណៈ ការចុះជួបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋ រដ្ឋបាលស្រុកមិនទាន់មានការរៀបចំជាសេចក្ដីប្រកាសព័ត៌មានស្ដីពីលទ្ធផលកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដូចជាលទ្ធផលការងារ ការដោះស្រាយបញ្ហាដែលកើតមានកន្លងមក និងទិសដៅការងារបន្ត ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសាធារណជនបានជ្រាបបន្ថែមទៀតនៅឡើយ | ✓ | ✓ | |
| ១៥ | ការរៀបចំវេទិកាសាធារណៈផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មិនដែលបានអនុវត្តនោះទេ ដែលធ្វើឱ្យបាត់ព័ត៌មានមួយចំនួនពីប្រជាពលរដ្ឋ | ✓ | ✓ | |
| ១៦ | ទោះបីរដ្ឋបាលស្រុកបានចេញសេចក្ដីសម្រេចបែងចែកតួនាទី ភារកិច្ច ដល់នាយករងរដ្ឋបាល ប្រធាន អនុប្រធានការិយាល័យ អង្គភាពរួចហើយ ប៉ុន្តែការអនុវត្តមិនទាន់បានពេញលេញនៅឡើយ ចំណែកការរៀបចំការបែងចែកភារកិច្ចដល់មន្ត្រី | ✓ | | |

| | | | | |
|---|---|---|---|---|
| | ចំណុះការិយាល័យ និងការកំណត់របបប្រជុំផ្ទៃក្នុងការិយាល័យ មិនបានទៀងទាត់ និងមិនទាន់ពេញលេញនៅឡើយ ការិយាល័យមួយចំនួននៅមិនសូវយកចិត្តទុកដាក់លើការចុះបញ្ជីវត្តមានមន្ត្រី និងមិនបានប្រគល់មកការិយាល័យគ្រប់គ្រងធនធានមនុស្សបានទៀងទាត់ តាមការណែនាំរបស់រដ្ឋបាល ក្រុង ស្រុក | | | |
| ១៧ | ពុំសូវមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការរបស់រដ្ឋបាលក្រុង ស្រុក | ✓ | | |
| ១៨ | ការរៀបចំចេញដីកា សេចក្តីសម្រេច និងបែបបទការងាររបស់រដ្ឋបាលក្រុង ស្រុក នៅមានខ្វះចន្លោះលើឯកសារយោងផ្សេងៗ ឯកសាររដ្ឋបាលមួយចំនួនបានកែប្រែ នីតិវិធីរដ្ឋបាលមួយចំនួនមាន តែមិនបានអនុវត្ត រង់ចាំការណែនាំថ្មី | | ✓ | |
| ១៩ | ស្នើសុំបញ្ចូលគណៈកម្មាធិការដោះស្រាយទំនាស់ និងនីតិកម្មទៅក្នុងរចនាសម្ព័ន្ធស្រុក | | ✓ | |
| ២០ | ពុំបានដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលស្រុកជូនក្រុមប្រឹក្សាស្រុក ពិនិត្យនិងអនុម័ត | ✓ | | |
| ២១ | ស្នើសុំបណ្តុះបណ្តាលសមត្ថភាពដល់គណៈកម្មាធិការនានារបស់ក្រុង ស្រុក | ✓ | ✓ | |
| **II. មុខងាររដ្ឋបាលក្រុង ស្រុក ខណ្ឌ (មុខងារជាអាណត្តិទូទៅ និងមុខងារផ្ទេរ)** | | | | |
| ១ | ខ្វះគោលការណ៍ និងនីតិវិធីអនុវត្តមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ព្រមទាំងការបណ្តុះបណ្តាល | | ✓ | ✓ |
| ២ | មុខងារជាច្រើនដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ពុំមានផ្ទេរធនធានហិរញ្ញវត្ថុ និងធនធានមនុស្សភ្ជាប់មកជាមួយ | | | ✓ |
| ៣ | ទំហំ និងប្រភេទសេវាមួយចំនួនដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយលែងសមស្របទៅនឹងស្ថានភាពរីកចម្រើនសេដ្ឋកិច្ច សង្គម គួរសិក្សា និងពិនិត្យមើលទំហំនិងប្រភេទសេវាឡើងវិញនិងធ្វើបច្ចុប្បន្នភាព | | ✓ | ✓ |
| ៤ | – មុខងារដែលបានប្រគល់ទៅឱ្យក្រុង ស្រុកហើយ ប៉ុន្តែមុខងារទាំងនោះនៅតែបន្តអនុវត្តដោយមន្ទីរជំនាញ (មន្ទីរកសិកម្ម)<br>– មុខងារមួយចំនួនដែលផ្ទេរមកហើយ ស្ថាប័នអនុវត្តមិនបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុកគឺនៅស្ថាប័នសាមី អនុវត្តនៅឡើយ(វិស័យធនធានទឹក ប្រឡាយជើងក្អែប អភិវឌ្ឍន៍ជនបទ វិស័យទេសចរណ៍......) | | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| | – ការផ្តល់អាជ្ញាប័ណ្ណបើកសាលាបឋមសិក្សាឯកជន នៅតែអនុវត្តដោយមន្ទីរអប់រំមិនទាន់ប្រគល់សិទ្ធិឱ្យរដ្ឋបាលក្រុង ស្រុក (អនុក្រឹត្យ២១៣) | | | |
| ៥ | សំណើសុំជួយកំណត់មុខងារជាជម្រើស និងកាតព្វកិច្ច និងរៀបចំសេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ នីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារជាជម្រើស និងកាតព្វកិច្ច | | ✓ | ✓ |
| ៦ | សំណើសុំផ្តល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំ និងការអនុវត្តគម្រោងក្រុង ស្រុក | | ✓ | |
| ៧ | – នីតិវិធីផ្តល់សេវារដ្ឋបាលនៃវិស័យមួយចំនួនស្មុគស្មាញ និងតម្រូវឯកសារច្រើនប្រភេទ (ដីធ្លី)<br>– វិស័យសំណង់៖ នីតិវិធីសុំច្បាប់សាងសង់មានភាពសាំញ៉ាំ | | ✓ | ✓ |
| ៨ | សំណើសុំបង់សួយសាររណ្តៅដីចល័ត និងសេវាបរិស្ថាននៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ដោយសារប្រជាពលរដ្ឋប្រកបរបរអាជីវកម្មមានការលំបាករត់ទៅស្រុកផង និងរត់ទៅខេត្តផង | | ✓ | |
| ៩ | សំណើសុំការបង់សេវាត្រួតពិនិត្យអនាម័យសាច់សត្វ នៅសត្តឃាតដ្ឋានតាមក្រុង ស្រុក | | ✓ | ✓ |
| ១០ | សំណើសុំផ្តល់សិទ្ធិជូនដល់មន្ត្រីការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានស្រុក ដើម្បីធ្វើការត្រួតពិនិត្យចំពោះអាជីវករពិឃាតសត្វនៅតំបន់ឆ្ងាយពីសត្តឃាតដ្ឋាន | | ✓ | ✓ |
| ១១ | ស្នើសុំផ្ទេរមុខងារគ្រប់គ្រងទីលានសត្តឃាតដ្ឋាន ការផ្ទេរការគ្រប់គ្រងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក មកស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក | | ✓ | ✓ |
| ១២ | ការិយាល័យច្រកចេញចូលតែមួយស្រុកមិនបានទទួលតម្លៃសេវាភាគលាភពីសេវាធនធានរ៉ែ ដីករណ្តៅដី និងបកអាចម៍ដីចល័ត ដោយសារត្រូវបង់ចូលទៅក្រសួងរ៉ែ និងថាមពល ១០០% | | ✓ | ✓ |
| ១៣ | ស្នើសុំមន្ត្រីសាខាពន្ធដារនៅថ្នាក់ស្រុក ដើម្បីបង្ខិតសេវាពន្ធដារឱ្យនៅជិតប្រជាពលរដ្ឋ | | ✓ | ✓ |
| ១៤ | សំណើសុំបញ្ចូលសង្កាត់រដ្ឋបាលជលផល និងសង្កាត់រដ្ឋបាលព្រៃឈើទៅក្នុងរចនាសម្ព័ន្ធការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានក្រុង ស្រុក | | ✓ | ✓ |
| ១៥ | ការភ្ជាប់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំជាមួយនឹងរដ្ឋបាលក្រុង ស្រុក | | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| ១៦ | វិស័យរ៉ែ មុខងារផ្តល់អោយ តែលំបាកក្នុងការចេញលិខិតអនុញ្ញាត ពីព្រោះមិនទាន់មានការកំណត់តម្លៃសេវាជាក់លាក់ ដូចជា ដេប៉ូខ្សាច់ ថ្ម ប្រេង ហ្គាស ជាដើម | | ✓ | ✓ |
| ១៧ | ស្នើសុំក្រសួងសាធារណការ និងដឹកជញ្ជូន ទំលាក់ប្រព័ន្ធ(USER)សម្រាប់ចុះបញ្ជីទោចក្រយានយន្ត និងត្រីចក្រយានយន្ត មករដ្ឋបាលស្រុក | | ✓ | ✓ |
| ១៨ | ស្នើសុំផ្ទេរការិយាល័យសុខាភិបាល ឬផ្ទេរមន្ទីរពេទ្យ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព មកក្រោមការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក | | | ✓ |
| ១៩ | ពុំទាន់មានការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ | ✓ | ✓ | |
| ២០ | ស្នើសុំឱ្យមានការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារដែលបានផ្ទេរ | | | ✓ |
| ២១ | ស្នើសុំពិចារណាផ្ទេរមុខងារក្នុងការផ្តល់សេវាផ្ទេរកម្មសិទ្ធិដែលបានចុះបញ្ជី (ប្លង់រឹង) មករដ្ឋបាលក្រុង ស្រុកទទួលខុសត្រូវ ដើម្បីពន្លឿនក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋលើការគ្រប់គ្រងដីធ្លី។ | | | ✓ |
| **III. ធនធានមនុស្សនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ** | | | | |
| ១ | ខ្វះការកំណត់មុខតំណែងវិជ្ជាជីវៈ និងលក្ខខណ្ឌការងារសម្រាប់មន្ត្រី | | ✓ | ✓ |
| ២ | ចំនួន និងសមត្ថភាពមន្ត្រីមិនទាន់អាចឆ្លើយតបទៅនឹងរចនាសម្ព័ន្ធថ្មី (ការសិក្សា និងអនុវត្តគម្រោង ឌីជីថល...) | | ✓ | ✓ |
| ៣ | ខ្វះមន្ត្រីជំនាញតាមវិស័យមួយចំនួន និងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ | | ✓ | ✓ |
| ៤ | ស្នើសុំឱ្យមានការរៀបចំយន្តការលើកទឹកចិត្តសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី | ✓ | | ✓ |
| ៥ | ការប្រលងជ្រើសរើសមន្ត្រី គួរយកមន្ត្រីដែលមានទីលំនៅក្នុងក្រុង ស្រុកផ្ទាល់ | | ✓ | |
| ៦ | ខ្វះប្រព័ន្ធលើកទឹកចិត្តដើម្បីជំរុញមន្ត្រីទៅធ្វើការនៅស្រុកជនបទ | | ✓ | ✓ |
| ៧ | ស្នើរដ្ឋបាលក្រុង ស្រុកមានសិទ្ធិក្នុងការជ្រើសរើសមន្ត្រីកិច្ចសន្យាតាមតម្រូវការ | | ✓ | |

| | | | | |
|---|---|---|---|---|
| ៨ | ស្នើសុំឱ្យមានប្រព័ន្ធគ្រប់គ្រងបញ្ជីវត្តមាន និងស្កេនដៃរួមជាមួយថ្នាក់ជាតិ (ឌីជីថល) | | ✓ | ✓ |
| ៩ | ក្រោយផ្ទេរមុខងារក្នុងវិស័យអប់រំ មិនទាន់ទទួលគោលការណ៍អនុញ្ញាតជ្រើសរើសបុគ្គលិកអប់រំកិច្ចសន្យា និងសមត្ថកិច្ចតែងតាំងថ្នាក់ដឹកនាំសាលា | | | ✓ |
| ១០ | ស្នើសុំប្រគល់សិទ្ធិលើការងារតែងតាំង និងបញ្ចប់មុខតំណែងស្មៀនឃុំ សង្កាត់ | | ✓ | |
| ១១ | ស្នើសុំពន្លឿនការរៀបចំនីតិវិធីនៃការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សា | | | ✓ |
| ១២ | ស្នើសុំប័ណ្ណសម្គាល់មន្ត្រីរាជការ | | ✓ | |
| ១៣ | មន្ត្រីនៅរដ្ឋបាលស្រុកមានវ័យចំណាស់ និងជិតចូលនិវត្តន៍ច្រើន | ✓ | ✓ | |
| **IV. ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** | | | | |
| ១ | – ការយល់ដឹងអំពីនីតិវិធីបញ្ចូល និងជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋនៅមានកម្រិត និងត្រូវចំណាយពេលវេលាយូរ<br>– ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមិនទាន់បានពេញលេញនៅឡើយ ជាពិសេស ការធ្វើបច្ចុប្បន្នភាពទ្រព្យសម្បត្តិរដ្ឋដែលខូចខាត លែងប្រើប្រាស់បាន ឬទិញចូលមកថ្មីបន្ថែម ដោយមានការបិទតែមបញ្ជាក់ដូចមានកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ | ✓ | ✓ | ✓ |
| ២ | ថវិកាអភិវឌ្ឍន៍មិនសមស្របនឹងតម្រូវការរបស់មូលដ្ឋាន | | | ✓ |
| ៣ | ទំហំធនធានសម្រាប់សេវាសង្គមនៅមានកម្រិត និងមិនទាន់មានការកំណត់មុខសញ្ញាចំណាយ និងនីតិវិធីទូទាត់សម្រាប់ប្រើប្រាស់ថវិកាសេវាសង្គម និងសេវាអនាម័យ | | ✓ | ✓ |
| ៤ | នីតិវិធីលទ្ធកម្មមានភាពស្មុគស្មាញ | | ✓ | |
| ៥ | នីតិវិធីទូទាត់ចំណាយមានភាពសាំញ៉ាំ និងស្មុគស្មាញ | | ✓ | ✓ |
| ៦ | ខ្វះធនធានថវិកាអនុវត្តមុខងារដែលបានផ្ទេរមកក្រុង ស្រុក (ប្រតិបត្តិការៈ ទំហំបេសកកម្ម និងរដ្ឋបាលកើនឡើង ប៉ុន្តែថវិកានៅដដែល) | | | ✓ |

| | | | | |
|---|---|---|---|---|
| ៧ | គ្របខ័ណ្ឌពេលវេលារៀបចំថវិកាប្រចាំឆ្នាំមានរយៈពេលតិចពេក | | ✓ | ✓ |
| ៨ | សំណូមពរឱ្យមានកញ្ចប់ថវិកាដោយឡែកសម្រាប់ក្រុមប្រឹក្សា | ✓ | ✓ | |
| ៩ | ការផ្តល់ឧបត្ថម្ភសមតុល្យពីថ្នាក់ជាតិ ស្នើសុំដកថវិកាអភិវឌ្ឍមូលដ្ឋានដោយឡែក ហើយថវិកាដែរនៅសល់ចែកជា៤ត្រីមាស ដើម្បីផ្តល់ឧបត្ថម្ភត្រីមាសជូនក្រុង ស្រុក | | ✓ | |
| ១០ | ស្នើសុំតុល្យភាពក្រុង ស្រុក ណាដែលផ្ញើដល់មុន ស្នើសុំរៀបចំផ្តល់មុន ឬរង់ចាំរយៈពេលខ្លី បើរង់ចាំរយៈពេលកន្លះខែ ឬមួយខែនោះមិនយុត្តិធម៌ចំពោះក្រុង ស្រុកដែលខិតខំបំពេញការងារ | | ✓ | |
| ១១ | សំណើជួយបន្ស៊ីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិកាក្រុង ស្រុក | | ✓ | |
| ១២ | ស្នើសុំផ្តល់ថវិកាតាមត្រីមាសដោយពុំចាំបាច់ស្នើសុំតុល្យភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ✓ | |
| ១៣ | មិនទាន់មានធនធានថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | | ✓ |
| ១៤ | មិនទាន់មានការកំណត់មុខសញ្ញាចំណាយ និងនីតិវិធីទូទាត់សម្រាប់ប្រើប្រាស់ថវិកាសេវាសង្គម និងអនាម័យបរិស្ថាន ស្នើសុំឱ្យមានការណែនាំឱ្យបានច្បាស់លាស់ ព្រមទាំងការកំណត់ឈ្មោះគម្រោងសេវាសង្គម | | | ✓ |
| ១៥ | – រដ្ឋបាលស្រុកមួយចំនួនពុំទាន់មានអគាររដ្ឋបាលសមរម្យនៅឡើយ<br>– ស្នើសុំអគារស្តង់ដាក្នុងសាលាក្រុង ស្រុក<br>– ស្នើសុំអគារច្រកចេញចូលតែមួយ | ✓ | ✓ | ✓ |
| ១៦ | ខ្វះអគារសិក្សា និងសម្ភារសិក្សារបស់សាលា | ✓ | ✓ | |
| ១៧ | – ស្នើពិចារណាក្នុងការគិតគូរទៅលើប្រាក់បេសកកម្មនៅពេលមន្ត្រីចុះអនុវត្តការគាំទ្រតាមមូលដ្ឋានទោះមិនគ្រប់គីឡូក៏ដោយ (សូមអោយមានប្រាក់ឧបត្ថម្ភប្រេង)<br>– ការទូទាត់ថវិកាបេសកកម្ម ដែលចុះបំពេញការងារក្នុងមូលដ្ឋាន (លុះត្រាមានចំងាយលើសពី ៤០គ.ម) នាំឱ្យមន្ត្រីបំពេញបេសកកម្មនៅភ្នំពេញ ពុំបានទទួលថវិកានោះឡើយ | | ✓ | ✓ |
| ១៨ | សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ដែលដាច់អាណត្តិ ចាប់ពី៣អាណត្តិ ឡើងទៅសុំឱ្យមានប្រាក់សោធនិវត្តន៍ | | | ✓ |

| | | | | |
|---|---|---|---|---|
| ១៩ | ពុំបានបិត និងផ្សព្វផ្សាយគម្រោងថវិការបស់រដ្ឋបាលស្រុកឱ្យបានទូលំទូលាយជាសាធារណៈជូនប្រជាពលរដ្ឋ | ✓ | ✓ | |
| ២០ | អនុវត្តផែនការលទ្ធកម្មមិនត្រឹមត្រូវតាមពេលវេលាកំណត់ | ✓ | ✓ | |
| ២១ | ប្រព័ន្ធថវិកាឃុំ សង្កាត់និងប្រព័ន្ធថវិកាក្រុង ស្រុក គឺពុំដូចគ្នាដែលនាំឱ្យមានការលំបាកក្នុងការតាមដាន និងគាំទ្រ ស្នើឱ្យរៀបចំប្រព័ន្ធដូចគ្នា | ✓ | ✓ | |
| ២២ | ថវិកា ក្រុង ស្រុកសម្រាប់វិស័យបរិស្ថាន និងសង្គមនៅមានកម្រិត | ✓ | ✓ | |
| **V.** | **ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌនិងរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយប្រជាពលរដ្ឋ** | | | |
| ១ | ការចូលរួមជាមតិយោបល់ សំណើ សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋផ្ទាល់នៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ មិនទាន់បានផុសផុលនៅឡើយ គឺភាគច្រើនជាការលើកឡើងរបស់អាជ្ញាធរមូលដ្ឋានទៅវិញប្រជាពលរដ្ឋភាគច្រើនលើកឡើងពីសំណើ សំណូមពរ កង្វល់ និងបណ្តឹងតាមរយៈប្រព័ន្ធបណ្តាញសង្គម | ✓ | ✓ | |
| ២ | ខ្វះការគាំទ្រពីមន្ទីរជំនាញដល់មន្ត្រីជំនាញរបស់ការិយាល័យជំនាញមួយចំនួន ក្រោយធ្វើសមាហរណកម្ម | | ✓ | |
| ៣ | ករណីមានការចុះបំពេញបេសកកម្មនានារបស់មន្ទីរជំនាញ ស្នើសុំឱ្យមានកិច្ចសហការជាមួយរដ្ឋបាលក្រុង ស្រុក | | ✓ | |
| ៤ | ក្រសួង ស្ថាប័ន និងមន្ទីរអង្គភាពមួយចំនួន ពុំសូវសហការគាំទ្របច្ចេកទេស លើមុខងារដែលបានផ្ទេរជូន | | ✓ | ✓ |
| ៥ | នៅមិនទាន់យល់ដឹងច្បាស់ពីខ្សែគណនេយ្យភាពជាមួយថ្នាក់ជាតិ និងថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ | ✓ | ✓ | |
| **VI.** | **ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** | | | |
| ១ | – ស្នើសុំឱ្យមានការរៀបចំប្រព័ន្ធឌីជីថលសម្រាប់ការងារកែតម្រូវអត្រានុកូលដ្ឋាន<br>– ដោយបញ្ជីអត្រានុកូលដ្ឋានមិនទាន់បញ្ចូលជាប្រព័ន្ធនៅឡើយ ការត្រួតពិនិត្យគល់បញ្ជីជាប្រចាំបានធ្វើឱ្យសៀវភៅមួយចំនួនធំខូច ស្នើសុំរៀបចំជាប្រព័ន្ធក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន | | | ✓ |

| | | | | |
|---|---|---|---|---|
| | – ការផ្គត់ផ្គង់សម្ភារសម្រាប់ផ្តល់សេវាអត្រានុកូលដ្ឋានមិនគ្រប់គ្រាន់ | | | |
| ២ | ស្នើសុំការកែសម្រួលទិន្នន័យអត្រានុកូលដ្ឋានត្រឹមរដ្ឋបាលក្រុង ស្រុក ឬខេត្ត | | ✓ | |
| ៣ | ពុំទាន់មានការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល | | | ✓ |
| ៤ | ការសិក្សា និងការរៀបចំគម្រោងអភិវឌ្ឍន៍មូលដ្ឋាននៅមានកម្រិត | | ✓ | ✓ |
| ៥ | ការទទួលវគ្គបណ្តុះបណ្តាលខុសពីការអនុវត្តមុខងារជាក់ស្តែង (ទាក់ទងនឹងតម្លៃសេវាការប្រគុំតន្ត្រីសាធារណៈ ការណែនាំគឺសេវាគិតជាលើក ៣ថ្ងៃ គិតមួយលើក តម្លៃ ៤០០.០០០រៀល តែមិនមានលិខិតបទដ្ឋានណាដែលបញ្ជាក់ថា ៣ថ្ងៃ គិតមួយលើក តម្លៃ ៤០០.០០០រៀលទេ ជាហេតុធ្វើឱ្យអ្នកមកស្នើសុំសេវា គិតមិនល្អមកលើមន្ត្រីបម្រើសេវាជូន ក្នុងការិយាល័យ នៅពេលយើងគិតជាថ្ងៃនៃការសម្តែង) | | | ✓ |
| ៦ | រដ្ឋបាលស្រុកមិនអាចដោះស្រាយបានគ្រប់បញ្ហាប្រឈម ដែលលើកឡើងតាមរយៈវេទិកាសាធារណៈដោយសារសមត្ថកិច្ច និងសមត្ថភាពរបស់ស្រុកនៅមានកម្រិត ហើយបញ្ហាខ្លះពាក់ព័ន្ធនឹងសមត្ថកិច្ចក្រសួង មន្ទីរ អង្គភាពជំនាញ | | ✓ | ✓ |
| ៧ | ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងមិនទាន់បានល្អ ដោយសារខ្វះក្រុមហ៊ុនផ្តល់សេវា ខ្វះទីលានចាក់សំរាម ការចូលរួមរបស់ប្រជាជនមានកម្រិត | ✓ | ✓ | |
| ៨ | គួរមានមន្ត្រីបច្ចេកទេសគម្រោងថ្នាក់ស្រុក ដើម្បីពន្លឿនការអនុវត្តគម្រោងឃុំ និងស្រុក | | ✓ | |
| ៩ | ស្នើសុំឱ្យមានប្លង់គោលប្រើប្រាស់ដីធ្លីថ្នាក់ក្រុង ស្រុក | | ✓ | ✓ |
| ១០ | សេវាសុខាភិបាលឯកជន មិនបានមកបន្តលិខិតអនុញ្ញាតទៀងទាត់ លើការស្នើសុំបើកបន្ទប់ព្យាបាលនិងមានមួយចំនួនបើកមុនមកសុំការអនុញ្ញាត | ✓ | ✓ | |
| ១១ | ការងារដែនដី នគរូបនីយកម្ម មិនមានឧបករណ៍បច្ចេកទេសគ្រប់គ្រាន់ | | ✓ | |
| ១២ | – ការរៀបចំកាតគ្រីម៉ូតូនៅថ្នាក់ស្រុក មានបញ្ហាអក្ខរាវិរុទ្ធក្នុងប្រព័ន្ធ សំណូមពរផ្ញើរឯកសារតាមប្រព័ន្ធ និងមិនចាំបាច់កាន់ឯកសារដើមជូនទៅក្រសួង | | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| | – ការចុះបញ្ជីទុតិយតាស្លាកលេខ និងបណ្ណមានការយឺតយ៉ាវក្នុងការទម្លាក់ទិន្នន័យ មកការិយាល័យច្រកចេញចូលតែមួយ ស្នើក្រសួងសាធារណការ និងដឹកជញ្ជូន ជួយទម្លាក់ទិន្នន័យឱ្យបានលឿន | | | |
| ១៣ | រដ្ឋបាលស្រុកស្នើទៅរដ្ឋបាលខេត្តជួយសម្របសម្រួល ជាមួយស្ថាប័នផ្ទេរមុខងារការផ្ទេរកម្មសិទ្ធិប្លង់រឹងមករដ្ឋបាលស្រុកទទួលខុសត្រូវក្នុងការផ្ដល់សេវាលើមុខងារនេះ។ ដោយសំអាងថាប្រជាពលរដ្ឋមានបណ្ណកម្មសិទ្ធិហើយ ម៉្យាងទៀតការិយាល័យដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលមានទិន្នន័យគ្រប់គ្រងដីដែលមានបណ្ណទាំងស្រុងក្នុងការសម្រួលដល់ការផ្ដល់សេវានេះឱ្យបានឆាប់រហ័ស | | ✓ | ✓ |
| ១៤ | ស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធ មុននឹងចេញអាជ្ញាប័ណ្ណ សូមឱ្យមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក | | ✓ | ✓ |
| ១៥ | ស្នើសុំសេវាសាងសង់របងនៅការិយាល័យច្រកចេញចូលតែមួយ (តម្រូវឱ្យប្រជាពលរដ្ឋមានប្លង់ស្ថាបត្យកម្មនៃសំណង់ និងវិញ្ញាបនបត្រក្រុមជាង ដោយជួលសេវាគូរខាងក្រៅអស់ថវិកាច្រើន) ស្នើសុំធ្វើការកែតម្រូវដាក់បញ្ចូលសេវាគូរប្លង់ស្ថាបត្យកម្មនៃសំណង់ទៅក្នុងសេវាច្រក និងកំណត់តម្លៃសមរម្យ | | ✓ | |
| **VII. ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្ម** | | | | |
| ១ | ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យគ្រប់ជំនាញនៅឡើយ | ✓ | ✓ | ✓ |
| ២ | ខ្វះការគាំទ្របច្ចេកទេស មធ្យោបាយ ការអភិវឌ្ឍសមត្ថភាពពីមន្ទីរជំនាញនានាដល់មន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុក ក្រោយធ្វើសមាហរណកម្មការិយាល័យជំនាញ | | ✓ | ✓ |
| ៣ | យន្តការចុះត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិមានច្រើនក្រុមពេកក្នុងមួយឆ្នាំៗ (ការងារត្រួតគ្នា) ហើយផ្ដល់ការណែនាំខុសៗគ្នា | | | ✓ |
| **VIII. បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | | | | |
| ១ | ប្រអប់សំបុត្រគណនេយ្យភាពគ្រប់ឃុំពុំសូវមានប្រជាពលរដ្ឋប្រើប្រាស់ | ✓ | ✓ | |

| | | | | |
|---|---|---|---|---|
| ២ | ស្នើសុំឱ្យមានថវិកាឧបត្ថម្ភ ការហូបចុក និងថ្លៃស្នាក់ សម្រាប់អភិបាលរងស្រុក ដែលដល់អាណត្តិ ហើយត្រូវផ្លាស់ប្តូរទៅក្រុង ស្រុកផ្សេងៗ | | ✓ | |
| ៣ | ស្នើសុំឱ្យមានការរៀបចំកិច្ចប្រជុំតាមប្រព័ន្ធ Online ឱ្យបានច្រើន ដើម្បីកាត់បន្ថយការឡើងទៅចូលរួមកិច្ចប្រជុំដោយផ្ទាល់នៅតាមក្រសួង ស្ថាប័ន | | ✓ | |
| ៤ | ស្នើសុំឱ្យមានមេធាវីស្ម័គ្រចិត្ត ១នាក់ នៅប្រចាំស្រុក។ | | ✓ | |

**កំណត់សម្គាល់÷**

- ក/ស/ខ៖ ក្រុង ស្រុក ខណ្ឌ
- រ/ខ៖ រាជធានី ខេត្ត
- ក្រ/ស៖ ក្រសួង ស្ថាប័ន

# តារាងឧបសម្ព័ន្ធទី ៣

## បញ្ជីបញ្ហាប្រឈម/សំណើសំណូមពរដែលស្នើឡើងដោយរដ្ឋបាលរាជធានី ខេត្ត និងដំណោះស្រាយទៅតាមស្ថាប័នមានសមត្ថកិច្ចនីមួយៗ

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | ស្ថាប័នដោះស្រាយ | |
|---|---|---|---|
| | | រ/ខ | ក្រ/ស |
| | **I. រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលរាជធានី ខេត្ត** | | |
| ១ | – រចនាសម្ព័ន្ធរដ្ឋបាលខេត្តពុំទាន់ក្លាយជារដ្ឋបាលឯកភាពដូចរដ្ឋបាលក្រុង ស្រុកដែលអាចគ្រប់គ្រង និងអភិវឌ្ឍលើគ្រប់វិស័យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– រចនាសម្ព័ន្ធខេត្តមួយចំនួនពុំទាន់សមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងចរិតលក្ខណៈរបស់រដ្ឋបាលខេត្តនីមួយៗ និងឆ្លើយតបទៅនឹងលក្ខខណ្ឌទីក្រុងឆ្លាត (ខេត្តតំបន់ឆ្នេរដែលជាប៉ូលសេដ្ឋកិច្ចសំខាន់ ឧ. ខេត្តព្រះសីហនុ)<br>– ស្នើសិក្សា និងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ តួនាទី ភារកិច្ចទីចាត់ការ ការិយាល័យរបស់រដ្ឋបាលខេត្តឱ្យស្របទៅតាមស្ថានភាពជាក់ស្តែង<br>– ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវានៅពុំទាន់មានលក្ខណៈទំនើបតាមប្រព័ន្ធឌីជីថល<br>– ស្នើសុំឱ្យមានការវិភាគមុខងាររបស់រដ្ឋបាលខេត្ត ដើម្បីជៀសវាងមុខងារដែលត្រួតស៊ីគ្នារវាងខេត្ត និងមន្ទីរ(ឧទាហរណ៍ ការងារស្ថិតិ ប្រជាពលរដ្ឋ ការងារស្ថិតិរោងចក្រ ការងារស្ថិតិកម្មករ និងការងារអត្រានុកូលដ្ឋាន) | | ✓ |
| ២ | – គណៈកម្មាធិការទាំង៣ របស់ក្រុមប្រឹក្សាខេត្តពុំទាន់បំពេញតួនាទីរបស់ខ្លួនបានពេញលេញដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត<br>– ស្នើអនុញ្ញាតជំរុញ និងលើកទឹកចិត្តឱ្យវិស័យឯកជន និងយុវជនចូលរួមជាសមាជិករបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា | ✓ | |

| | | | |
|---|---|---|---|
| | – ការផ្សព្វផ្សាយអំពីតួនាទីភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋនៅពុំទាន់បានផ្សព្វផ្សាយទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធ | | |
| ៣ | – សំណូមពរឱ្យមានអង្គភាពទទួលបន្ទុកការងារឌីជីថល<br>– ស្នើសុំឱ្យមានប្រព័ន្ធគ្រប់គ្រងបញ្ជីវត្តមានឌីជីថល | | ✓ |
| ៤ | ប្រព័ន្ធកសាងផែនការនៅថ្នាក់ខេត្តមិនទាន់រលូននៅឡើយ មិនទាន់បន្សុីគ្នារវាងក្របខ័ណ្ឌពេលវេលា (វដ្ត) នៃការរៀបចំគម្រោងថវិកា និងកម្មវិធីវិនិយោគបីឆ្នាំរំកិល | ✓ | ✓ |
| ៥ | – ស្នើសុំឱ្យមានអង្គភាពត្រួតពិនិត្យផ្ទៃក្នុងសម្រាប់រដ្ឋបាលខេត្ត<br>– ស្នើសុំឱ្យមានអង្គភាពទទួលបន្ទុកការប្រកាសទ្រព្យសម្បត្តិ និងការងារគាំទ្រក្រុមប្រឹក្សា (ការផ្លាស់ប្តូរ)<br>– ស្នើដំឡើងការិយាល័យធនធានមនុស្សទៅជាមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស | ✓ | ✓ |
| ៦ | បន្ទាប់ពីសមាហរណកម្មការិយាល័យជំនាញថ្នាក់ក្រុង ស្រុក ខណ្ឌ និងការផ្ទេរមុខងារនានាទៅឱ្យថ្នាក់ក្រោមជាតិ រចនាសម្ព័ន្ធរបស់មន្ទីរជំនាញមានការប្រែប្រួល ប៉ុន្តែក្របខ័ណ្ឌគតិយុត្ត ដូចជាការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ (សាធារណការ និងដឹកជញ្ជូន) នៅពុំទាន់បានកែសម្រួលឱ្យស្របទៅតាមស្ថានភាព និងការវិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ✓ | |
| ៧ | – ស្នើសុំកែសម្រួលក្របខ័ណ្ឌពេលវេលា ឆ្នាំនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាខេត្ត ខុសគ្នាជាមួយឆ្នាំនៃការរៀបចំវេទិការបស់ក្រុង ស្រុក ដោយឆ្លាស់ឆ្នាំគ្នា<br>– ស្នើសុំកែសម្រួលពេលវេលារៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាខេត្ត ពីអំឡុងត្រីមាសទី៤ មកក្នុងអំឡុងត្រីមាសទី១ នៃឆ្នាំវិញ<br>– ស្នើសុំកំណត់ទម្រង់របាយការណ៍រួមរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យមានលក្ខណៈដូចគ្នាដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិងាយស្រួលក្នុងការបូកសរុបរបាយការណ៍ផ្តល់ជូន | ✓ | |
| **II.** | **មុខងាររដ្ឋបាលរាជធានី ខេត្ត (មុខងារជាអាណាត្តិទូទៅ និងមុខងារដែលផ្ទេរ)** | | |
| ១ | – ការអនុវត្តមុខងារត្រួតគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នថ្នាក់ជាតិ | | ✓ |

| | | | |
|---|---|---|---|
| | – ការផ្ទេរមុខងារសេវាសាធារណការ និងមុខងារគ្រប់គ្រងមួយចំនួនជូនរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយ ប៉ុន្តែនៅមិនទាន់បានដកចេញពីប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ជាហេតុធ្វើឱ្យមានការត្រួតភារកិច្ចគ្នាក្នុងការអនុវត្ត និងគ្រប់គ្រងការងារ | | |
| ២ | – នៅខ្វះលិខិតបទដ្ឋានគតិយុត្តដែលកំណត់មុខងារជាមុខងារកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឧ. មុខងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ, សន្តិសុខ/សណ្តាប់ធ្នាប់, សុខាភិបាល, អប់រំ, សន្តិសុខស្បៀង, អនាម័យ/បរិស្ថាន, ការគ្រប់គ្រងនិងការប្រើប្រាស់ដីធ្លី, ការផ្គត់ផ្គង់ទឹកស្អាតនិងអគ្គិសនី ជាដើម)<br>– នៅពុំទាន់យល់ច្បាស់អំពីប្រភេទមុខងារ ភាពខុសគ្នានៃមុខងារ និងការអនុវត្តមុខងារ (មុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច)<br>– នីតិវិធី បែបបទនៃការរៀបចំគម្រោងសេវាសង្គម មានភាពស្មុគស្មាញ | ✓ | ✓ |
| ៣ | – ការអនុវត្តមុខងារការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល ៥លានដុល្លារចុះពុំទាន់អាចអនុវត្តបានពេញលេញនិងរលូននៅឡើយ ដោយសារក្រសួង ស្ថាប័នភាគច្រើនពុំទាន់ធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរ អង្គភាពរបស់ខ្លួននៅឡើយ និងនៅខ្វះសេចក្តីណែនាំបច្ចេកទេសអនុវត្ត និងការបណ្តុះបណ្តាល<br>– នីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ លើការនាំចូល និងការប្រើប្រាស់នូវសម្ភារសាងសង់ បរិក្ខារសំណង់ សម្ភារបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។ បច្ចុប្បន្នប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ពុំទាន់បានរៀបចំរួចរាល់នៅឡើយ<br>– រដ្ឋបាលរាជធានី ខេត្តមិនទាន់យល់ដឹងច្បាស់លាស់អំពីតួនាទីរបស់ខ្លួនក្នុងការទំនាក់ទំនង សម្របសម្រួល គាំទ្រ និងការតាមដានត្រួតពិនិត្យទៅលើគម្រោងវិនិយោគដែលចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ✓ | ✓ |

| | | | |
|---|---|---|---|
| | – ភាពមានកម្រិតនៃទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងសភាពាណិជ្ជកម្មលើការចែករំលែកព័ត៌មាន និងការដោះស្រាយបញ្ហានានា ដូចជាកម្លាំងពលកម្មជំនាញ ការអភិវឌ្ឍសហគ្រាស ផលិតផល.... (ជាសំណូមពរស្នើសុំខេត្តពិចារណាបញ្ចូលសមាសភាពតំណាងសភាពាណិជ្ជកម្មទៅក្នុងអនុគណៈកម្មាធិការវិនិយោគខេត្ត ឬយន្តការនានាដែលមានការពាក់ព័ន្ធ) | | |
| ៤ | ការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅពុំទាន់មាននីតិវិធីអនុវត្តច្បាស់លាស់ | | ✓ |
| ៥ | ស្នើផ្ទេរមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គការ សមាគម ដៃគូអភិវឌ្ឍន៍ មករដ្ឋបាលខេត្ត | ✓ | |
| **III. ធនធានមនុស្សនៅរដ្ឋបាលរាជធានី ខេត្ត** | | | |
| ១ | – ខ្វះមន្ត្រីនៅតាមទីចាត់ការមួយចំនួននៃរដ្ឋបាលខេត្ត និងខ្វះមន្ត្រីបច្ចេកទេសសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់<br>– ស្នើសុំផ្តល់ចំនួនក្របខ័ណ្ឌថ្មីឱ្យស្របទៅនឹងចំនួនក្របខ័ណ្ឌដែលបានបាត់បង់<br>– ខ្វះមន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកធៀបនឹងស្តង់ដាកំណត់ និងតម្រូវការសេវាជាក់ស្តែង (ផ្ទេរចេញ លាឈប់ និងចូលនិវត្តន៍...)<br>– ស្នើសុំឱ្យមានមន្ត្រីជំនាញសំណង់ស៊ីវិល និងវិស្វករសម្រាប់រដ្ឋបាលខេត្ត ជាពិសេសការត្រួតពិនិត្យគម្រោងឃុំ សង្កាត់ | | ✓ |
| ២ | – មន្ត្រីនៅពុំមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការការងារ និងជំនាញដែលតម្រូវឱ្យមានការបណ្តុះបណ្តាល (របាយការណ៍ និងនីតិវិធីហិរញ្ញវត្ថុ លទ្ធកម្ម នីតិវិធីផ្តល់សេវា ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ មុខងារនិងតួនាទីភារកិច្ចរបស់រដ្ឋបាលនីមួយៗ គម្រោងសេវាសង្គម ការប្រើប្រាស់ប្រព័ន្ធឌីជីថល ការិយាល័យប្រជាពលរដ្ឋ ការសម្រុះសម្រួលដោះស្រាយវិវាទ...)<br>– មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិមិនទាន់ទទួលបានការបណ្តុះបណ្តាលយ៉ាងតិច ៣០ម៉ោងក្នុងមួយឆ្នាំ តាមប្រកាសលេខ ៦៦០៦ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ដូចនេះស្នើថ្នាក់ជាតិផ្តល់ការបណ្តុះបណ្តាលឱ្យបានយ៉ាងតិច៣០ម៉ោងក្នុង១ឆ្នាំ | ✓ | ✓ |
| ៣ | មិនទាន់មានការកំណត់មុខតំណែងវិជ្ជាជីវៈ និងលក្ខខណ្ឌការងារច្បាស់លាស់សម្រាប់មន្ត្រីថ្នាក់រាជធានី ខេត្ត | ✓ | ✓ |
| ៤ | រដ្ឋបាលខេត្តពុំមានសិទ្ធិក្នុងការជ្រើសរើសមន្ត្រីកិច្ចសន្យារបស់ខ្លួន ស្នើផ្តល់សិទ្ធិសម្រេចក្នុងការជ្រើសរើស | ✓ | |

| | | | |
|---|---|---|---|
| ៥ | សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (សមាជិកថ្មី) មិនទាន់យល់ដឹងស៊ីជម្រៅលើការអនុវត្តតួនាទីភារកិច្ច និងនីតិវិធីនៃការកសាងផែនការ និងកម្មវិធីវិនិយោគ | ✓ | ✓ |
| ៦ | – សមត្ថភាព និងលទ្ធភាពនៃការអភិវឌ្ឍធនធានមនុស្សរបស់ទីចាត់ការគ្រប់គ្រងធនធានមនុស្សនៅមានកម្រិត<br>– ស្នើសុំបង្កើតការិយាល័យបន្ថែម សម្រាប់ទីចាត់ការគ្រប់គ្រងធនធានមនុស្ស | ✓ | ✓ |
| ៧ | ស្នើសុំរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរួមរបស់ថ្នាក់ជាតិ និងអាចអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិប្រើប្រាស់បាន | | ✓ |
| ៨ | – ស្នើសុំឱ្យមានការប្រឡងប្តូរប្រភេទក្របខ័ណ្ឌផ្ទៃក្នុង ដើម្បីជាការលើកទឹកចិត្តដល់មន្ត្រីដែលបានខិតខំបំពេញការងារ និងមានសញ្ញាបត្រគ្រប់គ្រាន់<br>– មន្ត្រីដែលជាថ្នាក់ដឹកនាំជាស្ត្រីមានចំនួនតិចតួច | ✓ | ✓ |
| ៩ | ស្នើសុំពិចារណាលើការតែងតាំងមុខតំណែងនាយករដ្ឋបាលសាលារាជធានី ខេត្ត ដោយអនុក្រឹត្យ ដើម្បីមានសង្គតិភាពក្នុងការសម្របសម្រួលការងារទូទៅជាមួយមន្ទីរ អង្គភាពជំនាញជុំវិញខេត្ត (ព្រះសីហនុ) | ✓ | |
| **IV.** | **ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលរាជធានី ខេត្ត** | | |
| ១ | ពុំទាន់មានការផ្ទេរទ្រព្យសម្បត្តិជាផ្លូវការពីក្រសួងសុខាភិបាលមកឱ្យរដ្ឋបាលខេត្ត | | ✓ |
| ២ | – ទំហំថវិការបស់រដ្ឋបាលខេត្តមួយចំនួន មិនទាន់ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍរបស់ខេត្ត<br>– ការចំណាយលើបេសកកម្មមានកំណើនច្រើន ដែលថវិការដ្ឋបាលខេត្តមានចំនួនតិច មិនអាចទូទាត់បានគ្រប់គ្រាន់ (មណ្ឌលគិរី)<br>– ស្នើសុំបន្ថែមខ្ទង់ចំណាយថវិកាប្រតិបត្តិការ ដើម្បីឱ្យឆ្លើយតបទៅនឹងទំហំមុខងារ ដែលក្រសួង ស្ថាប័នបានប្រតិភូកម្មមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– ការចំណាយថវិកាសម្រាប់ចុះតាមមូលដ្ឋាន គឺទទួលបានលុះត្រាតែការធ្វើដំណើរលើសពី២០គីឡូម៉ែត្រ ក្រោមនេះគឺមិនទទួលបានឡើយ និងសំណូមពរជួយផ្តល់នូវធនធានហិរញ្ញវត្ថុបេសកកម្មដែលចម្ងាយក្រោម២០គីឡូម៉ែត្រ | | ✓ |

| | | | |
|---|---|---|---|
| ៣ | ប្រព័ន្ធគ្រប់គ្រងចំណូល NRMIS និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ FMIS មិនទាន់ធ្វើសន្ធានកម្មបញ្ចូលគ្នានៅឡើយ | | ✓ |
| ៤ | – ការទម្លាក់ឥណទានបំពេញបន្ថែមនៅត្រីមាសទី៤មានភាពយឺតយ៉ាវ ធ្វើអោយការអនុវត្តមិនទាន់ពេលវេលាសម្រាប់រៀបចំការអនុវត្តគម្រោងខេត្ត<br>– ការទម្លាក់ថវិកាដើមឆ្នាំមានភាពយឺតយ៉ាវ និងស្នើសុំពន្លឿននីតិវិធីសំណើបំពេញតុល្យភាព<br>– ការទូទាត់ឯកសារមានការយឺតយូរដោយបុគ្គលិកត្រួតពិនិត្យរបស់រតនាគារមានចំនួនតិច ដោយរាល់ការដាក់ឯកសារត្រូវពិនិត្យម្តងៗ ពី១-២សប្តាហ៍ទើបរួចរាល់<br>– ការស្នើសុំនិយ័តភាពថវិកាមានការយឺតយ៉ាវ សំណូមពរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្លឿនការផ្តល់និយ័តភាពថវិកាឱ្យទាន់ពេលវេលា<br>– ស្នើអនុញ្ញាតឱ្យរដ្ឋទេយ្យចំណូល និងចំណូលរងអាចរក្សាទុកសាច់ប្រាក់លើសពី ២លានរៀល | | ✓ |
| ៥ | នីតិវិធីជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋមានភាពស្មុគស្មាញ ដែលធ្វើឱ្យការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌមានភាពយឺតយ៉ាវ | | ✓ |
| ៦ | ការប្រមូលចំណូលពីសេវារដ្ឋបាល (សាធារណការ....) ដែលអនុវត្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបង់មកថ្នាក់ជាតិ ហើយបន្ទាប់មកទើបថ្នាក់ជាតិបង្វែរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | | ✓ |
| ៧ | យោងតាមសារាចរណែនាំលេខ០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ២០២៥-២០២៧ និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៥ មិនមានការណែនាំដល់រដ្ឋបាលក្រុង ស្រុក អំពីការគ្រោងថវិកា ផ.អ.៥ទី១ និងមិនបានណែនាំអំពីការគ្រោងថវិកាភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពទេ។ ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលក្នុងសារាចរណែនាំ សម្រាប់ឆ្នាំបន្តបន្ទាប់ | ✓ | |
| ៨ | ស្នើសុំចំណូលដែលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ (ដី អគារ បឹង សណ្ឋាគារ) ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បង់ជាចំណូលរបស់រដ្ឋបាលខេត្ត | | ✓ |

| | | | |
|---|---|---|---|
| **V.** | **ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងរដ្ឋបាលរាជធានី ខេត្ត និងរវាងរដ្ឋបាលរាជធានី ខេត្តនិងរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលរាជធានី ខេត្តជាមួយប្រជាពលរដ្ឋ** | | |
| ១ | – ខ្សែគណនេយ្យភាពរវាងខេត្តជាមួយថ្នាក់ជាតិនៅមិនទាន់មានភាពច្បាស់លាស់<br>– គណៈកម្មាធិការ និងក្រុមការងារនានានៅថ្នាក់ខេត្តត្រូវបានបង្កើតច្រើនពេកដោយក្រសួង ស្ថាប័នថ្នាក់ជាតិ ហើយគណៈកម្មាធិការ និងក្រុមការងារភាគច្រើនពុំមានសកម្មភាពច្បាស់លាស់ និងធនធានសម្រាប់អនុវត្តការងាររបស់ខ្លួនទេ | ✓ | ✓ |
| ២ | – ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ដំណើការកសាងផែនការ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>– សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋមិនអាចឆ្លើយតបបានតាមតម្រូវការ | ✓ | |
| **VI.** | **ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** | | |
| ១ | – ទម្រង់ឯកសារស្នើសុំសេវាលើវិស័យសុរិយោដី និងសំណង់មានភាពស្មុគស្មាញ យឺតយ៉ាវ តម្រូវភ្ជាប់ឯកសារច្រើន ក្របខ័ណ្ឌពេលវេលានិងត្រូវការចុះហត្ថលេខាពីអង្គភាពពាក់ព័ន្ធច្រើន និងពុំទាន់មាននីតិវិធីច្បាស់លាស់<br>– មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅតែបន្តប្រគល់ដោយផ្ទាល់នូវលទ្ធផលសម្រេចចុងក្រោយទៅអ្នកស្នើសុំសេវាដោយមិនបញ្ជូនមកអង្គភាពច្រកចេញចូលតែមួយ<br>– ពាក្យស្នើសុំសេវាចុះបញ្ជីបំពេញបន្ថែមដាច់ដោយដុំ និងលិខិតលក់ផ្តាច់ និងអំណោយផ្តាច់ នៅមិនទាន់បានផ្ទេរមកឱ្យអង្គភាពច្រកចេញចូលតែមួយនៅឡើយដោយក្រសួងជាអ្នកបោះពុម្ពនៅឡើយ<br>– ការចុះបញ្ជីសេវាវិស័យសាធារណការ ត្រូវចុះបញ្ជីតាមប្រព័ន្ធ២ផ្សេងគ្នា គឺប្រព័ន្ធក្រសួងសាធារណការ និងដឹកជញ្ជូន និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងនិងផ្តល់សេវារបស់ក្រសួងមហាផ្ទៃ | ✓ | ✓ |
| ២ | – សេវាមួយចំនួនដែលផ្ទេរឱ្យរដ្ឋបាលខេត្តហើយ ត្រូវបានកែសម្រួលមកផ្តល់នៅថ្នាក់ក្រសួងវិញក្រោមហេតុផលធ្វើទំនើបកម្មប្រព័ន្ធផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យា | | ✓ |

| | | | |
|---|---|---|---|
| ៣ | – គម្រោងមួយចំនួនរបស់ក្រសួង ស្ថាប័នដែលគ្រោងអនុវត្តនៅរាជធានី ខេត្ត មិនបានអនុវត្តច្រើនឆ្នាំ ហើយខេត្តពុំមានសិទ្ធិអនុវត្តលើគម្រោងដែលបានគ្រោងនោះ<br>– សំណូមពរសុំក្រសួង ស្ថាប័នថ្នាក់ជាតិដែលមានគម្រោងអនុវត្តថ្នាក់ខេត្ត ផ្តល់ព័ត៌មានដល់ខេត្ត ដើម្បីជៀសវាងភាពត្រួតស៊ីគ្នា ឬអាចបំពេញឱ្យគ្នាបាន | | ✓ |
| ៤ | ការផ្តល់អាជ្ញាបណ្ណអភិវឌ្ឍមួយចំនួនពីថ្នាក់ជាតិ មិនស្របទៅនឹងប្លង់រៀបចំនគរូបនីយកម្ម និងប្លង់គោលប្រើប្រាស់ដីធ្លីរបស់ខេត្ត | | ✓ |
| ៥ | ការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិនៅមានភាពយឺតយ៉ាវ និងការលំបាក (សំណូមពរសុំឱ្យបង់នៅសាខាពន្ធដារខណ្ឌ បច្ចុប្បន្នបង់នៅអគ្គនាយកដ្ឋានពន្ធដារ) | | ✓ |
| ៦ | – ការទទួលខុសត្រូវលើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិ និងដីសាធារណៈរបស់រដ្ឋនៅមិនទាន់មានភាពច្បាស់លាស់<br>– ភាពមិនច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់រដ្ឋបាលខេត្តក្នុងការលើកគម្រោងអភិវឌ្ឍន៍កែលម្អតំបន់ដែលមានសក្តានុពលទេសចរណ៍ធម្មជាតិមួយចំនួន ដើម្បីរួមចំណែកថែរក្សាបានធនធានធម្មជាតិ និងការលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋ | | ✓ |
| ៧ | នីតិវិធី បែបបទនៃការរៀបចំគម្រោងមិនមានស្តង់ដាររួមតែមួយ ដោយការរៀបចំគម្រោងមួយផ្នែកតាមគោលការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមួយផ្នែកទៀតតាមការណែនាំរបស់ក្រសួងមហាផ្ទៃ | ✓ | |
| ៨ | ស្នើសុំឱ្យមានការរៀបចំការផ្តល់សេវាជាកញ្ចប់នៅអង្គភាពច្រកចេញចូលតែមួយ (ព័ត៌មាន ទេសចរណ៍ វប្បធម៌...) | ✓ | ✓ |
| ៩ | – ការចូលរួមជាមតិយោបល់ សំណើ សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈមានការថយចុះ ដោយភាគច្រើនជាការលើកឡើងរបស់អាជ្ញាធរមូលដ្ឋានទៅវិញ<br>– សំណូមពរស្ថាប័នមានសមត្ថកិច្ច ជួយពិនិត្យ និងដោះស្រាយសំណើសំណូមពររបស់ប្រជាពលរដ្ឋដែលលើកឡើងក្នុងវេទិកាសាធារណៈ | ✓ | |

| | | | |
|---|---|---|---|
| **VII. ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្ម** | | | |
| ១ | យន្តការចុះត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិមានច្រើនក្រុមពេកក្នុងមួយឆ្នាំៗ កិច្ចការទាំងនេះគឺត្រួតគ្នាដែលដាក់បន្ទុកដល់រដ្ឋបាលខេត្ត | | ✓ |
| ២ | ការធ្វើសវនកម្មផ្ទៃក្នុងនៅពុំមានភាពច្បាស់លាស់រវាងថ្នាក់ជាតិ (មហាផ្ទៃ) និងថ្នាក់ក្រោមជាតិ | | ✓ |
| ៣ | – ការគាំទ្របច្ចេកទេសក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិថយចុះ<br>– ការផ្សព្វផ្សាយ និងការបញ្ជូនលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងការអនុវត្តនៅថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ | ✓ | |
| ៤ | – ការគាំទ្រ (ការអភិវឌ្ឍសមត្ថភាព បច្ចេកទេស..) ការតាមដានត្រួតពិនិត្យ វាយតម្លៃរបស់ថ្នាក់ខេត្ត មន្ទីរអង្គភាពជំនាញទៅរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នៅមានកម្រិត<br>– ការគាំទ្រពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត | ✓ | |
| **VIII. បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | | | |
| ១ | – រដ្ឋបាលខេត្តមួយចំនួនពុំទាន់មានប្លង់រៀបចំនគរូបនីយកម្ម និងប្លង់ប្រើប្រាស់ដីធ្លី<br>– ព្រំប្រទល់រដ្ឋបាលមួយចំនួននៅពុំមានការឯកភាពគ្នា | | ✓ |
| ២ | – ការយល់ដឹងអំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិនៅមានកម្រិត ជាហេតុធ្វើឱ្យការចូលរួម ការគាំទ្រ ការតាមដានត្រួតពិនិត្យមានភាពស្ទាក់ស្ទើរ<br>– ការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ បរិយាបន្ន ការប្រែប្រួលអាកាសធាតុនៅមានកម្រិត | ✓ | |
| ៣ | ស្នើពិចារណាកំណត់ឱ្យមានប្រាក់ឧបត្ថម្ភប្រចាំខែ/ប្រាក់សោធននិវត្តន៍របស់ក្រុមប្រឹក្សា នៅពេលបាត់បង់តំណែងពីក្រុមប្រឹក្សាចំពោះក្រុមប្រឹក្សាណាដែលមានអតីតភាពចាប់ពី៣អាណត្តិឡើងទៅ | | ✓ |
| ៤ | សុំរថយន្តគិលានសង្គ្រោះសម្រាប់មណ្ឌលសុខភាពនៅឆ្ងាយ (លើសពី១០០គីឡូម៉ែត្រពីមន្ទីរពេទ្យបង្អែក) | ✓ | |

| | | | |
|---|---|---|---|
| ៥ | ស្នើសុំរៀបចំលិខិតបទដ្ឋានណែនាំអំពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយថ្នាក់ខេត្ត | ✓ | |
| ៦ | ប្រាក់សមាជិកភាពមានតិចតួច ក្នុងការទ្រទ្រង់ប្រតិបត្តិការ និងអនុវត្តសកម្មភាពផ្តល់សេវាដល់សមាជិកមិនបានពេញលេញ ស្នើសុំរាជរដ្ឋាភិបាលបង្កើនប្រាក់សមាជិកភាពឱ្យបាន៣% ដល់សមាគមក្រុមប្រឹក្សា | ✓ | |
| ៧ | – ស្នើកញ្ចប់ថវិកាសម្រាប់ឧបត្ថម្ភក្រុមប្រឹក្សាជាស្ត្រីដែលសម្រាលកូន<br>– សុំថ្នាក់ជាតិដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែដល់មេភូមិ អនុភូមិ ជំនួយការភូមិ។ | | ✓ |

**កំណត់សម្គាល់៖**

- រ/ខ៖ រាជធានី ខេត្ត
- ក្រ/ស៖ ក្រសួង ស្ថាប័ន

# តារាងឧបសម្ព័ន្ធទី ៤

## ការផ្តល់យោបល់របស់អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប.

## លើវិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរនានា ដែលលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| ១ | **– ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនមិនទាន់ឆ្លើយតបទៅនឹងការកើនឡើងចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ដែលស្នើសុំថ្នាក់ជាតិពិនិត្យមើលឡើងវិញនូវចំនួនសមាជិកក្រុមប្រឹក្សាឱ្យស្របទៅនឹងកើនឡើងនៃចំនួនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនោះស្នើសុំពិនិត្យលទ្ធភាពបង្កើតឱ្យមានការិយាល័យមួយចំនួននៅតាមឃុំ សង្កាត់។**<br><br>**ដំណើររឿង** ៖ ផ្អែកតាមមាត្រា១២នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យឃុំ សង្កាត់ត្រូវមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពី៥រូបទៅ១១រូប ផ្អែកទៅតាមប្រជាសាស្ត្រ និងភូមិសាស្ត្រនៃឃុំ សង្កាត់ និងត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០២ រហូតមកដល់បច្ចុប្បន្ន។ សព្វថ្ងៃនេះចំនួនប្រជាពលរដ្ឋ និងតម្រូវការសេវាមានការកើនឡើង ហើយក្រសួង ស្ថាប័នជាច្រើន រួមទាំងអង្គការសង្គមស៊ីវិលបានស្នើសុំឱ្យមានការចូលរួម គាំទ្រ និងសហការអនុវត្តពីរដ្ឋបាលឃុំ សង្កាត់។ ដោយសារបន្ទុកការងារកើនឡើង អាស្រ័យហេតុនេះ រដ្ឋបាលឃុំសង្កាត់មួយចំនួនបានស្នើសុំពិចារណាបង្កើនចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ (ក្នុងក្របខ័ណ្ឌដែលច្បាប់បានអនុញ្ញាតពី៥ទៅ១១រូប)។ ទន្ទឹមនឹងនោះ រដ្ឋបាលឃុំ សង្កាត់មួយចំនួនក៏បានស្នើសុំពិនិត្យលទ្ធភាពបង្កើតឱ្យមានការិយាល័យមួយចំនួននៅតាមឃុំ សង្កាត់ផងដែរ។<br><br>**សំណើដំណោះស្រាយ** ៖ ផ្អែកមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរប្រជាសាស្ត្រ និងភូមិសាស្ត្រហើយដែលអនុក្រឹត្យនេះ |

| | |
|---|---|
| | ត្រូវកំណត់យ៉ាងតិច៩ខែមុនថ្ងៃបោះឆ្នោតឃុំ សង្កាត់ (មាត្រា៦ច្បាប់បោះឆ្នោតឃុំ សង្កាត់)។ អាស្រ័យហេតុនេះ ជូនក្រសួងមហាផ្ទៃសិក្សា និងលើកសំណើ ដើម្បីគោរពស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងការស្នើសុំបង្កើតឱ្យមានការិយាល័យមួយចំនួននៅតាមឃុំ សង្កាត់ ផ្អែកតាមច្បាប់គ្រប់គ្រងឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធក្រោមច្បាប់ រដ្ឋបាលឃុំ សង្កាត់អាចរៀបចំឱ្យមានគណៈកម្មាធិការនានាតាមការចាំបាច់ ដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានារបស់ឃុំ សង្កាត់ ព្រមទាំងអាចរៀបចំឱ្យមានបុគ្គលិក (មន្ត្រីកិច្ចសន្យា) ទទួលបន្ទុកការងារផ្សេងៗ (ការងារហិរញ្ញវត្ថុ សេវាសង្គម សេវារដ្ឋបាល....) ទៅតាមការចាំបាច់ និងលទ្ធភាពថវិការបស់ឃុំ សង្កាត់។ ដូច្នេះ ចំពោះការស្នើសុំបង្កើតការិយាល័យនៅថ្នាក់ឃុំ សង្កាត់នេះ ស្នើជូនក្រសួងមហាផ្ទៃធ្វើការសិក្សាអំពីលទ្ធភាពនៃការរៀបចំឱ្យមានការិយាល័យ ឬផ្អែកផ្អែកតាមស្ថានភាព និងតម្រូវការសេវាតាមឃុំ សង្កាត់នានា។<br>*****<br>– **ស្នើសុំឱ្យមានការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការរៀបចំជារដ្ឋបាលសង្កាត់ចំណុះស្រុក។**<br>**ដំណើររឿង**៖ ផ្អែកតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា «...**ស្រុកចែកជាឃុំ និងជាសង្កាត់** តែរហូតមកដល់ពេលនេះ ពុំទាន់មានការកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់នៅក្នុងការបង្កើតសង្កាត់នៅក្នុងស្រុកឡើយ ដូច្នេះស្នើសុំឱ្យមានការកំណត់លក្ខណៈវិនិច្ឆ័យ ច្បាស់លាស់សម្រាប់ការរៀបចំជារដ្ឋបាលសង្កាត់នាពេលអនាគត។<br>**សំណើដំណោះស្រាយ**៖ ជូនក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ធ្វើការសិក្សា និងកំណត់អំពីលក្ខណៈវិនិច្ឆ័យនៃការរៀបចំសង្កាត់ក្នុងស្រុក ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច សម្រាប់ធ្វើជាមូលដ្ឋានលើការរៀបចំប្រែក្លាយឃុំដែលមានលក្ខណៈជាទីប្រជុំជន ទៅជាសង្កាត់ក្នុងស្រុកនាពេលអនាគត។ |
| ២ | – **ស្នើសុំឱ្យមានការពិនិត្យ និងកែសម្រួលសៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យស្របទៅតាមស្ថានភាពនៃការវិវឌ្ឍន៍នៃកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ការរីកចម្រើននៃបច្ចេកវិទ្យា និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។**<br>**ដំណើររឿង**៖ សៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០០៥ រហូតមកពេលនេះ កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់មានការប្រែប្រួល |

| | |
|---|---|
| | និងមានកិច្ចការថ្មីៗជាច្រើន ដែលត្រូវឱ្យមានឯកសារគោលទុកប្រើប្រាស់ជាមូលដ្ឋាននៅក្នុងការអនុវត្តការងារឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ចេញ។<br><br>**សំណើដំណោះស្រាយ** ៖ ជូនក្រសួងមហាផ្ទៃសិក្សា ពិនិត្យ និងកែសម្រួលសៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យស្របទៅតាមស្ថានភាពនៃការវិវឌ្ឍន៍នៃកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ការរីកចម្រើននៃបច្ចេកវិទ្យា និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។ |
| ៣ | **ស្នើសុំពិនិត្យ និងកែសម្រួលគោលការណ៍ នីតិវិធី និងលក្ខណសម្បត្តិនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិ (អាយុ កម្រិតវប្បធម៌ និងអាណត្តិការងារ)**<br><br>**ដំណើររឿង** ៖ ការជ្រើសរើសថ្នាក់ដឹកនាំភូមិត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ក្នុងនោះ មេភូមិត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងចំណោមបេក្ខជនឈរឈ្មោះដែលស្នើឡើងដោយមេឃុំ/ចៅសង្កាត់ ជំទប់/ចៅសង្កាត់រង ហើយអនុប្រធានភូមិ និងសមាជិកភូមិត្រូវបានបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងចំណោមបេក្ខជនឈរឈ្មោះដែលស្នើឡើងដោយមេភូមិ និងមេឃុំ/ចៅសង្កាត់។ ផ្អែកតាមសេចក្តីណែនាំថ្នាក់ដឹកនាំភូមិទាំង៣រូបនេះ ត្រូវបានកំណត់លក្ខណសម្បត្តិត្រឹមតែចេះអាន និងចេះសរសេរ និងពុំមានកំណត់អាយុ ឬអាណត្តិការងារនោះទេ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការផ្លាស់ប្តូរថ្នាក់ដឹកនាំភូមិ ជាពិសេសថ្នាក់ដឹកនាំភូមិភាគច្រើនមានវ័យចំណាស់ និងសមត្ថភាពធ្វើការងារមានកម្រិត។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងការធ្វើគណនេយ្យភាពរបស់ថ្នាក់ដឹកនាំភូមិចំពោះប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំ សង្កាត់មួយចំនួនបានស្នើសុំកែសម្រួលគោលការណ៍ នីតិវិធី និងលក្ខណសម្បត្តិនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិ។<br><br>**សំណើដំណោះស្រាយ** ៖ ផ្អែកតាមមាត្រា៣០ នៃច្បាប់គ្រប់គ្រងឃុំ សង្កាត់បានកំណត់ថាក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗ...។ ពាក់ព័ន្ធនឹងសំណើខាងលើនេះ គួរគប្បីពិចារណាទៅលើការកំណត់ឱ្យមានអាណត្តិការងារ ឬអាយុ (អាចជាជម្រើសថា ថ្នាក់ដឹកនាំភូមិ មានអាណត្តិការងារ៥ឆ្នាំ ហើយអាចឈរឈ្មោះឡើងវិញបាន០១អាណត្តិ ឬ០២អាណត្តិទៀត ឬក៏ជម្រើសណាមួយសមស្របទៀត)។ ដូច្នេះ ជូនក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. សិក្សា និងពិនិត្យមើលឡើងវិញនូវគោលការណ៍ លក្ខណសម្បត្តិ និងនីតិវិធីនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិ ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ |

| | |
|---|---|
| ៤ | – **ស្នើរៀបចំឱ្យមានលក្ខណៈវិនិច្ឆ័យសម្រាប់រៀបចំជារដ្ឋបាលក្រុង។**<br><br>**ដំណើររឿង** ៖ កន្លងមកនេះ មិនទាន់មានលក្ខណៈវិនិច្ឆ័យជាក់លាក់សម្រាប់ការបង្កើតរដ្ឋបាលក្រុង ឬប្រែក្លាយរដ្ឋបាលស្រុកដែលជាទីប្រជុំជនឱ្យទៅជារដ្ឋបាលក្រុង អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានស្នើឱ្យមានការកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការបង្កើតក្រុង និងការប្រែក្លាយស្រុកទៅជាក្រុង។<br><br>**សំណើដំណោះស្រាយ** ៖ កិច្ចការនេះមានកំណត់ជាសកម្មភាពអាទិភាពនៅក្នុងកម្មវិធីជាតិដំណាក់កាលទី២នៃ គ.ជ.អ.ប. ហើយបាននិងកំពុងសិក្សាដោយក្រសួងមហាផ្ទៃ  អាស្រ័យហេតុនេះ ជូនក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បន្តធ្វើការសិក្សា និងកំណត់អំពីលក្ខណៈវិនិច្ឆ័យនៃការរៀបចំក្រុង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច សម្រាប់ធ្វើជាមូលដ្ឋានលើការរៀបចំប្រែក្លាយស្រុកដែលមានលក្ខណៈទីប្រជុំជន ទៅជាក្រុងនាពេលអនាគត។<br><br>*****<br><br>– **ស្នើសុំឱ្យមានការសិក្សា  និងពិនិត្យមើលឡើងវិញលើការរៀបចំរចនាសម្ព័ន្ធ  មុខងារ  និងធនធានរបស់រដ្ឋបាលក្រុង  ស្រុក  ឱ្យស្របទៅតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពលសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែង។**<br><br>**ដំណើររឿង** ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំឡើងវិញនៅឆ្នាំ២០២០ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញទាំងអស់ ទាំងបុគ្គលិក និងមុខងារក្នុង២០វិស័យឱ្យទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ ទោះបីជារចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង និងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុកមានលក្ខណៈខុសគ្នាខ្លះៗដោយឆ្លុះបញ្ចាំងទៅនឹងមុខងារផ្តល់សេវាទីប្រជុំជនរបស់រដ្ឋបាលក្រុង និងមុខងារផ្តល់សេវាជនបទ (កសិកម្ម ធនធានធម្មជាតិ...) របស់រដ្ឋបាលស្រុកក៏ដោយ ក៏រចនាសម្ព័ន្ធថ្មី និងមុខងាររបស់រដ្ឋបាលក្រុងនីមួយៗ ស្រុកនីមួយៗ មានលក្ខណៈដូចគ្នាទាំងអស់ដោយពុំទាន់បានឆ្លុះបញ្ចាំងទៅតាមក្រុង ស្រុកដែលមានប្រជាជនច្រើន ឬតិច ឬឆ្លុះបញ្ចាំងទៅនឹងតម្រូវការសេវា និងសក្តានុពលខុសៗគ្នារបស់រដ្ឋបាលក្រុង ស្រុកនីមួយៗឡើយ។ |

| | |
|---|---|
| | **សំណើដំណោះស្រាយ ៖** ប្រគល់ភារកិច្ចឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ ដឹកនាំសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធសិក្សា ពិនិត្យមើលឡើងវិញ និងលើកយោបល់អំពីជម្រើសនានាសម្រាប់ការរៀបចំរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗឱ្យស្របទៅតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពលសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែង។ |
| ៥ | **– រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តពុំទាន់បានរៀបចំឱ្យស្របទៅតាមគោលការណ៍នៃរដ្ឋបាលឯកភាពដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ ជាហេតុធ្វើឱ្យក្រុមប្រឹក្សារាជធានី ខេត្តពុំទាន់អាចម្ចាស់ការពេញលេញក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលប្រកបដោយប្រសិទ្ធភាពលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍលើគ្រប់វិស័យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។**<br><br>**ដំណើររឿង ៖** ច្បាប់រៀបចំអង្គការបានតម្រូវឱ្យរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចដឹកនាំ សម្របសម្រួលការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមវិស័យនានា ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នាឆ្នាំ២០២០ រចនាសម្ព័ន្ធនៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងវិញ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញទាំងអស់ឱ្យទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ ប្រការនេះបានធ្វើឱ្យក្រុមប្រឹក្សាក្រុង ស្រុកមានសមត្ថកិច្ចដឹកនាំ គ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍលើគ្រប់វិស័យដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួន។ ដោយឡែក ចំពោះរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តបច្ចុប្បន្ន គឺបានធ្វើសមាហរណកម្មតែមន្ទីរសុខាភិបាលមួយប៉ុណ្ណោះឱ្យទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត។ មន្ទីរជំនាញក្នុងវិស័យជាអាទិភាពផ្សេងទៀតគឺស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ដែលប្រការនេះបានធ្វើឱ្យក្រុមប្រឹក្សារាជធានី ខេត្តមិនអាចដឹកនាំសម្របសម្រួលការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមវិស័យជំនាញទាំងនោះឱ្យមានប្រសិទ្ធភាពស្របតាមការកំណត់ដោយច្បាប់រៀបចំអង្គការនៅឡើយ។ អាស្រ័យហេតុនេះ រដ្ឋបាលខេត្តមួយចំនួនបានលើកសំណើឱ្យមានការសិក្សាពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តដោយស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ |

**សំណើដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួង (លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ) បានរៀបចំឯកសារទស្សនទាន និងផែនការសម្រាប់ការសិក្សាពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលមុខងារ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ព្រមទាំងគ្រោងទស្សនកិច្ចសិក្សាទៅប្រទេសមួយចំនួន (ប្រទេសថៃ ឥណ្ឌូនេស៊ី...) នៅដើមឆ្នាំ២០២៥នេះ អាស្រ័យហេតុនេះ ស្នើក្រុមការងារអន្តរក្រសួងនេះបន្តការសិក្សានេះឱ្យបានរួចរាល់នៅឆ្នាំ២០២៥។

*****

- **រចនាសម្ព័ន្ធជាអង្គភាព/ទីចាត់ការនៃរដ្ឋបាលខេត្តមួយចំនួននៅពុំទាន់មានភាពសមស្របជាមួយនឹងស្ថានភាពការរីកចម្រើននៃបច្ចេកវិទ្យា និងវិធានការគន្លឹះនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលករណីនេះចាំបាច់ត្រូវមានការពិនិត្យមើលឡើងវិញនូវមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត។ កិច្ចការអាទិភាព គឺស្នើសុំឱ្យមានការសិក្សាអំពីលទ្ធភាពនៃការបង្កើត ៖**
  **(១). អង្គភាពសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលរាជធានី ខេត្ត ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ចាត់ចែង និងការអនុវត្តមុខងារ និងធនធាន**
  **(២). អង្គភាពបរិវត្តកម្មឌីជីថលសម្រាប់រដ្ឋបាលរាជធានី ខេត្ត។**

**ដំណើររឿង** ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្តត្រូវរៀបចំឡើងវិញនៅឆ្នាំ២០០៩ ហើយរចនាសម្ព័ន្ធគ្រប់គ្រងនេះមានលក្ខណៈដូចៗគ្នាពីខេត្តមួយទៅខេត្តមួយ។ គិតរហូតមកដល់ពេលនេះ មានរយៈពេល១៥ឆ្នាំហើយ ដែលក្នុងអំឡុងពេលនេះ ត្រូវបានពិនិត្យឃើញថាទាំងស្ថានភាពប្រជាពលរដ្ឋ សេដ្ឋកិច្ច តម្រូវការសង្គម ផ្នែកបច្ចេកវិទ្យា និងសក្តានុពលនានាមានការប្រែប្រួលយ៉ាងខ្លាំង ដែលតម្រូវឱ្យមានការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្តឡើងវិញ ដើម្បីឱ្យឆ្លុះបញ្ចាំងទៅនឹងស្ថានភាពនៃតម្រូវការជាក់ស្តែង និងស្របតាមសក្តានុពលនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមរដ្ឋបាលខេត្តនីមួយៗ។

**សំណើដំណោះស្រាយ** ៖ ការស្នើសុំពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធជាអង្គភាព ឬទីចាត់ការរបស់រដ្ឋបាលរាជធានី ខេត្តនេះ មានការពាក់ព័ន្ធទៅនឹងការសិក្សា ការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តទាំងមូល អាស្រ័យហេតុនេះ ត្រូវរង់ចាំការពិនិត្យ និងរៀបចំនូវរចនាសម្ព័ន្ធ និងប្រព័ន្ធឡើងវិញតែម្តង។ ប៉ុន្តែចំពោះមុខ ការស្នើសុំពិចារណាលើការបង្កើតអង្គភាពពីរគឺអង្គភាព

| | |
|---|---|
| | សវនកម្មផ្ទៃក្នុង និងអង្គភាពបរិវត្តកម្មឌីជីថលសម្រាប់រដ្ឋបាលរាជធានី ខេត្ត ស្នើជូនក្រសួងមហាផ្ទៃសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងលេខាធិការដ្ឋាន គ.ជ.អ.ប. សិក្សា និងលើកយោបល់លើការបង្កើតអង្គភាពទាំងពីរនេះ។ |
| ៦ | – **ស្នើសុំពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្ដីពីកិច្ចការរដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្តឱ្យស្របទៅតាមការវិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ(ការផ្ទេរធនធានមនុស្ស និងទ្រព្យសម្បត្តិរដ្ឋ) និងការបំពេញបន្ថែមនូវកិច្ចការចាំបាច់នានា(ដូចជាការគ្រប់គ្រងបុគ្គលិក ទ្រព្យសម្បត្តិរដ្ឋ..)។**<br>**ដំណើររឿង ៖** សៀវភៅណែនាំស្ដីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តនាឆ្នាំ២០១៥ ដែលមានចំណុចមួយចំនួនទាមទារឱ្យមានការពិនិត្យ និងកែសម្រួលឡើងវិញ ដូចជាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក ទ្រព្យសម្បត្តិរដ្ឋ ហិរញ្ញវត្ថុ និងរបៀបរបបការងារជាដើម)។<br>**សំណើដំណោះស្រាយ ៖** កិច្ចការនេះក្រសួងមហាផ្ទៃ បាន និងកំពុងពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្ដីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត អាស្រ័យហេតុនេះ ស្នើប្រគល់ភារកិច្ចនេះជូនក្រសួងមហាផ្ទៃបន្តរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំនេះនៅឆ្នាំ២០២៥។ |
| ៧ | – **ស្នើសុំឱ្យមានការបន្តការប្រឡងប្រជែងជើងឯកផ្តល់សេវាសាធារណៈ ដោយគិតគូរអំពីការដាក់បញ្ចូលគ្មានូវការផ្តល់សេវាសង្គម ការងារគណនេយ្យភាពសង្គម សេវារដ្ឋបាល និងភូមិឃុំ សង្កាត់មានសុវត្ថិភាព។**<br>**ដំណើររឿង ៖** កន្លងមកក្រសួងមហាផ្ទៃបានដាក់ឱ្យអនុវត្តនូវកម្មវិធីប្រកួតប្រជែងជើងឯកសេវាសង្គម ប៉ុន្តែបច្ចុប្បន្នត្រូវបានបញ្ចប់នៅឆ្នាំ២០២៣។ ក្នុងន័យនេះ ឃុំ សង្កាត់បានស្នើសុំឱ្យមានការបន្តការប្រកួតប្រជែងជើងឯកផ្តល់សេវាសង្គមដោយគិតគូរអំពីការដាក់បញ្ចូលការផ្តល់សេវាសង្គមនេះរួមជាមួយនឹងការផ្តល់សេវាសាធារណៈផ្សេងៗទៀតដែលមានកំណត់នៅក្នុងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។<br>**សំណើដំណោះស្រាយ ៖** ប្រគល់ជូនក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាអំពីជម្រើស និងលទ្ធភាពនៃការរៀបចំកម្មវិធីប្រកួតប្រជែងនេះ និងស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល។ |

| | |
|---|---|
| | ការសិក្សានេះផ្តោតលើរៀបចំឱ្យមានយន្តការ នីតិវិធី សូចនាករ លក្ខណៈវិនិច្ឆ័យ និងប្រាក់រង្វាន់សមស្របសម្រាប់លើកទឹកចិត្តអង្គភាពដែលជាប់ជ័យលាភី។ |
| ៨ | **– ស្នើសុំឱ្យមានការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារដែលបានផ្ទេរមួយចំនួនដែលពុំទាន់បានធ្វើការបណ្តុះបណ្តាល ដូចជាមុខងារកសិកម្ម អភិវឌ្ឍន៍ជនបទ ធនធានទឹក ទេសចរណ៍...ជាដើម។**<br><br>**ដំណើររឿង ៖** ទន្ទឹមនឹងការធ្វើសមារណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ(២០២០) មានមុខងារចំនួន៥៥ត្រូវបានផ្ទេរភ្ជាប់ទៅជាមួយ។ មុខងារមួយចំនួនត្រូវបានរៀបចំឱ្យមានគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្ត ព្រមទាំងមានការបណ្តុះបណ្តាលជាបន្តបន្ទាប់ ដូចជាមុខងារអប់រំ បរិស្ថាន និងមុខងារផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ប៉ុន្តែនៅមានមុខងារមួយចំនួនទៀតនៅពុំទាន់មានគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តច្បាស់លាស់នៅឡើយ ដូចជាមុខងារកសិកម្ម អភិវឌ្ឍន៍ជនបទ ធនធានទឹក ទេសចរណ៍ជាដើម។<br><br>**សំណើដំណោះស្រាយ ៖** ផ្អែកតាមគោលការណ៍នៃការផ្ទេរមុខងារ ក្រសួង ស្ថាប័នដែលផ្ទេរមុខងារ ចាំបាច់ត្រូវរៀបចំឱ្យមានសេចក្តីណែនាំបច្ចេកទេសស្តង់ដាសេវា និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពក្នុងការគ្រប់គ្រងចាត់ចែងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ អាស្រ័យហេតុនេះ ស្នើក្រសួងដែលបានផ្ទេរមុខងារ ពន្លឿនការដាក់ចេញសេចក្តីណែនាំបច្ចេកទេសឱ្យបានឆាប់ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក និងមន្ត្រីបច្ចេកទេស ក្រោមការសម្របសម្រួលរបស់ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.។ |
| ៩ | **– ស្នើពិចារណាផ្ទេរមុខងារគ្រប់គ្រងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក មកស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។**<br><br>**ដំណើររឿង ៖** បច្ចុប្បន្ននេះ មុខងារក្នុងវិស័យសុខាភិបាលរួមមានមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពទាំងអស់ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តចាប់តាំងពីឆ្នាំ២០២០មក។ |

| | |
|---|---|
| | ដោយឡែក រដ្ឋបាលក្រុង ស្រុកពុំទាន់មានតួនាទីសំខាន់ណាមួយក្នុងវិស័យសុខាភិបាលនៅឡើយ ទោះបីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុកគឺជាអង្គភាពដែលត្រូវមានកិច្ចសហការ និងគាំទ្រយ៉ាងច្រើនពីរដ្ឋបាលក្រុង ស្រុកក៏ដោយ។<br><br>**សំណើដំណោះស្រាយ ៖** កិច្ចការនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានកំពុងសហការជាមួយក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ដើម្បីសិក្សា និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាវិស័យសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងសិក្សាអំពីលទ្ធភាពនៃការធ្វើប្រតិភូកម្មមុខងារសមស្របមួយចំនួនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយធានាឱ្យបាននូវនិរន្តភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាល អាស្រ័យហេតុនេះ ស្នើឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប. បន្តអនុវត្តកិច្ចការនេះឱ្យបានរួចរាល់នៅឆ្នាំ២០២៥។<br><br>****<br><br>– **ស្នើសុំពិចារណាផ្ទេរមុខងារគ្រប់គ្រងសត្តឃាតដ្ឋាន។**<br><br>**ដំណើររឿង ៖** ការគ្រប់គ្រងសត្តឃាតដ្ឋាន ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានីខេត្តផ្តល់សេវាតាមអង្គភាពច្រកចេញចូលតែមួយ (អនុក្រឹត្យលេខ១៨)។ ការអនុវត្តជាក់ស្តែង សត្តឃាតដ្ឋាននៅតាមស្រុកដែលនៅឆ្ងាយពីទីរួមខេត្ត ពុំទាន់មានការគ្រប់គ្រងបានល្អប្រសើរនៅឡើយ (ការតាមដានត្រួតពិនិត្យ)។ ប្រការនេះ ដើម្បីធានាដល់ការគ្រប់គ្រងសត្តឃាតដ្ឋានទាំងនេះឱ្យមានប្រសិទ្ធភាព រដ្ឋបាលស្រុកមួយចំនួនបានស្នើសុំឱ្យពិនិត្យលទ្ធភាពនៃការផ្ទេរមុខងារគ្រប់គ្រងសត្តឃាតដ្ឋានទាំងនេះទៅឱ្យរដ្ឋបាលស្រុក។<br><br>**សំណើដំណោះស្រាយ ៖** ពាក់ព័ន្ធនឹងសំណើនេះ ស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយនឹងលេខាធិការដ្ឋាន គ.ជ.អ.ប. និងអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ សិក្សា និងពិនិត្យមើលអំពីលទ្ធភាពនៃការផ្ទេរមុខងារនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ដើម្បីប្រសិទ្ធភាពនៃការគ្រប់គ្រងសត្តឃាតដ្ឋាន។ |
| ១០ | – **ស្នើសុំឱ្យមានការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច ព្រមទាំងនីតិវិធីនិងស្តង់ដាសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ស្នើដោយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)។** |

| | |
|---|---|
| | **ដំណើររឿង** ៖ បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់មូលនិធិធនធានុសិទ្ធិរបស់ខ្លួនស្ទើរទាំងអស់សម្រាប់អនុវត្តមុខងារជាជម្រើសនានាដែលផ្តោតលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងផ្តល់សេវាសង្គមមួយចំនួន។ ក្រៅពីមុខងារផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីមុខងារជាកាតព្វកិច្ចជាក់លាក់ដែលចាំបាច់ត្រូវអនុវត្តដើម្បីធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព សុវត្ថិភាព បរិយាបន្ន និងសមធម៌សង្គម រួមមានដូចជាការផ្តល់សេវាអនាម័យបរិស្ថាន ការងារយេនឌ័រ ការងារសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម.....ជាដើម។ អាស្រ័យហេតុនេះ មានការស្នើឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវកំណត់ឱ្យបានជាក់លាក់នូវមុខងារជាកាតព្វកិច្ច ព្រមទាំងរៀបចំឱ្យមាននីតិវិធី និងស្តង់ដាសម្រាប់អនុវត្តមុខងារទាំងនោះ។<br><br>**សំណើដំណោះស្រាយ** ៖ ការកំណត់ឱ្យបានជាក់លាក់នូវមុខងារជាកាតព្វកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការសំខាន់មួយដែលចាំបាច់ត្រូវកំណត់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិយល់ដឹងកាន់តែច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនដែលត្រូវមានផែនការ និងធនធានជាក់លាក់សម្រាប់អនុវត្តមុខងារទាំងនោះស្របតាមនិតិវិធី និងស្តង់ដាដែលបានកំណត់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ (ឧ. មុខងារអប់រំ មុខងារសុខាភិបាល មុខងារការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម មុខងារគ្រប់គ្រងសំរាម សំណល់រឹង-រាវ អនាម័យបរិស្ថានជាដើម)។ កិច្ចការនេះ ក៏ត្រូវបានគ្រោងជាសកម្មភាពអាទិភាពនៅក្នុងកម្មវិធីជាតិដំណាក់កាលទី២ ជាពិសេសនៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥របស់ គ.ជ.អ.ប.។ អាស្រ័យហេតុនេះ ស្នើលេខាធិការដ្ឋាន គ.ជ.អ.ប. និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធសិក្សា និងកំណត់មុខងារជាកាតព្វកិច្ច និងរៀបចំសេចក្តីណែនាំអំពីនីតិវិធី និងស្តង់ដាសម្រាប់អនុវត្តមុខងារឱ្យបានរួចរាល់ក្នុងឆ្នាំ២០២៥។ |
| ១១ | – **ការបែងចែកមុខងាររវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមុខងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទផ្សេងទៀត (ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់) នៅពុំទាន់បានបែងចែកច្បាស់លាស់។**<br><br>**ដំណើររឿង** ៖ ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានតម្រង់ទិសដល់ការបែងចែកមុខងារ និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងរដ្ឋបាលសាធារណៈតាមថ្នាក់នីមួយៗ។ ក្រសួង ស្ថាប័នថ្នាក់ជាតិមានមុខងារជាចម្បងក្នុងការដាក់ចេញគោលនយោបាយ ច្បាប់ លិខិត |

បទដ្ឋានគតិយុត្ត ស្តង់ដាសេវា ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ រដ្ឋបាលខេត្តត្រូវមានមុខងារចម្បងផ្តោតលើការអនុវត្តមុខងារតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិដោយផ្តោតលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការត្រួតពិនិត្យនីត្យានុកូលភាពលើរដ្ឋបាលមូលដ្ឋាន ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន (ក្រុង ស្រុក និងឃុំ សង្កាត់) និងអនុវត្តគម្រោងធំៗដែលមានលក្ខណៈបច្ចេកទេសខ្ពស់ និងមានលក្ខណៈអន្តរស្រុក។ រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ គឺជារដ្ឋបាលមូលដ្ឋានដែលមានមុខងារសំខាន់លើការផ្តល់សេវាដែលជាតម្រូវការមូលដ្ឋាន និងចាំបាច់នានាជូនប្រជាពលរដ្ឋដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បច្ចុប្បន្នការបែងចែកមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលតាមថ្នាក់នីមួយៗនៅមិនទាន់មានភាពច្បាស់លាស់ និងជាក់លាក់នៅឡើយ ដែលប្រការនេះចាំបាច់ត្រូវមានការពិនិត្យឡើងវិញ។

**សំណើដំណោះស្រាយ ៖** បញ្ហាប្រឈមនេះមានការពាក់ព័ន្ធទៅនឹងការសិក្សា ការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តទាំងមូលដែលកំពុងរៀបចំដោយក្រុមការងារបច្ចេកទេសអន្តរក្រសួង អាស្រ័យហេតុនេះ ស្នើលេខាធិការដ្ឋាន គ.ជ.អ.ប. ដឹកនាំសម្របសម្រួលក្រុមការងារបច្ចេកទេសអន្តរក្រសួង ក្នុងការបន្តការសិក្សាឱ្យបានចប់ក្នុងឆ្នាំ២០២៥។

****

- **ស្នើសុំឱ្យមានការកំណត់មុខងារ និងការទទួលខុសត្រូវឱ្យបានជាក់លាក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិ (ស្នើដោយខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់)។**

**ដំណើររឿង ៖** កន្លងមក ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការនានា ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមទទួលខុសត្រូវលើការការពារ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសធនធានធម្មជាតិ ព្រមទាំងធ្វើវិសោធនកម្មច្បាប់ព្រៃឈើ ច្បាប់ជលផល និងច្បាប់តំបន់ការពារធម្មជាតិ ដើម្បីបើកផ្លូវឱ្យមានការផ្ទេរមុខងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រមបរិស្ថាន(ដែលបានដាក់បញ្ចូលនូវច្បាប់តំបន់ការពារធម្មជាតិ) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនាពេលថ្មីៗនេះ ព្រមទាំងបានកំណត់ និងបែងចែកតួនាទី និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍតំបន់ធម្មជាតិក៏ដោយ ក៏ប៉ុន្តែលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តក្រមបរិស្ថាននេះនៅពុំទាន់ត្រូវបានរៀបចំ និងផ្សព្វផ្សាយអនុវត្តនៅឡើយ

| | |
|---|---|
| | ជាពិសេសអនុក្រឹត្យផ្ទេរមុខងារគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិនៅពុំទាន់បានរៀបចំដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។<br>**សំណើដំណោះស្រាយ ៖** ពាក់ព័ន្ធនឹងសំណើនេះ គិតមកដល់ពេលនេះ ក្រមបរិស្ថានបានដាក់ចេញ និងសេចក្ដីព្រាងច្បាប់ស្ដីពីជលផលបានដាក់ឆ្លងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីរួចហើយផងដែរ ប៉ុន្តែសេចក្ដីព្រាងច្បាប់ស្ដីពីព្រៃឈើកំពុងស្ថិតក្រោមការពិនិត្យរបស់ក្រសួងយុត្តិធម៌។ អាស្រ័យហេតុនេះ សូមជូនក្រសួងបរិស្ថានសហការជាមួយនឹងក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីរៀបចំ កំណត់មុខងារជាក់លាក់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ស្របទៅតាមក្រមបរិស្ថានដែលបានកំណត់ ដើម្បីលើកសំណើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ស្នើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយនឹងក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីពិនិត្យមើលមុខងារសមស្របដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបន្ទាប់ពីច្បាប់ជលផល និងច្បាប់ព្រៃឈើដាក់ចេញឱ្យប្រើប្រាស់។ |
| ១២ | – **ការអនុវត្តមុខងារការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល៥លានដុល្លារចុះពុំទាន់អាចអនុវត្តបានពេញលេញ និងរលូននៅឡើយ ដោយសារក្រសួង ស្ថាប័នមួយចំនួនពុំទាន់ធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរ អង្គភាពរបស់ខ្លួន និងនៅខ្វះសេចក្ដីណែនាំបច្ចេកទេសអនុវត្តមួយចំនួន និងការបណ្ដុះបណ្ដាលលើវិស័យពាក់ព័ន្ធ។**<br>**ដំណើររឿង ៖** គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៤ មានក្រសួងចំនួន៨ បានដាក់ចេញប្រកាសឬសេចក្ដីសម្រេចធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីររបស់ខ្លួន ក្រសួងទាំងនោះរួមមាន ១).ក្រសួងបរិស្ថាន ២).ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣).ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ៤).ក្រសួងសាធារណការនិងដឹកជញ្ជូន ៥).ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៦).ក្រសួងធនធានទឹកនិងឧតុនិយម ៧).ក្រសួងពាណិជ្ជកម្ម និង៨).ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ហើយក្រសួងចំនួន៣ ពុំទាន់បានដាក់ចេញរួមមានក្រសួងទេសចរណ៍(កំពុងរៀបចំ) ក្រសួងសុខាភិបាល(កំពុងរៀបចំ) និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ ទន្ទឹមនោះ ក្រសួងមួយចំនួនក៏ពុំទាន់បានរៀបចំនិងដាក់ចេញសេចក្ដីណែនាំបច្ចេកទេស និងផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ទីរ និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តនៅឡើយ។ |

| | |
|---|---|
| | **សំណើដំណោះស្រាយ** ៖ ស្នើក្រសួងដែលមិនទាន់ដាក់ចេញប្រកាសប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីររបស់ខ្លួន ត្រូវពន្លឿនការដាក់ចេញប្រកាសធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរ អង្គភាពរបស់ខ្លួន ព្រមទាំងរៀបចំសេចក្តីណែនាំបច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលឱ្យបានឆាប់ ដើម្បីឱ្យរដ្ឋបាលរាជធានី ខេត្តអាចគ្រប់គ្រង និងចុះបញ្ជីគម្រោងវិនិយោគស្របតាមច្បាប់វិនិយោគកម្ពុជា។<br>*****<br>– **រដ្ឋបាលរាជធានី ខេត្តមិនទាន់យល់ដឹងច្បាស់លាស់អំពីតួនាទីរបស់ខ្លួនក្នុងការចូលរួមតាមដាន ត្រួតពិនិត្យទៅលើគម្រោងវិនិយោគដែលចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលមានទីតាំងស្ថិតក្នុងដែនដីរបស់រាជធានី ខេត្ត។**<br>**ដំណើររឿង** ៖ បើទោះបីអនុក្រឹត្យលេខ១៣៩ ជំពូកទី៤ បានចែងអំពីការផ្តល់សេវាថែទាំវិនិយោគរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តដែលសំដៅដល់ការបង្កើតយន្តការផ្តល់សេវាថែទាំវិនិយោគដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលវិនិយោគ បង្កើនទំនុកចិត្ត និងស្វែងរកដំណោះស្រាយបញ្ហាប្រឈមនានារបស់វិនិយោគិនក៏ដោយ ក៏រដ្ឋបាលរាជធានី ខេត្តនៅមិនទាន់យល់ដឹងច្បាស់លាស់អំពីកិច្ចការទាំងនេះ ដែលត្រូវឱ្យមានការផ្សព្វផ្សាយ និងផ្តល់ការណែនាំឱ្យបានច្បាស់លាស់។<br>**សំណើដំណោះស្រាយ** ៖ ស្នើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កំណត់អំពីការចូលរួមរបស់រដ្ឋបាលរាជធានី ខេត្តក្នុងការចូលរួមតាមដាន ត្រួតពិនិត្យទៅលើគម្រោងវិនិយោគដែលចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលមានទីតាំងស្ថិតក្នុងដែនដីរបស់រាជធានី ខេត្ត។ |
| ១៣ | – **ការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់មាននីតិវិធីអនុវត្តច្បាស់លាស់ (ស្នើដោយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់)។**<br>**ដំណើររឿង** ៖ ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋានគឺជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចែងនៅក្នុងជំពូកទី២ ផ្នែកទី៦ នៃច្បាប់រៀបចំអង្គការ។ សព្វថ្ងៃ ការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺផ្អែកទៅលើគំនិតផ្តួចផ្តើម ការចាត់ចែង និងការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរៀងៗខ្លួន ពុំទាន់មាននីតិវិធីច្បាស់លាស់នៅឡើយ ដូច្នេះការដាក់ចេញនីតិវិធីសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកិច្ចការចាំបាច់។ |

| | |
|---|---|
| | **សំណើដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន) បាននិងកំពុងសហការជាមួយក្រសួងយុត្តិធម៌ក្នុងការរៀបចំ និងដាក់ចេញនូវសៀវភៅណែនាំស្តីពីនីតិវិធីនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រៀមកម្មវិធីសម្រាប់ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ស្នើសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បន្តការសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ក្នុងការរៀបចំសៀវភៅណែនាំនេះ និងផ្តល់ការបណ្តុះបណ្តាលនៅក្នុងឆ្នាំ២០២៥នេះ។ |
| ១៤ | **– ឃុំ សង្កាត់មួយចំនួនពុំមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីជ្រើសរើសបុគ្គលិកជំនួយការរដ្ឋបាលឃុំ សង្កាត់ឱ្យឆ្លើយតបទៅនឹងទំហំការងារ និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលឃុំ សង្កាត់ (ចំនួន និងសមត្ថភាពសមស្រប) ដោយសារធនធានថវិកាផ្ទៃក្នុងរដ្ឋបាលរបស់ឃុំ សង្កាត់មានកម្រិត។**<br><br>**ចំណើររឿង** ៖ អនុលោមតាមសេចក្តីណែនាំ០៥៥ ស.ណ.ន. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ បានណែនាំឱ្យរដ្ឋបាលឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកកិច្ចសន្យាមួយចំនួនធ្វើជាជំនួយការរដ្ឋបាលឃុំ សង្កាត់ អាស្រ័យទៅនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់(២នាក់សម្រាប់ឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាពី៥នាក់ទៅ៧នាក់ ៣នាក់សម្រាប់ឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាពី៩នាក់ទៅ១១នាក់)។ ទោះយ៉ាងនេះក្តី ដោយសារធនធានថវិកាផ្ទៃក្នុងរដ្ឋបាលរបស់ឃុំ សង្កាត់នៅមានកម្រិតបានធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់មិនមានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកកិច្ចសន្យាឱ្យឆ្លើយតបទៅនឹងបន្ទុកការងាររបស់ខ្លួនបានឡើយ។<br><br>**សំណើដំណោះស្រាយ** ៖ ការអនុវត្តជាក់ស្តែងកន្លងមក ឃុំ សង្កាត់នីមួយៗបានជ្រើសរើសបុគ្គលិកកិច្ចសន្យារបស់ខ្លួនទាំងចំនួន និងសមត្ថភាពសមស្របទៅនឹងបន្ទុកការងារ ប៉ុន្តែឃុំ សង្កាត់មួយចំនួនពុំអាចមានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកកិច្ចសន្យាដែលមានសមត្ថភាពសមស្របក្នុងការអនុវត្តការងាររបស់ឃុំ សង្កាត់នៅឡើយ ដូចនេះ ជូនក្រសួងមហាផ្ទៃ សហការជាមួយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ សិក្សាពីបន្ទុកការងាររបស់ឃុំ សង្កាត់ កំណត់អំពីតម្រូវការបុគ្គលិក និងលទ្ធភាពបង្កើនថវិកាបន្ទុកបុគ្គលិក ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់មានលទ្ធភាពអាចជ្រើសរើសបុគ្គលិកកិច្ចសន្យាដែលមានសមត្ថភាពសមស្រប។ |

| | |
|---|---|
| ១៥ | – **ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលដើម្បីធ្វើបច្ចុប្បន្នភាពដល់ស្មៀនឃុំ សង្កាត់អំពីការងាររដ្ឋបាល ផែនការ ហិរញ្ញវត្ថុ លទ្ធកម្ម និងបច្ចេកវិទ្យាឌីជីថល និងស្នើសុំឱ្យមានការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាដែលមានការផ្លាស់ប្តូរថ្មី។**<br><br>**ដំណើររឿង** ៖ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងរៀងរាល់០៥ឆ្នាំម្តង។ រៀងរាល់ការបោះឆ្នោតម្តងសមាជិកក្រុមប្រឹក្សាមួយចំនួនត្រូវបានផ្លាស់ប្តូរ ហើយក្រសួងមហាផ្ទៃក៏បានធ្វើការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាថ្មីផងដែរ បន្ទាប់ពីការបោះឆ្នោតតាមអាណត្តិនីមួយៗ ប៉ុន្តែការផ្លាស់ប្តូរសមាជិកថ្មីក្នុងអាណត្តិ (ករណីមរណភាព ការបាត់បង់សមាជិកភាព..) នៅមិនទាន់រៀបចំការបណ្តុះបណ្តាលឱ្យបានភ្លាមៗនៅឡើយទេ។ ទន្ទឹមនោះ ស្មៀនឃុំ សង្កាត់មួយចំនួនក៏ត្រូវបានផ្លាស់ប្តូរ ហើយការកសាងសមត្ថភាពដល់ស្មៀនឃុំ សង្កាត់អំពីនីតិវិធីថ្មីៗដែលបានដាក់ចេញក៏មិនទាន់បានធ្វើឡើងជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធនៅឡើយ គឺមានតែកម្រិតការផ្សព្វផ្សាយ ការណែនាំអនុវត្តទៅតាមនីតិវិធី និងគោលការណ៍ថ្មីៗដែលបានដាក់ចេញដោយថ្នាក់ជាតិ។ ក្នុងន័យនេះ ឃុំ សង្កាត់បានលើកសំណើនេះឡើង ដើម្បីឱ្យក្រសួងស្ថាប័នពាក់ព័ន្ធជួយបណ្តុះបណ្តាលដល់ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលផ្លាស់ប្តូរថ្មី។<br><br>**សំណើដំណោះស្រាយ** ៖ ប្រគល់ភារកិច្ចឱ្យសាលាជាតិរដ្ឋមូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ សហការជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ សិក្សាអំពីតម្រូវការនៃការបណ្តុះបណ្តាលដល់ស្មៀនឃុំ សង្កាត់ រៀបចំកម្មវិធីសិក្សាជាក់លាក់សម្រាប់អភិវឌ្ឍសមត្ថភាពដល់ស្មៀនឃុំ សង្កាត់ដែលត្រូវធ្វើឡើងជាប្រចាំ ព្រមទាំងគិតគូរអំពីវិធីសាស្ត្រសមស្របដើម្បីផ្តល់ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាទាំងថ្មី និងចាស់យ៉ាងហោចណាស់ឱ្យបានមួយដងក្នុង១អាណត្តិ។ |
| ១៦ | – **មន្ត្រីមួយចំនួននៅពុំមានសមត្ថភាពសមស្របឆ្លើយតបទៅនឹងតម្រូវការការងារ និងជំនាញដែលតម្រូវឱ្យមានការបណ្តុះបណ្តាល (ការរៀបចំរបាយការណ៍ និងនីតិវិធីហិរញ្ញវត្ថុ លទ្ធកម្ម ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ គម្រោងសេវាសង្គម ការប្រើប្រាស់ប្រព័ន្ធឌីជីថល ការសម្រុះសម្រួលដោះស្រាយវិវាទ...) ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចជាប្រចាំឆ្នាំដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>– **សមត្ថភាព និងលទ្ធភាពនៃការអភិវឌ្ឍធនធានមនុស្សរបស់ទីចាត់គ្រប់គ្រងធនធានមនុស្សនៅមានកម្រិត។** |

| | |
|---|---|
| | **ដំណើររឿង ៖** រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវបានរៀបចំឱ្យមានទីចាត់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សដែលមានតួនាទីគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពបុគ្គលិកក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរាជធានី ខេត្តផង និងផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ផង។ ជារួម ដោយសារចំនួនបុគ្គលិក និងចំនួនក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់មានចំនួនច្រើន ព្រមទាំងមានតម្រូវការអភិវឌ្ឍសមត្ថភាពតាមអាណត្តិនីមួយៗនៃក្រុមប្រឹក្សាច្រើនផងដែរ ដែលប្រការនេះធ្វើឱ្យទីចាត់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗមិនអាចមានលទ្ធភាព និងសមត្ថភាពផ្តល់សេវាអភិវឌ្ឍសមត្ថភាពឱ្យមានប្រសិទ្ធភាពបានឡើយ គឺចាំបាច់ត្រូវមានការពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនេះ។<br>**សំណើដំណោះស្រាយ ៖** ចំពោះមុខត្រូវបង្កើនសមត្ថភាព និងលទ្ធភាពនៃការបណ្តុះបណ្តាលពីសាលាជាតិរដ្ឋបាលមូលដ្ឋានឱ្យបានកាន់តែច្រើនដល់ក្រុមប្រឹក្សា បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមនេះ ក៏ចាំបាច់ត្រូវពង្រឹងសមត្ថភាព និងលទ្ធភាពរបស់ទីចាត់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សថ្នាក់រាជធានី ខេត្ត តាមរយៈការរៀបចំឱ្យមានក្រុមគ្រូបង្គោលដើម្បីរួមចំណែកដល់ការផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សម្រាប់រយៈពេលមធ្យមទៅវែង ចាំបាច់ត្រូវមានការសិក្សាអំពីជម្រើសនៃការបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់នៅតាមភូមិភាគមួយចំនួន និងពង្រឹងកិច្ចសហការគ្រឹះស្ថានសិក្សាក្នុងការជួយបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចការទាំងនេះប្រគល់ជូនសាលាជាតិរដ្ឋបាលមូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សហការជាមួយស្ថាប័នពាក់ព័ន្ធសិក្សាអំពីជម្រើសនានាបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់នេះ។ |
| ១៧ | – **ការប្រមូលចំណូលពីសេវារដ្ឋបាលវិស័យសាធារណការ ដែលអនុវត្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបង់មកថ្នាក់ជាតិ ហើយបន្ទាប់មកទើបថ្នាក់ជាតិបង្វែរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្នើសុំផ្ទេរការគ្រប់គ្រងចំណូលមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។**<br>**ដំណើររឿង ៖** តាមរយៈអនុក្រឹត្យលេខ១៨ មុខងារផ្តល់សេវារដ្ឋបាលមួយចំនួនក្នុងវិស័យសាធារណការ និងដឹកជញ្ជូនត្រូវផ្ទេរជូនរដ្ឋបាលរាជធានី ខេត្ត និងត្រូវអនុវត្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ប្រជាពលរដ្ឋត្រូវបង់កម្រៃសេវាតាមប្រព័ន្ធធនាគារ ឬភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់ ហើយចំណូលទាំងនោះត្រូវបង់ទៅគណនីរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមិនមែនបង់ទៅគណនីរបស់រាជធានី ខេត្តសាមីនីមួយៗទេ។ ជារៀងរាល់ខែ ក្រសួងសាធារណការនឹងផ្ទេរថវិកាទាំងនោះ |

| | |
|---|---|
| | ជូនរដ្ឋបាលរាជធានី ខេត្ត តែចំណែកថវិកាជាគុណប្រយោជន៍របស់រដ្ឋបាលរាជធានី ខេត្ត និងចំណែកប្រាក់រង្វាន់របស់រដ្ឋបាលរាជធានី ខេត្តប៉ុណ្ណោះ។ ដោយឡែកចំណែកប្រាក់រង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាល ចំណែកប្រាក់រង្វាន់របស់មន្ទីរសាធារណការ និងចំណែកប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការគឺជាអ្នកបែងចែកជូនភាគីពាក់ព័ន្ធ។ ករណីនេះបានបង្កជាការលំបាកដល់រដ្ឋបាលរាជធានី ខេត្តក្នុងការគ្រប់គ្រងចំណូលទាំងនេះ ពិបាកក្នុងការគ្រោងចំណូល និងពិបាកក្នុងការអនុវត្តកិច្ចបញ្ជិកាគណនេយ្យស្របតាមខ្លឹមសារមាត្រា៩ នៃអនុក្រឹត្យលេខ២៥ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយ។ ដោយឡែក រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនមិនទាន់យល់ច្បាស់ពីការបែងចែកនេះ ឬមិនបានទទួលថវិកាពីក្រសួងសាធារណការតែម្តង។<br>**សំណើដោះស្រាយ** ៖ ស្នើក្រសួងសាធារណការ និងដឹកជញ្ជូនពិភាក្សាគ្នាជាមួយអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ដើម្បីពិនិត្យមើលឡើងវិញនិងផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងចំណូលជូនរដ្ឋបាលរាជធានី ខេត្តដែលទទួលបានពីការផ្តល់សេវាដែលបានធ្វើប្រតិភូកម្ម ស្របតាមខ្លឹមសារអនុក្រឹត្យលេខ២៨៣ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌផ្ទេរមុខងារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។ |
| ១៨ | – **ស្នើសុំដល់ក្រសួង ស្ថាប័នថ្នាក់ជាតិផ្តល់ព័ត៌មាន ឬពិគ្រោះយោបល់ជាមួយរដ្ឋបាលខេត្តពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណលើការអភិវឌ្ឍ ឬការរៀបចំអនុវត្តគម្រោងអភិវឌ្ឍន៍នានានៅក្នុងខេត្ត។**<br>**ដំណើររឿង** ៖ គម្រោងវិនិយោគ ឬគម្រោងអភិវឌ្ឍន៍មួយចំនួនតូច មិនត្រូវបានជូនដំណឹងទៅឱ្យរដ្ឋបាលខេត្តទេ ជាហេតុធ្វើឱ្យគម្រោងខ្លះមិនអាចអនុវត្តបាន ឬអនុវត្តដោយខុសប្លង់គោលប្រើប្រាស់ដីរបស់ខេត្ត ដូច្នេះស្នើសុំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានាគួរឱ្យរដ្ឋបាលខេត្តចូលរួមចាប់តាំងពីដំណើរការសិក្សាគម្រោងដល់ការអនុវត្តគម្រោង។<br>**សំណើដោះស្រាយ** ៖ ស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ព័ត៌មានអំពីការរៀបចំគម្រោងអភិវឌ្ឍរបស់ខ្លួន ដោយមានការពិភាក្សាជាមួយរដ្ឋបាលខេត្តសាមី ដើម្បីធានាដល់ការអភិវឌ្ឍស្របតាមប្លង់រៀបចំដែនដីនគររូបនីយកម្មខេត្ត និងផែនការរៀបចំដែនដីរបស់ខេត្ត។<br>*** |

| | |
|---|---|
| | – **គម្រោងវិនិយោគសាធារណៈមួយចំនួនរបស់ក្រសួង ស្ថាប័នដែលគ្រោងអនុវត្តនៅខេត្ត មិនបានអនុវត្តច្រើនឆ្នាំ ហើយខេត្តពុំមានសិទ្ធិអនុវត្តលើគម្រោងដែលបានគ្រោងនោះ ដែលប្រការនេះធ្វើឱ្យរដ្ឋបាលរាជធានី ខេត្តជួបការលំបាកក្នុងការជំរុញការអភិវឌ្ឍនៅក្នុងខេត្តរបស់ខ្លួន។**<br>**ដំណើររឿង** ៖ ចំពោះគម្រោងវិនិយោគសាធារណៈមួយចំនួនរបស់ក្រសួង ស្ថាប័នដែលគ្រោងអនុវត្តនៅខេត្តមិនបានអនុវត្តច្រើនឆ្នាំ តែងតែកើតមានជារឿយៗ ដោយសារខ្វះទំនាក់ទំនង ព័ត៌មាន ឬការសហការគ្នារវាងក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលខេត្ត អាស្រ័យហេតុនេះ ធ្វើឱ្យរដ្ឋបាលខេត្តមិនអាចរៀបចំជាគម្រោងសម្រាប់អនុវត្តគម្រោងដែលបានគ្រោងដោយក្រសួង ស្ថាប័នសាមី។<br>**សំណើដោះស្រាយ** ៖ ស្នើសុំឱ្យក្រសួងសាមីដែលបានរៀបចំគម្រោងនីមួយៗ និងរដ្ឋបាលខេត្តសាមីត្រូវមានទំនាក់ទំនង និងការពិភាក្សាគ្នា ដើម្បីដោះស្រាយបញ្ហាគម្រោងនានាបានគ្រោងដោយក្រសួង ស្ថាប័នហើយ មិនបានអនុវត្តច្រើនឆ្នាំ។ |
| ១៩ | – **ការចុះបញ្ជីអត្រានុកូលដ្ឋាននៅជួបការលំបាក ដោយហេតុថា៖**<br>✓ **ការចុះបញ្ជីដោយដៃដែលនាំឱ្យប្រើពេលវេលាយូរ និងមានកំហុសច្រើន ពិបាកក្នុងការត្រួតពិនិត្យនិងកំណត់អត្តសញ្ញាណអ្នកមកសុំធ្វើសំបុត្រអត្រានុកូលដ្ឋានស្ទួន ស្នើសុំរៀបចំចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល**<br>✓ **ការផ្គត់ផ្គង់ក្រដាសអត្រានុកូលដ្ឋានសម្រាប់ផ្តល់សេវាអត្រានុកូលដ្ឋានមិនគ្រប់គ្រាន់ និងយឺតយ៉ាវ។**<br>**ដំណើររឿង** ៖ បច្ចុប្បន្ន រដ្ឋបាលឃុំ សង្កាត់មានសមត្ថកិច្ចផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋាន និងសេចក្តីចម្លងឯកសារអត្រានុកូលដ្ឋាន (ក្នុងឆ្នាំ) ជូនប្រជាពលរដ្ឋ។ ការចុះបញ្ជី និងការចេញសេចក្តីចម្លងនេះត្រូវធ្វើឡើងដោយដៃផ្ទាល់ និងអាចមានកំហុសច្រើន។ ក្រសួងមហាផ្ទៃគឺជាអ្នកបោះពុម្ពក្រដាសអត្រានុកូលដ្ឋាន និងផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែតាមបទពិសោធន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្គត់ផ្គត់នេះមានចំនួនតិចជាងតម្រូវការ និងមានភាពយឺតយ៉ាវ។ ប្រការទាំងនេះបានធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់ជួបការលំបាក និងប្រឈមមុខជាមួយប្រជាពលរដ្ឋក្នុងការផ្តល់សេវាអត្រានុកូលដ្ឋាន។ |

| | |
|---|---|
| | **សំណើដោះស្រាយ** ៖ (១). បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃបានដាក់ឱ្យដំណើរការសាកល្បងនូវការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដោយមានការជូនដំណឹងពីមូលដ្ឋានសុខាភិបាល ដោយផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) នៅសង្កាត់ចំនួន៦ ក្នុងរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ (ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣) ព្រមទាំងបាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងគ្រោងដាក់ឱ្យដំណើរការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធឌីជីថលគ្រប់សង្កាត់នៅរាជធានីភ្នំពេញនៅត្រីមាសទី២ ឆ្នាំ២០២៥ និងបន្តពង្រីកគ្រប់ក្រុងនៃទីរួមខេត្ត និងពង្រីកជាបន្តបន្ទាប់នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស។ អាស្រ័យហេតុនេះ ជូនក្រសួងមហាផ្ទៃ បន្តការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានទៅតាមផែនការដែលបានគ្រោង ព្រមទាំងពិនិត្យលទ្ធភាពក្នុងការផ្គត់ផ្គង់ក្រដាសអត្រានុកូលដ្ឋានដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្រប។ |
| ២០ | – **ទំហំ ប្រភេទ និងកម្រៃសេវាមួយចំនួនដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយលែងសមស្របទៅនឹងស្ថានភាពរីកចម្រើនសេដ្ឋកិច្ច សង្គម គួរសិក្សានិងពិនិត្យមើលទំហំ ប្រភេទ និងកម្រៃសេវាឡើងវិញ និងធ្វើបច្ចុប្បន្នភាព។**<br>**ដំណើររឿង** ៖ សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងអនុក្រឹត្យលេខ១៨២ លេខ១៨៣ លេខ១៨៤ ក្នុងនោះមានប្រភេទសេវាមួយចំនួននៅមិនទាន់បានកំណត់តម្លៃសេវាឡើយ ហើយមានប្រភេទសេវាមួយចំនួនដែលត្រូវធ្វើបច្ចុប្បន្នភាព ទាមទារការបែងចែកទំហំសេវា និងការគណនាតម្លៃសេវាឡើយវិញឱ្យស្របទៅបរិបទ និងស្ថានភាពសេដ្ឋកិច្ច។<br>**សំណើដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងការងារនេះ ក្រសួងមហាផ្ទៃកំពុងធ្វើបច្ចុប្បន្នភាពកម្រងសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឡើងវិញ អាស្រ័យហេតុនេះស្នើក្រសួងមហាផ្ទៃបន្តសិក្សា និងពិនិត្យមើលឡើងវិញសេវារដ្ឋបាលដែលកំពុងអនុវត្តនៅក្រុង ស្រុក ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ។<br>****<br>– **ស្នើសុំឱ្យមានការរៀបចំប្រព័ន្ធឌីជីថលសម្រាប់ការផ្តល់សេវាអត្រានុកូលដ្ឋាន និងសេវារដ្ឋបាលផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីងាយស្រួល ឆាប់រហ័ស និងមានភាពច្បាស់លាស់ក្នុងការផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ** |

| | |
|---|---|
| | – **ស្នើសុំរដ្ឋបាលស្រុកចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ជូនអ្នកដែលបាត់**<br>– **បែបបទនៃការស្នើសុំកែតម្រូវអត្រានុកូលដ្ឋានឆ្លងឆ្នាំមានភាពសាំញ៉ាំច្រើន**<br>– **ការផ្គត់ផ្គង់សម្ភារសម្រាប់ផ្តល់សេវាអត្រានុកូលដ្ឋានមិនគ្រប់គ្រាន់ ដែលធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការផ្តល់សេវា។**<br><br>**ដំណើររឿង** ៖ បច្ចុប្បន្ន អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំកម្មវិធីព័ត៌មានវិទ្យាសម្រាប់ទទួលពាក្យស្នើសុំ និងផ្តល់សេវាតាមប្រព័ន្ធអនឡាញនៅការិយាល័យច្រកចេញចូលតែមួយ និងកំពុងអនុវត្តសាកល្បងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅចំនួន៩ លើប្រភេទសេវាចំនួន៩ (៣សេវាពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ៣សេវាពាក់ព័ន្ធនឹងការធ្វើនីត្យានុកូលកម្ម និង៣សេវាពាក់ព័ន្ធនឹងអាជីវកម្មផ្ទះសំណាក់ក្នុងវិស័យទេសចរណ៍)។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃបាន និងកំពុងរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដោយកំណត់សមត្ថកិច្ចដល់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធគ្រប់គ្រងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន គ្រោងនឹងដាក់ឱ្យដំណើរការនៅត្រីមាសទី២ ឆ្នាំ២០២៥ នៅគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ចំពោះការកែតម្រូវឯកសារអត្រានុកូលដ្ឋាន ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០០៦ របស់ក្រសួងមហាផ្ទៃដែលតម្រូវឱ្យដាក់ពាក្យស្នើសុំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មុននឹងបញ្ជូនសំណើនោះជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មពិនិត្យ និងសម្រេច ដែលបញ្ហានេះមាននីតិវិធីស្មុគស្មាញ ឆ្លងកាត់ច្រើនដំណាក់កាល និងត្រូវចំណាយពេលយូរ។ ពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារដល់រដ្ឋបាលក្រុង ស្រុក ក្រសួងមហាផ្ទៃក៏បានគ្រោងនៅក្នុងផែនការក្នុងការផ្តល់សម្ភារដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០២៥។<br><br>**សំណើដោះស្រាយ** ៖ កិច្ចការនេះគួរជូនក្រសួងមហាផ្ទៃដើម្បីជាសមត្ថកិច្ចក្នុងការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធឌីជីថលសម្រាប់ការផ្តល់សេវាអត្រានុកូលដ្ឋាន និងដោះស្រាយបញ្ហាផ្សេងៗដែលបានលើកឡើងខាងលើនេះ។ |
| ២១ | – **ការរៀបចំកាតគ្រីម៉ូតូនៅថ្នាក់ស្រុក មានបញ្ហាអក្ខរាវិរុទ្ធក្នុងប្រព័ន្ធ សំណូមពរផ្ញើឯកសារតាមប្រព័ន្ធ និងមិនចាំបាច់កាន់ឯកសារដើមជូនទៅក្រសួង** |

| | |
|---|---|
| | – **ការចុះបញ្ជីទុតិយតាស្លាកលេខ និងប័ណ្ណសម្គាល់ទោចក្រយានយន្តមានការយឺតយ៉ាវក្នុងការទម្លាក់ទិន្នន័យ មកការិយាល័យច្រកចេញចូលតែមួយ ស្នើក្រសួងសាធារណការ និងដឹកជញ្ជូន ជួយទម្លាក់ទិន្នន័យឱ្យបានលឿន។**<br>**ដំណើររឿង** ៖ បច្ចុប្បន្ន នៅពេលបុគ្គលិកការិយាល័យច្រកចេញចូលតែមួយជួបប្រទះបញ្ហាបច្ចេកទេសក្នុងការបោះពុម្ពបណ្ណសម្គាល់ម៉ូតូ ដូចជា ករណីដាច់ភ្លើង ឬបញ្ហាប្រព័ន្ធអ៊ីនធឺណិតដើរយឺត ដែលធ្វើឱ្យបាត់ទិន្នន័យក្នុងប្រព័ន្ធ ឬព្រីនបណ្ណសម្គាល់ខុសលក្ខណៈបច្ចេកទេស(ខូចបណ្ណ) ក្រុមហ៊ុនកាំត្រង់ស៊ីបមិនអាចជួយដោះស្រាយបញ្ហាបានភ្លាមៗ ដោយសារតែក្រុមហ៊ុនបានតម្រូវឱ្យការិយាល័យច្រកចេញចូលតែមួយ ត្រូវទំនាក់ទំនងដោយផ្ទាល់ជាមួយមន្ត្រីជំនាញនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកជាមុនសិន (មិនទទួលយកលិខិត ឬការស្នើសុំសម្របសម្រួលតាមប្រព័ន្ធតេលេក្រាម)។ ជាមួយគ្នានេះ ពាក់ព័ន្ធនឹងការស្នើសុំទុតិយតាស្លាកលេខ និងបណ្ណសម្គាល់ទោចក្រយានយន្ត ជាពិសេសសម្រាប់ទោចក្រយានយន្តដែលបានចុះបញ្ជីដោយដៃមុនការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្ម បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការទំនាក់ទំនងទៅមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ដើម្បីស្វែងរកឯកសារចុះបញ្ជី និងបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធ មុននឹងទម្លាក់ទិន្នន័យក្នុងប្រព័ន្ធជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ។ ការងារនេះចំណាយពេលយូរ ដែលនាំឱ្យប្រជាពលរដ្ឋមានការមិនសប្បាយចិត្ត។<br>**សំណើដោះស្រាយ** ៖ ជូនក្រសួងមហាផ្ទៃ ពិភាក្សាជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ពិនិត្យ និងដោះស្រាយបញ្ហាប្រឈមទាំងពីរខាងលើដែលស្នើឡើងដោយក្រុង ស្រុក ខណ្ឌ។ |
| ២២ | – **ស្នើសុំពិចារណាផ្ទេរមុខងារក្នុងការផ្តល់សេវាផ្ទេរកម្មសិទ្ធិដែលបានចុះបញ្ជី (ប្លង់រឹង) មករដ្ឋបាលក្រុង ស្រុកទទួលខុសត្រូវ ដើម្បីពន្លឿនក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋលើការគ្រប់គ្រងដីធ្លី។**<br>**ដំណើររឿង** ៖ បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចផ្តល់សេវាផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជីជូនប្រជាពលរដ្ឋ។ ដោយឡែកសម្រាប់ការផ្ទេរកម្មសិទ្ធិដែលបានចុះបញ្ជី (ប្លង់រឹង) ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត តាមរយៈអង្គភាពច្រកចេញចូលតែមួយ។ |

| | |
|---|---|
| | **សំណើដោះស្រាយ ៖** ជូនក្រសួងមហាផ្ទៃ លេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សិក្សានិងពិនិត្យមើលលទ្ធភាពនៃការផ្ទេរមុខងារនេះជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ។<br>*****<br>– **នីតិវិធី និងសំណុំឯកសារនៃការផ្តល់សេវារដ្ឋបាលលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី(ប្លង់ទន់) និងការសុំច្បាប់សាងសង់មានភាពស្មុគស្មាញ ចំណាយពេលយូរ និងតម្រូវឯកសារច្រើនប្រភេទ។**<br>**ដំណើររឿង ៖** ការផ្តល់សេវាកម្មសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជីមានការអនុវត្តបែបបទ និងនីតិវិធីខុសៗគ្នាពីរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ដោយសារក្រសួង ស្ថាប័នពាក់ព័ន្ធមិនទាន់បានរៀបចំ និងដាក់ចេញសេចក្តីណែនាំដែលកំណត់ទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់សេវាឱ្យមានស្តង់ដារួមតែមួយ សម្រាប់ការងារសំណង់ ជាពិសេសសម្រាប់ស្រុកដែលនៅឆ្ងាយពីទីរួមខេត្ត មានការពិបាកក្នុងការស្វែងរកក្រុមជាងសំណង់ដែលទទួលស្គាល់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាបត្យករដែលបានចុះបញ្ជី ដើម្បីរៀបចំ និងគូសប្លង់ស្ថាបត្យកម្មសំណង់ជូនប្រជាពលរដ្ឋ ហើយប្លង់ស្ថាបត្យកម្មនេះមានតម្លៃថ្លៃ (សេវាឯកជន)។<br>**សំណើដោះស្រាយ ៖** ជូនក្រសួងមហាផ្ទៃ ពិភាក្សាជាមួយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យមើលឡើងវិញអំពីនីតិវិធី និងសំណុំឯកសារសម្រាប់ការផ្តល់សេវាការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី(ប្លង់ទន់) និងការសុំច្បាប់សាងសង់ ដើម្បីឱ្យមានសាមញ្ញងាយស្រួល និងឆាប់រហ័សជូនប្រជាពលរដ្ឋ។ |
| ២៣ | – **ស្នើសុំឱ្យរដ្ឋបាលក្រុង ស្រុកទទួលបានចំណូលសួយសារពីធនធានរ៉ែ (ការជីកអាចម៍ដី រណ្តៅដីចល័ត ប្រតិបត្តិការបកយកអាចម៍ដី ...)ដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាប័ណ្ណ។**<br>**ដំណើររឿង ៖** តាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ លេខ១៨៤ រាជរដ្ឋាភិបាលបានប្រគល់មុខងារក្នុងវិស័យរ៉ែ និងថាមពលជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចជាការជីកអាចម៍ដី រណ្តៅដីចល័ត (ក្រឡាផ្ទៃមិនលើសពី០,៥ហិកតា និងជម្រៅមិនលើសពី៣ម៉ែត្រ) និងប្រតិបត្តិការបកយកអាចម៍ដី (ក្រឡាផ្ទៃមិនលើសពី១ហិកតា និងជម្រៅមិនលើសពី១ម៉ែត្រ) រដ្ឋបាលក្រុង ស្រុក ខណ្ឌមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ និងចុះបញ្ជីអាជ្ញាបណ្ណជូនអ្នកស្នើសុំសេវាប៉ុណ្ណោះ ប៉ុន្តែចំពោះការប្រមូលសួយសារ និងការចុះពិនិត្យផាកពិន័យផ្សេងៗជាសមត្ថកិច្ចរបស់ |

| | |
|---|---|
| | មន្ទីររ៉ែ និងថាមពល ហើយបង់ចំណូលទៅក្រសួងថ្នាក់ជាតិ។ ក្រសួងបានផ្តល់ជាថវិការង្វាន់មករដ្ឋបាលរាជធានី ខេត្ត តែមិនមានផ្តល់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌឡើយ។<br>**សំណើដោះស្រាយ** ៖ ស្នើសុំឱ្យក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យមើលពីលទ្ធភាពនៃការអនុញ្ញាតរដ្ឋបាលក្រុង ស្រុកទទួលបានចំណូលស្ទួយសារពីធនធានរ៉ែ (ការជីកអាចម៍ដី រណ្តៅដីចល័ត ប្រតិបត្តិការបកយកអាចម៍ដី ...)ដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាបណ្ណ។<br>*****<br>– **មុខងារដែលបានផ្ទេរឱ្យក្នុងវិស័យរ៉ែ មានការលំបាកក្នុងការចេញលិខិតអនុញ្ញាត ពីព្រោះមិនទាន់មានការកំណត់តម្លៃសេវាជាក់លាក់ ដូចជាដេប៉ូខ្សាច់ ថ្ម ប្រេង ហ្គាសជាដើម។**<br>**ចំណើររឿង** ៖ មុខងារផ្តល់សេវារដ្ឋបាលចុះបញ្ជីដេប៉ូខ្សាច់ ថ្ម លិខិតអនុញ្ញាតសម្រាប់អាជីវកម្មលក់ប្រេងម៉ាស៊ីន និង ហ្គាស ជាប្រភេទសេវាថ្មីដែលបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយមិនទាន់មានប្រកាសអន្តរក្រសួងដើម្បីកំណត់តម្លៃសេវានៅឡើយទេ។ បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចផ្តល់សេវានេះជូនប្រជាពលរដ្ឋដោយមិនមានគិតថ្លៃសេវា។ ក្រសួងមហាផ្ទៃកំពុងសម្របសម្រួលការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>**សំណើដោះស្រាយ** ៖ ជូនក្រសួងមហាផ្ទៃបន្តសម្របសម្រួលជាមួយក្រសួងរ៉ែ និងថាមពល ដើម្បីដាក់ចេញប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| ២៤ | **សេវារដ្ឋបាល (ច្រកចេញចូលតែមួយ)៖**<br>– **ទម្រង់ឯកសារស្នើសុំសេវាលើវិស័យសុរិយោដី និងសំណង់មានភាពស្មុគស្មាញ យឺតយ៉ាវ តម្រូវភ្ជាប់ឯកសារច្រើន រយៈពេលយូរ និងត្រូវការចុះហត្ថលេខាពីអង្គភាពពាក់ព័ន្ធច្រើន និងពុំទាន់មាននីតិវិធីច្បាស់លាស់។** |

| | |
|---|---|
| | **ដំណើររឿង ៖** សេវានៅក្នុងវិស័យសុរិយោដីមានច្រើនប្រភេទសេវា ហើយការរៀបចំឯកសារសម្រាប់ស្នើសុំសេវានីមួយៗមានការលំបាក ដោយសារ (១). ទាមទារតម្រូវការឯកសារភ្ជាប់ច្រើន និងខុសៗគ្នាអាស្រ័យទៅតាមស្ថានភាពរបស់បុគ្គលស្នើសុំសេវា (២).មានប្រើប្រាស់ពាក្យបច្ចេកទេសច្រើន ដែលប្រជាពលរដ្ឋពិបាកយល់ និងមិនអាចបំពេញដោយខ្លួនឯងបាន (៣).នីតិវិធីសាំញ៉ាំ និងត្រូវឆ្លងកាត់ការពិនិត្យ សម្រេចពីអាជ្ញាធរ និងអ្នកពាក់ព័ន្ធច្រើន តាំងពីថ្នាក់ឃុំ សង្កាត់ រហូតដល់ថ្នាក់រាជធានី ខេត្ត។<br>**សំណើដោះស្រាយ ៖** ជូនក្រសួងមហាផ្ទៃ បន្តពិភាក្សាជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យមើលឡើងវិញអំពីនីតិវិធី និងសំណុំឯកសារភ្ជាប់។<br>*****<br>– **ការចុះបញ្ជីសេវាវិស័យសាធារណការ ត្រូវចុះបញ្ជីតាមប្រព័ន្ធ២ផ្សេងគ្នាគឺប្រព័ន្ធក្រសួងសាធារណការ និងដឹកជញ្ជូន និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវារបស់ក្រសួងមហាផ្ទៃ។**<br>**ដំណើររឿង ៖** បច្ចុប្បន្ន បុគ្គលិករបស់អង្គភាពច្រកចេញចូលតែមួយ ត្រូវបញ្ចូលទិន្នន័យចុះបញ្ជីសេវាចំនួន២ដងនៅក្នុងប្រព័ន្ធ២ផ្សេងគ្នា រួមមាន៖ ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (សម្រាប់ផ្តល់សេវា) និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅច្រកចេញចូលតែមួយរបស់ក្រសួងមហាផ្ទៃ (សម្រាប់គ្រប់គ្រងតួលេខ និងទិន្នន័យសេវា) ដោយសារប្រព័ន្ធទាំងពីរនៅមិនទាន់បានធ្វើសន្ទានកម្មទិន្នន័យជាមួយគ្នា។ មន្ត្រីមានការលំបាកក្នុងការបញ្ចូលទិន្នន័យដដែលៗ និងបង្កភាពយឺតយ៉ាវដល់មន្ត្រីក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។<br>**សំណើដោះស្រាយ ៖** ស្នើក្រសួងក្រសួងសាធារណការ និងដឹកជញ្ជូន ពិភាក្សាជាមួយក្រសួងមហាផ្ទៃ ដើម្បីពន្លឿនការធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ជាមួយកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>***** |

- **សេវាមួយចំនួនដែលផ្ទេរឱ្យរដ្ឋបាលរាជធានី ខេត្តហើយ ត្រូវបានកែសម្រួលយកមកផ្តល់នៅថ្នាក់ក្រសួងវិញក្រោមហេតុផលធ្វើទំនើបកម្មប្រព័ន្ធផ្តល់សេវាតាមបច្ចេកវិទ្យា ដូចជា៖ (១).ការចុះបញ្ជីយានយន្ត (វិស័យសាធារណការ) (២). ការចុះបញ្ជីបង្កើតសិប្បកម្មដែលគ្មានហានិភ័យដើមទុនតិចជាង ឬស្មើ២ម៉ឺនដុល្លារ (វិស័យឧស្សាហកម្ម) (៣).ការផ្តល់វិញ្ញាបនបត្រដំណើរការសិប្បកម្មគ្មានហានិភ័យដើមទុនតិចជាង ឬស្មើ២ម៉ឺនដុល្លារ (វិស័យឧស្សាហកម្ម) ។**

**ដំណើររឿង** ៖ បច្ចុប្បន្ន មានក្រសួងមួយចំនួនបានដកយកមុខងារមួយចំនួនមកអនុវត្តនៅថ្នាក់ជាតិវិញ ទោះបីជាមុខងារទាំងនោះត្រូវបានកំណត់នៅក្នុងអនុក្រឹត្យលេខ១៨ ដែលបានប្រតិភូកម្មជូនរដ្ឋបាលរាជធានី ខេត្តរួចហើយ រួមមាន៖

- **ក្រសួងសាធារណការ និងដឹកជញ្ជូន**៖ នៅបន្តអនុវត្តការផ្ទេរកម្មសិទ្ធិយានយន្តនៅថ្នាក់ក្រសួងដដែល ដោយលើកហេតុផលថា កន្លងមកឯកសារចុះបញ្ជីយានយន្តមួយចំនួនធ្វើឡើងដោយដៃ និងនៅមិនទាន់បានបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មនៅឡើយ ដែលនាំឱ្យក្រសួងមិនអាចអនុញ្ញាតឱ្យរដ្ឋបាលរាជធានី ខេត្តផ្តល់សេវានេះបាន
- **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**៖ បានចូលរួមអនុវត្តក្នុងថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យ CamDX សម្រាប់ផ្តល់សេវាផ្សេងៗតាមប្រព័ន្ធអនឡាញ ជាពិសេសគឺការចុះបញ្ជីសិប្បកម្ម។ ការស្នើសុំសេវាតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យ CamDX ប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំសេវាចុះបញ្ជីសិប្បកម្មគ្រប់ទំហំដើមទុន ទាំងទំហំដើមទុនដែលស្ថិតក្រោមសមត្ថកិច្ចពិនិត្យសម្រេចរបស់រដ្ឋបាលកណ្តាល និងទំហំដើមទុនដែលស្ថិតក្រោមសមត្ថកិច្ចពិនិត្យសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក្រសួងឧស្សាហកម្មក៏បានពិនិត្យសម្រេចលើការស្នើសុំនោះ បើទោះបីជាសិប្បកម្មនោះមានទំហំដើមទុនស្ថិតក្រោមការពិនិត្យសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ។

**សំណើដោះស្រាយ** ៖ ជូនក្រសួងមហាផ្ទៃ ពិភាក្សាជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដើម្បីពិនិត្យ និងដោះស្រាយទៅលើប្រភេទសេវាដែលបានធ្វើប្រតិភូកម្មទៅឱ្យរាជធានី ខេត្ត។

*****

- **សុំឱ្យមានការរៀបចំការផ្តល់សេវាជាកញ្ចប់នៅអង្គភាពច្រកចេញចូលតែមួយ និងផ្តល់សេវាអនឡាញ។**

| | |
|---|---|
| | **ដំណើររឿង** ៖ រដ្ឋបាលរាជធានី ខេត្ត ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋទៅតាមលិខិតបទដ្ឋានបច្ចេកទេស ឬការអនុវត្ត ដែលមន្ទីរធ្លាប់ផ្តល់សេវាកន្លងមកដោយតម្រូវឱ្យប្រជាពលរដ្ឋត្រូវស្នើសុំសេវានីមួយៗដាច់ដោយឡែកពីគ្នា និងមិនទាន់អាចធ្វើបានជាកញ្ចប់ក្នុងពេលតែមួយ។ ករណីនេះ ធ្វើឱ្យប្រជាពលរដ្ឋនៅតែជួបការលំបាកក្នុងការស្នើសុំសេវារដ្ឋបាលនីមួយៗដាច់ពីគ្នាដែលត្រូវការចំណាយពេលវេលា និងថវិកាច្រើន បើទោះបីជាការផ្តល់សេវារដ្ឋបាលទាំងនោះនៅកន្លែងតែមួយ គឺនៅការិយាល័យ ឬអង្គភាពច្រកចេញចូលតែមួយក៏ដោយ។ ករណីនេះ ក្រសួងមហាផ្ទៃនឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំជាលិខិតបទដ្ឋានបច្ចេកទេសតាមសេវានីមួយៗ ដោយពិនិត្យលទ្ធភាពក្នុងការកែសម្រួល និងរៀបចំឱ្យមានការស្នើសុំសេវាជាកញ្ចប់ ចំពោះប្រភេទសេវាដែលមានការពាក់ព័ន្ធគ្នា។<br>**សំណើដោះស្រាយ** ៖ ជូនក្រសួងមហាផ្ទៃសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំជាលិខិតបទដ្ឋានបច្ចេកទេសតាមសេវានីមួយៗ ដោយពិនិត្យលទ្ធភាពក្នុងការកែសម្រួល និងរៀបចំឱ្យមានការស្នើសុំសេវាជាកញ្ចប់ ចំពោះប្រភេទសេវាដែលមានការពាក់ព័ន្ធគ្នា។ |
| ២៥ | **– ខ្វះការគាំទ្របច្ចេកទេស មធ្យោបាយ ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យពីមន្ទីរជំនាញ/អង្គភាពជំនាញដល់មន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្រោយផ្ទេរសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក (ស្នើដោយក្រុង ស្រុក)។**<br>**ដំណើររឿង** ៖ បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យជំនាញក្នុង២០វិស័យទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួង ស្ថាប័នបានផ្ទេរបុគ្គលិកជំនាញចំនួនប្រមាណជិត៨.០០០នាក់ (លើកលែងគ្រូបង្រៀន) ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចាប់ពីឆ្នាំ២០២០មក។ បន្ទាប់ពីការធ្វើសមាហរណកម្មនេះមក ការគាំទ្របច្ចេកទេស ឧបករណ៍ សម្ភារ ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យរបស់មន្ទីរជំនាញសាមីនីមួយៗមានការថយចុះ បើប្រៀបធៀបទៅនឹងស្ថានភាពមុនការផ្ទេរមុខងារ និងបុគ្គលិក ដែលជាហេតុធ្វើឱ្យអង្គភាពជំនាញនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ជួបការលំបាកក្នុងការអនុវត្តមុខងាររបស់ខ្លួនផងដែរ។ ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ គឺបញ្ហាសំខាន់មួយក្នុងដំណើរការនៃវិមជ្ឈការ។ បើទោះបីជាមុខងារ និងធនធានទាំងនោះបានផ្ទេរតាមបែបវិមជ្ឈការទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ក្រសួង ស្ថាប័នក្នុងវិស័យជំនាញនៅតែមានការទទួលខុសត្រូវចំពោះវិស័យរបស់ខ្លួនតាមរយៈការគាំទ្របច្ចេកទេស ធនធាន ការអភិវឌ្ឍសមត្ថភាព និងការត្រួតពិនិត្យលើការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការសម្រេចបានតាមគោលនយោបាយវិស័យ ផែនការយុទ្ធសាស្ត្រ ស្តង់ដាបច្ចេកទេស ព្រមទាំងគោលការណ៍ នីតិវិធីនានាដែលបានកំណត់។ |

| | |
|---|---|
| | **សំណើដោះស្រាយ ៖** ស្នើក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្តនីមួយៗ ផ្តល់ការណែនាំដល់មន្ទីរ អង្គភាពជំនាញ ដើម្បីជំរុញការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| ២៦ | – **ការធ្វើសវនកម្មផ្ទៃក្នុងនៅពុំមានភាពច្បាស់លាស់រវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។**<br>**សំណើដោះស្រាយ ៖** ជូនក្រសួងមហាផ្ទៃ ពិនិត្យពិភាក្សាផ្ទៃក្នុងដើម្បីដោះស្រាយសំណើនេះ។ |
| ២៧ | – **ភូមិមួយចំនួននៅតែជាភូមិឧបសម្ព័ន្ធដែលមិនទាន់មានការការចុះបញ្ជីទទួលស្គាល់ពីក្រសួងមហាផ្ទៃ។**<br>**ដំណើររឿង ៖** ការបង្កើតភូមិត្រូវអនុវត្តដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ០០៤ ឆ្នាំ២០០៦។ ក្រសួងមហាផ្ទៃបាននិងកំពុងរៀបចំកែសម្រួលសេចក្តីណែនាំនេះ ដោយកំណត់លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបង្រួម និងការរំសាយភូមិស្របតាមស្ថានភាពវិវឌ្ឍន៍នៃសេដ្ឋកិច្ច-សង្គម ប្រជាសាស្ត្រ និងភូមិសាស្ត្របច្ចុប្បន្ន។<br>**សំណើដោះស្រាយ ៖** ជូនក្រសួងមហាផ្ទៃសិក្សា និងរៀបចំកំណត់លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបង្រួម និងការរំសាយភូមិ ស្របតាមស្ថានភាពវិវឌ្ឍន៍នៃសេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រ និងភូមិសាស្ត្របច្ចុប្បន្ន។ |
| ២៨ | – **រដ្ឋបាលស្រុកមួយចំនួនពុំទាន់មានអគាររដ្ឋបាលសមរម្យនៅឡើយ។**<br>**ដំណើររឿង ៖** បច្ចុប្បន្ន មានរដ្ឋបាលក្រុង ស្រុកសរុប១៩៦ ក្នុងនោះរដ្ឋបាលក្រុង ស្រុកគ្មានអគារចំនួន៧ អគារទ្រុឌទ្រោមចំនួន២៨ អគារមធ្យមចំនួន៦២ អគារល្អចំនួន៥០ និងអគារថ្មីចំនួន៤៨។<br>**សំណើដោះស្រាយ ៖** ប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំផែនការសាងសង់អគាររដ្ឋបាលស្រុកឱ្យបានសមស្រប។ |

| | |
|---|---|
| ២៩ | – **រដ្ឋបាលខេត្តមួយចំនួនពុំទាន់មានប្លង់រៀបចំនគរូបនីយកម្ម និងប្លង់ប្រើប្រាស់ដីធ្លី**<br>– **ស្នើសុំឱ្យមានប្លង់គោលប្រើប្រាស់ដីធ្លីថ្នាក់ក្រុង ស្រុក។**<br>**ដំណើររឿង** ៖ ការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មនេះ គឺស្ថិតក្រោមសមត្ថកិច្ចគណៈកម្មាធិការអន្តរក្រសួង ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។ បច្ចុប្បន្ន រដ្ឋបាលខេត្តចំនួន៣គឺខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងខេត្តមណ្ឌលគិរី មានផែនការរៀបចំដែនដីខេត្តរួចហើយ។ ក្រៅពីនេះ ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ប្លង់គោលប្រើប្រាស់ដីខណ្ឌចំនួន៨ គឺខណ្ឌជ្រោយចង្វារ, ខណ្ឌសែនសុខ, ខណ្ឌដូនពេញ, ខណ្ឌ៧មករា, ខណ្ឌព្រែកព្នៅ, ខណ្ឌទួលគោក, ខណ្ឌឫស្សីកែវ និងខណ្ឌមានជ័យ ប្លង់គោលប្រើប្រាស់ដីក្រុងចំនួន១៦គឺ ក្រុងព្រះសីហនុ, ក្រុងកែប, ក្រុងកំពត, ក្រុងខេមរភូមិន្ទ, ក្រុងបូកគោ, ក្រុងសៀមរាប, ក្រុងបាត់ដំបង, ក្រុងតាខ្មៅ, ក្រុងស្ទឹងត្រែង, ក្រុងបាវិត, ក្រុងសួង, ក្រុងប៉ោយប៉ែត, ក្រុងដូនកែវ, ក្រុងព្រះវិហារ, ក្រុងកំពង់ចាម និងក្រុងកោះរ៉ុង ប្លង់គោលប្រើប្រាស់ដីស្រុកចំនួន១ គឺ ស្រុកបរិបូណ៌ និងប្លង់គោលប្រើប្រាស់ដីទីប្រជុំជនចំនួន២ គឺទីប្រជុំជនត្បូងឃ្មុំ និងទីប្រជុំជនជ្រៃធំ ក៏ត្រូវបានរៀបចំរួចហើយផងដែរ។ ផ្អែកតាមស្ថានភាពនេះ រដ្ឋបាលខេត្ត ក្រុង ស្រុកមួយចំនួនធំនៅពុំទាន់មានផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដីនៅឡើយ។<br>**សំណើដោះស្រាយ** ៖ ស្នើគណៈកម្មាធិការអន្តរក្រសួង ពន្លឿនការរៀបចំប្លង់រៀបចំនគរូបនីយកម្ម និងប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោលប្រើប្រាស់ដីធ្លីថ្នាក់ក្រុង ស្រុក។ |
| ៣០ | – **មិនទាន់មានការកំណត់ច្បាស់លាស់នូវព្រំប្រទល់ឃុំ-ភូមិមួយចំនួនដែលនាំឱ្យពិបាកក្នុងការផ្តល់សេវា និងការងារសន្តិសុខសណ្តាប់ធ្នាប់**<br>– **ព្រំប្រទល់រដ្ឋបាលក្រុង ស្រុកមួយចំនួនពុំទាន់មានភាពច្បាស់លាស់**<br>– **ព្រំប្រទល់រដ្ឋបាលខេត្តមួយចំនួននៅពុំមានការឯកភាពគ្នា។**<br>**ដំណើររឿង** ៖ ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងកំណត់ឡើងវិញឱ្យបានច្បាស់លាស់នាឆ្នាំ២០០១ ដោយអនុលោមតាមមាត្រា៨៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ក្រសួងមហាផ្ទៃបានដាក់ចេញនូវប្រកាសលេខ៤៩៣ ឆ្នាំ២០០១ ស្តីពីការកំណត់ចំនួន |

| | |
|---|---|
| | ឈ្មោះ និងព្រំប្រទល់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលពេលនោះផែនទីត្រូវបានគូសដោយដៃ ដោយសារពេលនោះនៅពុំទាន់មានបច្ចេកទេសតាមប្រព័ន្ធឌីជីថលនៅឡើយ។ ទោះបីជាមានការកំណត់ ព្រំប្រទល់រដ្ឋបាលរួចហើយក្តី ប៉ុន្តែស្ថានភាពនៃការអនុវត្តជាក់ស្តែង កន្លែងមួយចំនួនមានការប្រទាញប្រទង់គ្នានៅឡើយ។ បញ្ហាទាំងនេះត្រូវបាន និងកំពុងសម្របសម្រួល និងចាត់វិធានការដោះស្រាយជាបណ្តើរៗដោយក្រសួងមហាផ្ទៃសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។<br><br>**សំណើដោះស្រាយ** ៖ ប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃ រៀបចំកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ |

# តារាងឧបសម្ព័ន្ធទី ៥

## ការផ្តល់យោបល់របស់អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប. លើវិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរនានា ដែលលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| ១ | **– រដ្ឋបាលក្រុង ស្រុកភាគច្រើនខ្វះមន្ត្រីជំនាញតាមវិស័យមួយចំនួន (កសិកម្ម ធនធានទឹក បរិស្ថាននិងអនាម័យ អភិវឌ្ឍន៍ជនបទ សាធារណការ និងធនធានធម្មជាតិ....) និងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់លើការកសាងផែនការ ការសិក្សា រៀបចំ និងអនុវត្តគម្រោងឃុំ សង្កាត់...**<br>**– មន្ត្រីរបស់រដ្ឋបាលក្រុង ស្រុកដែលមានស្រាប់ពុំទាន់មានជំនាញបច្ចេកទេសច្បាស់លាស់តាមវិស័យ ដែលស្នើសុំឱ្យមានការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពជំនាញ។**<br><br>**ដំណើររឿង៖** ផ្អែកតាមអនុក្រឹត្យលេខ១៨២ និងលេខ១៨៤ ឆ្នាំ២០១៩ បុគ្គលិករបស់ការិយាល័យជំនាញតាមវិស័យនានាត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។ ទោះយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពបច្ចុប្បន្ន បុគ្គលិកដែលបានផ្ទេរទាំងនោះក្នុងវិស័យមួយចំនួនមានបុគ្គលិកតិចឬពុំមានបុគ្គលិក បុគ្គលិកមួយចំនួនពុំមានជំនាញបច្ចេកទេស បុគ្គលិកខ្លះមានអាយុច្រើន និងចូលនិវត្តន៍ជាបណ្តើរៗ **(បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុង២០វិស័យរួមទាំងក្រសួងមហាផ្ទៃផងក្នុងឆ្នាំ២០២០ មានចំនួន១៣.០៧៤នាក់ រហូតដល់បច្ចុប្បន្នគិតត្រឹមខែកក្កដា ឆ្នាំ២០២៤ មានចំនួន១០.០២៤នាក់ ដូច្នេះមានការថយចុះមានចំនួន២.៩៥០នាក់)**។ ជាមួយគ្នានេះក្នុងអំឡុងពេលប៉ុន្មានឆ្នាំក្រោយមកនេះ រាជរដ្ឋាភិបាលបានផ្អាកការជ្រើសរើសបុគ្គលិកក្របខ័ណ្ឌរដ្ឋថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ជំនួសអ្នកដែលចូលនិវត្តន៍...) អាស្រ័យហេតុនេះធ្វើឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុកជួបបញ្ហាប្រឈមពាក់ព័ន្ធនឹងការខ្វះបុគ្គលិកជំនាញសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យ។ |

| | |
|---|---|
| | **វិធានការដោះស្រាយ ៖**<br>(១). ក្រសួងមុខងារសាធារណៈសហការជាមួយនឹងក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ពន្លឿនការផ្សព្វផ្សាយអនុក្រឹត្យលេខ ៧៦ ស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុកមានមូលដ្ឋានក្នុងការកំណត់ប្រភេទមុខតំណែងវិជ្ជាជីវៈ និងចំនួនបុគ្គលិកតាមមុខតំណែងវិជ្ជាជីវៈនីមួយៗដែលត្រូវការជាក់ស្តែងពិតប្រាកដផ្អែកលើមុខងារជាក់លាក់ ទំហំការងារ តម្រូវការសេវា និងសក្តានុពលសេដ្ឋកិច្ចនៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗ ព្រមទាំងរៀបចំផែនការបុគ្គលិកឱ្យបានច្បាស់លាស់។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវរួមគ្នាធ្វើការសិក្សា និងពិនិត្យមើលឡើងវិញនូវស្ថានភាពនិងតម្រូវការមន្ត្រីជាក់ស្តែង ផ្អែកទៅតាមមុខងារជាក់លាក់ និងជាវិធានការចំពោះមុខ ត្រូវពង្រឹងការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីដែលមានស្រាប់ ដើម្បីបំពេញការងារជាមួយនឹងការពង្រឹងសមត្ថភាពដល់មន្ត្រីទាំងនោះ។<br>(២). ចំពោះការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្នើឱ្យមានកិច្ចសហការគ្នារវាងសាលាភូមិន្ទរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ដើម្បីពិភាក្សាគ្នាអំពីវិធីសាស្រ្ត និងកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីជំនាញនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២ | **– ស្នើសុំឱ្យមានប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីបំពេញការងារនៅរដ្ឋបាលក្រុង ស្រុក ជាពិសេសនៅស្រុកជនបទ។**<br>**ដំណើររឿង៖** ការខ្វះចំនួនបុគ្គលិកជំនាញវិជ្ជាជីវៈពិតប្រាកដសម្រាប់អនុវត្តមុខងារតាមវិស័យជាអាទិភាពនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក គឺជាបញ្ហាចម្បងដែលត្រូវបានលើកឡើងស្ទើរគ្រប់រដ្ឋបាលក្រុង ស្រុកទាំងអស់។ ផ្អែកតាមការវិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការរហូតមកដល់បច្ចុប្បន្ន មានមុខងារ ធនធាន និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែច្រើនឡើងៗត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក។ ក្នុងពេលដែលបន្ទុកការងារកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ក៏ប៉ុន្តែប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិកដែលបំពេញការងារនៅរដ្ឋបាលក្រុង ស្រុកពុំទាន់ត្រូវបានពិនិត្យ និងកែសម្រួលឱ្យស្របទៅនឹងបន្ទុកការងារ និងដើម្បីលើកទឹកចិត្តឱ្យបុគ្គលិកដែលមានសមត្ថភាព មានជំនាញវិជ្ជាជីវៈខ្ពស់ៗ និងបទពិសោធន៍ការងារចង់ទៅបម្រើការងារនៅរដ្ឋបាលក្រុង ស្រុកនៅឡើយ ជាពិសេសនៅតាមស្រុកដែលស្ថិតនៅតំបន់ជនបទ និងតំបន់ជួបការ |

| | |
|---|---|
| | លំបាក ដោយសារមានការលើកឡើងថា កម្រិតនៃក្របខ័ណ្ឌ ឋានន្តរស័ក្តិ មុខតំណែង ប្រាក់បំណាច់មុខងារមានកម្រិតទាបជាងនៅថ្នាក់ខេត្ត និងនៅថ្នាក់ជាតិ និងពុំមានប្រាក់ឧបត្ថម្ភលើកទឹកចិត្តបន្ថែម។<br>**វិធានការដោះស្រាយ ៖** ពាក់ព័ន្ធនឹងសំណើខាងលើនេះ ការគិតគូរអំពីប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិកបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅរដ្ឋបាលក្រុង ស្រុក ក៏ត្រូវបានកំណត់នៅក្នុងកម្មវិធីជាតិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដំណាក់កាលទី២ រួចហើយ ហើយក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភានេះ ក៏ត្រូវបានគិតគូរអំពីប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មផងដែរ។ អាស្រ័យហេតុនេះ ស្នើឱ្យមន្ត្រីបច្ចេកទេសនៃក្រសួងមុខងារសាធារណៈ សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំការសិក្សាអំពីជម្រើសនានាក្នុងការលើកទឹកចិត្តទាំងកម្រិតនៃឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ ប្រាក់លើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម និងការផ្តល់គ្រឿងឥស្សរិយយសជាដើម ដើម្បីជំរុញបុគ្គលិកឱ្យស្ម័គ្រចិត្តទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសតំបន់ជនបទ។ ការងារនេះក៏ជួយក្នុងការទាក់ទាញ និងពង្រាយបុគ្គលិកពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមានបុគ្គលិកច្រើនឱ្យទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតំបន់ជនបទដែលខ្វះបុគ្គលិក។ |
| ៣ | – **ស្នើសុំពន្លឿនការរៀបចំនីតិវិធីនៃការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សា ព្រមទាំងការកំណត់ឱ្យបានច្បាស់លាស់អំពីនីតិវិធី គោលការណ៍នៃការជ្រើសរើសគ្រូជាប់កិច្ចសន្យានៅសាលាបឋមសិក្សា និងមត្តេយ្យសិក្សា។**<br>**ដំណើររឿង ៖** កន្លងមក ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សា ត្រូវធ្វើឡើងដោយដីការបស់អភិបាលក្រុង ស្រុកសាមីនីមួយៗ។ ការអនុវត្តជាក់ស្តែង ការជ្រើសរើស និងការតែងតាំងនាយកមួយចំនួនក៏មិនទាន់ជ្រើសរើសបាននាយកល្អដើម្បីដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាពក្នុងការដឹកនាំ និងអភិវឌ្ឍសាលារៀន ឆ្លើយតបទៅនឹងកំណែទម្រង់គន្លឹះក្នុងវិស័យអប់រំ។ អាស្រ័យហេតុនេះ **សម្តេចមហាបវរធិបតី** បានផ្តល់ជាអនុសាសន៍ណែនាំឱ្យមានការគិតគូរអំពីការតែងតាំងនាយកសាលាបឋមសិក្សា និងសាលាមត្តេយ្យសិក្សាត្រូវធ្វើឡើងដោយដីការបស់អភិបាលរាជធានី ខេត្ត ដើម្បីធានាដល់ការជ្រើសរើសបាននាយកល្អដែលមានសមត្ថភាព មានគំនិតផ្តួចផ្តើមក្នុងការដឹកនាំសាលា និងមានមនសិការវិជ្ជាជីវៈខ្ពស់ និងប្រកបដោយតម្លាភាព។ ពាក់ព័ន្ធនឹងកិច្ចការនេះ គឺចាំបាច់ត្រូវ |

| | |
|---|---|
| | មានការសិក្សា និងកែតម្រូវលិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួន រួមមាន ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យ និងសេចក្ដីណែនាំបច្ចេកទេសជាដើម ហើយកិច្ចការនេះក៏បាន និងកំពុងរៀបចំដោយមានកិច្ចសហការគ្នារវាងក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.។<br>**វិធានការដោះស្រាយ** ៖ មកដល់ពេលនេះ ព្រះរាជក្រឹត្យស្ដីពីការកែសម្រួលលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សាត្រូវបានដាក់ចេញថ្មីៗនេះ។ ដូចនេះ ជាវិធានការបន្ត គឺរៀបចំការផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលដល់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តនៅដើមឆ្នាំ២០២៥នេះ។ |
| ៤ | – **ការភ្ជាប់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំជាមួយនឹងរដ្ឋបាលក្រុង ស្រុក។**<br>**ដំណើររឿង** ៖ រដ្ឋបាលក្រុង ស្រុកត្រូវបានចាត់ទុកថាជាថ្នាក់រដ្ឋបាលដែលមានតួនាទី ភារកិច្ច មុខងារ និងមន្ត្រីជំនាញតាមវិស័យនានាសម្រាប់ការគាំទ្រ និងផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសជូនដល់ប្រជាពលរដ្ឋ។ នាពេលបច្ចុប្បន្ននេះ រដ្ឋបាលក្រុង ស្រុក បាននិងកំពុងជួបបញ្ហាប្រឈម គឺការខ្វះមន្ត្រីជំនាញសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យ ជាពិសេសការិយាល័យកសិកម្មក្រុង ស្រុកកំពុងមានតម្រូវការចាំបាច់នូវមន្ត្រីជំនាញដូចជា ជំនាញក្សេត្រសាស្ត្រ បសុព្យាបាល ផ្សព្វផ្សាយកសិកម្ម គ្រឿងយន្តកសិកម្ម ជាដើម ដើម្បីធានាឱ្យការិយាល័យនេះអាចបំពេញតួនាទីគាំទ្រដល់កសិករនៅតាមភូមិ ឃុំក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបាននិងកំពុងជ្រើសរើស និងពង្រាយមន្ត្រីកសិកម្មនៅតាមឃុំ សង្កាត់នីមួយៗ។ ក្នុងន័យនេះ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការគាំទ្រ និងការប្រើប្រាស់មន្ត្រីកសិកម្មទាំងនេះ និងដោះស្រាយនូវបញ្ហាកង្វះមន្ត្រីជំនាញកសិកម្មនៅថ្នាក់ក្រុង ស្រុក រដ្ឋបាលក្រុង ស្រុកបានស្នើសុំឱ្យពិចារណាភ្ជាប់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំជាមួយនឹងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាននៃរដ្ឋបាលក្រុង ស្រុក ដើម្បីងាយស្រួលក្នុងការសម្របសម្រួលផ្ដល់ការគាំទ្រ និងការផ្សព្វផ្សាយបច្ចេកទេសកសិកម្មជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសន្សំសំចៃ។ |

| | |
|---|---|
| | **វិធានការដោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ ក្រសួងមុខងារសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរួមគ្នាសិក្សា និងលើកយោបល់អំពីការរៀបចំឱ្យមានប្រព័ន្ធការងារមួយដែលផ្សារភ្ជាប់គ្នារវាងមន្ត្រីកសិកម្មឃុំ ជាមួយនឹងការិយាល័យកសិកម្ម ធនធានធម្មជាតិ រដ្ឋបាលស្រុក និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានមូលដ្ឋានក្នុងការលើកយោបល់ជូន**សម្តេចធិបតី នាយករដ្ឋមន្ត្រី** ពិនិត្យ និងសម្រេច។ |
| ៥ | **– ខ្វះមន្ត្រីនៅតាមទីចាត់ការមួយចំនួន និងខ្វះមន្ត្រីបច្ចេកទេស (ជំនាញសំណង់ស៊ីវិល និងវិស្វករ) សម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ លើការងារសិក្សា រៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម និងការរៀបចំផែនការអភិវឌ្ឍន៍... (ស្នើដោយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់)។**<br><br>**ដំណើររឿង** ៖ ធនធានឆន្ទានុសិទ្ធិ ជាពិសេសមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុកដើម្បីប្រើប្រាស់សម្រាប់រៀបចំ និងអនុវត្តគម្រោងនានា រួមមានទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសេវាកម្មដែលឃុំ សង្កាត់ និងក្រុង ស្រុកនីមួយៗ ត្រូវរៀបចំ និងអនុវត្តក្នុងឆ្នាំនីមួយៗ។ ការរៀបចំ និងអនុវត្តគម្រោងទាំងនេះចាំបាច់ត្រូវមានការសិក្សាលទ្ធភាពគម្រោង ការសិក្សាផលប៉ះពាល់បរិស្ថាននិងសង្គម ការរៀបចំប្លង់គម្រោង និងការសិក្សាលក្ខណៈបច្ចេកទេសលើចំណុចសំខាន់ៗជាច្រើនផ្សេងទៀត។ ផ្អែកតាមតម្រូវការជាក់ស្តែង បើប្រៀបធៀបទៅនឹងសមត្ថភាព និងលទ្ធភាពគាំទ្រផ្នែកបច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្ត គឺនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកដែលត្រូវការរៀបចំ និងអនុវត្តគម្រោងតាមឆ្នាំនីមួយៗប្រកបដោយប្រសិទ្ធភាពបានឡើយ ដោយសារកង្វះមន្ត្រីបច្ចេកទេស និងសមត្ថភាពគាំទ្របច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ នៅតាមទីចាត់ការមួយចំនួនក៏មានការខ្វះមន្ត្រីមួយចំនួនបើធៀបទៅនឹងទំហំការងារ និងតួនាទីភារកិច្ចរបស់ទីចាត់ការនីមួយៗ។<br><br>**វិធានការដោះស្រាយ** ៖ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. រួមគ្នាសិក្សា និងកំណត់អំពីមុខតំណែងវិជ្ជាជីវៈឱ្យបានច្បាស់លាស់តាមអង្គភាពនីមួយៗនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីមានមូលដ្ឋានកំណត់អំពី |

តម្រូវការធនធានមនុស្សជាក់ស្តែងឆ្លើយតបទៅនឹងមុខងារនិងតួនាទីភារកិច្ចរបស់អង្គភាពនីមួយៗ។ ជាវិធានការចំពោះមុខត្រូវពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីដែលមានស្រាប់ ដើម្បីបំពេញការងារជាមួយនឹងការពង្រឹងសមត្ថភាពដល់មន្ត្រីទាំងនោះ។

*****

- **ខ្វះមន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកធៀបនឹងស្តង់ដាកំណត់ និងតម្រូវការសេវាជាក់ស្តែង**
- **ស្នើសុំផ្តល់ចំនួនក្របខ័ណ្ឌថ្មីឱ្យស្របទៅនឹងចំនួនក្របខ័ណ្ឌដែលបានបាត់បង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។**

**ដំណើររឿង៖** មុខងារសុខាភិបាលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តនាដើមឆ្នាំ២០២០ ដែលការផ្ទេរមុខងារនេះ ក៏បានផ្ទេរទៅជាមួយនូវបុគ្គលិកសុខាភិបាល (គ្រូពេទ្យ) ចំនួនប្រមាណជាង២០.០០០នាក់ ទៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត។ រហូតមកដល់ចុងឆ្នាំ២០២៤នេះ រដ្ឋបាលរាជធានី ខេត្តបានលើកឡើងនូវបញ្ហាប្រឈមពាក់ព័ន្ធទៅនឹងការខ្វះមន្ត្រីសុខាភិបាលបម្រើការងារនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក បើប្រៀបធៀបទៅនឹងស្តង់ដាកំណត់ និងតម្រូវការនៃការផ្តល់សេវាជាក់ស្តែង ដែលបានស្នើសុំឱ្យមានការបន្ថែមបុគ្គលិកសុខាភិបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកដែលមានការខ្វះខាត។

**វិធានការដោះស្រាយ ៖** ពាក់ព័ន្ធទៅនឹងការខ្វះមន្ត្រីសុខាភិបាលតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនេះ កន្លងមកនេះ ក្រសួងសុខាភិបាលបានលើកផែនការស្នើសុំមកក្រសួងមុខងារសាធារណៈ ហើយបានឯកភាពគ្នាដោយលើកសំណើសុំគោលការណ៍ទៅ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ហើយក៏ទទួលបានការឯកភាពជាគោលការណ៍រួចហើយពី **សម្តេចធិបតី** ក្នុងការជ្រើសរើសមន្ត្រីសុខាភិបាលបន្ថែមចំនួន**ជាង ១.០០០នាក់** សម្រាប់ឆ្នាំ២០២៥-២០២៦។ ដូច្នេះ បញ្ហាសំណើសំណូមពរនេះ ត្រូវបាននិងកំពុងដោះស្រាយ។

*****

- **ស្នើសុំឱ្យមានការប្រឡងផ្ទៃក្នុងប្តូរប្រភេទក្របខ័ណ្ឌ ដើម្បីជាការលើកទឹកចិត្តដល់មន្ត្រីដែលបានខិតខំបំពេញការងារ។**

**ដំណើររឿង ៖** ការប្រឡងផ្ទៃក្នុងដើម្បីផ្លាស់ប្តូរក្របខ័ណ្ឌត្រូវបានផ្អាកជាច្រើនឆ្នាំមកហើយ។ ករណីនេះ ដើម្បីជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកដែលបានខិតខំរៀនសូត្រទទួលបានសញ្ញាបត្រខ្ពស់ និងមានជំនាញវិជ្ជាជីវៈច្បាស់លាស់ រដ្ឋបាលថ្នាក់ក្រោមជាតិស្នើសុំឱ្យមានការប្រឡងប្រជែងផ្ទៃក្នុង ដើម្បីផ្លាស់ប្តូរក្របខ័ណ្ឌ។

| | |
|---|---|
| | **វិធានការដោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ ស្នើឱ្យមន្ត្រីបច្ចេកទេសនៃក្រសួងមុខងារសាធារណៈធ្វើការសិក្សា និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈពិនិត្យ និងសម្រេច។ |
| ៦ | **– ស្នើសុំឱ្យមានប្រព័ន្ធវាយតម្លៃផ្អែកលើសមិទ្ធកម្មសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។**<br>**ដំណើររឿង** ៖ បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើលទ្ធផលបំពេញការងារឱ្យបានច្បាស់លាស់នៅឡើយ ទាំងលើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ និងការតែងតាំង... (យន្តការ នីតិវិធី លក្ខណៈវិនិច្ឆ័យ/សូចនាករ)។ ក្នុងន័យនេះ ដើម្បីធានារដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងបុគ្គលិកប្រកបដោយប្រសិទ្ធភាព តម្លាភាព ត្រឹមត្រូវ យុត្តិធម៌ និងមានការលើកទឹកចិត្តចំពោះបុគ្គលិកដែលខិតខំប្រឹងប្រែងបំពេញការងារ ព្រមទាំងលើកកម្ពស់ការប្រកួតប្រជែងក្នុងការបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានស្នើសុំឱ្យមានប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្មឱ្យបានច្បាស់លាស់។<br>**វិធានការដោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ កម្មវិធីជាតិដំណាក់កាលទី២ និងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ បានកំណត់ឱ្យមានការរៀបចំប្រព័ន្ធវាយតម្លៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើសមិទ្ធកម្ម តាមរយៈការរៀបចំឱ្យមានការពិពណ៌នាមុខតំណែង ប្រព័ន្ធគ្រប់គ្រងវត្តមាន ក្រមសីលធម៌វិជ្ជាជីវៈ ជាពិសេសគឺការរៀបចំឱ្យមានលក្ខខណ្ឌការងារច្បាស់លាស់(ការទទួលខុសត្រូវ លទ្ធផលរំពឹងទុក សូចនាករ ចំណុចដៅ និងក្របខ័ណ្ឌពេលវេលា...)សម្រាប់បុគ្គលិកម្នាក់ៗ ដើម្បីធ្វើជាមូលដ្ឋាននៃការវាយតម្លៃបុគ្គលិកផ្អែកលើលទ្ធផលបំពេញការងារសម្រាប់ការឡើងថ្នាក់ ឋានន្តរស័ក្តិ ការតែងតាំង ការលើកទឹកចិត្ត ការអភិវឌ្ឍសមត្ថភាព និងការដាក់វិន័យជាដើម។ អាស្រ័យហេតុនេះ ស្នើឱ្យមន្ត្រីបច្ចេកទេសនៃក្រសួងមុខងារសាធារណៈសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្មនេះ ដើម្បីស្នើសុំការពិនិត្យសម្រេចពីថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាលនៅក្នុងឆ្នាំ២០២៥នេះ។ |

| | |
|---|---|
| ៧ | **– ស្នើសុំរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ជាតិ។**<br><br>**ដំណើររឿង ៖** គិតមកដល់បច្ចុប្បន្ននេះ បុគ្គលិកប្រមាណជាង១០ម៉ឺននាក់ត្រូវបានផ្ទេរទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងបុគ្គលិក គឺជាបន្ទុកការងារច្រើន រួមមានដូចជា ការជ្រើសរើស ការតែងតាំង ការឡើងថ្នាក់ ឋានន្តរស័ក្តិ ការរៀបចំបញ្ជីបៀវត្សរ៍ ការគ្រប់គ្រងវត្តមាន និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងទៀតរបស់បុគ្គលិក ដែលកិច្ចការទាំងនោះតម្រូវឱ្យមានការគ្រប់គ្រង និងការចាត់ចែងប្រកបដោយភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌។ ក្នុងន័យនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងបុគ្គលិក ចាំបាច់ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលអាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅថ្នាក់ជាតិផងដែរ។<br><br>**វិធានការដោះស្រាយ ៖** ពាក់ព័ន្ធនឹងសំណើនេះ បច្ចុប្បន្ន ក្រសួងមុខងារសាធារណៈបាននិងកំពុងរៀបចំថ្នាលព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យមន្ត្រីរួមដែលមានមុខងារទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកឱ្យស្ថិតក្នុងប្រព័ន្ធតែមួយ ដោយកំពុងធ្វើសមាហរណកម្មទិន្នន័យពីប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រី (HRMIS) ប្រព័ន្ធគ្រប់គ្រងបៀវត្សរ៍ និងប្រព័ន្ធរណបផ្សេងៗទៀត។ នៅពេលធ្វើសមាហរណកម្មទិន្នន័យពីប្រព័ន្ធនានាចូលក្នុងថ្នាលព័ត៌មានវិទ្យាគ្រប់គ្រងមន្ត្រីរួម និងបានកែលម្អមុខងារគ្រប់គ្រងធនធានមនុស្សក្នុងប្រព័ន្ធនេះរួចរាល់ ក្រសួងស្ថាប័នថ្នាក់ជាតិ និងរាជធានី ខេត្តអាចប្រើប្រាស់ប្រព័ន្ធនេះបានក្នុងការគ្រប់គ្រង ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសារមន្ត្រីការវិវឌ្ឍន៍អាជីពមន្ត្រីរាជការរហូតដល់ចូលនិវត្តន៍។ ដូច្នេះ សំណើនេះត្រូវបាននិងកំពុងដោះស្រាយជាបណ្តើរៗហើយ។ |

# តារាងឧបសម្ព័ន្ធទី ៦

## ការផ្តល់យោបល់របស់អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុនៃ គ.ជ.អ.ប.

## លើវិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពរនានា ដែលលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

<table>
<tr><th>ល.រ</th><th>បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ</th></tr>
<tr><td>១</td><td>– សុំឱ្យមានប្រព័ន្ធលើកទឹកចិត្តដល់សមាជិកក្រុមប្រឹក្សា៖<br>▪ ប្រាក់សោធននិវត្តន៍សម្រាប់សមាជិកក្រុមប្រឹក្សាដែលបានជាប់ឆ្នោតលើសពី៣ អាណត្តិឡើង<br>▪ ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សាជាស្ត្រី។<br><br>ដំណើររឿង ៖ ការស្នើសុំឱ្យមានប្រព័ន្ធលើកទឹកចិត្តនេះ គឺដើម្បីឱ្យសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនមែនជាអតីតមន្ត្រីរាជការ គឺជាប្រជាពលរដ្ឋសុទ្ធសាធដែលបានជាប់ក្នុងការបោះឆ្នោតជាសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនអាណត្តិ(៣អាណត្តិ) ដើម្បីឱ្យទទួលបានប្រាក់គាំពារសង្គម និងប្រាក់លើកទឹកចិត្តនៅពេលដែលបញ្ចប់ការងារដោយសារហេតុផលសុខភាព ចាស់ជរា ឬដោយសារមូលហេតុផ្សេងទៀត។ ករណីនេះ ចំពោះបុគ្គលិកដែលបម្រើការងារនៅតាមវិស័យផ្សេងៗសុទ្ធតែមានការគិតគូរអំពីការឧបត្ថម្ភគាំទ្រសង្គមនៅពេលបាត់បង់ការងារ ដូចជាកម្មករបម្រើការងាររោងចក្រ និងតាមសិប្បកម្មវិស័យឯកជនជាដើម។ ជាមួយគ្នានេះ បទពិសោធន៍នៃប្រទេសនានាដូចជាប្រទេសឥណ្ឌូនេស៊ីក៏ត្រូវបានផ្តល់ការឧបត្ថម្ភគាំទ្រសង្គមនេះ ចំពោះសមាជិកក្រុមប្រឹក្សាណាដែលបំពេញការងារបាន ១អាណត្តិផងដែរ។<br><br>សំណើដំណោះស្រាយ៖<br>▪ ឯកភាពជាគោលការណ៍។ ស្នើឱ្យមានការសិក្សាឱ្យបានម៉ត់ចត់ ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ រួមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ, ក្រសួងមុខងារសាធារណៈ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារ</td></tr>
</table>

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | សង្គម ដើម្បីពិនិត្យលទ្ធភាព និងសុំគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាលដើម្បីចាប់ផ្ដើមអនុវត្តចាប់ពីឆ្នាំ២០២៧។ លើសពីនេះ ក៏ត្រូវមានការគិតគូរប្រៀបធៀបជាមួយគោលការណ៍ប្រាក់សោធននិវត្តន៍របស់មន្ត្រីរាជការស៊ីវិល និងបន្ទុកចំណាយថវិការដ្ឋ<br>– សម្រាប់មន្ត្រីរាជការ, អតីតភាពការងារលើសពី៣០ឆ្នាំ ស្មើនឹង៨០% និងលើសពី២០ឆ្នាំ ស្មើនឹង៦០%<br>– ឃុំ សង្កាត់មានចំនួនសរុប ១,៦៥២ និងមានក្រុមប្រឹក្សាសរុប ចំនួន ១១,៦២២នាក់ ក្នុងនោះ៖<br>+ ជាមន្ត្រីរាជការ ទទួលបានប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា<br>+ ជាអតីតមន្ត្រីរាជការចូលនិវត្តន៍ ទទួលបានប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា<br>+ ជាប្រជាពលរដ្ឋ ទទួលបានប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាសុទ្ធសាធ<br>▪ ត្រូវសិក្សាបន្ថែមអំពីចំនួនក្រុមប្រឹក្សាដែលជាប្រជាពលរដ្ឋ ដើម្បីពិនិត្យលទ្ធភាពថវិកា ដោយសិក្សារួម ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (សរុបរួម ១៥ ៨២២រូប)ផងដែរ<br>▪ ឯកភាពជាគោលការណ៍លើសំណើផ្តល់ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សាជាស្ត្រី។ ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវធ្វើការសិក្សាអំពីបញ្ហានេះ ដោយមានកិច្ចសហការជាមួយស្ថាប័ន/អង្គភាពពាក់ព័ន្ធ ដើម្បីលើកយោបល់អំពីលទ្ធភាពនៃការចាប់ផ្ដើមអនុវត្តពីឆ្នាំ២០២៥នេះ ឬដើមឆ្នាំ២០២៦។ |
| ២ | **សុំថ្នាក់ជាតិដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែដល់មេភូមិ អនុភូមិ ជំនួយការភូមិ។**<br>**ដំណើររឿង** ៖ ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំភូមិត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០០៤ ស.ណ.ន. ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ក្នុងនោះ មេភូមិត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងចំណោមបេក្ខជនឈរឈ្មោះ ដែលស្នើឡើងដោយមេឃុំ ចៅសង្កាត់ ចៅសង្កាត់រង និងជំទប់ ហើយអនុប្រធានភូមិ និងសមាជិកភូមិត្រូវបានបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងចំណោមបេក្ខជនឈរឈ្មោះដែលស្នើឡើងដោយមេភូមិ និងមេឃុំ ឬចៅសង្កាត់។ ផ្អែកតាមសេចក្តីណែនាំថ្នាក់ដឹកនាំភូមិទាំង៣រូបនេះ ត្រូវបានកំណត់លក្ខណសម្បត្តិត្រឹមតែចេះអាន និងសរសេរ និងពុំមានកំណត់អាយុ ឬអាណត្តិការងារនោះទេ ដែលជាហេតុធ្វើឱ្យមានការលំបាក |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
| --- | --- |

ក្នុងការផ្លាស់ប្តូរថ្នាក់ដឹកនាំភូមិ ជាពិសេសថ្នាក់ដឹកនាំភូមិភាគច្រើនមានវ័យចំណាស់ និងសមត្ថភាពធ្វើការងារមានកម្រិត។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងការធ្វើគណនេយ្យភាពរបស់ថ្នាក់ដឹកនាំភូមិចំពោះប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំ សង្កាត់មួយចំនួនបានស្នើសុំកែសម្រួលគោលការណ៍ នីតិវិធី និងលក្ខណសម្បត្តិនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិដូចខាងលើ និងស្នើសុំពិចារណាការដំឡើងប្រាក់ឧបត្ថម្ភដល់ថ្នាក់ដឹកនាំភូមិផងដែរ។

ប្រាក់ឧបត្ថម្ភបច្ចុប្បន្ន

| ប្រាក់ឧបត្ថម្ភ | ២០២៤ | កើន | ២០២៥ |
| --- | --- | --- | --- |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ ៦៥០ ០០០៛ | ៣៥,០០០៛ | ១ ៦៨៥ ០០០៛ |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ១ ២៤៥ ០០០៛ | ៣៥,០០០៛ | ១ ២៨០ ០០០៛ |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ១ ៣៦៥ ០០០៛ | ៣០,០០០៛ | ១ ៣៩៥ ០០០៛ |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ១ ០២០ ០០០៛ | ៣០,០០០៛ | ១ ០៥០ ០០០៛ |
| មេឃុំ ចៅសង្កាត់ | ១ ៣២០ ០០០៛ | ២៥,០០០៛ | ១ ៣៤៥ ០០០៛ |
| ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ | ៩៨០ ០០០៛ | ២៥,០០០៛ | ១ ០០៥ ០០០៛ |
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ៨៧០ ០០០៛ | ២៥,០០០៛ | ៨៩៥ ០០០៛ |
| មេភូមិ | ៥៥០ ០០០៛ | ២០,០០០៛ | ៥៧០ ០០០៛ |
| អនុប្រធានភូមិ | ៤៣០ ០០០៛ | ១៥,០០០៛ | ៤៤៥ ០០០៛ |
| សមាជិកភូមិ | ៤០០ ០០០៛ | ១៥,០០០៛ | ៤១៥ ០០០៛ |

- ធៀបឆ្នាំ២០១៩, សម្រាប់ឆ្នាំ២០២៥៖ ប្រាក់ឧបត្ថម្ភមេភូមិ កើន ៣២.៥%, អនុប្រធានភូមិ កើន ៤៣% និងសមាជិកភូមិ កើន ៤៨%
- ចំនួនសមាជិកភូមិនៅទូទាំងប្រទេសសរុប ៤៣,៧៤៣នាក់
- ទំហំធនធានថវិកានៅរដ្ឋបាលឃុំ សង្កាត់ នៅមានកម្រិត

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | – ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ គួរទទួលបាននៅក្នុងរង្វង់មិនឱ្យខ្ពស់ជាងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងផ្អែកលើទំហំការងារនៅមូលដ្ឋានភូមិ នៃឃុំ សង្កាត់នីមួយៗ<br>– មន្ត្រីភូមិ ទទួលបានការដំឡើងប្រាក់ឧបត្ថម្ភជាបន្តបន្ទាប់រៀងរាល់ឆ្នាំ ក្នុងកម្រិតមួយសមស្រប តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល *(ខ្ពស់ជាងអត្រាអតិផរណាបន្តិច)*<br><br>**សំណើដំណោះស្រាយ ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងសិក្សាលើលទ្ធភាពនៃការដំឡើងប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិ ដោយកំណត់យកពិដាននៃប្រាក់ឧបត្ថម្ភមេភូមិ ប្រហាក់ប្រហែលនឹងបុគ្គលិកជាប់កិច្ចសន្យា (បច្ចុប្បន្នស្មើនឹង ៧៩០.០០០រៀល) ហើយអនុប្រធានភូមិ និងសមាជិកភូមិ ត្រូវគិតគូរក្នុងគម្លាតពីមេភូមិក្នុងកម្រិតសមស្របណាមួយ។ ជាមួយគ្នានេះ ត្រូវគិតគូរអំពីរយៈពេលនៃការបង្កើនប្រាក់ឧបត្ថម្ភមេភូមិឱ្យស្មើពិដានបុគ្គលិកកិច្ចសន្យាក្នុងរយៈពេលណាមួយសមស្រប (៣ឆ្នាំទៅ៥ឆ្នាំ) ដែលអាចនឹងចាប់ផ្តើមអនុវត្តពីឆ្នាំ២០២៦ ទៅដល់ឆ្នាំ២០២៨ ឬពីឆ្នាំ២០២៧ ទៅដល់ឆ្នាំ២០៣០។ ជាមួយគ្នានេះ ក៏ត្រូវគិតអំពីលទ្ធភាពនៃការបង្កើនថវិការបស់ឃុំ សង្កាត់ដែរ ដើម្បីរ៉ាប់រងលើការចំណាយប្រាក់ឧបត្ថម្ភនេះ។ |
| ៣ | **ស្នើសុំពិចារណាបែងចែកថវិកាឃុំ សង្កាត់ទៅតាមស្ថានភាពភូមិសាស្ត្រ (សម្រាប់ឃុំដែលមានក្រឡាផ្ទៃដីធំ ឃុំដាច់ស្រយាលគួរមានប្រាក់ចំណាយប្រតិបត្តិការរដ្ឋបាល ឬបេសកកម្មច្រើនជាងឃុំ សង្កាត់ដែលមានក្រឡាផ្ទៃដីតូច)។**<br><br>**ដំណើររឿង ៖** កន្លងមកនេះ ការបែងចែកថវិកាសម្រាប់ប្រតិបត្តិការរដ្ឋបាលទៅឱ្យរដ្ឋបាលឃុំ សង្កាត់ គឺប្រើប្រាស់នូវសូចនាករចំនួន២គឺ (១).ចំណែកស្មើគ្នា (២).ចំនួនសមាជិកក្រុមប្រឹក្សា។ ទោះជាយ៉ាងណា ការប្រើប្រាស់សូចនាករទាំង២នេះ នៅមិនទាន់បានឆ្លុះបញ្ចាំងអំពីស្ថានភាពនៃតម្រូវការចំណាយប្រតិបត្តិការរដ្ឋបាលជាក់ស្តែងនៅឡើយ ដែលប្រការនេះរដ្ឋបាលឃុំ សង្កាត់ស្នើសុំឱ្យការពិនិត្យឡើងវិញនូវរបៀបនៃការវិភាជន៍ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាលនៃមូលនិធិឃុំ សង្កាត់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗឱ្យបានសមស្របទៅតាមស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **សំណើដំណោះស្រាយ៖**<br>– អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ ចំណាយរដ្ឋបាលត្រូវបានកំណត់មិនឱ្យលើសពី ១៧% នៃមូលនិធិសរុប ដកបន្ទុកបុគ្គលិក (បន្តអនុវត្តពីអនុក្រឹត្យមុន) និងវិភាជន៍តាមគោលការណ៍ចំណែកស្មើគ្នា (៤០%) និងចំនួនក្រុមប្រឹក្សា (៦០%) (ចំនួនក្រុមប្រឹក្សានេះ ក៏បានគិតគូរផ្អែកលើចំនួនប្រជាពលរដ្ឋនៅឃុំ សង្កាត់)។ ការគិតគូរនៅពេលនោះ គឺមានការឯកភាពគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដើម្បីធានាឱ្យបាននូវការចំណាយអភិវឌ្ឍន៍ឃុំ សង្កាត់នីមួយៗ ត្រូវបង្កើនឱ្យដល់ ១០ម៉ឺនដុល្លារអាមេរិក ចាប់ពីឆ្នាំ២០២៤ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល<br>– អនុក្រឹត្យលេខ១៥៣ មានថេរវេលារយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨<br>– ***ដូច្នេះ នៅពេលរៀបចំអនុក្រឹត្យថ្មី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយក្រសួងមហាផ្ទៃ នឹងពិនិត្យឡើងវិញនៅសមាសភាគវិភាជន៍ថវិកាឱ្យបានសមស្របនឹងស្ថានភាពភូមិសាស្ត្រនៅមូលដ្ឋាន និងការរីកចម្រើននៃសង្គមសេដ្ឋកិច្ច*** |
| ៤ | **ស្នើសុំឱ្យមានថវិកាគាំទ្រសមស្របសម្រាប់ការអនុវត្តមុខងារជាភ្នាក់ងារ (ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជនរងហានិភ័យ និងជនមានពិការភាព និងការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព...)។**<br>**ដំណើររឿង ៖** សព្វថ្ងៃនេះ រដ្ឋបាលឃុំ សង្កាត់ត្រូវបានស្នើឱ្យចូលរួមគាំទ្រ និងអនុវត្តកិច្ចការជាច្រើនរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ដែលរួមមានដូចជាការងារការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជនងាយរងគ្រោះ ការផ្សព្វផ្សាយ និងការអនុវត្តគោលនយោបាយភូមិឃុំ សង្កាត់មានសុវត្ថិភាពជាដើម។ ទោះយ៉ាងណា ការអនុវត្តការងារដូចបានរៀបរាប់ខាងលើនេះមិនបានផ្តល់នូវថវិកាគាំទ្រសមស្របឡើយ។ ក្នុងន័យនេះ ឃុំ សង្កាត់ស្នើសុំឱ្យមានការគាំទ្រថវិកា និងសមត្ថភាពឱ្យបានសមស្របសម្រាប់ការអនុវត្តមុខងារជាភ្នាក់ងារដែលបានធ្វើប្រតិភូកម្មដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **សំណើដំណោះស្រាយ៖**<br>– ឆ្នាំកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងផ្តល់ថវិកា សម្រាប់ក្រសួងពាក់ព័ន្ធអនុវត្តការងារ *ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជនរងហានិភ័យ និងជនមានពិការភាព និងការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព...*<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលយកសំណើនេះ ពិនិត្យសិក្សាផ្ទៀងផ្ទាត់ជាមួយក្រសួងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គម អំពីយន្តការការងារ និងការចំណាយថវិកាលើមុខងារនេះ<br>– ជាមួយគ្នានេះផងដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសិក្សារៀបចំយន្តការ និងក្របខ័ណ្ឌគតិយុត្ត ស្តីពីការអនុវត្តថវិកាមុខងារជាភ្នាក់ងារ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (ចែងក្នុងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ) |
| ៥ | **មុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលឃុំ សង្កាត់ពុំមានផ្ទេរមកជាមួយនូវធនធានហិរញ្ញវត្ថុ (មុខងារវិស័យសង្គមកិច្ច៖ សេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះ....)។**<br>**ដំណើររឿង** ៖ មុខងារថែទាំកុមាររងគ្រោះ និងងាយរងគ្រោះត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់តាមអនុក្រឹត្យលេខ៣៤ (ឆ្នាំ២០១៥) ប៉ុន្តែពុំបានផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលឃុំ សង្កាត់ ដោយហេតុថាកិច្ចការនេះត្រូវបានអនុវត្តដោយឃុំ សង្កាត់តាំងពីមុនការផ្ទេរជាផ្លូវការមកឱ្យឃុំ សង្កាត់។ បច្ចុប្បន្នឃុំ សង្កាត់បានប្រើប្រាស់មូលនិធិរបស់ខ្លួនដើម្បីអនុវត្តការងារនេះ។ អាស្រ័យហេតុនេះ ឃុំ សង្កាត់បានស្នើសុំរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត ពិនិត្យលទ្ធភាពផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារនេះ។<br>**សំណើដំណោះស្រាយ ៖**<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ កំពុងរៀបចំសេចក្តីណែនាំរួម ស្តីពីការកំណត់មុខសញ្ញាចំណាយសេវាសង្គម ដែលគ្របដណ្តប់លើមុខសញ្ញាចំណាយទាំងនេះផងដែរ។ តួលេខចំណាយសេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ ដោយមានការបង្កើនភាគរយ |

<table>
<tr><th>ល.រ</th><th>បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ</th></tr>
<tr><td></td><td>
វិភាជន៍ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ តាមរយៈអនុក្រឹត្យលេខ១៥៣ ដែលនាំឱ្យថវិកាមានការកើនឡើងជារៀងរាល់ឆ្នាំ ដូចខាងក្រោម៖<br>
+ ថវិកាកញ្ចប់សេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ មានកំណើនជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដែលអាចរ៉ាប់រងចំណាយលើមុខសញ្ញាខាងលើនេះបាន<br>
<table>
<tr><td rowspan="2">ថវិកាសេវាសង្គម/ប្រមាណជាមធ្យមក្នុង១ឃុំ សង្កាត់</td><td>២០២៤</td><td>២០២៥</td><td>២០២៦</td><td>២០២៧</td><td>២០២៨</td></tr>
<tr><td>៤០លរ</td><td>៦៥លរ</td><td>៨៤លរ</td><td>១១៥លរ</td><td>១៥៩ លរ</td></tr>
</table>
+ *គួររៀបចំគោលការណ៍ណែនាំជាក់លាក់ (ក្នុងកម្រិតរាជរដ្ឋាភិបាល) បន្ថែមលើអនុក្រឹត្យ ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់លក្ខខណ្ឌជាក់លាក់ សម្រាប់ការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន ត្រូវមានភ្ជាប់ជាមួយធនធានសមស្របសម្រាប់អនុវត្តមុខងារដែលផ្ទេរ ជៀសវាងបង្កើនបន្ទុកចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារថ្មី។*
</td></tr>
<tr><td>៦</td><td>
**នីតិវិធីការងារ៖ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង (សវនកម្មផ្ទៃក្នុង) សម្រាប់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៅមិនទាន់បានរៀបចំ ដែលជាហេតុធ្វើឱ្យការិយាល័យនេះពុំអាចអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបាន (សំណូមពរស្នើសុំដាក់ចេញនូវនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង និងផ្តល់ការបណ្តុះបណ្តាល)។**<br>
**ដំណើររឿង** ៖ បន្ទាប់ពីការបង្កើតការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលក្រុង ស្រុក ក្រសួង ស្ថាប័នពាក់ព័ន្ធនៅពុំទាន់បានដាក់ចេញ និងផ្តល់ការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងនៅឡើយ។ ក្នុងន័យនេះ រដ្ឋបាលក្រុង ស្រុក បានស្នើឱ្យមានការរៀបចំនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង/សវនកម្មផ្ទៃក្នុង។
</td></tr>
</table>

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **សំណើដំណោះស្រាយ៖** ជំរុញក្រុមការងារបច្ចេកទេសអន្តរក្រសួងដែលបានបង្កើតរួចហើយ បន្តរៀបចំគោលការណ៍ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការិយាល័យក្រុង ស្រុកឱ្យបានលឿន។ |
| ៧ | **ថវិកាអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក មិនទាន់ឆ្លើយតបបានសមស្របនឹងតម្រូវការជាអាទិភាពជាច្រើនរបស់ប្រជាពលរដ្ឋ ដូចនេះស្នើសុំថ្នាក់ជាតិពិនិត្យលទ្ធភាពបង្កើនធនធានថវិកាផ្នែកអភិវឌ្ឍន៍ និងសេវាសង្គម... (ស្នើដោយក្រុង ស្រុក ឃុំ សង្កាត់)។** |

**ដំណើររឿង ៖** ទោះបីថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកត្រូវបានបង្កើនជាបន្តបន្ទាប់ក៏ដោយ (ឧ. ក្នុងឆ្នាំ២០០២ ឃុំ សង្កាត់នីមួយៗទទួលបានថវិកាផ្នែកអភិវឌ្ឍន៍ជាមធ្យមប្រមាណ ២.៧០០ដុល្លារ និងក្នុងឆ្នាំ២០២៤នេះ មានការកើនរហូតដល់ប្រមាណជាង១០ម៉ឺនដុល្លារក៏ដោយ ប៉ុន្តែតម្រូវការអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននៅតែមានចំនួនច្រើន លើសពីលទ្ធភាពថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក (ផ្អែកតាមគម្រោងអាទិភាពដែលបានលើកឡើងក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។

**បច្ចុប្បន្ន ចំណាយអភិវឌ្ឍន៍រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវបានបង្កើនរៀងរាល់ឆ្នាំ៖**

- កញ្ចប់ថវិកាក្រុង ស្រុកនីមួយៗសរុប ជាមធ្យម ក្នុង១ឆ្នាំ

| **បរិយាយ** | **ឆ្នាំ២០២៣** | **ឆ្នាំ២០២៤** | **ឆ្នាំ២០២៥** | **២៥/២៤** |
|---|---|---|---|---|
| **ថវិកាក្រុង ស្រុកនីមួយៗ ជាមធ្យមក្នុង១ឆ្នាំ (ដុល្លារ)** | **៤៩២ ៥០០** | **៥៨៦ ០០០** | **៦៦៤ ០០០** | **១៣.៣%** |
| *បន្ទុកបុគ្គលិក* | ២១០ ២០០ | ២៣១ ០០០ | ២២៥ ០០០ | ៩៧.៥% |
| *រដ្ឋបាល* | ៧៤ ៣០០ | ៩៦ ០០០ | ៩៦ ០០០ | - |

| ឈ.៖ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|

| | | | | |
|---|---|---|---|---|
| *សេវាសង្គម និងបរិស្ថាន* | | ២៥ ០០០ | ២៥ ០០០ | - |
| *ចំណាយអភិវឌ្ឍន៍ជាមធ្យម* | ២០៨ ០០០ | ២៣៤ ០០០ | ៣១៨ ០០០ | ៣៥.៨% |

– កញ្ចប់ថវិកាឃុំ សង្កាត់នីមួយៗសរុប ជាមធ្យម ក្នុង១ឆ្នាំ

| **បរិយាយ (ដុល្លារ)** | **ឆ្នាំ២០២៣** | **ឆ្នាំ២០២៤** | **ឆ្នាំ២០២៥** | **២៥/២៤** |
|---|---|---|---|---|
| **ថវិកាឃុំ សង្កាត់នីមួយៗ ជាមធ្យម ក្នុង ១ឆ្នាំ (ដុល្លារ)** | **១៥៦ ០០០** | **១៨៨ ០០០** | **២១០ ០០០** | **១១.៧%** |
| *បន្ទុកបុគ្គលិក* | ៥៥ ៥០០ | ៥៩ ០០០ | ៦១ ៧០០ | ៤.៥% |
| *រដ្ឋបាល* | ១២ ៥០០ | ១៦ ៣០០ | ១៩ ៧០០ | ២០.៨% |
| *សេវាអនាម័យ-បរិស្ថាន* | | ៩ ៧០០ | ១៦ ០០០ | ៦៤.៩% |
| *ចំណាយអភិវឌ្ឍន៍ជាមធ្យម* | ៨៨ ០០០ | ១០៣ ០០០ | ១១២ ៦០០ | ៩.៣% |

– រដ្ឋបាលក្រុង ស្រុក៖ បង្កើនថវិកាមូលនិធិក្រុង ស្រុក តាមរយៈការកើនឡើងនៃចំណូលចរន្តថវិកាជាតិ ពីមួយឆ្នាំទៅមួយឆ្នាំ (១,៦%) ការផ្តល់ចំណូលពីចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្តជូនរដ្ឋបាលក្រុង ស្រុក (៤%) ដែលនាំឱ្យរដ្ឋបាល ក្រុង ស្រុកបច្ចុប្បន្ននេះមានថវិកាចំណាយអភិវឌ្ឍន៍មូលប្រមាណជាមធ្យម ***៣១៨ ០០០ដុល្លារអាមេរិក***

– រដ្ឋបាលឃុំ សង្កាត់៖ បង្កើនថវិកាមូលនិធិឃុំ សង្កាត់ តាមរយៈការកើនឡើងនៃចំណូលចរន្តថវិកាជាតិ ពីមួយឆ្នាំទៅមួយឆ្នាំ (៣,៥%), ធនធានបន្ថែមនៃចំណូលចរន្តថវិកាជាតិសម្រាប់អភិវឌ្ឍន៍ (១%), ការបង្កើនចំណូលពីចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលរាជធានី ខេត្ត

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | ជូនរដ្ឋបាលឃុំ សង្កាត់រៀងរាល់ឆ្នាំ (៦%) ដែលនាំឱ្យរដ្ឋបាលឃុំ សង្កាត់បច្ចុប្បន្ននេះមានថវិកាចំណាយអភិវឌ្ឍន៍មូលប្រមាណជាមធ្យម ***១១២ ៦០០ដុល្លារអាមេរិក។***<br>**សំណើដំណោះស្រាយ ៖**<br>– រក្សាអត្រាវិភាជន៍ពីថវិការដ្ឋទៅមូលនិធិក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ តាមស្មារតីនៃអនុក្រឹត្យលេខ១៥២ និង១៥៣ ដែលបានកំណត់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨។ អត្រានេះនឹងត្រូវគិតគូរឡើងវិញចាប់ពីឆ្នាំ២០២៩<br>– ទន្ទឹមនឹងនេះ នៅពេលឆាប់ៗខាងមុខនេះ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នឹងទទួលបានធនធានបន្ថែមពីយន្តការមូលនិធិភាតរភាព ដែលប្រភពចំណូលសំខាន់ពីការផ្ទេរចំណូលពីសេវាសាធារណៈ (១៥%) និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងស្ថាប័ន។ **បច្ចុប្បន្ន សេចក្ដីព្រាងអនុក្រឹត្យស្ដីពីមូលនិធិភាតរភាព ត្រូវបានរៀបចំរួច គ្រោងប្រជុំពិភាក្សាជាមួយក្រសួងមហាផ្ទៃ និងដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥**<br>– ជាមួយគ្នានេះផងដែរ រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នឹងត្រូវបន្ថែមនូវអត្រា០,៥% ពីការបែងចែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តនៅពេលដែលរដ្ឋបាលរាជធានី ខេត្ត នឹងទទួលបានប្រភពចំណូលសំខាន់ថ្មីមួយគឺពន្ធលើប្រាក់ចំណេញមូលធន (Capital Gain Tax)។ |
| ៨ | **មិនទាន់មានធនធានថវិកាសម្រាប់អនុវត្តមុខងារ (ការអភិវឌ្ឍ និងការផ្ដល់សេវា) ដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (លើកលែងមុខងារអប់រំ យុវជន និងកីឡា)។**<br>**ដំណើររឿង** ៖ ផ្អែកតាមការធ្វើសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក (២០២០) មានមុខងារចំនួន៥៥ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ កន្លងមក រាជរដ្ឋាភិបាលបានផ្ទេរតែថវិកាសម្រាប់ប្រាក់បៀវត្សរ៍ និងប្រាក់ចំណាយប្រតិបត្តិការរដ្ឋបាល ប៉ុន្តែពុំទាន់បានផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ លើកលែងតែមុខងារវិស័យអប់រំ ដូច្នេះរដ្ឋបាលក្រុង |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | ស្រុក ខណ្ឌស្នើសុំផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរឱ្យបានសមស្របតាមស្មារតីនៃអនុក្រឹត្យ១៨២ ១៨៣ និង១៨៤។<br>**សំណើដំណោះស្រាយ៖**<br>- ក្រុមការងារអន្តរក្រសួងដែលមានសមាសភាពពី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបានបង្កើត តាមរយៈសេចក្តីសម្រេចលេខ ០៦៧ សហវ.ស.ស.រ.អហក ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងសិក្សាមុខងារ និងធនធាននៃវិស័យជំនាញទាំង២០ (មុខងារទាំង៥៥) ដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>- រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្តចំនួន៨ (រាជធានីភ្នំពេញ កណ្តាល ព្រះសីហនុ ព្រៃវែង រតនគិរី បាត់ដំបង សៀមរាប និងតាកែវ) ត្រូវបានសិក្សា និងពិនិត្យឡើងវិញនូវបញ្ហាប្រឈមនានាពាក់ព័ន្ធការអនុវត្តមុខងារទាំង៥៥ ក្នុងគោលបំណងផ្តល់ធនធានសមស្របសម្រាប់អនុវត្តមុខងារ កាលពីខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២៤ កន្លងមកនេះ<br>- **បច្ចុប្បន្ននេះ ក្រុមការងារបានចុះសិក្សារួចរាល់ និងកំពុងបូកសរុបរៀបចំរបាយការណ៍រួមស្តីពីលទ្ធផល និងបញ្ហាប្រឈម ដើម្បីគោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅចុងត្រីមាសទី១ ឆ្នាំ២០២៥។** |
| ៩ | **មិនទាន់មានការកំណត់មុខសញ្ញាចំណាយ និងនីតិវិធីទូទាត់សម្រាប់ប្រើប្រាស់ថវិកាសេវាសង្គម និងអនាម័យបរិស្ថាន ស្នើសុំឱ្យមានការណែនាំឱ្យបានច្បាស់លាស់ ព្រមទាំងការកំណត់ឈ្មោះគម្រោងសេវាសង្គមនៅរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក។**<br>**ដំណើររឿង** ៖ ទោះបីអនុក្រឹត្យលេខ១៩២ និង១៩៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៣ បានកំណត់ឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់អាចប្រើប្រាស់ថវិកាសម្រាប់ការផ្តល់សេវាសង្គម និងអនាម័យបរិស្ថានក៏ដោយ ក៏រហូតមកដល់ពេលនេះ មិនទាន់មានការណែនាំច្បាស់លាស់ពាក់ព័ន្ធនឹងការកំណត់មុខងារសញ្ញា និងនីតិវិធីទូទាត់ការចំណាយលើការផ្តល់សេវាសង្គម និងអនាម័យ បរិស្ថាននៅឡើយទេ ដែលជាហេតុធ្វើឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ជួបការលំបាកក្នុងការអនុវត្តកិច្ចការនេះ។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **សំណើដំណោះស្រាយ៖**<br>– ក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំ ដើម្បីកំណត់នីតិវិធីចំណាយ និងមុខសញ្ញាចំណាយជាក់លាក់ ដោយផ្អែកលើមូលដ្ឋាននីតិវិធីចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់<br>– សេចក្តីព្រាងនេះបានឯកភាពជាគោលការណ៍កម្រិតជំនាញរួចហើយ និងគ្រោងរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តនៅក្នុង ត្រីមាសទី១ ឆ្នាំ២០២៥នេះ។ |
| ១០ | **ក្របខ័ណ្ឌពេលវេលារៀបចំថវិកាប្រចាំឆ្នាំមានរយៈពេលតិចពេក (ចាប់ពីខែមិថុនាដល់ខែកក្កដា) ស្នើសុំឱ្យមានពេលវេលាសមស្រប។**<br>**ដំណើររឿង** ៖ ផ្អែកតាមអនុក្រឹត្យលេខ១៧២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក បានកំណត់ក្របខ័ណ្ឌពេលវេលាសម្រាប់រៀបចំថវិកាប្រចាំឆ្នាំមានរយៈពេលតែ២ខែប៉ុណ្ណោះ (ចាប់ពីខែមិថុនា ដល់ខែកក្កដា) ដែលរយៈពេលនេះគឺខ្លី និងមិនសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំដែលតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធនោះឡើយ។<br>**សំណើដំណោះស្រាយ ៖**<br>– យោងមាត្រា៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសារាចរស្តីពីប្រតិទិនលម្អិតនៃការរៀបចំថវិកាប្រចាំឆ្នាំនៅអំឡុងពាក់កណ្តាលខែមករា<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១(ថ្មី) បន្ទាប់ពីច្បាប់នេះចូលជាធរមាន ការងារបន្តនឹងកែសម្រួលគ្រប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់នេះ ដែលនឹងដោះស្រាយកង្វល់ដែលបានលើកឡើងនេះ<br>– ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិនិត្យមើលឡើងវិញពីក្របខ័ណ្ឌពេលវេលារៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានសង្គតិភាពគ្នានៃវំហូរការងារពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | – *យ៉ាងណាក៏ដោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាកិច្ចការដែលត្រូវធ្វើជាប្រចាំ ដូច្នេះ រដ្ឋបាល ក្រុង ស្រុក ក៏ត្រូវមានភាពបុរេសកម្ម ក្នុងការរៀបចំគម្រោងថវិកានេះផងដែរ។* |
| ១១ | **ការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិដីធ្លីនៅមានភាពយឺតយ៉ាវ និងការលំបាក (សំណូមពរសុំឱ្យបង់នៅសាខាពន្ធដារខណ្ឌ ឬគួរមានភ្នាក់ងារពន្ធដារនៅអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ)។**<br>**ដំណើររឿង** ៖ ចំពោះការស្នើសុំសេវាផ្ទេរកម្មសិទ្ធិបណ្ណសម្គាល់(ប្លង់រឹង) និងការស្នើសុំសេវាផ្ទេរកម្មសិទ្ធិអចលទ្រព្យដែលពុំទាន់ចុះបញ្ជី នៅពេលមន្ត្រីបច្ចេកទេសបានពិនិត្យរួចរាល់ហើយ តម្រូវឱ្យអ្នកស្នើសុំសេវាកាន់ឯកសារទៅបង់ពន្ធប្រថាប់ត្រា៤%នៅសាខាពន្ធដារ ឬអគ្គនាយកដ្ឋានពន្ធដារ។ អ្នកស្នើសុំសេវាត្រូវធ្វើដំណើរទៅមកៗច្រើនលើកដើម្បីបង់ពន្ធ និងត្រូវកាន់ឯកសារទៅបង់ពន្ធដោយខ្លួនឯង។ ជាមួយគ្នានេះ អត្រាពន្ធក៏មានភាពមិនច្បាស់លាស់ គឺអាស្រ័យទៅតាមការកំណត់របស់មន្ត្រីពន្ធដារ។<br>**សំណើដំណោះស្រាយ៖**<br>– អ្នកជាប់ពន្ធ ឬអ្នកតំណាង អាចស្នើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ឬតាមអនឡាញ កម្មវិធីរដ្ឋបាលអេឡិចត្រូនិចពន្ធដារ (GDT e-Administration) ដែលអគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យអនុវត្តតាំងពីដើមឆ្នាំ២០២៤។ ***ករណីដែលឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់ ការបង់ពន្ធប្រថាប់ត្រានឹងរួចរាល់ក្នុងរយៈពេលពី ៤-៨ថ្ងៃនៃថ្ងៃធ្វើការ***<br>– ចាប់តាំងពីឆ្នាំ២០១៦មក ការបង់ពន្ធប្រថាប់ត្រានៅទូទាំងប្រទេស ត្រូវប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យ ដែលមូលដ្ឋានគិតពន្ធជាតម្លៃអចលនទ្រព្យ(ដីនិងសំណង់) កំណត់តាមឧបសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លក្ខខណ្ឌលើកលែងឬអនុគ្រោះពន្ធ និងការគណនាប្រាក់ពន្ធជាស្វ័យប្រវត្តិក្នុងប្រព័ន្ធ។ ករណីម្ចាស់អចលនទ្រព្យមានចម្ងល់ពីតម្លៃមូលដ្ឋានគិតពន្ធ អាចពិនិត្យលើឧបសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសៀវភៅណែនាំស្តីពីពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមានជា |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | ឧទាហរណ៍អំពីរបៀបពិនិត្យតម្លៃដីនិងសំណង់ និងរបៀបគណនាប្រាក់ពន្ធ ដែលមាននៅក្នុងគេហទំព័រ និង Facebook Page ផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ឬទំនាក់ទំនងសួរមក Call Center តាមរយៈលេខ ១២៧៧ (មិនគិតថ្លៃ) ឬ GDT Live Chat។ បន្ថែមពីនេះ អ្នកជាប់ពន្ធឬអ្នកតំណាងអាចប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ GDT Check and Track App ដើម្បីតាមដានវឌ្ឍនភាពនៃឯកសាររបស់ខ្លួន និងត្រួតពិនិត្យផ្ទៀងផ្ទាត់សុក្រឹត្យភាពនៃឯកសារគតិយុត្តនានាដែលចេញដោយរដ្ឋបាលសារពើពន្ធ ថាតើឯកសារពិត ឬក្លែងក្លាយ ដោយមានបង្ហាញប្រាក់ពន្ធត្រូវបង់ទៀតផង<br>– ចាប់តាំងពីឆ្នាំ២០១៦នេះដែរ អគ្គនាយកដ្ឋានពន្ធដារបានចាត់បញ្ជូនមន្ត្រីដើម្បីប្រចាំការនៅរដ្ឋបាលខណ្ឌ សម្រាប់ផ្តល់សេវាពាក់ព័ន្ធការបង់ពន្ធនេះ ហើយនៅតាមបណ្តាស្រុកនានានៃខេត្តក៏មានមន្ត្រីពន្ធដារនៃការិយាល័យស្រុកដើម្បីសហការផ្តល់សេវានេះដែរ។<br>– យ៉ាងណាក៏ដោយ យោងមាត្រា១៦៣ នៃច្បាប់ស្តីពីសារពើពន្ធ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ មិនត្រូវបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ករណីដែលអ្នកជាប់ពន្ធមិនទាន់បានបង់ពន្ធប្រថាប់ត្រា។ ដូចនេះ សូមអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ពង្រឹងនិងសហការបញ្ជូនសំណុំឯកសារមកបង់ពន្ធប្រថាប់ត្រាឱ្យបានត្រឹមត្រូវ ចៀសវាងប្រជាពលរដ្ឋដែលកាន់កាប់ចុងក្រោយត្រូវរងការបង់ពន្ធច្រើនតំណ<br>– អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយអំពីសេវាកម្មរបស់អគ្គនាយកដ្ឋានពន្ធដារដែលបានដាក់ឱ្យដំណើការរួមមាន កម្មវិធីរដ្ឋបាលអេឡិចត្រូនិចពន្ធដារ (GDT e-Administration) និងកម្មវិធីទូរស័ព្ទដៃ GDT Check and Track App ដែលមានជាសេចក្តីជូនដំណឹង និងវីដេអូឃ្លីបណែនាំផងដែរ។ |
| ១២ | **នៅពុំទាន់មាននីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូល និងការប្រើប្រាស់សម្ភារសាងសង់ បរិក្ខារសំណង់ សម្ភារបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅថ្នាក់រាជធានី ខេត្ត។**<br>**ដំណើររឿង ៖** ច្បាប់ស្តីពីវិនិយោគ និងអនុក្រឹត្យលេខ១២០ បានប្រតិភូកម្មដល់រដ្ឋបាលរាជធានី ខេត្តក្នុងការពិនិត្យ និងសម្រេចលើការចុះបញ្ជីគម្រោងវិនិយោគ និងការផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគឯកជនដែលមានទុនវិយោគសមមូលនឹង៥លានដុល្លារអាមេរិកចុះ។ ក្នុងការ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | អនុវត្តជាក់ស្តែងមកដល់បច្ចុប្បន្ននេះ រដ្ឋបាលរាជធានី ខេត្តនៅមិនទាន់មាននីតិវិធីច្បាស់លាស់សម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តនៅឡើយ។<br>**សំណើដំណោះស្រាយ ៖**<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងពិនិត្យ និងជំរុញកិច្ចការនេះឱ្យបានរួចរាល់ត្រឹមត្រីមាសទី១ ឆ្នាំ២០២៥។ |
| ១៣ | – **ស្នើសុំឱ្យមានការផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិភ្ជាប់ទៅនឹងមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលរាជធានី ខេត្ត (វិស័យសុខាភិបាល និងសង្គមកិច្ច) និងក្រុង ស្រុក ខណ្ឌ (វិស័យទាំង២០) ដើម្បីឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភាពម្ចាស់ការក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។**<br>**ដំណើររឿង ៖** យោងអនុក្រឹត្យលេខ១៩៣ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារ និងផ្តល់សេវាសុខាភិបាលទៅរដ្ឋបាលរាជធានី ខេត្ត និងអនុក្រឹត្យលេខ៣៤ អំពីការផ្ទេរមុខងារវិស័យសង្គមកិច្ច ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ចបានផ្ទេរបុគ្គលិកសុខាភិបាល និងធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្តរួចហើយ។ ដោយឡែក ចំពោះទ្រព្យសម្បត្តិដែលត្រូវប្រើប្រាស់សម្រាប់អនុវត្តមុខងារក្នុងវិស័យទាំងពីរនេះ ពុំទាន់បានផ្ទេរជាផ្លូវការទៅឱ្យរដ្ឋបាលរាជធានី ខេត្តនៅឡើយ។ ដូចគ្នានេះដែរ បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យជំនាញឱ្យទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ ឆ្នាំ២០១៩ គិតរហូតដល់ពេលនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធនៅមិនទាន់ផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិភ្ជាប់ជាមួយនឹងមុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅឡើយ។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
| --- | --- |

**សំណើដំណោះស្រាយ ៖**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ ០០១ សហវ.សរ.អទច ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ ស្ដីពីការផ្ទេរសិទ្ធិកាន់កាន់ និងប្រើប្រាស់លើទ្រព្យសម្បត្តិរដ្ឋ ដោយមានចែងលម្អិតអំពីយន្តការ និងនីតិវិធីនៃការផ្ទេរ បូករួមទាំងការផ្ទេរទ្រព្យសម្បត្តិរដ្ឋក្នុងក្របខ័ណ្ឌនៃការគាំទ្រការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដើម្បីជំរុញការអនុវត្តសារាចរនេះ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការផ្សព្វផ្សាយសារាចរណែនាំនេះជាបន្តបន្ទាប់ លើកចុងក្រោយ គឺនៅខែវិច្ឆិកា ឆ្នាំ២០២៤ នៅក្នុងសិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនៅខេត្តព្រះសីហនុ
- ជំរុញអនុវត្ត ដោយបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអនុវត្តសារាចរនេះ នៅមុនដំណាច់ត្រីមាសទី១ ឆ្នាំ២០២៥។

*****

- **នីតិវិធីនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋមានភាពស្មុគស្មាញ និងប្រើប្រាស់ពេលវេលាច្រើន ស្នើសុំថ្នាក់ជាតិពិនិត្យមើលឡើងវិញនូវនីតិវិធី និងពន្លឿនការជម្រះបញ្ជី (ស្នើដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)។**

**ដំណើររឿង ៖** យោងអនុក្រឹត្យលេខ៦៦ ស្ដីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានកំណត់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវស្នើសុំគោលការណ៍សម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងធ្វើការជម្រះបញ្ជីទ្រព្យសម្បត្តិចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ វិធាន និងនីតីវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទោះយ៉ាងនេះក្ដី រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជួបការលំបាកក្នុងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តទាំងនេះ។

**ការពន្យល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ០០២ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ស្ដីពីនីតិវិធីលម្អិតនៃការជម្រះ

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយមានចែងលម្អិតអំពីយន្តការ និងនីតិវិធី។ ប្រកាសនេះ គឺជួយឱ្យអ្នកអនុវត្តស្វែងយល់ច្បាស់អំពីនីតិវិធី និងសម្រួលដល់ការអនុវត្ត។<br>– អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តការផ្សព្វផ្សាយនីតិវិធីបច្ចេកទេសលម្អិតដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ពិសេសដល់មន្ត្រីទទួលបន្ទុកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>– ជំរុញអាជ្ញាធរគ្រប់គ្រង និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋឱ្យបន្តពង្រឹងកិច្ចសហការដើម្បីពន្លឿនការជំរុញអនុវត្តនីតិវិធីនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ |
| ១៤ | **ស្នើសុំឱ្យមានការសិក្សា និងកំណត់អំពីក្របខ័ណ្ឌពេលវេលាឱ្យមានសង្គតិភាពជាមួយគ្នារវាងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រើប្រាស់ធនធានថវិការបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋដែលបានកំណត់ក្នុងកម្មវិធីវិនិយោគបានទាន់ពេលវេលា។**<br>**ដំណើររឿង** ៖ រយៈពេលកន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំប្រចាំឆ្នាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ ដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវដាក់គម្រោងថវិការបស់រដ្ឋបាលសាមីនីមួយៗជូនក្រុមប្រឹក្សាអនុម័តឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា នៃឆ្នាំមុនឆ្នាំអនុវត្តថវិកា។ ដោយឡែក ប្រកាសអន្តរក្រសួងរវាងក្រសួងផែនការ និងក្រសួងមហាផ្ទៃលេខ៧៣, ៧៤, ៧៥, ៧៦, ៧៧, ៧៨ និង៩៧ (ឆ្នាំ២០១៧) ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលសង្កាត់ ឃុំ ខណ្ឌ ស្រុក ខេត្ត រាជធានី មិនបានកំណត់ប្រតិទិនសម្រាប់ការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមជំហាននីមួយៗទេ ដែលជាហេតុធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអនុម័តកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរហូតដល់ដំណាច់ឆ្នាំ ពោលគឺកម្មវិធីវិនិយោគទាំងនោះត្រូវបានអនុម័តក្រោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ករណីនេះ គឺផ្ទុយទៅនឹងទិដ្ឋភាពបច្ចេកទេស ដែលតម្រូវឱ្យការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវឆ្លើយតបទៅនឹងកម្មវិធី |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | វិនិយោគ៣ឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សា។ ប៉ុន្តែ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងផែនការ និងក្រសួងមហាផ្ទៃបានដាក់ចេញនូវប្រកាសអន្តរក្រសួងស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីនិយោគ៣ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗពិនិត្យ និងអនុម័តលើបញ្ជីគម្រោងវិនិយោគជាអាទិភាពឱ្យបានមុនដំណើរការនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ថវិកាឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងឆ្នាំនីមួយៗ។<br>**សំណើដំណោះស្រាយ៖**<br>– ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ តាមការស្នើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងផែនការ បានចេញប្រកាសអន្តរក្រសួងលេខ ០១៤៩ ផកប្រ.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ប្រកាសនេះបានកែសម្រួលក្របខ័ណ្ឌពេលវេលា ឱ្យស្របតាមរំហូរការងារការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកា។ ប៉ុន្តែការអនុវត្តនៅមិនទាន់បានទូលំទូលាយ<br>– យ៉ាងណាក៏ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តធ្វើការជាមួយក្រសួងមហាផ្ទៃ និងក្រសួងផែនការ ដើម្បីពិនិត្យឡើងវិញក្របខ័ណ្ឌពេលវេលានៃការរៀបចំ និងអនុម័តកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ឱ្យទាន់ពេលប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែលកំណត់ដោយច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ *ព្រមទាំងគិតគូរនៅក្នុងក្របខ័ណ្ឌនៃការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធការវិនិយោគសាធារណៈ២០២៦-២០៣០ នាពេលខាងមុខ។* |
| ១៥ | ស្នើសុំឱ្យមានគោលការណ៍សម្រាប់រៀបចំកញ្ចប់ថវិការបស់ក្រុមប្រឹក្សាដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចរៀបចំផែនការការងារ និងការអនុវត្តមុខងាររបស់ខ្លួនបានច្បាស់លាស់ និងមានប្រសិទ្ធភាព (ស្នើដោយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **ដំណើររឿង ៖** យោងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមាត្រា១១ បានកំណត់ថា អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា គឺជាអាណាប័កដើមខ្សែ ជាអ្នករៀបចំ និងអនុវត្តថវិការបស់រដ្ឋបាលសាមីនីមួយៗ។ ក្នុងការអនុវត្តថវិកា អភិបាលគឺជាអ្នកបញ្ជាចំណូល សន្យាចំណាយ ជម្រះបញ្ជី និងបញ្ជាចំណាយដោយផ្អែកលើគម្រោងថវិកាដែលបានអនុម័តដោយក្រុមប្រឹក្សា។ ដូច្នេះរាល់ការចំណាយរបស់ការិយាល័យជំនាញ និងចំណាយនានារបស់ក្រុមប្រឹក្សាសម្រាប់អនុវត្តសកម្មភាពរបស់ខ្លួនត្រូវមានការឯកភាពពីអភិបាលដែលជាអាណាប័កថវិកា។ ប្រការនេះជាហេតុនាំឱ្យមានភាពលំបាកសម្រាប់ក្រុមប្រឹក្សានៅពេលមានតម្រូវការចំណាយសម្រាប់អនុវត្តសកម្មភាពរបស់ខ្លួន។<br><br>**សំណើដំណោះស្រាយ៖**<br><br>– យោងតាមគោលការណ៍ច្បាប់ដែលមានជាធរមាន កញ្ចប់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សារដ្ឋបាលសាមី***ដែលជាម្ចាស់ថវិកា***។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងក្រុង ស្រុក ***ជាអាណាប័កដើមខ្សែ*** ក្នុងការអនុវត្តថវិកា។ ***កញ្ចប់ថវិកាសម្រាប់ក្រុមប្រឹក្សា ជាការសម្របសម្រួលផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។***<br>– ***ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរទទួលយកសំណើនេះ ដើម្បីរៀបចំយន្តការច្បាស់លាស់សម្រាប់ការរៀបចំ និងគ្រោងកញ្ចប់ថវិកាសម្រាប់ក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលសាមី។*** |
| ១៦ | – **ទំហំថវិការបស់រដ្ឋបាលខេត្តមួយចំនួន មិនទាន់ឆ្លើយតបទៅនឹងតម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍរបស់ខេត្ត។**<br><br>**ដំណើររឿង ៖** យោងតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន (ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ) ចំណាយគុណប្រយោជន៍ និងចំណាយរដ្ឋបាលរបស់រដ្ឋបាលខេត្តត្រូវរ៉ាប់រងទាំងស្រុងដោយចំណូលផ្ទៃក្នុងរបស់រដ្ឋបាលខេត្តសាមី លើកលែងតែចំណាយសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានប្រគល់ដោយថ្នាក់ជាតិដែលត្រូវរ៉ាប់រងដោយការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ។ ពាក់ព័ន្ធបញ្ហានេះ រដ្ឋបាលខេត្តមួយចំនួនមានបញ្ហា |

<table>
<tr><th>ល.រ</th><th>បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ</th></tr>
<tr><td></td><td>
ប្រឈមក្នុងការប្រមូលចំណូលផ្ទាល់របស់ខ្លួន ដោយសារប្រភពចំណូលក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមិនសូវមានសក្តានុពល។<br><br>
សំណើដំណោះស្រាយ៖<br>
– ទំហំថវិការបស់រដ្ឋបាលខេត្តនីមួយៗទទួលបានតាមរយៈសក្តានុពលនៃការប្រមូលចំណូលនៅមូលដ្ឋានផ្ទាល់ ដែលរួមមាន ចំណូលមិនមែនសារពើពន្ធ និងសារពើពន្ធ<br>
– កន្លងមកដោយសក្តានុពលនៃការប្រមូលចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត នីមួយៗ មានគម្លាតទំហំចំណូល ទើបមានការបែងចែកចំណូលពីរដ្ឋបាលរាជធានី ខេត្តដែលមានទំហំចំណូលច្រើន ទៅរដ្ឋបាលខេត្តដែលមានទំហំចំណូលតិច ដើម្បីធានាសមធម៌ និងបន្ថយគម្លាតអភិវឌ្ឍន៍ពីខេត្តមួយទៅខេត្តមួយ<br>
– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំឱ្យមានយន្តការឧបត្ថម្ភធនប្រចាំឆ្នាំ ជូនរដ្ឋបាលខេត្ត។ ប្រភពធនធាននេះ រួមមានចំណូលពីខេត្តដែលមានសក្តានុពលប្រមូលចំណូល និងបែងចែកជូនរដ្ឋបាលខេត្តដែលមានប្រភពចំណូលខ្សត់ខ្សោយ។ ការផ្ទេរនេះ ត្រូវបានកំណត់ដោយរូបមន្តច្បាស់លាស់ ដើម្បីធានាសមធម៌ ព្រមទាំងគិតគូរផងដែរពីតម្រូវការជាក់ស្តែងរបស់រដ្ឋបាលខេត្តមួយចំនួនដែលមានលក្ខណៈចាំបាច់ បន្ទាន់ និងដែលមានការចង្អុលបង្ហាញដោយផ្ទាល់ពីរាជរដ្ឋាភិបាល<br>
– លើសពីនេះ ក៏មានការបែងចែកថវិកាពី មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ (អតិរេកថវិការាជធានី ខេត្តបន្ថែមជូនរដ្ឋបាលរាជធានី ខេត្តផងដែរ) ប៉ុន្តែ ប្រភពពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនេះ ដែលជាអតិរេកថវិកា មានការប្រែប្រួលមិនទៀងទាត់ អាស្រ័យលើការអនុវត្តចំណូល ចំណាយថវិកាប្រចាំឆ្នាំជាក់ស្តែង ឧទាហរណ៍ ឆ្នាំ២០២២ មានចំនួន ១២៤ ៤៨៥,៦លានរៀល យោងទៅច្បាប់ឆ្នាំ២០២៤ និងឆ្នាំ២០២៣ មានចំនួន ១៥ ៧០០លានរៀល យោងទៅច្បាប់ឆ្នាំ២០២៥<br>
– ទិសដៅទៅមុខ៖<br>
+ សិក្សាលទ្ធភាពនៃការកំណត់ប៉ារ៉ាម៉ែត្រនៃការវិភាជន៍ឧបត្ថម្ភធនជូនរដ្ឋបាលរាជធានី ខេត្តតាមរូបមន្ត<br>
+ រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងទទួលបានការបែងចែកចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន តាមរយៈយន្តការ “មូលនិធិភាតរភាព”
</td></tr>
</table>

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | + *រដ្ឋបាលរាជធានី ខេត្ត នឹងទទួលបានធនធានបន្ថែមពី Capital Gain Tax ពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យផងដែរ។*<br><br>*****<br><br>– ការចំណាយផ្នែកប្រតិបត្តិការរដ្ឋបាល ជាពិសេសចំណាយបេសកកម្មមានតម្រូវការច្រើន ផ្អែកទៅលើទំហំការងារ មុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរកាន់តែច្រើនឡើងៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ប្រតិភូកម្ម និងប្រគល់) កិច្ចប្រជុំនៅថ្នាក់ជាតិ និងការចុះគាំទ្ររដ្ឋបាលមូលដ្ឋាន (ក្រុង ស្រុក ឃុំ សង្កាត់) ដែលថវិការដ្ឋបាលខេត្តមានកម្រិត មិនអាចទូទាត់បានគ្រប់គ្រាន់ អាស្រ័យហេតុនេះស្នើសុំឱ្យមានការពិចារណាក្នុងការបង្កើនចំណាយផ្នែកប្រតិបត្តិការរដ្ឋបាលឱ្យបានសមស្រប។<br><br>**ដំណើររឿង៖** មុខងារសំខាន់ៗមួយចំនួនត្រូវបានផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ ប្រការនេះបានធ្វើឱ្យបន្ទុកការងារ ការទទួលខុសត្រូវ និងការចំណាយរបស់រដ្ឋបាលរាជធានី ខេត្តសម្រាប់រ៉ាប់រងលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះមានការកើនឡើងជាលំដាប់ផងដែរ ដែលជាហេតុធ្វើឱ្យរដ្ឋបាលរាជធានី ខេត្តខ្វះថវិកាសម្រាប់គាំទ្រផ្នែកប្រតិបត្តិការ។<br><br>**សំណើដំណោះស្រាយ៖**<br>– តាមគោលការណ៍របស់រាជរដ្ឋាភិបាល ចំណាយប្រតិបត្តិការរដ្ឋបាលជាមុខសញ្ញាចំណាយដែលត្រូវមានការគិតគូរក្នុងស្មារតី សន្សំសំចៃ<br>– លើកទឹកចិត្តដល់រដ្ឋបាលរាជធានី ខេត្ត ផ្តល់អាទិភាពដល់ការចំណាយការអភិវឌ្ឍន៍មូលដ្ឋាន និងការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធនានានៅមូលដ្ឋាន<br>– កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតឱ្យមានការគ្រោងកើនថវិកាចំណាយប្រតិបត្តិការដ្ឋបាល ក្នុងរង្វង់ ៣% ផងដែរ ប្រសិនបើ មានតម្រូវការចាំបាច់គាំទ្រការអនុវត្តសកម្មភាពថ្មីៗ ក្នុងការផ្តល់សេវាសាធារណៈ ឧទាហរណ៍ តម្រូវការចំណាយកាត់ឯកសណ្ឋាន បេសកកម្ម អគ្គីសនី ទឹក...<br>– ក្នុងស្មារតីសន្សំសំចៃ រដ្ឋបាលរាជធានី ខេត្ត ត្រូវគិតគូរផ្តល់អាទិភាពដល់មុខសញ្ញាចំណាយប្រតិបត្តិការរដ្ឋបាល ដែលឆ្លើយតបទៅនឹងសកម្មភាពការងារ និងតម្រូវការចាំបាច់នៃការផ្តល់សេវានៅមូលដ្ឋាន។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | *****<br><br>– **ការចំណាយថវិកាសម្រាប់ចុះតាមមូលដ្ឋានរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺទទួលបានចាប់ពីការធ្វើដំណើរលើសពី២០គីឡូម៉ែត្រ ក្រោម២០គីឡូម៉ែត្រគឺមិនទទួលបានឡើយ និងសំណូមពរជួយផ្តល់នូវធនធានហិរញ្ញវត្ថុសម្រាប់ចម្ងាយក្រោម២០គីឡូម៉ែត្រ (ប្រេង)។**<br><br>**ដំណើររឿង** ៖ យោងប្រកាសលេខ៥៥៩ ឆ្នាំ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ បានកំណត់ថា ប្រាក់បេសកកម្មត្រូវផ្តល់ជូនមន្ត្រីរាជការសាធារណៈ ដែលចុះធ្វើសកម្មភាពចេញពីរង្វង់ដែនដីរាជធានី ឬរង្វង់ដែនដីនៃឃុំ/សង្កាត់នៃក្រុង ស្រុកសាមី ដែលមានចម្ងាយចាប់ពី២០គីឡូម៉ែត្រឡើងទៅ។ ពាក់ព័ន្ធនឹងបញ្ហានេះ ផ្អែកតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានលក្ខណៈខុសគ្នា ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្ថានភាពភូមិសាស្ត្រធំទូលាយ ស្នើសុំឱ្យមានការពិចារណាក្នុងការផ្តល់ប្រាក់បេសកម្មសម្រាប់ការធ្វើសកម្មភាពក្រោម២០គីឡូម៉ែត្រចេញពីរង្វង់ដែនដីរបស់ខ្លួន។<br><br>**សំណើដំណោះស្រាយ៖** ប្រកាសលេខ ៥៥៩ សហវ.អហក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងស្មារតី ***សន្សំសំចៃថវិកា*** និងបានកំណត់៖<br><br>– ការបម្លាស់ទីក្នុងគោលដៅបេសកកម្មចេញពីដែនដីនៃឃុំ សង្កាត់មួយទៅដែនដីឃុំ សង្កាត់មួយផ្សេងៗទៀត ទទួលប្រាក់បេសកកម្ម (លើកលែងបម្លាស់ទី ក្នុងរង្វង់រាជធានីភ្នំពេញ)<br>– សោហ៊ុយធ្វើដំណើរដោយមធ្យោបាយរដ្ឋ ឬផ្ទាល់ខ្លួន (រថយន្ត ១០០គីឡូម៉ែត្រ= ៨ម៉ឺនរៀល, ទោចក្រយានយន្ត ១០០គីឡូម៉ែត្រ= ២,៥ម៉ឺនរៀល, ការទូទាត់តាមសមាមាត្រនៃចំងាយផ្លូវជាក់ស្តែង)<br>– សោហ៊ុយធ្វើដំណើរដោយមធ្យោបាយសាធារណៈ ដូចជា រថយន្តក្រុង រថយន្តឈ្នួល កាណូត ឬកប៉ាល់ ត្រូវទូទាត់តាមវិក្កយបត្រជាក់ស្តែង<br>– ***សម្រាប់ការបម្លាស់ទីដែលមានចម្ងាយក្រោម ២០ គ.ម ឆ្លងឃុំ មានការផ្តល់ជូន ប្រាក់ហោប៉ៅ (ទទួលបានយ៉ាងតិច ១៦ ០០០ រៀល ដល់ ២៤ ០០០ រៀល ទៅតាមឋានៈ)*** |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | – ផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងសោហ៊ុយធ្វើដំណើរ សម្រាប់ការបម្លាស់ទីដែល មានចម្ងាយចាប់ពី ២០ គ.ម និងផ្តល់ជូនបន្ថែមប្រាក់ស្នាក់នៅ សម្រាប់ការបម្លាស់ទីចម្ងាយលើសពី ៤០ គ.ម<br>– ***គួរបន្តអនុវត្តទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន (មិនផ្តល់ជូនប្រាក់បេសកកម្ម សម្រាប់ការធ្វើដំណើរនៅក្នុងឃុំ ទោះមានចម្ងាយផ្លូវ ២០គ.ម ក៏ដោយ)***<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តពង្រឹងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ១៧ | – **ប្រព័ន្ធគ្រប់គ្រងចំណូល NRMIS និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ FMIS ត្រូវបាន និងកំពុងអនុវត្តស្របគ្នាដែលធ្វើឱ្យរដ្ឋបាលរាជធានី ខេត្ត ត្រូវកត់ត្រាប្រតិបត្តិការចំណូលដដែលៗពីរដងក្នុងប្រព័ន្ធពីរផ្សេងគ្នា ដូច្នេះស្នើសុំឱ្យមានការធ្វើសន្ទានកម្មជាមួយគ្នា។**<br>**ដំណើររឿង ៖** យោងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០៧ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត និងសារាចរណែនាំលេខ០០២ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រាស់FMIS នៅរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលសម្រាប់ឆ្នាំ២០២២។<br>**ការពន្យល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖**<br>– ការធ្វើសន្ទានកម្មរវាងប្រព័ន្ធ NRMIS នឹងប្រព័ន្ធ FMIS នៅមានបញ្ហាធ្វើ mapping field អង្គភាពការងារ (Business Unit) អង្គភាពប្រតិបត្តិការ (Operating Unit) និង រដ្ឋបាល (Admin)។<br>– ជាដំណោះស្រាយ ក្រុមការងារបច្ចេកទេសប្រព័ន្ធ NRMIS កំពុងជំរុញការដោះស្រាយ។<br>***** |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
| --- | --- |
| | – **សំណូមពរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្លឿនការផ្ដល់និយ័តភាពថវិកាឱ្យទាន់ពេលវេលា។**<br><br>**ដំណើររឿង ៖** យោងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០២៣) កថាខណ្ឌទី៤ នៃមាត្រា៦៦ បានកំណត់ថា៖ ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយនៅផ្ទៃក្នុងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិសម្រេចក្នុងការធ្វើនិយ័តកម្មឥណទានថវិការបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់។ ការអនុវត្តជាក់ស្ដែង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពុំបានធ្វើប្រតិភូកម្មនោះឡើយ ដែលធ្វើឱ្យការស្នើសុំនិយ័តភាពថវិកាតែងតែមានការយឺតយ៉ាវ។<br><br>**សំណើដំណោះស្រាយ៖**<br><br>– ការផ្ទេរឥណទានថវិកាគឺចាប់ពីត្រីមាសទី២ នៃឆ្នាំអនុវត្តថវិកា<br>– ការផ្ទេរឥណទានថវិកាលើមុខសញ្ញាចំណាយដែលមានហានិភ័យទាប និងក្នុងជំពូកថវិកា ត្រូវបានប្រគល់សិទ្ធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសាមីក្នុងការសម្រេច។ លើកលែងតែការផ្ទេរឥណទានថវិកាឆ្លងជំពូកថវិកា ទើបត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(លើកលែងរដ្ឋបាលឃុំ សង្កាត់ស្នើសុំត្រឹមរដ្ឋបាលរាជធានី ខេត្តសាមី)។<br>– ការអនុវត្តកន្លងមករដ្ឋបាលថ្នាក់ក្រោមជាតិសាមីមួយចំនួនមានភាពយឺតយ៉ាវ ក្នុងការស្នើសុំបង្វែរឥណទានថវិកានេះ<br>– ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងយកចិត្តទុកដាក់ជំរុញបន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌការងារនៅក្នុងអគ្គនាយកដ្ឋានផ្ទាល់ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ។<br><br>*****<br><br>– **ស្នើអនុញ្ញាតឱ្យរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងអាចរក្សាទុកសាច់ប្រាក់លើសពី២លានរៀល។** |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **ដំណើររឿង** ៖ យោងតាមប្រការ១០ នៃប្រកាសលេខ១៨៩០ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិង រដ្ឋបាលថ្នាក់ក្រោមជាតិ មិនអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់ក្នុងបេឡា ឬមូលប្បទានប័ត្រលើសពី ២លានរៀលឡើយ។ បច្ចុប្បន្ន ការផ្តល់សេវាប្រចាំថ្ងៃនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តមានចំនួនច្រើន ហើយតម្លៃសេវាមួយចំនួនមានតម្លៃខ្ពស់លើសពី២លានរៀល ដែលធ្វើឱ្យមន្ត្រីបេឡានៅអង្គភាពច្រកចេញចូលតែមួយមិនអាចអនុវត្តតាមគោលការណ៍ ដែលតម្រូវឱ្យរក្សាទុកទឹកប្រាក់មិនឱ្យលើសពី ២លានរៀលនេះបានឡើយ ហើយក្រុមការងារសវនកម្ម ឬអធិការកិច្ចតែងតែចាប់កំហុសបុគ្គលិកបេឡារបស់អង្គភាពច្រកចេញចូលតែមួយលើបញ្ហានេះ។<br><br>**សំណើដំណោះស្រាយ៖**<br><br>– ជាយុទ្ធសាស្ត្រកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងការកៀរគរសាច់ប្រាក់ ចូលគណនីទោលរតនាគារ ដើម្បីឱ្យមានសាច់ប្រាក់គ្រប់គ្រាន់ក្នុងការបើកផ្តល់ជូនក្រសួងស្ថាប័ន និងអ្នកផ្គត់ផ្គង់វិញ ការអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់នៅតាមអង្គភាពប្រមូលចំណូលអាចនឹងធ្វើឱ្យគណនេយ្យករសាធារណៈកង្វះសាច់ប្រាក់<br>– ដើម្បីកុំឱ្យមានហានិភ័យបាត់បង់សាច់ប្រាក់ដោយសារចោរកម្ម ឬការភាន់ច្រឡំនៅពេលទទួលប្រាក់ឬដកប្រាក់<br>– ជួយលើកស្ទួយការប្រើប្រាស់ប្រព័ន្ធធនាគារ តាមរយៈការបង់ចំណូលតាម ប្រព័ន្ធអេឡិចត្រូនិក ដែលឱ្យការប្រមូលសាច់ប្រាក់ចូលគណនីទោលរតនាគារ បានលឿន និងឆាប់រហ័ស ព្រោះរជ្ជទេយ្យករចំណូល ឬអ្នកបង់ចំណូល ពុំចាំបាច់ចំណាយពេលអង្គុយរង់ចាំបង់ប្រាក់នៅតាមបញ្ជរធនាគារ<br>– ជាទិសដៅយុទ្ធសាស្ត្រកៀរគរចំណូលមិនមែនសារពើពន្ធតាមកម្មវិធីកំណែទម្រង់នៅឆ្នាំ២០២៥-២០២៧ ការអនុវត្តប្រព័ន្ធទូទាត់តាមអេឡិចត្រូនិកនឹងត្រូវដាក់ឱ្យអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ១៨ | **ស្នើសុំចំណូលដែលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ (ដី អគារ បឹង សណ្ឋាគារ) ដែលស្ថិតក្នុងដែនសមត្ថកិច្ច បង់ជាចំណូលរបស់រដ្ឋបាលខេត្ត។** |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | **ដំណើររឿង** ៖ យោងអនុក្រឹត្យលេខ២៤៩ ឆ្នាំ២០២៤ ស្តីពីការកំណត់អត្រាចែករំលែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិជូនជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មាត្រា៤ បានកំណត់ថា៖ ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋត្រូវបានចែករំលែកដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា (១). ចំណូលពីសម្បទាននេសាទក្នុងអត្រា១០០% (២). ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញរាជធានី ខេត្តក្នុងអត្រា៥០% (៣). ចំណូលពីដីសម្បទានសេដ្ឋកិច្ចក្នុងអត្រា៣០% និង(៤). ចំណូលពីផលព្រៃឈើក្នុងអត្រា៣០%។ បន្ថែមលើនេះ យោងអនុក្រឹត្យលេខ២៤៣ ឆ្នាំ២០២៣ ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កថាខណ្ឌទី៣ មាត្រា២៦ បានកំណត់ថា៖ ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលត្រូវចែករំលែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ជូនមួយចំណែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលចូលរួមកៀរគរចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរដ្ឋបាលសាមី។ ចំណូលចែករំលែកមួយចំណែកទៀត ត្រូវផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិដោយអនុវត្តតាមយន្តការ "មូលនិធិភាតរភាព"។ អត្រានៃការបែងចែកចំណូលចែករំលែករវាងរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និងការអនុវត្តតាមយន្តការ "មូលនិធិភាតរភាព" ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ។<br><br>**សំណើដំណោះស្រាយ៖**<br><br>– ផ្អែកលើលិខិតបទដ្ឋានគតិយុត្តខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរលេខ ០១៣ សហវ.ស.រ.អគហ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ ស្តីពីការអនុវត្តគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ចប់សេចក្តីព្រាងមូលនិធិភាតរភាព។ សេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវបានគ្រោងដាក់ប្រជុំពិភាក្សាជាមួយក្រសួងមហាផ្ទៃ នាពេលខាងមុខ និងគ្រោងដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| | – លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដឹកនាំកែសម្រួលប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ (ជាង ៨០ប្រកាស) នាពេលខាងមុខ<br>– បច្ចុប្បន្ន សេចក្តីព្រាងប្រកាសស្តីពីការដាក់ប្រើគំរូប្រកាសអន្តរក្រសួង/ប្រកាសរួម និងគំរូរបាយការណ៍ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការពិន័យ ត្រូវបានរៀបចំរួច<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពន្លឿនការរៀបចំលិខិតបទដ្ឋាន ឬកិច្ចការនានាដែលនៅសល់ ដើម្បីអនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះ។ |
| ១៩ | **ប្រាក់សមាជិកភាពនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានតិចតួចក្នុងការទ្រទ្រង់ប្រតិបត្តិការ និងអនុវត្តសកម្មភាពផ្តល់សេវាដល់សមាជិកមិនបានពេញលេញ ស្នើសុំរាជរដ្ឋាភិបាលបង្កើនប្រាក់សមាជិកភាពឱ្យបាន៣% ដល់សមាគមក្រុមប្រឹក្សា។**<br><br>**ដំណើររឿង ៖** នាពេលបច្ចុប្បន្នប្រាក់សមាជិកភាពនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គឺមានក្នុងអត្រា**២%**នៃថវិកាផ្នែកប្រតិបត្តិការរដ្ឋបាលនៃមូលនិធិឃុំ សង្កាត់។ ទោះយ៉ាងនេះក្តី ចំនួនថវិកានេះមានចំនួនតិចមិនអាចរ៉ាប់រងការចំណាយនានាសម្រាប់ទ្រទ្រង់ប្រតិបត្តិការ និងអនុវត្តសកម្មភាពផ្តល់សេវាដល់សមាជិកមិនបានពេញលេញ។ អាស្រ័យហេតុនេះ ស្នើបង្កើនប្រាក់សមាជិកភាពនេះទៅ**៣%**នៃថវិកាផ្នែកប្រតិបត្តិការរដ្ឋបាលនៃមូលនិធិឃុំ សង្កាត់។<br><br>**សំណើដំណោះស្រាយ៖**<br><br>– កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ក្រសួងមហាផ្ទៃបានរៀបចំកិច្ចប្រជុំពិភាក្សាលើការស្នើរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន ២% ទៅ ៣%នេះ អង្គប្រជុំបានសម្រេចរក្សាអត្រា ២% ដដែល ផ្អែកលើមូលហេតុមួយចំនួន៖<br>+ នៅឆ្នាំ២០២៤ ការវិភាជន៍ថវិកាពីថ្នាក់ជាតិ តាមរយៈមូលនិធិក្រុង ស្រុកបានបង្កើនអត្រាពី ១,៥% ទៅ ១,៦% និងមូលនិធិឃុំ សង្កាត់ បង្កើនអត្រាពី ៣,៤% ទៅ ៣,៥% ថេរ រហូតដល់ឆ្នាំ២០២៨ ដែលការបង្កើនអត្រានេះ សម្រាប់បង្កើនចំណាយបន្ទុកបុគ្គលិក និងចំណាយគាំទ្រសេវាសង្គម និងអនាម័យបរិស្ថាន។ ម្យ៉ាងទៀត ចំណាយប្រតិបត្តិការរដ្ឋបាលទូទៅនិងចំណាយអភិវឌ្ឍន៍មូលដ្ឋាន |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
| --- | --- |
| | របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានកំណើនជារៀងរាល់ឆ្នាំ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន<br>+ សម្ពាធនៃចំណាយថវិកាជាតិ ពិសេសចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>+ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន គួរគិតគូរពិចារណាបង្កើនអត្រាបែងចែកពី ២០% ទៅ ៣០% នៅក្នុងចំណែកថវិកាចំនួន ២% នៃថវិកាផ្នែករដ្ឋបាល ដកបន្ទុកបុគ្គលិក សម្រាប់ថវិកាបង់សមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ប្រចាំឆ្នាំ។<br>– យ៉ាងណាក៏ដោយនៅពេលស្ថានភាពចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិ មានស្ថានភាពល្អប្រសើរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសិក្សាសំណើខាងលើនេះ។ |
| ២០ | **រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្តពុំមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយតប និងដោះស្រាយតម្រូវការជាអាទិភាពជាច្រើនរបស់ប្រជាពលរដ្ឋដែលបានលើកឡើងតាមរយៈវេទិកាសាធារណៈនានា ដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងាររាជរដ្ឋាភិបាល។**<br>**ដំណើររឿង ៖** ការរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងាររាជរដ្ឋាភិបាល គឺជាយន្តការដ៏មានសារៈសំខាន់ក្នុងការផ្តល់ព័ត៌មាន ការស្តាប់មតិយោបល់ បញ្ហាប្រឈមនិងសំណើសំណូមពរនានា ព្រមទាំងការឆ្លើយតបចំពោះតម្រូវការអាទិភាពនានា និងដោះស្រាយបញ្ហាប្រឈមជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ក្នុងការអនុវត្តជាក់ស្តែង មានសំណើសំណូមពរជាច្រើនត្រូវបានលើកឡើង ប៉ុន្តែលទ្ធភាពហិរញ្ញវត្ថុ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតដែលមិនអាចឆ្លើយតបទៅនឹងសំណើ និងសំណូមពរដ៏ច្រើនរបស់ប្រជាពលរដ្ឋបានទេ។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣ថ្នាក់ ស្នើសុំក្រសួង ស្ថាប័នពិនិត្យលទ្ធភាពជួយគាំទ្រ និងដោះស្រាយសំណើសំណូមពរជាអាទិភាពនានា។<br>**សំណើដំណោះស្រាយ៖** គួររៀបចំជាការសេចក្តីណែនាំរួមមួយក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលពង្រឹងការរៀបចំ និងបញ្ចូលគម្រោងទាំងនេះ ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ក្រសួងស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិសាមី ដើម្បីធ្វើអាទិភាវូបនីយកម្មគម្រោងដែលជាតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋដែលបានស្នើ។ |

| ល.រ | បញ្ហាប្រឈម សំណើសំណូមពរ និងសំណើដំណោះស្រាយ |
|---|---|
| ២១ | **យន្តការចុះត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិមានច្រើនក្រុមក្នុងមួយឆ្នាំៗ កិច្ចការទាំងនេះគឺត្រួតគ្នាដែលដាក់បន្ទុកដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (NAA, MEF, MOI, MINS...) (ស្នើដោយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់)។**<br>**ដំណើររឿង** ៖ ក្នុងពេលដែលមុខងារ និងធនធានតាមវិស័យនានាកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានតម្រូវឱ្យក្រសួង ស្ថាប័នតាមវិស័យនីមួយៗ ត្រូវចុះធ្វើអធិការកិច្ចលើការអនុវត្តមុខងារ និងធនធានដែលបានផ្ទេរទាំងនោះ។ ប្រការនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរងសម្ពាធ និងត្រូវចំណាយពេលវេលាជាច្រើនក្នុងការចូលរួម និងឆ្លើយតបទៅនឹងសកម្មភាពនៃការចុះធ្វើអធិការកិច្ចទាំងនេះ។<br>**សំណើដំណោះស្រាយ៖** ក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងរៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីកំណត់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងការធ្វើសវនកម្ម និងអធិការកិច្ច អភិក្រមនៃការធ្វើអធិការកិច្ច ព្រមទាំងវិធាន និងនីតិវិធីប្រតិបត្តិ (Standard Operating Procedure-SOP) ឱ្យបានច្បាស់ ក្នុងគោលបំណងកាត់បន្ថយការធ្វើសវនកម្មនិងអធិការកិច្ចស្ទួនគ្នា និងច្រើនដង ឆ្លើយតបទៅនឹងការធ្វើសុខដុមនីយកម្មនៃយន្តការសវនកម្ម និងអធិការកិច្ចរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ ការព្រួយប្រារព្ធខាងលើនេះ អាចនឹងត្រូវបានដោះស្រាយ បន្ទាប់ពីការវិភាគមុខងារ និងការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ដែលកំពុងធ្វើឡើងដោយក្រសួងមុខងារសាធារណៈ។ |

## តារាងឧបសម្ព័ន្ធទី៧.១ (ស្ថានភាពទី១)

# បញ្ជីបញ្ហាប្រឈម សំណើសំណូមពរចំនួន៥ ដែលបានដោះស្រាយរួច និងបានរាយការណ៍ក្នុងកិច្ចប្រជុំ គ.ជ.អ.ប. ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ និងដំណោះស្រាយ |
|---|---|
| ១ | **ស្នើសុំពន្លឿនការរៀបចំនីតិវិធីនៃការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សា។**<br>**ចំណើររឿង** ៖ កន្លងមក ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សា ត្រូវធ្វើឡើងដោយដីការបស់អភិបាលក្រុង ស្រុកសាមីនីមួយៗ។ ការអនុវត្តជាក់ស្តែង ការជ្រើសរើស និងការតែងតាំងនាយកមួយចំនួនក៏មិនទាន់ជ្រើសរើសបាននាយកល្អដើម្បីដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាពក្នុងការដឹកនាំ និងអភិវឌ្ឍសាលារៀនឆ្លើយតបទៅនឹងកំណែទម្រង់គន្លឹះក្នុងវិស័យអប់រំ។ អាស្រ័យហេតុនេះ សម្តេចមហាបវរធិបតី បានផ្តល់ជាអនុសាសន៍ណែនាំឱ្យមានការគិតគូរអំពីការតែងតាំងនាយកសាលាបឋមសិក្សា និងសាលាមត្តេយ្យសិក្សាត្រូវធ្វើឡើងដោយដីការបស់អភិបាលរាជធានី ខេត្ត ដើម្បីធានាដល់ការជ្រើសរើសបាននាយកល្អដែលមានសមត្ថភាព មានគំនិតផ្តួចផ្តើមក្នុងការដឹកនាំសាលា និងមានមនសិការវិជ្ជាជីវៈខ្ពស់ និងប្រកបដោយតម្លាភាព។ ពាក់ព័ន្ធនឹងកិច្ចការនេះ គឺចាំបាច់ត្រូវមានការសិក្សា និងកែតម្រូវលិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួន រួមមាន ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យ និងសេចក្តីណែនាំបច្ចេកទេសជាដើម ហើយកិច្ចការនេះក៏បាន និងកំពុងរៀបចំដោយមានកិច្ចសហការគ្នារវាងក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.។<br>**ដំណោះស្រាយ** ៖ មកដល់ពេលនេះ ព្រះរាជក្រឹត្យស្តីពីការកែសម្រួលលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សាត្រូវបានដាក់ចេញថ្មីៗនេះ។ ដូចនេះ ជាវិធានការបន្ត គឺ |

| | |
|---|---|
| | រៀបចំការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តនៅដើមឆ្នាំ២០២៥នេះ។ |
| ២ | **ខ្វះមន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកធៀបនឹងស្តង់ដាកំណត់ និងតម្រូវការសេវាជាក់ស្តែង។**<br>**ដំណើររឿង៖** មុខងារសុខាភិបាលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តនាដើមឆ្នាំ២០២០ ដែលការផ្ទេរមុខងារនេះ ក៏បានផ្ទេរទៅជាមួយនូវបុគ្គលិកសុខាភិបាល (គ្រូពេទ្យ) ចំនួនប្រមាណជាង២០.០០០នាក់ ទៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត។ រហូតមកដល់ចុងឆ្នាំ២០២៤នេះ រដ្ឋបាលរាជធានី ខេត្តបានលើកឡើងនូវបញ្ហាប្រឈមពាក់ព័ន្ធទៅនឹងការខ្វះមន្ត្រីសុខាភិបាលបម្រើការងារនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក បើប្រៀបធៀបទៅនឹងស្តង់ដាកំណត់ និងតម្រូវការនៃការផ្តល់សេវាជាក់ស្តែង ដែលបានស្នើសុំឱ្យមានការបន្ថែមបុគ្គលិកសុខាភិបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកដែលមានការខ្វះខាត។<br>**ដំណោះស្រាយ ៖** ពាក់ព័ន្ធទៅនឹងការខ្វះមន្ត្រីសុខាភិបាលតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនេះ កន្លងមកនេះ ក្រសួងសុខាភិបាលបានលើកផែនការស្នើសុំមកក្រសួងមុខងារសាធារណៈ ហើយបានឯកភាពគ្នាដោយលើកសំណើសុំគោលការណ៍ទៅ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ហើយក៏ទទួលបានការឯកភាពជាគោលការណ៍រួចហើយពីសម្តេចធិបតី ក្នុងការជ្រើសរើសបន្ថែមមន្ត្រីសុខាភិបាលចំនួន**ជាង ១.០០០នាក់** សម្រាប់ឆ្នាំ២០២៥-២០២៦។ ដូច្នេះ បញ្ហាសំណើសំណូមពរខាងលើនេះ ត្រូវបាន និងកំពុងដោះស្រាយហើយ។ |
| ៣ | **នៅពុំទាន់មាននីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូល និងការប្រើប្រាស់សម្ភារសាងសង់ បរិក្ខារសំណង់ សម្ភារបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅថ្នាក់រាជធានី ខេត្ត។**<br>**ដំណើររឿង ៖** ច្បាប់ស្តីពីវិនិយោគ និងអនុក្រឹត្យលេខ១២០ បានប្រតិភូកម្មដល់រដ្ឋបាលរាជធានី ខេត្តក្នុងការពិនិត្យ និងសម្រេចលើការចុះបញ្ជីគម្រោងវិនិយោគ និងការផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគឯកជនដែលមានទុនវិនិយោគសមមូលនឹង៥លានដុល្លារអាមេរិកចុះ។ ក្នុងការអនុវត្តជាក់ស្តែងមកដល់បច្ចុប្បន្ននេះ រដ្ឋបាលរាជធានី ខេត្តនៅមិនទាន់មាននីតិវិធីច្បាស់លាស់សម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តនៅឡើយ។ |

| | |
|---|---|
| | **ដំណោះស្រាយ៖** ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅរាជធានី-ខេត្ត ត្រូវបានដាក់ចេញរួចហើយ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ដូចនេះបញ្ហានេះត្រូវបានដោះស្រាយ។ |
| ៤ | **ស្នើសុំឱ្យមានការសិក្សា និងកំណត់អំពីក្របខ័ណ្ឌពេលវេលាឱ្យមានសង្គតិភាពជាមួយគ្នារវាងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រើប្រាស់ធនធានថវិការបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋដែលបានកំណត់ក្នុងកម្មវិធីវិនិយោគបានទាន់ពេលវេលា។**<br><br>**ដំណើររឿង៖** រយៈពេលកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំប្រចាំឆ្នាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ ដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវដាក់គម្រោងថវិការបស់រដ្ឋបាលសាមីនីមួយៗជូនក្រុមប្រឹក្សាអនុម័តឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា នៃឆ្នាំមុនឆ្នាំអនុវត្តថវិកា។ ដោយឡែក ប្រកាសអន្តរក្រសួងរវាងក្រសួងផែនការ និងក្រសួងមហាផ្ទៃលេខ៧៣, ៧៤, ៧៥, ៧៦, ៧៧, ៧៨ និង៩៧ (ឆ្នាំ២០១៧) ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលសង្កាត់ ឃុំ ខណ្ឌ ស្រុក ខេត្ត រាជធានី មិនបានកំណត់ប្រតិទិនសម្រាប់ការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមជំហាននីមួយៗទេ ដែលជាហេតុធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអនុម័តកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរហូតដល់ដំណាច់ឆ្នាំ ពោលគឺកម្មវិធីវិនិយោគទាំងនោះត្រូវបានអនុម័តក្រោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ករណីនេះ គឺផ្ទុយទៅនឹងទិដ្ឋភាពបច្ចេកទេសដែលតម្រូវឱ្យការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវឆ្លើយតបទៅនឹងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សា។ ប៉ុន្តែ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងផែនការ និងក្រសួងមហាផ្ទៃបានដាក់ចេញនូវប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីនិយោគ៣ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗពិនិត្យ និងអនុម័តលើបញ្ជីគម្រោងវិនិយោគជាអាទិភាពឱ្យបានមុនដំណើរការនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ថវិកាឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងឆ្នាំនីមួយៗ។ |

| | |
|---|---|
| | **ដំណោះស្រាយ៖**<br>– ក្រសួងមហាផ្ទៃ និងក្រសួងផែនការ បានចេញប្រកាសអន្តរក្រសួងលេខ ០១៤៩ ផកប្រ.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ប្រកាសនេះ បានកែសម្រួលក្របខ័ណ្ឌពេលវេលា ឱ្យស្របតាមរំហូរការងារការរៀបចំផែនការយុទ្ធសាស្រ្តថវិកា និងគម្រោងថវិកា<br>– យ៉ាងណាក៏ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តធ្វើការជាមួយក្រសួងមហាផ្ទៃ និងក្រសួងផែនការ ដើម្បីពិនិត្យឡើងវិញក្របខ័ណ្ឌពេលវេលានៃការរៀបចំ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យទាន់ពេលប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែលកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈព្រមទាំងគិតគូរនៅក្នុងក្របខ័ណ្ឌនៃការរៀបចំយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធវិនិយោគសាធារណៈ២០២៦-២០៣០ នាពេលខាងមុខ។ |
| ៥ | **សុំប្រាក់សមាជិកភាពនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានតិចតួចក្នុងការទ្រទ្រង់ប្រតិបត្តិការ និងអនុវត្តសកម្មភាពផ្តល់សេវាដល់សមាជិកមិនបានពេញលេញ ស្នើសុំរាជរដ្ឋាភិបាលបង្កើនប្រាក់សមាជិកភាពឱ្យបាន៣% ដល់សមាគមក្រុមប្រឹក្សា។**<br>**ដំណើររឿង ៖** នាពេលបច្ចុប្បន្នប្រាក់សមាជិកភាពនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គឺមានក្នុងអត្រា២%នៃថវិកាផ្នែកប្រតិបត្តិការរដ្ឋបាលនៃមូលនិធិឃុំ សង្កាត់។ ទោះយ៉ាងនេះក្តី ចំនួនថវិកានេះមានចំនួនតិចមិនអាចរ៉ាប់រងការចំណាយនានាសម្រាប់ទ្រទ្រង់ប្រតិបត្តិការ និងអនុវត្តសកម្មភាពផ្តល់សេវាដល់សមាជិកមិនបានពេញលេញ។ អាស្រ័យហេតុនេះ ស្នើបង្កើនប្រាក់សមាជិកភាពនេះទៅ៣%នៃថវិកាផ្នែកប្រតិបត្តិការរដ្ឋបាលនៃមូលនិធិឃុំ សង្កាត់។<br>**ដំណោះស្រាយ៖** កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ក្រសួងមហាផ្ទៃបានរៀបចំកិច្ចប្រជុំពិភាក្សាលើការស្នើរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន ២% ទៅ៣%នេះ អង្គប្រជុំបានសម្រេចរក្សាអត្រា ២% ដដែល ផ្អែកលើមូលហេតុមួយចំនួន៖ |

| | |
|---|---|
| | – នៅឆ្នាំ២០២៤ ការវិភាជន៍ថវិកាពីថ្នាក់ជាតិ តាមរយៈមូលនិធិក្រុង ស្រុកបានបង្កើនអត្រាពី ១,៥% ទៅ ១,៦% និងមូលនិធិឃុំ សង្កាត់ បង្កើនអត្រាពី ៣,៤% ទៅ ៣,៥% ថេរ រហូតដល់ឆ្នាំ២០២៨ ដែលការបង្កើនអត្រានេះ សម្រាប់បង្កើនចំណាយបន្ទុកបុគ្គលិក និងចំណាយគាំទ្រសេវាសង្គម និងអនាម័យបរិស្ថាន។ ម្យ៉ាងទៀត ចំណាយប្រតិបត្តិការរដ្ឋបាលទូទៅនិងចំណាយអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានកំណើនជារៀងរាល់ឆ្នាំ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន<br>– សម្ពាធនៃចំណាយថវិកាជាតិ ពិសេសចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– យ៉ាងណាក៏ដោយ នៅពេលស្ថានភាពចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានស្ថានភាពល្អប្រសើរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសិក្សាសំណើខាងលើនេះ។ |

### តារាងឧបសម្ព័ន្ធទី៧.២ (ស្ថានភាពទី២)

## បញ្ជីបញ្ហាប្រឈម សំណើសំណូមពរចំនួន១២
## ដែលបាននិងកំពុងដោះស្រាយដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងត្រូវបានពិនិត្យ សម្រេច
## ក្នុងកិច្ចប្រជុំ គ.ជ.អ.ប. កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ និងដំណោះស្រាយ |
|---|---|
| ១ | **ស្នើសុំពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្តឱ្យស្របទៅតាមការវិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ(ការផ្ទេរធនធានមនុស្ស និងទ្រព្យសម្បត្តិរដ្ឋ) និងការបំពេញបន្ថែមនូវកិច្ចការចាំបាច់នានា(ដូចជាការគ្រប់គ្រងបុគ្គលិក ទ្រព្យសម្បត្តិរដ្ឋ...)។**<br>**ដំណើររឿង ៖** សៀវភៅណែនាំស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តនាឆ្នាំ២០១៥ ដែលមានចំណុចមួយចំនួនទាមទារឱ្យមានការពិនិត្យ និងកែសម្រួលឡើងវិញ ដូចជាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ និងរបៀបរបបការងារជាដើម)។<br>**ដំណោះស្រាយ ៖** ក្រសួងមហាផ្ទៃបាននិងកំពុងពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត អាស្រ័យហេតុនេះ ស្នើប្រគល់ភារកិច្ចនេះជូនក្រសួងមហាផ្ទៃបន្តរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំនេះនៅឆ្នាំ២០២៥។ |
| ២ | **ស្នើសុំឱ្យមានការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច ព្រមទាំងនីតិវិធីនិងស្តង់ដាសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ស្នើដោយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)។**<br>**ដំណើររឿង ៖** បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់ថវិកាមូលនិធិឆន្ទានុសិទ្ធិរបស់ខ្លួនស្ទើរទាំងអស់សម្រាប់អនុវត្តមុខងារជាជម្រើសនានាដែលផ្តោតលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងផ្តល់សេវាសង្គមមួយចំនួន។ ក្រៅពីមុខងារផ្តល់សេវារដ្ឋបាលតាមយន្តការ |

| | |
|---|---|
| | ច្រកចេញចូលតែមួយ រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីមុខងារជាកាតព្វកិច្ចជាក់លាក់ដែលចាំបាច់ត្រូវអនុវត្ត ដើម្បីធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព សុវត្ថិភាព បរិយាបន្ន និងសមធម៌សង្គម រួមមានដូចជាការផ្តល់សេវាអនាម័យបរិស្ថាន ការងារយេនឌ័រ ការងារសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម.....ជាដើម។ អាស្រ័យហេតុនេះ មានការស្នើឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវកំណត់ឱ្យបានជាក់លាក់នូវមុខងារជាកាតព្វកិច្ច ព្រមទាំងរៀបចំឱ្យមាននីតិវិធី និងស្តង់ដាសម្រាប់អនុវត្តមុខងារទាំងនោះ។<br><br>**ដំណោះស្រាយ** ៖ ការកំណត់ឱ្យបានជាក់លាក់នូវមុខងារជាកាតព្វកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការសំខាន់មួយដែលចាំបាច់ត្រូវកំណត់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិយល់ដឹងកាន់តែច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនដែលត្រូវមានផែនការ និងធនធានជាក់លាក់សម្រាប់អនុវត្តមុខងារទាំងនោះស្របតាមនីតិវិធី និងស្តង់ដាដែលបានកំណត់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ (ឧ. មុខងារអប់រំ មុខងារសុខាភិបាល មុខងារការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម មុខងារគ្រប់គ្រងសំរាម សំណល់រឹង-រាវ អនាម័យបរិស្ថានជាដើម)។ កិច្ចការនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា ដើម្បីកំណត់អំពីមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចប់ការសិក្សា និងកំណត់មុខងារជាកាតព្វកិច្ច និងរៀបចំសេចក្តីណែនាំអំពីនីតិវិធី និងស្តង់ដាសម្រាប់អនុវត្តឱ្យបានរួចរាល់ក្នុងឆ្នាំ២០២៥។ |
| ៣ | **ការអនុវត្តមុខងារការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនសមមូល៥លានដុល្លារចុះពុំទាន់អាចអនុវត្តបានពេញលេញនៅឡើយ ដោយសារក្រសួងស្ថាប័នមួយចំនួនពុំទាន់ធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរ អង្គភាពរបស់ខ្លួន និងនៅខ្វះសេចក្តីណែនាំបច្ចេកទេសអនុវត្តមួយចំនួន ព្រមទាំងការបណ្តុះបណ្តាលលើវិស័យពាក់ព័ន្ធ។ ទន្ទឹមនេះ រដ្ឋបាលរាជធានី ខេត្តក៏មិនទាន់យល់ដឹងច្បាស់អំពីតួនាទីរបស់ខ្លួនក្នុងការចូលរួមតាមដានត្រួតពិនិត្យទៅលើគម្រោងវិនិយោគដែលចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។**<br><br>**ដំណើររឿង** ៖ គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៤ មានក្រសួងចំនួន៨ បានដាក់ចេញប្រកាសឬសេចក្តីសម្រេចធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីររបស់ខ្លួន រួមមាន (១).ក្រសួងបរិស្ថាន (២).ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៣).ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ (៤).ក្រសួងសាធារណការនិងដឹកជញ្ជូន (៥).ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៦).ក្រសួងធនធានទឹកនិងឧតុនិយម (៧).ក្រសួង |

| | |
|---|---|
| | ពាណិជ្ជកម្ម និង(៨).ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ក្រសួងចំនួន៣ ពុំទាន់បានដាក់ចេញរួមមាន ក្រសួងទេសចរណ៍(កំពុងរៀបចំ) ក្រសួងសុខាភិបាល(កំពុងរៀបចំ) និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ ទន្ទឹមនោះ ក្រសួងមួយចំនួនក៏ពុំទាន់បានរៀបចំនិងដាក់ចេញសេចក្តីណែនាំបច្ចេកទេស និងផ្តល់ការបណ្តុះបណ្តាលដល់មន្ទីរ និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តនៅឡើយ។<br>**ដំណោះស្រាយ** ៖ ក្រសួងចំនួន៣ដែលមិនទាន់ដាក់ចេញប្រកាសប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីររបស់ខ្លួន បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យមន្ទីរ អង្គភាពរបស់ខ្លួន និងកំពុងរៀបចំសេចក្តីណែនាំបច្ចេកទេស ដើម្បីត្រៀមការបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពជំនាញលើការគ្រប់គ្រង និងការចុះបញ្ជីគម្រោងវិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាកំពុងរៀបចំឱ្យមានយន្តការប្រទាក់ក្រឡាគ្នា និងមានសង្គតិភាពនៃលំហូរការងារពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងការចុះបញ្ជីគម្រោងវិនិយោគ និងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគ។ |
| ៤ | **ការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់មាននីតិវិធីអនុវត្តច្បាស់លាស់។**<br>**ដំណើររឿង** ៖ ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋានគឺជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចែងនៅក្នុងជំពូកទី២ ផ្នែកទី៦ នៃច្បាប់រៀបចំអង្គការ។ សព្វថ្ងៃ ការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺផ្អែកទៅលើគំនិតផ្តួចផ្តើម ការចាត់ចែង និងការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរៀងៗខ្លួន ពុំទាន់មាននីតិវិធីច្បាស់លាស់នៅឡើយ ដូច្នេះការដាក់ចេញនីតិវិធីសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកិច្ចការចាំបាច់។<br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន) បាននិងកំពុងសហការជាមួយក្រសួងយុត្តិធម៌ក្នុងការរៀបចំ និងដាក់ចេញនូវសៀវភៅណែនាំស្តីពីនីតិវិធីនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រៀមកម្មវិធីសម្រាប់ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ស្នើសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បន្តការសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ក្នុងការរៀបចំសៀវភៅណែនាំនេះ និងផ្តល់ការបណ្តុះបណ្តាលនៅក្នុងឆ្នាំ២០២៥នេះ។ |

| | |
|---|---|
| ៥ | **ការចុះបញ្ជីអត្រានុកូលដ្ឋាននៅជួបការលំបាក៖ (១). ស្នើសុំរៀបចំចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល (២). ការផ្គត់ផ្គង់ក្រដាស និងសម្ភារអត្រានុកូលដ្ឋាន (៣). ការកែតម្រូវអត្រានុកូលដ្ឋាន។**<br><br>**ដំណើររឿង** ៖ បច្ចុប្បន្ន រដ្ឋបាលឃុំ សង្កាត់មានសមត្ថកិច្ចផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋាន និងសេចក្តីចម្លងឯកសារអត្រានុកូលដ្ឋាន (ក្នុងឆ្នាំ) ជូនប្រជាពលរដ្ឋ។ ការចុះបញ្ជី និងការចេញសេចក្តីចម្លងនេះត្រូវធ្វើឡើងដោយដៃផ្ទាល់ និងអាចមានកំហុសច្រើន។ ក្រសួងមហាផ្ទៃគឺជាអ្នកបោះពុម្ពក្រដាសអត្រានុកូលដ្ឋាន និងផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែតាមបទពិសោធន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្គត់ផ្គង់នេះមានចំនួនតិចជាងតម្រូវការ និងមានភាពយឺតយ៉ាវ។ ប្រការទាំងនេះបានធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់ជួបការលំបាក និងប្រឈមមុខជាមួយប្រជាពលរដ្ឋក្នុងការផ្តល់សេវាអត្រានុកូលដ្ឋាន។<br><br>**ដោះស្រាយ** ៖ បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃបានដាក់ឱ្យដំណើរការសាកល្បងការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដោយមានការជូនដំណឹងពីមូលដ្ឋានសុខាភិបាល ដោយផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) នៅសង្កាត់ចំនួន៦ ក្នុងរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ (ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣) ព្រមទាំងបាននិងកំពុងធ្វើបច្ចុប្បន្នភាពប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងគ្រោងដាក់ឱ្យដំណើរការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធឌីជីថលគ្រប់សង្កាត់នៅរាជធានីភ្នំពេញនៅត្រីមាសទី២ ឆ្នាំ២០២៥ និងបន្តពង្រីកគ្រប់ក្រុងនៃទីរួមខេត្ត និងពង្រីកជាបន្តបន្ទាប់នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស។ បញ្ហាប្រឈមនេះ ក្រសួងមហាផ្ទៃនឹងបន្តការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានទៅតាមផែនការដែលបានគ្រោង ព្រមទាំងពិនិត្យលទ្ធភាពក្នុងការផ្គត់ផ្គង់ក្រដាសអត្រានុកូលដ្ឋានដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្រប។ |
| ៦ | **ទំហំ ប្រភេទ និងកម្រៃសេវាមួយចំនួនដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយលែងសមស្របទៅនឹងស្ថានភាពរីកចម្រើនសេដ្ឋកិច្ច-សង្គម គួរសិក្សានិងពិនិត្យមើលទំហំ ប្រភេទ និងកម្រៃសេវាឡើងវិញ និងធ្វើបច្ចុប្បន្នភាព។**<br><br>**ដំណើររឿង** ៖ សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងអនុក្រឹត្យលេខ១៨២ លេខ១៨៣ លេខ១៨៤ ក្នុងនោះមានប្រភេទសេវាមួយចំនួននៅមិនទាន់បានកំណត់តម្លៃសេវាឡើយ ហើយមានប្រភេទសេវាមួយចំនួនដែលត្រូវធ្វើបច្ចុប្បន្នភាព ទាមទារការ |

| | |
|---|---|
| | បែងចែកទំហំសេវា និងការគណនាតម្លៃសេវាឡើងវិញឱ្យស្របទៅតាមបរិបទ និងស្ថានភាពសេដ្ឋកិច្ច។<br>**ដំណោះស្រាយ ៖** ពាក់ព័ន្ធនឹងការងារនេះ ក្រសួងមហាផ្ទៃកំពុងធ្វើបច្ចុប្បន្នភាពកម្រងសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឡើងវិញ អាស្រ័យហេតុនេះក្រសួងមហាផ្ទៃនឹងបន្តសិក្សា និងពិនិត្យមើលឡើងវិញសេវារដ្ឋបាលដែលកំពុងអនុវត្តនៅក្រុង ស្រុក ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ |
| ៧ | **នីតិវិធីការងារ៖ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង (សវនកម្មផ្ទៃក្នុង) សម្រាប់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៅមិនទាន់បានរៀបចំ ដែលជាហេតុធ្វើឱ្យការិយាល័យនេះពុំអាចអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបាន (សំណូមពរស្នើសុំដាក់ចេញនូវនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង និងផ្តល់ការបណ្តុះបណ្តាល)។**<br>**ដំណើររឿង ៖** បន្ទាប់ពីការបង្កើតការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលក្រុង ស្រុក ក្រសួង ស្ថាប័នពាក់ព័ន្ធនៅពុំទាន់បានដាក់ចេញ និងផ្តល់ការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងនៅឡើយ។ ក្នុងន័យនេះ រដ្ឋបាលក្រុង ស្រុក បានស្នើឱ្យមានការរៀបចំនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង/សវនកម្មផ្ទៃក្នុង។<br>**ដំណោះស្រាយ៖** ជំរុញក្រុមការងារបច្ចេកទេសអន្តរក្រសួងដែលបានបង្កើតរួចហើយ បន្តរៀបចំគោលការណ៍ និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការិយាល័យក្រុង ស្រុកឱ្យបានលឿន។ |
| ៨ | **មិនទាន់មានធនធានថវិកាសម្រាប់អនុវត្តមុខងារ (ការអភិវឌ្ឍ និងការផ្តល់សេវា) ដែលបានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (លើកលែងមុខងារអប់រំយុវជន និងកីឡា)។**<br>**ដំណើររឿង ៖** ផ្អែកតាមការធ្វើសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក (២០២០) មានមុខងារចំនួន៥៥ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ កន្លងមក រាជរដ្ឋាភិបាលបានផ្ទេរតែថវិកាសម្រាប់ប្រាក់បៀវត្សរ៍ និងប្រាក់ចំណាយប្រតិបត្តិការរដ្ឋបាល ប៉ុន្តែពុំទាន់បានផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ លើកលែងតែមុខងារវិស័យអប់រំ ដូច្នេះរដ្ឋបាលក្រុង ស្រុក ខណ្ឌស្នើសុំផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរឱ្យបានសមស្របតាមស្មារតីនៃអនុក្រឹត្យ១៨២ ១៨៣ និង១៨៤។ |

| | |
|---|---|
| | **ដំណោះស្រាយ៖**<br>– ក្រុមការងារអន្តរក្រសួងដែលមានសមាសភាពពី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងគ.ជ.អ.ប ត្រូវបានបង្កើត តាមរយៈសេចក្តីសម្រេចលេខ ០៦៧ សហវ.ស.ស.រ.អហក ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងសិក្សាមុខងារ និងធនធាននៃវិស័យជំនាញទាំង ២០ (មុខងារទាំង៥៥) ដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្តចំនួន៨ (រាជធានីភ្នំពេញ, កណ្តាល, ព្រះសីហនុ, ព្រៃវែង, រតនគិរី, បាត់ដំបង, សៀមរាប និងតាកែវ) ត្រូវបានសិក្សា និងពិនិត្យឡើងវិញនូវបញ្ហាប្រឈមនានាពាក់ព័ន្ធការអនុវត្តមុខងារទាំង៥៥ ក្នុងគោលបំណងផ្តល់ធនធានសមស្របសម្រាប់អនុវត្តមុខងារ កាលពីខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២៤ កន្លងមកនេះ<br>– បច្ចុប្បន្ននេះ ក្រុមការងារបានចុះសិក្សារួចរាល់ និងកំពុងបូកសរុបរៀបចំរបាយការណ៍រួមស្តីពីលទ្ធផល និងបញ្ហាប្រឈម ដើម្បីគោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នៅចុងត្រីមាសទី១ ឆ្នាំ២០២៥។ |
| ៩ | **មិនទាន់មានការកំណត់មុខសញ្ញាចំណាយ និងនីតិវិធីទូទាត់សម្រាប់ប្រើប្រាស់ថវិកាសេវាសង្គម និងអនាម័យបរិស្ថាន ស្នើសុំឱ្យមានការណែនាំឱ្យបានច្បាស់លាស់ ព្រមទាំងការកំណត់ឈ្មោះគម្រោងសេវាសង្គមនៅរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក។**<br>**ដំណើររឿង** ៖ ទោះបីអនុក្រឹត្យលេខ១៥២ និង១៥៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៣ បានកំណត់ឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់អាចប្រើប្រាស់ថវិកាសម្រាប់ការផ្តល់សេវាសង្គម និងអនាម័យបរិស្ថានក៏ដោយ ក៏រហូតមកដល់ពេលនេះ មិនទាន់មានការណែនាំច្បាស់លាស់ពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា និងនីតិវិធីទូទាត់ការចំណាយលើការផ្តល់សេវាសង្គម និងអនាម័យ បរិស្ថាននៅឡើយទេ ដែលជាហេតុធ្វើឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ជួបការលំបាកក្នុងការអនុវត្តកិច្ចការនេះ។<br>**ដំណោះស្រាយ៖** ក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ, ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប កំពុងរៀបចំសេចក្តីព្រាងសេចក្តីណែនាំ ដើម្បីកំណត់នីតិវិធីចំណាយនិងមុខសញ្ញាចំណាយជាក់លាក់ ដោយផ្អែកលើមូលដ្ឋាននីតិវិធីចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងបានឯកភាពជាគោលការណ៍កម្រិតជំនាញរួចហើយ និងគ្រោងរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥នេះ។ |

| | |
|---|---|
| ១០ | – **ប្រព័ន្ធគ្រប់គ្រងចំណូល NRMIS និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ FMIS ត្រូវបាន និងកំពុងអនុវត្តស្របគ្នាដែលធ្វើឱ្យរដ្ឋបាលរាជធានី ខេត្ត ត្រូវកត់ត្រាប្រតិបត្តិការចំណូលដដែលៗពីរដងក្នុងប្រព័ន្ធពីរផ្សេងគ្នា ដូច្នេះស្នើសុំឱ្យមានការធ្វើសន្ធានកម្មជាមួយគ្នា។**<br><br>**ដំណើររឿង** ៖ យោងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០៧ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត និងសារាចរណែនាំលេខ០០២ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រាស់ប្រព័ន្ធFMIS នៅរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលសម្រាប់ឆ្នាំ២០២២។<br><br>**ដំណោះស្រាយ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន និងកំពុងធ្វើសន្ធានកម្មរវាងប្រព័ន្ធទាំងពីរនេះ។<br><br>* * * * *<br><br>– **សំណូមពរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្លឿនការផ្តល់និយ័តភាពថវិកាឱ្យទាន់ពេលវេលា។**<br><br>**ដំណើររឿង** ៖ យោងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០២៣) កថាខណ្ឌទី៤ នៃមាត្រា៦៦ បានកំណត់ថា៖ ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយនៅផ្ទៃក្នុងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិសម្រេចក្នុងការធ្វើនិយ័តកម្មឥណទានថវិការបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់។ ការអនុវត្តជាក់ស្តែង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពុំបានធ្វើប្រតិភូកម្មនោះឡើយ ដែលធ្វើឱ្យការស្នើសុំនិយ័តភាពថវិកាតែងតែមានការយឺតយ៉ាវ។<br><br>**ដំណោះស្រាយ៖**<br><br>– ការផ្ទេរឥណទានថវិកាគឺចាប់ពីត្រីមាសទី២ នៃឆ្នាំអនុវត្តថវិកា។ ការផ្ទេរឥណទានថវិកាលើមុខសញ្ញាចំណាយដែលមានហានិភ័យទាប និងក្នុងជំពូកថវិកា ត្រូវបានប្រគល់សិទ្ធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសាមីក្នុងការសម្រេច លើកលែងតែការផ្ទេរឥណទានថវិកាឆ្លង |

| | |
|---|---|
| | ជំពូកថវិកា ទើបត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (លើកលែងរដ្ឋបាលឃុំ សង្កាត់ស្នើសុំត្រឹមរដ្ឋបាលរាជធានី ខេត្តសាមី)<br>– ការអនុវត្តកន្លងមករដ្ឋបាលថ្នាក់ក្រោមជាតិសាមីមួយចំនួនមានភាពយឺតយ៉ាវក្នុងការស្នើសុំបង្វែរឥណទានថវិកានេះ<br>– ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងយកចិត្តទុកដាក់ជំរុញបន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌការងារនៅក្នុងអគ្គនាយកដ្ឋានផ្ទាល់ ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ។<br>* * * * *<br>– **ស្នើអនុញ្ញាតឱ្យរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរងអាចរក្សាទុកសាច់ប្រាក់លើសពី២លានរៀល។**<br>**ដំណើររឿង** ៖ យោងតាមប្រការ១០ នៃប្រកាសលេខ១៨៩០ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់ក្នុងបេឡា ឬមូលប្បទានប័ត្រលើសពី ២លានរៀលឡើយ។ បច្ចុប្បន្ន ការផ្តល់សេវាប្រចាំថ្ងៃនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តមានចំនួនច្រើន ហើយតម្លៃសេវាមួយចំនួនមានតម្លៃខ្ពស់លើសពី២លានរៀល ដែលធ្វើឱ្យមន្ត្រីបេឡានៅអង្គភាពច្រកចេញចូលតែមួយមិនអាចអនុវត្តតាមគោលការណ៍ ដែលតម្រូវឱ្យរក្សាទុកទឹកប្រាក់មិនឱ្យលើសពី២លានរៀលនេះបានឡើយ ហើយក្រុមការងារសវនកម្ម ឬអធិការកិច្ចតែងតែចាប់កំហុសបុគ្គលិកបេឡារបស់អង្គភាពច្រកចេញចូលតែមួយលើបញ្ហានេះ។<br>**ដំណោះស្រាយ៖**<br>– ជាយុទ្ធសាស្ត្រកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងការកៀរគរសាច់ប្រាក់ចូលគណនីទោលរតនាគារ ដើម្បីឱ្យមានសាច់ប្រាក់គ្រប់គ្រាន់ក្នុងការបើកផ្តល់ជូនក្រសួងស្ថាប័ន និងអ្នកផ្គត់ផ្គង់វិញ ការអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់នៅតាមអង្គភាពប្រមូលចំណូលអាចនឹងធ្វើឱ្យគណនេយ្យករសាធារណៈកង្វះសាច់ប្រាក់<br>– ដើម្បីកុំឱ្យមានហានិភ័យបាត់បង់សាច់ប្រាក់ដោយសារចោរកម្ម ឬការភាន់ច្រឡំនៅពេលទទួលប្រាក់ឬដកប្រាក់<br>– ជួយលើកស្ទួយការប្រើប្រាស់ប្រព័ន្ធធនាគារ តាមរយៈការបង់ចំណូលតាម ប្រព័ន្ធអេឡិចត្រូនិក ដែលឱ្យការប្រមូលសាច់ប្រាក់ចូលគណនីទោលរតនាគារបានលឿន និងឆាប់រហ័ស ព្រោះរជ្ជទេយ្យករចំណូល ឬអ្នកបង់ចំណូល ពុំចាំបាច់ចំណាយពេលអង្គុយរង់ចាំបង់ប្រាក់នៅ |

| | |
|---|---|
| | តាមបញ្ជរធនាគារ និង<br>– ជាទិសដៅយុទ្ធសាស្ត្រកៀរគរចំណូលមិនមែនសារពើពន្ធតាមកម្មវិធីកំណែទម្រង់នៅឆ្នាំ២០២៥-២០២៧ ការអនុវត្តប្រព័ន្ធទូទាត់តាមអេឡិចត្រូនិកនឹងត្រូវដាក់ឱ្យអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ១១ | **ស្នើសុំចំណូលដែលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ (ដី អគារ បឹង សណ្ឋាគារ) ដែលស្ថិតក្នុងដែនសមត្ថកិច្ច បង់ជាចំណូលរបស់រដ្ឋបាលខេត្ត។**<br><br>**ដំណើររឿង** ៖ យោងអនុក្រឹត្យលេខ២៤៩ ឆ្នាំ២០២៤ ស្តីពីការកំណត់អត្រាចែករំលែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីរដ្ឋបាលថ្នាក់ជាតិជូនជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មាត្រា៤ បានកំណត់ថា៖ ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានចែករំលែកដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា (១). ចំណូលពីសម្បទាននេសាទក្នុងអត្រា១០០% (២). ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញរាជធានី ខេត្តក្នុងអត្រា៥០% (៣). ចំណូលពីដីសម្បទានសេដ្ឋកិច្ចក្នុងអត្រា៣០% និង(៤). ចំណូលពីផលព្រៃឈើក្នុងអត្រា៣០%។ បន្ថែមលើនេះ យោងអនុក្រឹត្យលេខ២៨៣ ឆ្នាំ២០២៣ ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កថាខណ្ឌទី៣ មាត្រា២៦ បានកំណត់ថា ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលត្រូវចែករំលែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ជូនមួយចំណែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលចូលរួមកៀរគរចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរដ្ឋបាលសាមី។ ចំណូលចែករំលែកមួយចំណែកទៀត ត្រូវផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិដោយអនុវត្តតាមយន្តការ "មូលនិធិភាតរភាព"។ អត្រានៃការបែងចែកចំណូលចែករំលែករវាងរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និងការអនុវត្តតាមយន្តការ "មូលនិធិភាតរភាព" ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ។<br><br>**ដំណោះស្រាយ៖**<br>– ផ្អែកលើលិខិតបទដ្ឋានគតិយុត្តិខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរលេខ ០១៣ សហវ.ស.រ.អគហ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ ស្តីពីការអនុវត្តគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ |

| | |
|---|---|
| | និងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ចប់សេចក្តីព្រាងមូលនិធិភាតរភាព។ សេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវបានគ្រោងដាក់ប្រជុំពិភាក្សាជាមួយក្រសួងមហាផ្ទៃ នាពេលខាងមុខ និងគ្រោងដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥<br>– លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ ត្រូវដឹកនាំកែសម្រួលប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ (ជាង៨០ប្រកាស) នាពេលខាងមុខ<br>– បច្ចុប្បន្ន សេចក្តីព្រាងប្រកាសស្តីពីការដាក់ប្រើគំរូប្រកាសអន្តរក្រសួង/ប្រកាសរួម និងគំរូរបាយការណ៍ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការពិន័យ ត្រូវបានរៀបចំរួច<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពន្លឿនការរៀបចំលិខិតបទដ្ឋាន ឬកិច្ចការនានាដែលនៅសល់ ដើម្បីអនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះ។ |
| ១២ | **យន្តការចុះត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិមានច្រើនក្រុមក្នុងមួយឆ្នាំៗ កិច្ចការទាំងនេះគឺត្រួតគ្នាដែលដាក់បន្ទុកដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (NAA, MEF, MOI, MINS…) (ស្នើដោយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់)។**<br>**ដំណើររឿង ៖** ក្នុងពេលដែលមុខងារ និងធនធានតាមវិស័យនានាកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានតម្រូវឱ្យក្រសួង ស្ថាប័នតាមវិស័យនីមួយៗត្រូវចុះធ្វើអធិការកិច្ចលើការអនុវត្តមុខងារ និងធនធានដែលបានផ្ទេរទាំងនោះ។ ប្រការនេះបាន ធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរវងសម្ពាធ និងត្រូវចំណាយពេលវេលាជាច្រើនក្នុងការចូលរួម និងឆ្លើយតបទៅនឹងសកម្មភាពនៃការចុះធ្វើអធិការកិច្ចទាំងនេះ។<br>**ដំណោះស្រាយ៖**<br>– ក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយក.ស.ហ.វ. កំពុងរៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ដើម្បីកំណត់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងការធ្វើសវនកម្មនិងអធិការកិច្ច អភិក្រមនៃការធ្វើអធិការកិច្ច ព្រមទាំងវិធាននិងនីតិវិធីប្រតិបត្តិ (Standard Operating Procedure-SOP) ឱ្យបានច្បាស់ ក្នុងគោលបំណងកាត់បន្ថយការធ្វើសវនកម្មនិងអធិការកិច្ចស្ទួនគ្នា និងច្រើនដងឆ្លើយតបទៅនឹងការធ្វើសុខដុមនីយកម្មនៃយន្តការសវនកម្ម និងអធិការកិច្ចរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា |

| | |
|---|---|
| | - ការព្រួយបារម្ភខាងលើនេះ អាចនឹងត្រូវបានដោះស្រាយ បន្ទាប់ពីការវិភាគមុខងារ និងការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន ដែលកំពុងធ្វើឡើងដោយក្រសួងមុខងារសាធារណៈ។ |

**តារាងឧបសម្ព័ន្ធទី៧.៣ (ស្ថានភាពទី៣)**

# បញ្ហាប្រឈម សំណើសំណូមពរចំនួន២៩ ដែលមានគោលការណ៍ និងបានគ្រោងជាសកម្មភាព សម្រាប់អនុវត្តរួចហើយក្នុងកម្មវិធីជាតិ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន និងត្រូវបានពិនិត្យ សម្រេចក្នុងកិច្ចប្រជុំ គ.ជ.អ.ប. ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ និងដំណោះស្រាយ |
|---|---|
| ១ | **– ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនមិនទាន់ឆ្លើយតបទៅនឹងការកើនឡើងចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ដែលស្នើសុំថ្នាក់ជាតិពិនិត្យមើលឡើងវិញនូវចំនួនសមាជិកក្រុមប្រឹក្សាឱ្យស្របទៅនឹងកើនឡើងនៃចំនួនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនោះ ស្នើសុំពិនិត្យលទ្ធភាពបង្កើតឱ្យមានការិយាល័យមួយចំនួននៅតាមឃុំ សង្កាត់។**<br>**ដំណើររឿង** ៖ ផ្អែកតាមមាត្រា១២នៃច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យឃុំ សង្កាត់ត្រូវមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពី៥រូបទៅ១១រូប ផ្អែកទៅតាមប្រជាសាស្ត្រ និងភូមិសាស្ត្រនៃឃុំ សង្កាត់ និងត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០២ រហូតមកដល់បច្ចុប្បន្ន។ សព្វថ្ងៃនេះ ចំនួនប្រជាពលរដ្ឋ និងតម្រូវការសេវាមានការកើនឡើង ហើយក្រសួង ស្ថាប័នជាច្រើន រួមទាំងអង្គការសង្គមស៊ីវិលបានស្នើសុំឱ្យមានការចូលរួម គាំទ្រ និងសហការអនុវត្តពីរដ្ឋបាលឃុំ សង្កាត់។ ដោយសារបន្ទុកការងារកើនឡើង អាស្រ័យហេតុនេះ រដ្ឋបាលឃុំសង្កាត់មួយចំនួនបានស្នើសុំពិចារណាបង្កើនចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ (ក្នុងក្របខ័ណ្ឌដែលច្បាប់បានអនុញ្ញាតពី៥ទៅ១១រូប)។ ទន្ទឹមនឹងនោះ រដ្ឋបាលឃុំ សង្កាត់មួយចំនួនក៏បានស្នើសុំពិនិត្យលទ្ធភាពបង្កើតឱ្យមានការិយាល័យមួយចំនួននៅតាមឃុំ សង្កាត់ផងដែរ។ |

**ដំណោះស្រាយ** ៖ ផ្អែកមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរប្រជាសាស្ត្រ និងភូមិសាស្ត្រ ហើយដែលអនុក្រឹត្យនេះត្រូវកំណត់យ៉ាងតិច៩ខែមុនថ្ងៃបោះឆ្នោតឃុំ សង្កាត់ (មាត្រា៦ច្បាប់បោះឆ្នោតឃុំ សង្កាត់)។ អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃនឹងសិក្សា និងលើកសំណើ ដើម្បីគោរពស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងការស្នើសុំបង្កើតឱ្យមានការិយាល័យមួយចំនួននៅតាមឃុំ សង្កាត់ ផ្អែកតាមច្បាប់គ្រប់គ្រងឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធក្រោមច្បាប់ រដ្ឋបាលឃុំ សង្កាត់អាចរៀបចំឱ្យមានគណៈកម្មាធិការនានាតាមការចាំបាច់ ដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានារបស់ឃុំ សង្កាត់ ព្រមទាំងអាចរៀបចំឱ្យមានបុគ្គលិក (មន្ត្រីកិច្ចសន្យា) ទទួលបន្ទុកការងារផ្សេង (ការងារហិរញ្ញវត្ថុ សេវាសង្គម សេវារដ្ឋបាល....) ទៅតាមការចាំបាច់ និងលទ្ធភាពថវិការបស់ឃុំ សង្កាត់។ ដូច្នេះ ចំពោះការស្នើសុំបង្កើតការិយាល័យនៅថ្នាក់ឃុំ សង្កាត់នេះ ស្នើជូនក្រសួងមហាផ្ទៃធ្វើការសិក្សាអំពីលទ្ធភាពនៃរៀបចំឱ្យមានការិយាល័យឬផ្នែកដោយផ្អែកទៅតាមស្ថានភាព និងតម្រូវការសេវាតាមឃុំ សង្កាត់នានា។

*****

## – ស្នើសុំឱ្យមានការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការរៀបចំជារដ្ឋបាលសង្កាត់ចំណុះស្រុក។

**ដំណើររឿង** ៖ ផ្អែកតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្រុក ចែងថា «...**ស្រុកចែកជាឃុំ និងជាសង្កាត់** តែរហូតមកដល់ពេលនេះ ពុំទាន់មានការកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់នៅក្នុងការបង្កើតសង្កាត់នៅក្នុងស្រុកឡើយ ដូច្នេះស្នើសុំឱ្យមានការកំណត់លក្ខណៈវិនិច្ឆ័យ ច្បាស់លាស់សម្រាប់ការរៀបចំជារដ្ឋបាលសង្កាត់នាពេលអនាគត។

**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងធ្វើការសិក្សា និងកំណត់អំពីលក្ខណៈវិនិច្ឆ័យនៃការរៀបចំសង្កាត់ក្នុងស្រុក ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច សម្រាប់ធ្វើជាមូលដ្ឋានលើការរៀបចំប្រែក្លាយឃុំដែលមានលក្ខណៈជាទីប្រជុំជន ទៅជាសង្កាត់ក្នុងស្រុកនាពេលអនាគត។

| | |
|---|---|
| ២ | – **ស្នើសុំឱ្យមានការពិនិត្យ និងកែសម្រួលសៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យស្របទៅតាមស្ថានភាពនៃការវិវឌ្ឍន៍នៃកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ការរីកចម្រើននៃបច្ចេកវិទ្យា និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។**<br>**ដំណើររឿង** ៖ សៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០០៥ រហូតមកពេលនេះ កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់មានការប្រែប្រួល និងមានកិច្ចការថ្មីៗជាច្រើន ដែលត្រូវឱ្យមានឯកសារគោលទុកប្រើប្រាស់ជាមូលដ្ឋាននៅក្នុងការអនុវត្តការងារឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ចេញ។<br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃនឹងសិក្សា ពិនិត្យ និងកែសម្រួលសៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យស្របទៅតាមស្ថានភាពនៃការវិវឌ្ឍន៍នៃកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ការរីកចម្រើននៃបច្ចេកវិទ្យា និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។ |
| ៣ | – **ស្នើរៀបចំឱ្យមានលក្ខណៈវិនិច្ឆ័យសម្រាប់រៀបចំជារដ្ឋបាលក្រុង។**<br>**ដំណើររឿង** ៖ កន្លងមកនេះ មិនទាន់មានលក្ខណៈវិនិច្ឆ័យជាក់លាក់សម្រាប់ការបង្កើតរដ្ឋបាលក្រុង ឬប្រែក្លាយរដ្ឋបាលស្រុកដែលជាទីប្រជុំជនឱ្យទៅជារដ្ឋបាលក្រុង អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានស្នើឱ្យមានការកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការបង្កើតក្រុង និងការប្រែក្លាយស្រុកទៅជាក្រុង។<br>**ដំណោះស្រាយ** ៖ កិច្ចការនេះមានកំណត់ជាសកម្មភាពអាទិភាពនៅក្នុងកម្មវិធីជាតិដំណាក់កាលទី២នៃ គ.ជ.អ.ប. ហើយបាន និងកំពុងសិក្សាដោយក្រសួងមហាផ្ទៃ អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តធ្វើការសិក្សា និងកំណត់អំពីលក្ខណៈវិនិច្ឆ័យនៃការរៀបចំក្រុង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចសម្រាប់ធ្វើជាមូលដ្ឋានលើការរៀបចំប្រែក្លាយស្រុកដែលមានលក្ខណៈទីប្រជុំជន ទៅជាក្រុងនាពេលអនាគត។<br>***** |

| | |
|---|---|
| | – ស្នើសុំឱ្យមានការសិក្សា និងពិនិត្យមើលឡើងវិញលើការរៀបចំរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុកឱ្យស្របទៅតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពលសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែង។<br>**ដំណើររឿង ៖** រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំឡើងវិញនៅឆ្នាំ២០២០ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញទាំងអស់ ទាំងបុគ្គលិក និងមុខងារក្នុង២០វិស័យឱ្យទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ ទោះបីជារចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង និងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុកមានលក្ខណៈខុសគ្នាខ្លះៗដោយឆ្លុះបញ្ចាំងទៅនឹងមុខងារផ្តល់សេវាទីប្រជុំជនរបស់រដ្ឋបាលក្រុង និងមុខងារផ្តល់សេវាជនបទ (កសិកម្ម ធនធានធម្មជាតិ...) របស់រដ្ឋបាលស្រុកក៏ដោយ ក៏រចនាសម្ព័ន្ធថ្មី និងមុខងាររបស់រដ្ឋបាលក្រុងនីមួយៗ ស្រុកនីមួយៗ មានលក្ខណៈដូចគ្នាទាំងអស់ដោយពុំទាន់បានឆ្លុះបញ្ចាំងទៅតាមក្រុង ស្រុកដែលមានប្រជាជនច្រើន ឬតិច ឬឆ្លុះបញ្ចាំងទៅនឹងតម្រូវការសេវា និងសក្តានុពលខុសៗគ្នារបស់រដ្ឋបាលក្រុង ស្រុកនីមួយៗឡើយ។<br>**ដំណោះស្រាយ ៖** លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ នឹងដឹកនាំសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធសិក្សា ពិនិត្យមើលឡើងវិញ និងលើកយោបល់អំពីជម្រើសនានាសម្រាប់ការរៀបចំរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗឱ្យស្របទៅតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពលសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែង។ |
| ៤ | – រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តពុំទាន់បានរៀបចំឱ្យស្របទៅតាមគោលការណ៍នៃរដ្ឋបាលឯកភាពដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ ជាហេតុធ្វើឱ្យក្រុមប្រឹក្សារាជធានី ខេត្តពុំទាន់អាចម្ចាស់ការពេញលេញក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលប្រកបដោយប្រសិទ្ធភាពលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍលើគ្រប់វិស័យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។<br>**ដំណើររឿង ៖** ច្បាប់រៀបចំអង្គការបានតម្រូវឱ្យរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចដឹកនាំ សម្របសម្រួលការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមវិស័យនានា ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នាឆ្នាំ២០២០ រចនាសម្ព័ន្ធនៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងវិញ ដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញទាំងអស់ឱ្យទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកតាមគោលការណ៍នៃរដ្ឋបាល |

| | |
|---|---|
| | ឯកភាព។ ប្រការនេះបានធ្វើឱ្យក្រុមប្រឹក្សាក្រុង ស្រុកមានសមត្ថកិច្ចដឹកនាំ គ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួន។ ដោយឡែក ចំពោះរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត បច្ចុប្បន្ន គឺបានធ្វើសមាហរណកម្មតែមន្ទីរសុខាភិបាលមួយប៉ុណ្ណោះឱ្យទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត។ មន្ទីរជំនាញក្នុងវិស័យជាអាទិភាពផ្សេងទៀតគឺនៅស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ដែលប្រការនេះបានធ្វើឱ្យក្រុមប្រឹក្សារាជធានី ខេត្តមិនអាចដឹកនាំសម្របសម្រួលការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមវិស័យជំនាញទាំងនោះឱ្យមានប្រសិទ្ធភាពស្របតាមការកំណត់ដោយច្បាប់រៀបចំអង្គការនៅឡើយ។ អាស្រ័យហេតុនេះ រដ្ឋបាលខេត្តមួយចំនួនបានលើកសំណើឱ្យមានការសិក្សាពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តដោយស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។<br><br>**ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួង (លេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ) បានរៀបចំឯកសារទស្សនទាន និងផែនការសម្រាប់ការសិក្សាពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលមុខងារ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ព្រមទាំងគ្រោងទស្សនកិច្ចសិក្សាទៅប្រទេសមួយចំនួន (ប្រទេសថៃ ឥណ្ឌូនេស៊ី...) នៅដើមឆ្នាំ២០២៥នេះ អាស្រ័យហេតុនេះ ក្រុមការងារអន្តរក្រសួងនេះនឹងបន្តការសិក្សាឱ្យបានរួចរាល់នៅឆ្នាំ២០២៥។<br><br>*****<br><br>– **រចនាសម្ព័ន្ធជាអង្គភាព/ទីចាត់ការនៃរដ្ឋបាលខេត្តមួយចំនួននៅពុំទាន់មានភាពសមស្របជាមួយនឹងស្ថានភាពនៃការរីកចម្រើននៃបច្ចេកវិទ្យា និងវិធានការគន្លឹះនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលករណីនេះចាំបាច់ត្រូវមានការពិនិត្យមើលឡើងវិញនូវមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត។ កិច្ចការអាទិភាព គឺស្នើសុំឱ្យមានការសិក្សាអំពីលទ្ធភាពនៃការបង្កើត ៖**<br>**(១). អង្គភាពសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលរាជធានី ខេត្ត ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ចាត់ចែង និងការអនុវត្តមុខងារ និងធនធាន**<br>**(២). អង្គភាពបរិវត្តកម្មឌីជីថលសម្រាប់រដ្ឋបាលរាជធានី ខេត្ត។**<br><br>**ដំណើររឿង** ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្តត្រូវរៀបចំឡើងវិញនៅឆ្នាំ២០០៩ ហើយរចនាសម្ព័ន្ធគ្រប់គ្រងនេះមានលក្ខណៈដូចៗគ្នាពីខេត្តមួយទៅខេត្តមួយ។ គិតរហូតមកដល់ពេលនេះ មានរយៈពេល១៥ឆ្នាំហើយ ដែលក្នុងអំឡុងពេលនេះ ត្រូវបានពិនិត្យឃើញថាទាំងស្ថានភាព |

ប្រជាពលរដ្ឋ សេដ្ឋកិច្ច តម្រូវការសង្គម ផ្នែកបច្ចេកវិទ្យា និងសក្តានុពលនានាមានការប្រែប្រួលយ៉ាងខ្លាំង ដែលតម្រូវឱ្យមានការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្តឡើងវិញ ដើម្បីឱ្យឆ្លុះបញ្ចាំងទៅនឹងស្ថានភាពនៃតម្រូវការជាក់ស្តែង និងស្របតាមសក្តានុពលនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមរដ្ឋបាលខេត្តនីមួយៗ។

**ដំណោះស្រាយ** ៖ ការស្នើសុំពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធជាអង្គភាព ឬទីចាត់ការរបស់រដ្ឋបាលរាជធានី ខេត្តនេះ មានការពាក់ព័ន្ធទៅនឹងការសិក្សាការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តទាំងមូល អាស្រ័យហេតុនេះ ត្រូវរង់ចាំការពិនិត្យ និងរៀបចំនូវរចនាសម្ព័ន្ធ និងប្រព័ន្ធឡើងវិញតែម្តង។ ប៉ុន្តែចំពោះមុខ ការស្នើសុំពិចារណាលើការបង្កើតអង្គភាពពីរគឺអង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពបរិវត្តកម្មឌីជីថលសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រសួងមហាផ្ទៃនឹងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងលេខាធិការដ្ឋាន គ.ជ.អ.ប. សិក្សា និងលើកយោបល់លើការបង្កើតអង្គភាពទាំងពីរនេះ។

*****

- **ស្នើសុំឱ្យមានការកំណត់មុខងារ និងការទទួលខុសត្រូវឱ្យបានជាក់លាក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិ។**

**ដំណើររឿង** ៖ កន្លងមក ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការនានា ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមទទួលខុសត្រូវលើការការពារ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសធនធានធម្មជាតិ ព្រមទាំងធ្វើវិសោធនកម្មច្បាប់ព្រៃឈើ ច្បាប់ជលផល និងច្បាប់តំបន់ការពារធម្មជាតិ ដើម្បីបើកផ្លូវឱ្យមានការផ្ទេរមុខងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រមបរិស្ថាន(ដែលបានដាក់បញ្ចូលនូវច្បាប់តំបន់ការពារធម្មជាតិ) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនាពេលថ្មីៗនេះ ព្រមទាំងបានកំណត់ និងបែងចែកតួនាទី និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍតំបន់ធម្មជាតិក៏ដោយ ក៏ប៉ុន្តែលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តក្រមបរិស្ថាននេះនៅពុំទាន់ត្រូវបានរៀបចំ និងផ្សព្វផ្សាយអនុវត្តនៅឡើយ ជាពិសេសអនុក្រឹត្យផ្ទេរមុខងារគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិនៅពុំទាន់បានរៀបចំដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

| | |
|---|---|
| | **ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ គិតមកដល់ពេលនេះ ក្រមបរិស្ថានបានដាក់ចេញ និងសេចក្តីព្រាងច្បាប់ស្តីពីជលផលបានដាក់ឆ្លងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីរួចហើយផងដែរ ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើកំពុងស្ថិតក្រោមការពិនិត្យរបស់ក្រសួងយុត្តិធម៌។ អាស្រ័យហេតុនេះ ក្រសួងបរិស្ថាននឹងសហការជាមួយក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ដើម្បីរៀបចំ កំណត់មុខងារជាក់លាក់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ស្របទៅតាមក្រមបរិស្ថានដែលបានកំណត់ ដើម្បីលើកសំណើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ស្នើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយនឹងក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ដើម្បីពិនិត្យមើលមុខងារសមស្របដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់ពីច្បាប់ជលផល និងច្បាប់ព្រៃឈើដាក់ចេញឱ្យប្រើប្រាស់។ |
| ៥ | – **ស្នើសុំឱ្យមានការបន្តការប្រឡងប្រជែងជើងឯកផ្តល់សេវាសាធារណៈ ដោយគិតគូរអំពីការដាក់បញ្ចូលគ្នានូវការផ្តល់សេវាសង្គម ការងារគណនេយ្យភាពសង្គម សេវារដ្ឋបាល និងភូមិឃុំ សង្កាត់មានសុវត្ថិភាព។**<br>**ដំណើររឿង** ៖ កន្លងមកក្រសួងមហាផ្ទៃបានដាក់ឱ្យអនុវត្តនូវកម្មវិធីប្រកួតប្រជែងជើងឯកសេវាសង្គម ប៉ុន្តែបច្ចុប្បន្នត្រូវបានបញ្ចប់នៅឆ្នាំ២០២៣។ ក្នុងន័យនេះ ឃុំ សង្កាត់បានស្នើសុំឱ្យមានការបន្តការប្រកួតប្រជែងជើងឯកផ្តល់សេវាសង្គមដោយគិតគូរអំពីការដាក់បញ្ចូលការផ្តល់សេវាសង្គមនេះរួមជាមួយនឹងការផ្តល់សេវាសាធារណៈផ្សេងៗទៀតដែលមានកំណត់នៅក្នុងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។<br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងសិក្សាអំពីជម្រើស និងលទ្ធភាពនៃការរៀបចំកម្មវិធីប្រកួតប្រជែងនេះ និងស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល។ ការសិក្សានេះ ផ្តោតលើរៀបចំឱ្យមានយន្តការ នីតិវិធី សូចនាករ លក្ខណៈវិនិច្ឆ័យ និងប្រាក់រង្វាន់សមស្របសម្រាប់លើកទឹកចិត្តអង្គភាពដែលជាប់ជ័យលាភី។ |
| ៦ | – **ស្នើសុំឱ្យមានការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារដែលបានផ្ទេរមួយចំនួនដែលពុំទាន់បានធ្វើការបណ្តុះបណ្តាល ដូចជាមុខងារកសិកម្ម អភិវឌ្ឍជនបទ ធនធានទឹក ទេសចរណ៍...ជាដើម។** |

| | |
|---|---|
| | **ដំណើររឿង** ៖ ទន្ទឹមនឹងការធ្វើសមារណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ(២០២០) មានមុខងារចំនួន៥៥ត្រូវបានផ្ទេរភ្ជាប់ទៅជាមួយ។ មុខងារមួយចំនួនត្រូវបានរៀបចំឱ្យមានគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្ត ព្រមទាំងមានការបណ្តុះបណ្តាលជាបន្តបន្ទាប់ ដូចជាមុខងារអប់រំ បរិស្ថាន និងមុខងារផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ប៉ុន្តែនៅមានមុខងារមួយចំនួនទៀតនៅពុំទាន់មានគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តច្បាស់លាស់នៅឡើយ ដូចជាមុខងារកសិកម្ម អភិវឌ្ឍជនបទ ធនធានទឹក ទេសចរណ៍ ជាដើម។<br><br>**ដំណោះស្រាយ** ៖ ផ្អែកតាមគោលការណ៍នៃការផ្ទេរមុខងារ ក្រសួង ស្ថាប័នដែលផ្ទេរមុខងារ ចាំបាច់ត្រូវរៀបចំឱ្យមានសេចក្តីណែនាំបច្ចេកទេស ស្តង់ដាសេវា និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពក្នុងការគ្រប់គ្រង ចាត់ចែងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ អាស្រ័យហេតុនេះ ក្រសួងដែលបានផ្ទេរមុខងារនឹងពន្លឿនការដាក់ចេញសេចក្តីណែនាំបច្ចេកទេសឱ្យបានឆាប់ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក និងមន្ត្រីបច្ចេកទេសក្រោមការសម្របសម្រួលរបស់ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ។ |
| ៧ | – **ស្នើពិចារណាផ្ទេរមុខងារគ្រប់គ្រងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក មកស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។**<br><br>**ដំណើររឿង** ៖ បច្ចុប្បន្ននេះ មុខងារក្នុងវិស័យសុខាភិបាលរួមមានមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពទាំងអស់ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តចាប់តាំងពីឆ្នាំ២០២០មក។ ដោយឡែក រដ្ឋបាលក្រុង ស្រុកពុំទាន់មានតួនាទីសំខាន់ណាមួយក្នុងវិស័យសុខាភិបាលនៅឡើយ ទោះបីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុកគឺជាអង្គភាពដែលត្រូវមានកិច្ចសហការ និងគាំទ្រយ៉ាងច្រើនពីរដ្ឋបាលក្រុង ស្រុកក៏ដោយ។<br><br>**ដំណោះស្រាយ** ៖ កិច្ចការនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានកំពុងសហការជាមួយក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ដើម្បីសិក្សា និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាវិស័យសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងសិក្សាអំពីលទ្ធភាពនៃការធ្វើ |

| | |
|---|---|
| | ប្រតិភូកម្មមុខងារសមស្របមួយចំនួនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយធានាឱ្យបាននូវនិរន្តរភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាល អាស្រ័យហេតុនេះ ស្នើឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប. បន្តអនុវត្តកិច្ចការនេះឱ្យបានរួចរាល់នៅឆ្នាំ២០២៥។<br>******<br>– **ស្នើសុំពិចារណាផ្ទេរមុខងារគ្រប់គ្រងសត្តឃាតដ្ឋាន។**<br>**ដំណើររឿង** ៖ ការគ្រប់គ្រងសត្តឃាតដ្ឋាន ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានីខេត្តផ្តល់សេវាតាមអង្គភាពច្រកចេញចូលតែមួយ (អនុក្រឹត្យលេខ១៨)។ ការអនុវត្តជាក់ស្តែង សត្តឃាតដ្ឋាននៅតាមស្រុកដែលនៅឆ្ងាយពីទីរួមខេត្ត ពុំទាន់មានការគ្រប់គ្រងបានល្អប្រសើរនៅឡើយ (ការតាមដានត្រួតពិនិត្យ)។ ប្រការនេះ ដើម្បីធានាដល់ការគ្រប់គ្រងសត្តឃាតដ្ឋានទាំងនេះឱ្យមានប្រសិទ្ធភាព រដ្ឋបាលស្រុកមួយចំនួនបានស្នើសុំឱ្យពិនិត្យលទ្ធភាពនៃការផ្ទេរមុខងារគ្រប់គ្រងសត្តឃាតដ្ឋានទាំងនេះទៅឱ្យរដ្ឋបាលស្រុក។<br>**ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយនឹងលេខាធិការដ្ឋាន គ.ជ.អ.ប. និងអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃនឹងសិក្សា និងពិនិត្យមើលអំពីលទ្ធភាពនៃការផ្ទេរមុខងារនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ដើម្បីប្រសិទ្ធភាពនៃការគ្រប់គ្រងសត្តឃាតដ្ឋាន។ |
| ៨ | – **ឃុំ សង្កាត់មួយចំនួនពុំមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីជ្រើសរើសបុគ្គលិកជំនួយការរដ្ឋបាលឃុំ សង្កាត់ឱ្យឆ្លើយតបទៅនឹងទំហំការងារ និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលឃុំ សង្កាត់ (ចំនួន និងសមត្ថភាពសមស្រប) ដោយសារធនធានថវិកាផ្នែករដ្ឋបាលរបស់ឃុំ សង្កាត់មានកម្រិត។**<br>**ដំណើររឿង** ៖ អនុលោមតាមសេចក្តីណែនាំ០៥៥ ស.ណ.ន. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ បានណែនាំឱ្យរដ្ឋបាលឃុំ សង្កាត់អាចធ្វើការជ្រើសរើសបុគ្គលិកកិច្ចសន្យាមួយចំនួនធ្វើជាជំនួយការរដ្ឋបាលឃុំ សង្កាត់ អាស្រ័យទៅនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់(២នាក់ សម្រាប់ឃុំ សង្កាត់មានសមាជិកក្រុមប្រឹក្សាពី៥នាក់ទៅ៧នាក់ ៣នាក់ សម្រាប់ឃុំ សង្កាត់មានសមាជិកក្រុមប្រឹក្សាពី៩នាក់ទៅ១១នាក់)។ ទោះយ៉ាងនេះក្តី ដោយសារធនធានថវិកាផ្នែករដ្ឋបាលរបស់ |

| | |
|---|---|
| | ឃុំ សង្កាត់នៅមានកម្រិតបានធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់មិនមានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកកិច្ចសន្យាឱ្យឆ្លើយតបទៅនឹងបន្ទុកការងាររបស់ខ្លួនបានឡើយ។<br>**ដំណោះស្រាយ** ៖ ការអនុវត្តជាក់ស្តែងកន្លងមក ឃុំ សង្កាត់នីមួយៗបានជ្រើសរើសបុគ្គលិកកិច្ចសន្យារបស់ខ្លួនទាំងចំនួន និងសមត្ថភាពសមស្របទៅនឹងបន្ទុកការងារ ប៉ុន្តែឃុំ សង្កាត់មួយចំនួនពុំអាចមានលទ្ធភាពក្នុងការជ្រើសរើសបុគ្គលិកកិច្ចសន្យាដែលមានសមត្ថភាពសមស្របក្នុងការអនុវត្តការងាររបស់ឃុំ សង្កាត់នៅឡើយ ដូចនេះ ក្រសួងមហាផ្ទៃ សហការជាមួយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹងសិក្សាពីបន្ទុកការងាររបស់ឃុំ សង្កាត់ កំណត់អំពីតម្រូវការបុគ្គលិក និងលទ្ធភាពបង្កើនថវិកាបន្ទុកបុគ្គលិក ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់មានលទ្ធភាពអាចជ្រើសរើសបុគ្គលិកកិច្ចសន្យាដែលមានសមត្ថភាពសមស្រប។<br>*****<br>– **ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលដើម្បីធ្វើបច្ចុប្បន្នភាពដល់ស្មៀនឃុំ សង្កាត់អំពីការងាររដ្ឋបាល ផែនការ ហិរញ្ញវត្ថុ លទ្ធកម្ម និងបច្ចេកវិទ្យាឌីជីថល និងស្នើសុំឱ្យមានការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាដែលមានការផ្លាស់ប្តូរថ្មី។**<br>**ដំណើររឿង** ៖ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងរៀងរាល់០៥ឆ្នាំម្តង។ រៀងរាល់ការបោះឆ្នោតម្តងសមាជិកក្រុមប្រឹក្សាមួយចំនួនត្រូវបានផ្លាស់ប្តូរ ហើយក្រសួងមហាផ្ទៃក៏បានធ្វើការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាថ្មីផងដែរបន្ទាប់ពីការបោះឆ្នោតតាមអាណត្តិនីមួយៗ ប៉ុន្តែការផ្លាស់ប្តូរសមាជិកថ្មីក្នុងអាណត្តិ (ករណីមរណភាព ការបាត់បង់សមាជិកភាព..) នៅមិនទាន់រៀបចំការបណ្តុះបណ្តាលឱ្យបានភ្លាមៗនៅឡើយទេ។ ទន្ទឹមនោះ ស្មៀនឃុំ សង្កាត់មួយចំនួនក៏ត្រូវបានផ្លាស់ប្តូរ ហើយការកសាងសមត្ថភាពដល់ស្មៀនឃុំ សង្កាត់អំពីនីតិវិធីថ្មីៗដែលបានដាក់ចេញក៏មិនទាន់បានធ្វើឡើងជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធនៅឡើយ គឺមានតែកម្រិតការផ្សព្វផ្សាយ ការណែនាំអនុវត្តទៅតាមនីតិវិធី និងគោលការណ៍ថ្មីៗដែលបានដាក់ចេញដោយថ្នាក់ជាតិ។ ក្នុងន័យនេះ ឃុំ សង្កាត់បានលើកសំណើនេះឡើង ដើម្បីឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធជួយបណ្តុះបណ្តាលដល់ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលផ្លាស់ប្តូរថ្មី។ |

| | |
|---|---|
| | **ដំណោះស្រាយ** ៖ សាលាជាតិរដ្ឋបាលមូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ នឹងសហការជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ សិក្សាអំពីតម្រូវការនៃការបណ្តុះបណ្តាលដល់ស្មៀនឃុំ សង្កាត់ រៀបចំកម្មវិធីសិក្សាជាក់លាក់សម្រាប់អភិវឌ្ឍសមត្ថភាពដល់ស្មៀនឃុំ សង្កាត់ដែលត្រូវធ្វើឡើងជាប្រចាំ ព្រមទាំងគិតគូរអំពីវិធីសាស្ត្រសមស្របដើម្បីផ្តល់ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាទាំងថ្មី និងចាស់យ៉ាងហោចណាស់ឱ្យបានមួយដងក្នុង១អាណត្តិ។ |
| ៩ | **– មន្ត្រីមួយចំនួននៅពុំមានសមត្ថភាពសមស្របឆ្លើយតបទៅនឹងតម្រូវការការងារ និងជំនាញដែលតម្រូវឱ្យមានការបណ្តុះបណ្តាល (ការរៀបចំរបាយការណ៍ និងនីតិវិធីហិរញ្ញវត្ថុ លទ្ធកម្ម ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ គម្រោងសេវាសង្គម ការប្រើប្រាស់ប្រព័ន្ធឌីជីថល ការសម្រុះសម្រួលដោះស្រាយវិវាទ...) ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចជាប្រចាំឆ្នាំដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>**– សមត្ថភាព និងលទ្ធភាពនៃការអភិវឌ្ឍធនធានមនុស្សរបស់ទីចាត់ការគ្រប់គ្រងធនធានមនុស្សនៅមានកម្រិត។**<br><br>**ដំណើររឿង** ៖ រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវបានរៀបចំឱ្យមានទីចាត់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សដែលមានតួនាទីគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពបុគ្គលិកក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរាជធានី ខេត្តផង និងផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ផង។ ជារួម ដោយសារចំនួនបុគ្គលិក និងចំនួនក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់មានចំនួនច្រើន ព្រមទាំងមានតម្រូវការអភិវឌ្ឍសមត្ថភាពតាមអាណត្តិនីមួយៗនៃក្រុមប្រឹក្សាច្រើនផងដែរ ដែលប្រការនេះធ្វើឱ្យទីចាត់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗមិនអាចមានលទ្ធភាព និងសមត្ថភាពផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពឱ្យមានប្រសិទ្ធភាពបានឡើយ គឺចាំបាច់ត្រូវមានការពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនេះ។<br><br>**ដំណោះស្រាយ** ៖ ចំពោះមុខត្រូវបង្កើនសមត្ថភាព និងលទ្ធភាពនៃការបណ្តុះបណ្តាលពីសាលាជាតិរដ្ឋបាលមូលដ្ឋានឱ្យបានកាន់តែច្រើនដល់ក្រុមប្រឹក្សា បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមនេះ ក៏ចាំបាច់ត្រូវពង្រឹងសមត្ថភាព និងលទ្ធភាពរបស់ទីចាត់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សថ្នាក់រាជធានី ខេត្ត តាមរយៈការរៀបចំឱ្យមានក្រុមគ្រូបង្គោលដើម្បីរួមចំណែកដល់ការផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សម្រាប់រយៈពេលមធ្យមទៅវែង ចាំបាច់ត្រូវមានការសិក្សាអំពីជម្រើសនៃការបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់នៅតាម |

| | |
|---|---|
| | ភូមិភាគមួយចំនួន និងពង្រឹងកិច្ចសហការគ្រឹះស្ថានសិក្សាក្នុងការជួយបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ កិច្ចការទាំងនេះ សាលាជាតិរដ្ឋបាលមូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃនឹងសហការជាមួយស្ថាប័នពាក់ព័ន្ធសិក្សាអំពីជម្រើសនានាបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់នេះ។ |
| ១០ | **ការប្រមូលចំណូលពីសេវារដ្ឋបាលវិស័យសាធារណការ ដែលអនុវត្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបង់មកថ្នាក់ជាតិ ហើយបន្ទាប់មកទើបថ្នាក់ជាតិបង្វែរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្នើសុំផ្ទេរការគ្រប់គ្រងចំណូលមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។**<br><br>**ដំណើររឿង** ៖ តាមរយៈអនុក្រឹត្យលេខ១៨ មុខងារផ្តល់សេវារដ្ឋបាលមួយចំនួនក្នុងវិស័យសាធារណការ និងដឹកជញ្ជូនត្រូវផ្ទេរជូនរដ្ឋបាលរាជធានី ខេត្ត និងត្រូវអនុវត្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ប្រជាពលរដ្ឋត្រូវបង់កម្រៃសេវាតាមប្រព័ន្ធធនាគារ ឬភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់ ហើយចំណូលទាំងនោះត្រូវបង់ទៅគណនីរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមិនមែនបង់ទៅគណនីរបស់រាជធានី ខេត្តសាមីនីមួយៗទេ។ ជារៀងរាល់ខែ ក្រសួងសាធារណការនឹងផ្ទេរថវិកាទាំងនោះជូនរដ្ឋបាលរាជធានី ខេត្ត តែចំណែកថវិកាជាគុណប្រយោជន៍របស់រដ្ឋបាលរាជធានី ខេត្ត និងចំណែកប្រាក់រង្វាន់របស់រដ្ឋបាលរាជធានី ខេត្តប៉ុណ្ណោះ។ ដោយឡែកចំណែកប្រាក់រង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាល ចំណែកប្រាក់រង្វាន់របស់មន្ទីរសាធារណការ និងចំណែកប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការគឺជាអ្នកបែងចែកជូនភាគីពាក់ព័ន្ធ។ ករណីនេះបានបង្កជាការលំបាកដល់រដ្ឋបាលរាជធានី ខេត្តក្នុងការគ្រប់គ្រងចំណូលទាំងនេះ ពិបាកក្នុងការគ្រោងចំណូល និងពិបាកក្នុងការអនុវត្តកិច្ចបញ្ជិកាគណនេយ្យ ស្របតាមខ្លឹមសារមាត្រា៩ នៃអនុក្រឹត្យលេខ២៥ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយ។ ដោយឡែក រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួនមិនទាន់យល់ច្បាស់ពីការបែងចែកនេះ ឬមិនបានទទួលថវិកាពីក្រសួងសាធារណការតែម្តង។<br><br>**ដំណោះស្រាយ** ៖ ក្រសួងសាធារណការ និងដឹកជញ្ជូននឹងពិភាក្សាជាមួយអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ដើម្បីពិនិត្យមើលឡើងវិញ និងផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងចំណូលជូនរដ្ឋបាលរាជធានី ខេត្តដែលទទួលបានពីការផ្តល់សេវាដែលបានធ្វើប្រតិភូកម្ម ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ២៨៣ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌផ្ទេរមុខងារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។ |

| | |
|---|---|
| ១១ | – **ស្នើសុំដល់ក្រសួង ស្ថាប័នថ្នាក់ជាតិផ្តល់ព័ត៌មាន ឬពិគ្រោះយោបល់ជាមួយរដ្ឋបាលខេត្តពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណលើការអភិវឌ្ឍ ឬការរៀបចំអនុវត្តគម្រោងអភិវឌ្ឍន៍នានានៅក្នុងខេត្ត។**<br><br>**ដំណើររឿង ៖** គម្រោងវិនិយោគ ឬគម្រោងអភិវឌ្ឍមួយចំនួនតូច មិនត្រូវបានជូនដំណឹងទៅឱ្យរដ្ឋបាលខេត្តទេ ជាហេតុធ្វើឱ្យគម្រោងខ្លះមិនអាចអនុវត្តបាន ឬអនុវត្តដោយខុសប្លង់គោលប្រើប្រាស់ដីរបស់ខេត្ត ដូច្នេះស្នើសុំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានាគួរឱ្យរដ្ឋបាលខេត្តចូលរួមចាប់តាំងពីដំណើរការសិក្សាគម្រោងដល់ការអនុវត្តគម្រោង។<br><br>**ដំណោះស្រាយ ៖** ក្រសួង ស្ថាប័នពាក់ព័ន្ធនានា នឹងផ្តល់ព័ត៌មានអំពីការរៀបចំគម្រោងអភិវឌ្ឍន៍របស់ខ្លួន ដោយមានការពិភាក្សាជាមួយរដ្ឋបាលខេត្តសាមី ដើម្បីធានាដល់ការអភិវឌ្ឍស្របតាមប្លង់រៀបចំដែនដីនគររូបនីយកម្មខេត្ត និងផែនការរៀបចំដែនដីរបស់ខេត្ត។<br><br>*****<br><br>– **គម្រោងវិនិយោគសាធារណៈមួយចំនួនរបស់ក្រសួង ស្ថាប័នដែលគ្រោងអនុវត្តនៅខេត្ត មិនបានអនុវត្តច្រើនឆ្នាំ ហើយខេត្តពុំមានសិទ្ធិអនុវត្តលើគម្រោងដែលបានគ្រោងនោះ ដែលប្រការនេះធ្វើឱ្យរដ្ឋបាលរាជធានី ខេត្តជួបការលំបាកក្នុងការជំរុញការអភិវឌ្ឍនៅក្នុងខេត្តរបស់ខ្លួន។**<br><br>**ដំណើររឿង ៖** ចំពោះគម្រោងវិនិយោគសាធារណៈមួយចំនួនរបស់ក្រសួង ស្ថាប័នដែលគ្រោងអនុវត្តនៅខេត្តមិនបានអនុវត្តច្រើនឆ្នាំ តែងតែកើតមានជារឿយៗ ដោយសារខ្វះទំនាក់ទំនង ព័ត៌មាន ឬការសហការគ្នារវាងក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលខេត្ត អាស្រ័យហេតុនេះ ធ្វើឱ្យរដ្ឋបាលខេត្តមិនអាចរៀបចំជាគម្រោងសម្រាប់អនុវត្តគម្រោងដែលបានគ្រោងដោយក្រសួង ស្ថាប័នសាមី។<br><br>**ដំណោះស្រាយ ៖** ក្រសួងសាមីដែលមានគម្រោងនីមួយៗ និងរដ្ឋបាលខេត្តសាមីត្រូវមានទំនាក់ទំនង និងការពិភាក្សាគ្នា ដើម្បីដោះស្រាយបញ្ហាគម្រោងនានាបានគ្រោងដោយក្រសួង ស្ថាប័ន ហើយមិនបានអនុវត្តច្រើនឆ្នាំ។ |

| | |
|---|---|
| ១២ | – **ការរៀបចំកាតគ្រីម៉ូតូនៅថ្នាក់ស្រុក មានបញ្ហាអក្ខរាវិរុទ្ធក្នុងប្រព័ន្ធ សំណូមពរផ្ញើឯកសារតាមប្រព័ន្ធ និងមិនចាំបាច់កាន់ឯកសារដើមជូនទៅក្រសួង**<br>– **ការចុះបញ្ជីទុតិយតាស្លាកលេខ និងបណ្ណសម្គាល់ទោចក្រយានយន្តមានការយឺតយ៉ាវក្នុងការទម្លាក់ទិន្នន័យ មកការិយាល័យច្រកចេញចូលតែមួយ ស្នើក្រសួងសាធារណការ និងដឹកជញ្ជូន ជួយទម្លាក់ទិន្នន័យឱ្យបានលឿន។**<br><br>**ដំណើររឿង ៖** បច្ចុប្បន្ន នៅពេលបុគ្គលិកការិយាល័យច្រកចេញចូលតែមួយជួបប្រទះបញ្ហាបច្ចេកទេសក្នុងការបោះពុម្ពបណ្ណសម្គាល់ម៉ូតូ ដូចជា ករណីដាច់ភ្លើង ឬបញ្ហាប្រព័ន្ធអ៊ីនធឺណិតដើរយឺត ដែលធ្វើឱ្យបាត់ទិន្នន័យក្នុងប្រព័ន្ធ ឬព្រីនបណ្ណសម្គាល់ខុសលក្ខណៈបច្ចេកទេស(ខូចបណ្ណ) ក្រុមហ៊ុនកាំត្រង់ស៊ីបមិនអាចជួយដោះស្រាយបញ្ហាបានភ្លាមៗ ដោយសារតែក្រុមហ៊ុនបានតម្រូវឱ្យការិយាល័យច្រកចេញចូលតែមួយត្រូវទំនាក់ទំនងដោយផ្ទាល់ជាមួយមន្ត្រីជំនាញនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកជាមុនសិន (មិនទទួលយកលិខិត ឬការស្នើសុំសម្របសម្រួលតាមប្រព័ន្ធតេលេក្រាម)។ ជាមួយគ្នានេះ ពាក់ព័ន្ធនឹងការស្នើសុំទុតិយតាស្លាកលេខ និងបណ្ណសម្គាល់ទោចក្រយានយន្ត ជាពិសេសសម្រាប់ទោចក្រយានយន្តដែលបានចុះបញ្ជីដោយដៃមុនការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្ម បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការទំនាក់ទំនងទៅមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ដើម្បីស្វែងរកឯកសារចុះបញ្ជី និងបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធ មុននឹងទម្លាក់ទិន្នន័យក្នុងប្រព័ន្ធជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ។ ការងារនេះចំណាយពេលយូរ ដែលនាំឱ្យប្រជាពលរដ្ឋមានការមិនសប្បាយចិត្ត។<br><br>**ដំណោះស្រាយ ៖** ក្រសួងមហាផ្ទៃ នឹងពិភាក្សាជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ពិនិត្យ និងដោះស្រាយបញ្ហាប្រឈមទាំងពីរខាងលើដែលស្នើឡើងដោយក្រុង ស្រុក ខណ្ឌ។ |
| ១៣ | – **ស្នើសុំឱ្យរដ្ឋបាលក្រុង ស្រុកទទួលបានចំណូលសួយសារពីធនធានរ៉ែ (ការជីកអាចម៍ដី រណ្ដៅដីចល័ត ប្រតិបត្តិការបកយកអាចម៍ដី...) ដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាប័ណ្ណ។**<br><br>**ដំណើររឿង ៖** តាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ លេខ១៨៤ រាជរដ្ឋាភិបាលបានប្រគល់មុខងារក្នុងវិស័យរ៉ែ និងថាមពលជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចជាការជីកអាចម៍ដី រណ្ដៅដីចល័ត (ក្រឡាផ្ទៃមិនលើសពី០,៥ហិកតា និងជម្រៅមិនលើសពី៣ម៉ែត្រ) និងប្រតិបត្តិការបកយក |

<table>
<tr>
<td></td>
<td>អាចម៍ដី (ក្រឡាផ្ទៃមិនលើសពី១ហិកតា និងជម្រៅមិនលើសពី១ម៉ែត្រ) រដ្ឋបាលក្រុង ស្រុក ខណ្ឌមានសមត្ថកិច្ចក្នុងការចេញអាជ្ញាប័ណ្ណ និងចុះបញ្ជីអាជ្ញាប័ណ្ណជូនអ្នកស្នើសុំសេវាប៉ុណ្ណោះ ប៉ុន្តែចំពោះការប្រមូលសួយសារ និងការចុះពិនិត្យផាកពិន័យផ្សេងៗជាសមត្ថកិច្ចរបស់មន្ទីររ៉ែនិងថាមពល ហើយបង់ចំណូលទៅក្រសួងថ្នាក់ជាតិ។ ក្រសួងបានផ្តល់ជាថវិការង្វាន់មករដ្ឋបាលរាជធានី ខេត្ត តែមិនមានផ្តល់ជូនរដ្ឋបាល ក្រុង ស្រុក ខណ្ឌឡើយ។<br><br>ដំណោះស្រាយ ៖ ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពិនិត្យមើលពីលទ្ធភាពនៃការអនុញ្ញាតរដ្ឋបាលក្រុង ស្រុកទទួលបានចំណូលសួយសារពីធនធានរ៉ែ (ការជីកអាចម៍ដី រណ្តៅដីចល័ត ប្រតិបត្តិការបកយកអាចម៍ដី...) ដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាប័ណ្ណ។<br><br>*****<br><br>– មុខងារដែលបានផ្ទេរឱ្យក្នុងវិស័យរ៉ែ មានការលំបាកក្នុងការចេញលិខិតអនុញ្ញាត ពីព្រោះមិនទាន់មានការកំណត់តម្លៃសេវាជាក់លាក់ ដូចជាដេប៉ូខ្សាច់ ថ្ម ប្រេង ហ្គាសជាដើម។<br><br>ដំណើររឿង ៖ មុខងារផ្តល់សេវារដ្ឋបាលចុះបញ្ជីដេប៉ូខ្សាច់ ថ្ម លិខិតអនុញ្ញាតសម្រាប់អាជីវកម្មលក់ប្រេងម៉ាស៊ីន និងហ្គាស ជាប្រភេទសេវាថ្មីដែលបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយមិនទាន់មានប្រកាសអន្តរក្រសួងដើម្បីកំណត់តម្លៃសេវានៅឡើយទេ។ បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចផ្តល់សេវានេះជូនប្រជាពលរដ្ឋដោយមិនមានគិតថ្លៃសេវា។ ក្រសួងមហាផ្ទៃកំពុងសម្របសម្រួលការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។<br><br>ដំណោះស្រាយ ៖ ក្រសួងមហាផ្ទៃនឹងបន្តសម្របសម្រួលជាមួយក្រសួងរ៉ែ និងថាមពល ដើម្បីដាក់ចេញប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។</td>
</tr>
<tr>
<td>១៤</td>
<td>សេវារដ្ឋបាល (ច្រកចេញចូលតែមួយ)៖<br>– ទម្រង់ឯកសារស្នើសុំសេវាលើវិស័យសុរិយោដី និងសំណង់មានភាពស្មុគស្មាញ យឺតយ៉ាវ តម្រូវភ្ជាប់ឯកសារច្រើន រយៈពេលយូរ និងត្រូវការចុះហត្ថលេខាពីអង្គភាពពាក់ព័ន្ធច្រើន និងពុំទាន់មាននីតិវិធីច្បាស់លាស់។</td>
</tr>
</table>

**ដំណើររឿង** ៖ សេវានៅក្នុងវិស័យសុរិយោដីមានច្រើនប្រភេទសេវា ហើយការរៀបចំឯកសារសម្រាប់ស្នើសុំសេវានីមួយៗមានការលំបាក ដោយសារ (១).ទាមទារតម្រូវការឯកសារភ្ជាប់ច្រើន និងខុសៗគ្នាអាស្រ័យទៅតាមស្ថានភាពរបស់បុគ្គលស្នើសុំសេវា (២).មានប្រើប្រាស់ពាក្យបច្ចេកទេសច្រើន ដែលប្រជាពលរដ្ឋពិបាកយល់ និងមិនអាចបំពេញដោយខ្លួនឯងបាន (៣).នីតិវិធីសាំញ៉ាំ និងត្រូវឆ្លងកាត់ការពិនិត្យ សម្រេចពីអាជ្ញាធរ និងអ្នកពាក់ព័ន្ធច្រើន តាំងពីថ្នាក់ឃុំ សង្កាត់ រហូតដល់ថ្នាក់រាជធានី ខេត្ត។

**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃនឹងបន្តពិភាក្សាជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យមើលឡើងវិញអំពីនីតិវិធី និងសំណុំឯកសារភ្ជាប់។

*****

– **ស្នើសុំពិចារណាផ្ទេរមុខងារក្នុងការផ្តល់សេវាផ្ទេរកម្មសិទ្ធិដែលបានចុះបញ្ជី (ប្លង់រឹង) មករដ្ឋបាលក្រុង ស្រុកទទួលខុសត្រូវ ដើម្បីពន្លឿនក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋលើការគ្រប់គ្រងដីធ្លី។**

**ដំណើររឿង** ៖ បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចផ្តល់សេវាផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជីជូនប្រជាពលរដ្ឋ។ ដោយឡែកសម្រាប់ការផ្ទេរកម្មសិទ្ធិដែលបានចុះបញ្ជី (ប្លង់រឹង) ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត តាមរយៈអង្គភាពច្រកចេញចូលតែមួយ។

**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងសិក្សានិងពិនិត្យមើលលទ្ធភាពនៃការផ្ទេរមុខងារនេះជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

*****

– **នីតិវិធី និងសំណុំឯកសារនៃការផ្តល់សេវារដ្ឋបាលលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី(ប្លង់ទន់) និងការសុំច្បាប់សាងសង់មានភាពស្មុគស្មាញ ចំណាយពេលយូរ និងតម្រូវឯកសារច្រើនប្រភេទ។**

**ដំណើររឿង** ៖ ការផ្តល់សេវាកម្មសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជីមានការអនុវត្តបែបបទ និងនីតិវិធីខុសៗគ្នាពីរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ដោយសារក្រសួង ស្ថាប័នពាក់ព័ន្ធមិនទាន់បានរៀបចំ និងដាក់ចេញសេចក្តីណែនាំដែលកំណត់ទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់ សេវាឱ្យ

| | |
|---|---|
| | មានស្តង់ដារួមតែមួយ សម្រាប់ការងារសំណង់ ជាពិសេសសម្រាប់ស្រុកដែលនៅឆ្ងាយពីទីរួមខេត្ត មានការពិបាកក្នុងការស្វែងក្រុមជាងសំណង់ដែលទទួលស្គាល់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាបត្យករដែលបានចុះបញ្ជី ដើម្បីរៀបចំ និងគូសប្លង់ស្ថាបត្យកម្មសំណង់ជូនប្រជាពលរដ្ឋ ហើយប្លង់ស្ថាបត្យកម្មនេះមានតម្លៃថ្លៃ (សេវាឯកជន)។<br><br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃនឹងពិភាក្សាជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យមើលឡើងវិញអំពីនីតិវិធី និងសំណុំឯកសារសម្រាប់ការផ្តល់សេវាការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី(ប្លង់ទន់) និងការសុំច្បាប់សាងសង់ ដើម្បីឱ្យមានសាមញ្ញងាយស្រួល និងឆាប់រហ័សជូនប្រជាពលរដ្ឋ។<br><br>*****<br><br>– **ការចុះបញ្ជីសេវាវិស័យសាធារណការ ត្រូវចុះបញ្ជីតាមប្រព័ន្ធ២ផ្សេងគ្នាគឺប្រព័ន្ធក្រសួងសាធារណការ និងដឹកជញ្ជូន និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវារបស់ក្រសួងមហាផ្ទៃ។**<br><br>**ដំណើររឿង** ៖ បច្ចុប្បន្ន បុគ្គលិករបស់អង្គភាពច្រកចេញចូលតែមួយ ត្រូវបញ្ចូលទិន្នន័យចុះបញ្ជីសេវាចំនួន២ដងនៅក្នុងប្រព័ន្ធ២ផ្សេងគ្នា រួមមាន៖ ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (សម្រាប់ផ្តល់សេវា) និងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅច្រកចេញចូលតែមួយរបស់ក្រសួងមហាផ្ទៃ (សម្រាប់គ្រប់គ្រងតួលេខ និងទិន្នន័យសេវា) ដោយសារប្រព័ន្ធទាំងពីរនៅមិនទាន់បានធ្វើសន្ទានកម្មទិន្នន័យជាមួយគ្នា។ មន្ត្រីមានការលំបាកក្នុងការបញ្ចូលទិន្នន័យដដែលៗ និងបង្កភាពយឺតយ៉ាវដល់មន្ត្រីក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។<br><br>**ដំណោះស្រាយ** ៖ ក្រសួងក្រសួងសាធារណការ និងដឹកជញ្ជូននឹងពិភាក្សាជាមួយក្រសួងមហាផ្ទៃ ដើម្បីពន្លឿនការធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ជាមួយកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។<br><br>***** |

- **សេវាមួយចំនួនដែលផ្ទេរឱ្យរដ្ឋបាលរាជធានី ខេត្តហើយ ត្រូវបានកែសម្រួលយកមកផ្តល់នៅថ្នាក់ក្រសួងវិញក្រោមហេតុផលធ្វើទំនើបកម្មប្រព័ន្ធផ្តល់សេវាតាមបច្ចេកវិទ្យា ដូចជា៖ (១).ការចុះបញ្ជីយានយន្ត (វិស័យសាធារណការ) (២). ការចុះបញ្ជីបង្កើតសិប្បកម្មដែលគ្មានហានិភ័យដើមទុនតិចជាង ឬស្មើ២ម៉ឺនដុល្លារ (វិស័យឧស្សាហកម្ម) (៣).ការផ្តល់វិញ្ញាបនបត្រដំណើរការសិប្បកម្មគ្មានហានិភ័យដើមទុនតិចជាង ឬស្មើ២ម៉ឺនដុល្លារ (វិស័យឧស្សាហកម្ម) ។**

**ដំណើររឿង** ៖ បច្ចុប្បន្ន មានក្រសួងមួយចំនួនបានដកយកមុខងារមួយចំនួនមកអនុវត្តនៅថ្នាក់ជាតិវិញ ទោះបីជាមុខងារទាំងនោះត្រូវបានកំណត់នៅក្នុងអនុក្រឹត្យលេខ១៨ ដែលបានប្រតិភូកម្មជូនរដ្ឋបាលរាជធានី ខេត្តរួចហើយ រួមមាន៖

- **ក្រសួងសាធារណការ និងដឹកជញ្ជូន**៖ នៅបន្តអនុវត្តការផ្ទេរកម្មសិទ្ធិយានយន្តនៅថ្នាក់ក្រសួងដដែល ដោយលើកហេតុផលថា កន្លងមកឯកសារចុះបញ្ជីយានយន្តមួយចំនួនធ្វើឡើងដោយដៃ និងនៅមិនទាន់បានបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មនៅឡើយ ដែលនាំឱ្យក្រសួងមិនអាចអនុញ្ញាតឱ្យរដ្ឋបាលរាជធានី ខេត្តផ្តល់សេវានេះបាន
- **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**៖ បានចូលរួមអនុវត្តក្នុងថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យ CamDX សម្រាប់ផ្តល់សេវាផ្សេងៗតាមប្រព័ន្ធអនឡាញ ជាពិសេសគឺការចុះបញ្ជីសិប្បកម្ម។ ការស្នើសុំសេវាតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យ CamDX ប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំសេវាចុះបញ្ជីសិប្បកម្មគ្រប់ទំហំដើមទុន ទាំងទំហំដើមទុនដែលស្ថិតក្រោមសមត្ថកិច្ចពិនិត្យសម្រេចរបស់រដ្ឋបាលកណ្តាល និងទំហំដើមទុនដែលស្ថិតក្រោមសមត្ថកិច្ចពិនិត្យសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក៏បានពិនិត្យសម្រេចលើការស្នើសុំនោះ បើទោះបីជាសិប្បកម្មនោះមានទំហំដើមទុនស្ថិតក្រោមការពិនិត្យសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ។

**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃនឹងពិភាក្សាជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ដើម្បីពិនិត្យ និងដោះស្រាយទៅលើប្រភេទសេវាដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

*****

- **សុំឱ្យមានការរៀបចំការផ្តល់សេវាជាកញ្ចប់នៅអង្គភាពច្រកចេញចូលតែមួយ និងផ្តល់សេវាអនឡាញ។**

| | |
|---|---|
| | **ដំណើររឿង** ៖ រដ្ឋបាលរាជធានី ខេត្ត ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋទៅតាមលិខិតបទដ្ឋានបច្ចេកទេស ឬការអនុវត្ត ដែលមន្ទីរធ្លាប់ផ្តល់សេវាកន្លងមក ដោយតម្រូវឱ្យប្រជាពលរដ្ឋត្រូវស្នើសុំសេវានីមួយៗដាច់ដោយឡែកពីគ្នា និងមិនទាន់អាចធ្វើបានជាកញ្ចប់ក្នុងពេលតែមួយ។ ករណីនេះ ធ្វើឱ្យប្រជាពលរដ្ឋនៅតែជួបការលំបាកក្នុងការស្នើសុំសេវារដ្ឋបាលនីមួយៗដាច់ពីគ្នាដែលត្រូវការចំណាយពេលវេលា និងថវិកាច្រើន បើទោះបីជាការផ្តល់សេវារដ្ឋបាលទាំងនោះនៅកន្លែងតែមួយ គឺនៅការិយាល័យ ឬអង្គភាពច្រកចេញចូលតែមួយក៏ដោយ។ ករណីនេះ ក្រសួងមហាផ្ទៃនឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំជាលិខិតបទដ្ឋានបច្ចេកទេសតាមសេវានីមួយៗ ដោយពិនិត្យលទ្ធភាពក្នុងការកែសម្រួល និងរៀបចំឱ្យមានការស្នើសុំសេវាជាកញ្ចប់ ចំពោះប្រភេទសេវាដែលមានការពាក់ព័ន្ធគ្នា។<br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃនឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំជាលិខិតបទដ្ឋានបច្ចេកទេសតាមសេវានីមួយៗ ដោយពិនិត្យលទ្ធភាពក្នុងការកែសម្រួល និងរៀបចំឱ្យមានការស្នើសុំសេវាជាកញ្ចប់ ចំពោះប្រភេទសេវាដែលមានការពាក់ព័ន្ធគ្នា។ |
| ១៥ | **ខ្វះការគាំទ្របច្ចេកទេស មធ្យោបាយ ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យពីមន្ទីរជំនាញ/អង្គភាពជំនាញដល់មន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្រោយធ្វើសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក។**<br>**ដំណើររឿង** ៖ បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យជំនាញក្នុង២០វិស័យទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួង ស្ថាប័នបានផ្ទេរបុគ្គលិកជំនាញចំនួនប្រមាណជិត៨.០០០នាក់ (លើកលែងគ្រូបង្រៀន) ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចាប់ពីឆ្នាំ២០២០មក។ បន្ទាប់ពីការធ្វើសមាហរណកម្មនេះមក ការគាំទ្របច្ចេកទេស ឧបករណ៍ សម្ភារ ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យរបស់មន្ទីរជំនាញសាមីនីមួយៗមានការថយចុះ បើប្រៀបធៀបទៅនឹងស្ថានភាពមុនការផ្ទេរមុខងារ និងបុគ្គលិក ដែលជាហេតុធ្វើឱ្យអង្គភាពជំនាញនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ជួបការលំបាកក្នុងការអនុវត្តមុខងាររបស់ខ្លួនផងដែរ។ ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ គឺបញ្ហាសំខាន់មួយក្នុងដំណើរការនៃវិមជ្ឈការ។ បើទោះបីជាមុខងារ និងធនធានទាំងនោះបានផ្ទេរតាមបែបវិមជ្ឈការទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ក្រសួង ស្ថាប័នក្នុងវិស័យជំនាញនៅតែមានការទទួលខុសត្រូវចំពោះវិស័យរបស់ខ្លួនតាមរយៈការគាំទ្របច្ចេកទេស ធនធាន ការអភិវឌ្ឍសមត្ថភាព និងការត្រួតពិនិត្យលើការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការសម្រេចបានតាមគោលនយោបាយវិស័យ ផែនការយុទ្ធសាស្ត្រ ស្តង់ដាបច្ចេកទេស ព្រមទាំងគោលការណ៍ នីតិវិធីនានាដែលបានកំណត់។ |

| | |
|---|---|
| | **ដំណោះស្រាយ ៖** ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្តនីមួយៗនឹងផ្តល់ការណែនាំដល់មន្ទីរ អង្គភាពជំនាញ ដើម្បីជំរុញការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| ១៦ | **ការធ្វើសវនកម្មផ្ទៃក្នុងនៅពុំមានភាពច្បាស់លាស់រវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។**<br>**ដំណោះស្រាយ ៖** ក្រសួងមហាផ្ទៃបាននិងកំពុងវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង និងកំពុងសិក្សាអំពីលទ្ធភាពនៃការបង្កើតឱ្យមានអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត។ ដូច្នេះ ក្រសួងមហាផ្ទៃនឹងពិនិត្យមើលអំពីមុខងារសវនកម្មផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធានាកុំឱ្យមានភាពត្រួតស៊ីគ្នា និងធានាដល់ការគាំទ្រការធ្វើសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនាពេលខាងមុខ។ |
| ១៧ | **ភូមិមួយចំនួននៅតែជាភូមិឧបសម្ព័ន្ធដែលមិនទាន់មានការការចុះបញ្ជីទទួលស្គាល់ពីក្រសួងមហាផ្ទៃ។**<br>**ដំណើររឿង ៖** ការបង្កើតភូមិត្រូវអនុវត្តដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ004 ឆ្នាំ២00៦។ ក្រសួងមហាផ្ទៃបាននិងកំពុងរៀបចំកែសម្រួលសេចក្តីណែនាំនេះ ដោយកំណត់លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបង្រួម និងការរំសាយភូមិស្របតាមស្ថានភាពវិវឌ្ឍន៍នៃសេដ្ឋកិច្ច-សង្គម ប្រជាសាស្ត្រ និងភូមិសាស្ត្របច្ចុប្បន្ន។<br>**ដំណោះស្រាយ ៖** ក្រសួងមហាផ្ទៃនឹងសិក្សា និងរៀបចំកំណត់លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបង្រួម និងការរំសាយភូមិ ស្របតាមស្ថានភាពវិវឌ្ឍន៍នៃសេដ្ឋកិច្ច-សង្គម ប្រជាសាស្ត្រ និងភូមិសាស្ត្របច្ចុប្បន្ន។ |
| ១៨ | – មិនទាន់មានការកំណត់ច្បាស់លាស់នូវព្រំប្រទល់ឃុំ-ភូមិមួយចំនួនដែលនាំឱ្យពិបាកក្នុងការផ្តល់សេវា និងការងារសន្តិសុខសណ្តាប់ធ្នាប់<br>– ព្រំប្រទល់រដ្ឋបាលក្រុង ស្រុកមួយចំនួនពុំទាន់មានភាពច្បាស់លាស់<br>– ព្រំប្រទល់រដ្ឋបាលខេត្តមួយចំនួននៅពុំមានការឯកភាពគ្នា។ |

| | |
|---|---|
| | **ដំណើររឿង៖** ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងកំណត់ឡើងវិញឱ្យបានច្បាស់លាស់នាឆ្នាំ២០០១ ដោយអនុលោមតាមមាត្រា៨៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ក្រសួងមហាផ្ទៃបានដាក់ចេញនូវប្រកាសលេខ៤៩៣ ឆ្នាំ២០០១ ស្តីពីការកំណត់ចំនួន ឈ្មោះ និងព្រំប្រទល់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលពេលនោះផែនទីត្រូវបានគូសដោយដៃ ដោយសារពេលនោះនៅពុំទាន់មានបច្ចេកទេសតាមប្រព័ន្ធឌីជីថលនៅឡើយ។ ទោះបីជាមានការកំណត់ ព្រំប្រទល់រដ្ឋបាលរួចហើយក្តី ប៉ុន្តែស្ថានភាពនៃការអនុវត្តជាក់ស្តែងកន្លែងមួយចំនួនមានការប្រទាញប្រទង់គ្នានៅឡើយ។ បញ្ហាទាំងនេះត្រូវបាន និងកំពុងសម្របសម្រួល និងចាត់វិធានការដោះស្រាយជាបណ្តើរៗដោយក្រសួងមហាផ្ទៃសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។<br><br>**ដំណោះស្រាយ៖** ក្រសួងមហាផ្ទៃនឹងរៀបចំកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ |
| ១៩ | **ស្នើសុំឱ្យមានប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីបំពេញការងារនៅរដ្ឋបាលក្រុង ស្រុក ជាពិសេសនៅស្រុកជនបទ។**<br><br>**ដំណើររឿង៖** ការខ្វះចំនួនបុគ្គលិកជំនាញវិជ្ជាជីវៈពិតប្រាកដសម្រាប់អនុវត្តមុខងារតាមវិស័យជាអាទិភាពនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក គឺជាបញ្ហាចម្បងដែលត្រូវបានលើកឡើងស្ទើរគ្រប់រដ្ឋបាលក្រុង ស្រុកទាំងអស់។ ផ្អែកតាមការវិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការរហូតមកដល់បច្ចុប្បន្ន មានមុខងារ ធនធាន និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែច្រើនឡើងៗត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក។ ក្នុងពេលដែលបន្ទុកការងារកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ក៏ប៉ុន្តែប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិកដែលបំពេញការងារនៅរដ្ឋបាលក្រុង ស្រុកពុំទាន់ត្រូវបានពិនិត្យ និងកែសម្រួលឱ្យស្របទៅនឹងបន្ទុកការងារ និងដើម្បីលើកទឹកចិត្តឱ្យបុគ្គលិកដែលមានសមត្ថភាព មានជំនាញវិជ្ជាជីវៈខ្ពស់ៗ និងបទពិសោធន៍ការងារចង់ទៅបម្រើការងារនៅរដ្ឋបាលក្រុង ស្រុកនៅឡើយ ជាពិសេសនៅតាមស្រុកដែលស្ថិតនៅតំបន់ជនបទ និងតំបន់ជួបការលំបាក ដោយសារមានការលើកឡើងថា កម្រិតនៃក្របខ័ណ្ឌ ឋានន្តរស័ក្តិ មុខតំណែង ប្រាក់បំណាច់មុខងារមានកម្រិតទាបជាងនៅថ្នាក់ខេត្តនិងនៅថ្នាក់ជាតិ និងពុំមានប្រាក់ឧបត្ថម្ភលើកទឹកចិត្តបន្ថែម។ |

| | |
|---|---|
| | **ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើខាងលើនេះ ការគិតគូរអំពីប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិកបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅរដ្ឋបាលក្រុង ស្រុក ក៏ត្រូវបានកំណត់នៅក្នុងកម្មវិធីជាតិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដំណាក់កាលទី២រួចហើយ ហើយក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភានេះ ក៏ត្រូវបានគិតគូរអំពីប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មផងដែរ។ អាស្រ័យហេតុនេះ មន្ត្រីបច្ចេកទេសនៃក្រសួងមុខងារសាធារណៈ នឹងសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. សិក្សាអំពីជម្រើសនានាក្នុងការលើកទឹកចិត្តទាំងកម្រិតនៃឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ ប្រាក់លើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម និងការផ្តល់គ្រឿងឥស្សរិយយសជាដើម ដើម្បីជំរុញបុគ្គលិកឱ្យស្ម័គ្រចិត្តទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសតំបន់ជនបទ។ ការងារនេះក៏ជួយក្នុងការទាក់ទាញ និងពង្រាយបុគ្គលិកពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមានបុគ្គលិកច្រើនឱ្យទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតំបន់ជនបទដែលខ្វះបុគ្គលិក។ |
| ២០ | **ស្នើសុំឱ្យមានប្រព័ន្ធវាយតម្លៃផ្អែកលើសមិទ្ធកម្មសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។**<br><br>**ដំណើររឿង** ៖ បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើលទ្ធផលបំពេញការងារឱ្យបានច្បាស់លាស់នៅឡើយទាំងលើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ និងការតែងតាំង... (យន្តការ នីតិវិធី លក្ខណៈវិនិច្ឆ័យ/សូចនាករ)។ ក្នុងន័យនេះ ដើម្បីធានារដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងបុគ្គលិកប្រកបដោយប្រសិទ្ធភាព តម្លាភាព ត្រឹមត្រូវ យុត្តិធម៌ និងមានការលើកទឹកចិត្តចំពោះបុគ្គលិកដែលខិតខំប្រឹងប្រែងបំពេញការងារ ព្រមទាំងលើកកម្ពស់ការប្រកួតប្រជែងក្នុងការបំពេញការងាររបស់បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិបានស្នើសុំឱ្យមានប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្មឱ្យបានច្បាស់លាស់។<br><br>**ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ កម្មវិធីជាតិដំណាក់កាលទី២ និងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ បានកំណត់ឱ្យមានការរៀបចំប្រព័ន្ធវាយតម្លៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើសមិទ្ធកម្ម តាមរយៈការរៀបចំឱ្យមានការពិពណ៌នាមុខតំណែង ប្រព័ន្ធគ្រប់គ្រងវត្តមាន ក្រមសីលធម៌វិជ្ជាជីវៈជាពិសេសគឺការរៀបចំឱ្យលក្ខខណ្ឌការងារច្បាស់លាស់ (ការទទួលខុសត្រូវ លទ្ធផលរំពឹងទុក សូចនាករ ចំណុចដៅ និងក្របខ័ណ្ឌពេលវេលា...) សម្រាប់បុគ្គលិកម្នាក់ៗ ដើម្បីធ្វើជាមូលដ្ឋាននៃការវាយតម្លៃបុគ្គលិកផ្អែកលើលទ្ធផលបំពេញការងារសម្រាប់ |

| | |
|---|---|
| | ការឡើងថ្នាក់ ឋានន្តរស័ក្តិ ការតែងតាំង ការលើកទឹកចិត្ត ការអភិវឌ្ឍសមត្ថភាព និងការដាក់វិន័យជាដើម។ អាស្រ័យហេតុនេះ មន្ត្រីបច្ចេកទេសនៃក្រសួងមុខងារសាធារណៈសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងរៀបចំប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្មនេះ ដើម្បីស្នើសុំការពិនិត្យ សម្រេចពីថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាលនៅក្នុងឆ្នាំ២០២៥នេះ។ |
| ២១ | **ស្នើសុំរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ជាតិ។**<br><br>**ដំណើររឿង** ៖ គិតមកដល់បច្ចុប្បន្ននេះ បុគ្គលិកប្រមាណជាង១០ម៉ឺននាក់ត្រូវបានផ្ទេរទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងបុគ្គលិក គឺជាបន្ទុកការងារច្រើន រួមមានដូចជា ការជ្រើសរើស ការតែងតាំង ការឡើងថ្នាក់ ឋានន្តរស័ក្តិ ការរៀបចំបញ្ជីបៀវត្សរ៍ ការគ្រប់គ្រងវត្តមាន និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងទៀតរបស់បុគ្គលិក ដែលកិច្ចការទាំងនោះតម្រូវឱ្យមានការគ្រប់គ្រង និងការចាត់ចែងប្រកបដោយភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌។ ក្នុងន័យនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងបុគ្គលិក ចាំបាច់ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលអាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅថ្នាក់ជាតិផងដែរ។<br><br>**ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ បច្ចុប្បន្ន ក្រសួងមុខងារសាធារណៈបាននិងកំពុងរៀបចំថ្នាលព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យមន្ត្រីរួម ដែលមានមុខងារទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកឱ្យស្ថិតក្នុងប្រព័ន្ធតែមួយ ដោយកំពុងធ្វើសមាហរណកម្មទិន្នន័យពីប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រី (HRMIS) ប្រព័ន្ធគ្រប់គ្រងបៀវត្សរ៍ និងប្រព័ន្ធរណបផ្សេងៗទៀត។ នៅពេលធ្វើសមាហរណកម្មទិន្នន័យពីប្រព័ន្ធនានាចូលក្នុងថ្នាលព័ត៌មានវិទ្យាគ្រប់គ្រងមន្ត្រីរួម និងបានកែលម្អមុខងារគ្រប់គ្រងធនធានមនុស្សក្នុងប្រព័ន្ធនេះរួចរាល់ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរាជធានី ខេត្តអាចប្រើប្រាស់ប្រព័ន្ធនេះបានក្នុងការគ្រប់គ្រង ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រូសារមន្ត្រី ការវិវឌ្ឍន៍អាជីពមន្ត្រីរាជការរហូតដល់ចូលនិវត្តន៍។ ដូច្នេះ សំណើនេះត្រូវបាននិងកំពុងដោះស្រាយជាបណ្តើរៗហើយ។ |
| ២២ | **ស្នើសុំពិចារណាបែងចែកថវិកាឃុំ សង្កាត់ទៅតាមស្ថានភាពភូមិសាស្ត្រ (សម្រាប់ឃុំដែលមានក្រឡាផ្ទៃដីធំ ឃុំដាច់ស្រយាលគួរមានប្រាក់ចំណាយប្រតិបត្តិការរដ្ឋបាល ឬបេសកកម្មច្រើនជាងឃុំ សង្កាត់ដែលមានក្រឡាផ្ទៃដីតូច)។** |

<table>
<tr><td></td><td>ដំណើររឿង ៖ កន្លងមកនេះ ការបែងចែកថវិកាសម្រាប់ប្រតិបត្តិការរដ្ឋបាលទៅឱ្យរដ្ឋបាលឃុំ សង្កាត់គឺប្រើប្រាស់នូវសូចនាករចំនួន២គឺ (១).ចំណែកស្មើគ្នា (២).ចំនួនសមាជិកក្រុមប្រឹក្សា។ ទោះយ៉ាងណាការប្រើប្រាស់សូចនាករទាំង២នេះនៅមិនទាន់បានឆ្លុះបញ្ចាំងអំពីស្ថានភាពនៃតម្រូវការចំណាយប្រតិបត្តិការរដ្ឋបាលជាក់ស្តែងនៅឡើយ ដែលប្រការនេះរដ្ឋបាលឃុំ សង្កាត់ស្នើសុំឱ្យការពិនិត្យឡើងវិញនូវរបៀបនៃការវិភាជន៍ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាលនៃមូលនិធិឃុំ សង្កាត់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗឱ្យបានសមស្របទៅតាមស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ។<br><br>ដំណោះស្រាយ ៖<br>– អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់, ចំណាយរដ្ឋបាលត្រូវបានកំណត់មិនឱ្យលើសពី ១៧% នៃមូលនិធិសរុប ដក បន្ទុកបុគ្គលិក (បន្តអនុវត្តពីអនុក្រឹត្យមុន) និង វិភាជន៍តាមគោលការណ៍ចំណែកស្មើគ្នា (៤០%) និងចំនួនក្រុមប្រឹក្សា (៦០%) (ចំនួនក្រុមប្រឹក្សានេះក៏បានគិតគូរផ្អែកលើចំនួនប្រជាពលរដ្ឋនៅឃុំ សង្កាត់), ការគិតគូរនៅពេលនោះ គឺមានការឯកភាពគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដើម្បីធានាឱ្យបានចំណាយអភិវឌ្ឍន៍ឃុំ សង្កាត់នីមួយៗ ត្រូវបង្កើនឱ្យដល់ ១០ម៉ឺនដុល្លារអាមេរិក ចាប់ពីឆ្នាំ២០២៤ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល<br>– អនុក្រឹត្យលេខ១៥៣ មានថេរវេលារយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨<br>– ដូច្នេះ នៅពេលរៀបចំអនុក្រឹត្យថ្មី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយក្រសួងមហាផ្ទៃ នឹងពិនិត្យឡើងវិញនៅសមាសភាគវិភាជន៍ថវិកាឱ្យបានសមស្របស្ថានភាពភូមិសាស្ត្រនៅមូលដ្ឋាន និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច។</td></tr>
<tr><td>២៣</td><td>ស្នើសុំឱ្យមានថវិកាគាំទ្រសមស្របសម្រាប់ការអនុវត្តមុខងារជាភ្នាក់ងារ (ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជនរងហានិភ័យ និងជនមានពិការភាព និងការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព...)។<br><br>ដំណើររឿង ៖ សព្វថ្ងៃនេះ រដ្ឋបាលឃុំ សង្កាត់ត្រូវបានស្នើឱ្យចូលរួមគាំទ្រ និងអនុវត្តកិច្ចការជាច្រើនរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ដែលរួមមានដូចជាការងារការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជនងាយរងគ្រោះ ការផ្សព្វផ្សាយ និងការអនុវត្តគោលនយោបាយភូមិឃុំ សង្កាត់មាន</td></tr>
</table>

| | |
|---|---|
| | សុវត្ថិភាព ជាដើម។ ទោះយ៉ាងណា ការអនុវត្តការងារដូចបានរៀបរាប់ខាងលើនេះមិនបានផ្តល់នូវថវិកាគាំទ្រសមស្របឡើយ។ ក្នុងន័យនេះ ឃុំ សង្កាត់ស្នើសុំឱ្យមានការគាំទ្រថវិកា និងសមត្ថភាពឱ្យបានសមស្របសម្រាប់ការអនុវត្តមុខងារជាភ្នាក់ងារដែលបានធ្វើប្រតិភូកម្មដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។<br>**ដំណោះស្រាយ ៖**<br>– ឆ្នាំកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងតែផ្តល់ថវិកា សម្រាប់ក្រសួងពាក់ព័ន្ធអនុវត្តការងារ ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជនរងហានិភ័យ និងជនមានពិការភាព និងការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព...<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលយកសំណើនេះ ពិនិត្យសិក្សាផ្ទៀងផ្ទាត់ជាមួយក្រសួងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គម អំពីយន្តការការងារ និងការចំណាយថវិកាលើមុខងារនេះ<br>– ជាមួយគ្នានេះផងដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសិក្សារៀបចំយន្តការ និងក្របខ័ណ្ឌគតិយុត្ត ស្តីពីការអនុវត្តថវិកាមុខងារជាភ្នាក់ងារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (ចែងក្នុងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ)។ |
| ២៤ | **មុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលឃុំ សង្កាត់ពុំមានផ្ទេរមកជាមួយនូវធនធានហិរញ្ញវត្ថុ (មុខងារវិស័យសង្គមកិច្ច៖ សេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះ...)។**<br>**ដំណើររឿង ៖** មុខងារថែទាំកុមាររងគ្រោះ និងងាយរងគ្រោះត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់តាមអនុក្រឹត្យលេខ៣៤ (ឆ្នាំ២០១៥) ប៉ុន្តែពុំបានផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលឃុំ សង្កាត់ ដោយហេតុថាកិច្ចការនេះត្រូវបានអនុវត្តដោយឃុំ សង្កាត់តាំងពីមុនការផ្ទេរជាផ្លូវការមកឱ្យឃុំ សង្កាត់។ បច្ចុប្បន្នឃុំ សង្កាត់បានប្រើប្រាស់មូលនិធិរបស់ខ្លួនដើម្បីអនុវត្តការងារនេះ។ អាស្រ័យហេតុនេះ ឃុំ សង្កាត់បានស្នើសុំរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត ពិនិត្យលទ្ធភាពផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារនេះ។<br>**ដំណោះស្រាយ ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ កំពុងរៀបចំសេចក្តីណែនាំរួម ស្តីពីការកំណត់មុខសញ្ញាចំណាយសេវាសង្គម ដែលគ្របដណ្តប់លើមុខសញ្ញាចំណាយទាំងនេះផងដែរ។ តួលេខចំណាយសេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ ដោយមានការបង្កើនភាគរយ |

| | |
|---|---|
| | វិភាជន៍ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ តាមរយៈអនុក្រឹត្យលេខ១៥៣ ដែលនាំឱ្យថវិកាមានការកើនឡើងជារៀងរាល់ឆ្នាំ ដូចខាងក្រោម៖<br>– ថវិកាកញ្ចប់សេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ មានកំណើនជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដែលអាចរ៉ាប់រងចំណាយលើមុខសញ្ញាខាងលើនេះបាន<br>– គួររៀបចំគោលការណ៍ណែនាំជាក់លាក់ (ក្នុងកម្រិតរាជរដ្ឋាភិបាល) បន្ថែមលើអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់លក្ខខណ្ឌជាក់លាក់សម្រាប់ការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន ត្រូវមានភ្ជាប់ជាមួយធនធានសមស្របសម្រាប់អនុវត្តមុខងារដែលផ្ទេរ ចៀសវាងបង្កើនបន្ទុកចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារថ្មី។ |
| ២៥ | **ក្របខ័ណ្ឌពេលវេលារៀបចំថវិកាប្រចាំឆ្នាំមានរយៈពេលតិចពេក (ចាប់ពីខែមិថុនាដល់ខែកក្កដា) ស្នើសុំឱ្យមានពេលវេលាសមស្រប។**<br>**ដំណើររឿង** ៖ ផ្អែកតាមអនុក្រឹត្យលេខ១៧២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក បានកំណត់ក្របខ័ណ្ឌពេលវេលាសម្រាប់រៀបចំថវិកាប្រចាំឆ្នាំមានរយៈពេលតែ២ខែប៉ុណ្ណោះ (ចាប់ពីខែមិថុនា ដល់ខែកក្កដា) ដែលរយៈពេលនេះគឺខ្លី និងមិនសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំដែលតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធនោះឡើយ។<br>**ដំណោះស្រាយ** ៖<br>– យោងមាត្រា៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញសារាចរស្តីពីប្រតិទិនលម្អិតនៃការរៀបចំថវិកាប្រចាំឆ្នាំនៅអំឡុងពាក់កណ្តាលខែមករា<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១(ថ្មី), បន្ទាប់ពីច្បាប់នេះចូលជាធរមាន ការងារបន្តនឹងធ្វើការកែសម្រួលគ្រប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់នេះ ដែលនឹងដោះស្រាយកង្វល់ដែលបានលើកឡើងនេះ |

<table>
<tr>
<td></td>
<td>– ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងពិនិត្យមើលឡើងវិញពីក្របខ័ណ្ឌពេលវេលារៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានសង្គតិភាពគ្នានៃរំហូរការងារពាក់ព័ន្ធនឹងការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ<br>– យ៉ាងណាក៏ដោយ ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាកិច្ចការដែលត្រូវធ្វើជាប្រចាំ ដូច្នេះរដ្ឋបាល ក្រុង ស្រុក ក៏ត្រូវមានភាពបុរេសកម្មក្នុងការរៀបចំគម្រោងថវិកានេះផងដែរ។</td>
</tr>
<tr>
<td>២៦</td>
<td>ស្នើសុំឱ្យមានគោលការណ៍សម្រាប់រៀបចំកញ្ចប់ថវិការបស់ក្រុមប្រឹក្សាដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចរៀបចំផែនការការងារ និងការអនុវត្តមុខងាររបស់ខ្លួនបានច្បាស់លាស់ និងមានប្រសិទ្ធភាព។<br><br>ដំណើររឿង ៖ យោងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមាត្រា១១ បានកំណត់ថា អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា គឺជាអាណាប័កដើមខ្សែ ជាអ្នករៀបចំ និងអនុវត្តថវិការបស់រដ្ឋបាលសាមីនីមួយៗ។ ក្នុងការអនុវត្តថវិកា អភិបាលគឺជាអ្នកបញ្ជាចំណូល សន្យាចំណាយ ជម្រះបញ្ជី និងបញ្ជាចំណាយដោយផ្អែកលើគម្រោងថវិកាដែលបានអនុម័តដោយក្រុមប្រឹក្សា។ ដូច្នេះ រាល់ការចំណាយរបស់ការិយាល័យជំនាញ និងចំណាយនានារបស់ក្រុមប្រឹក្សាសម្រាប់អនុវត្តសកម្មភាពរបស់ខ្លួនត្រូវមានការឯកភាពពីអភិបាលដែលជាអាណាប័កថវិកា។ ប្រការនេះនាំឱ្យមានភាពលំបាកសម្រាប់ក្រុមប្រឹក្សានៅពេលមានតម្រូវការចំណាយអនុវត្តសកម្មភាពរបស់ខ្លួន។<br><br>ដំណោះស្រាយ៖<br><br>– យោងតាមគោលការណ៍ច្បាប់ដែលមានជាធរមាន កញ្ចប់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សារដ្ឋបាលសាមីដែលជាម្ចាស់ថវិកា។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងក្រុង ស្រុក ជាអាណាប័កដើមខ្សែ ក្នុងការអនុវត្តថវិកា។ កញ្ចប់ថវិកាសម្រាប់ក្រុមប្រឹក្សា ជាការសម្របសម្រួលផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំយន្តការច្បាស់លាស់ សម្រាប់ការរៀបចំ និងគ្រោងកញ្ចប់ថវិកាសម្រាប់ក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលសាមី។</td>
</tr>
</table>

| | |
|---|---|
| ២៧ | **ការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិដីធ្លីនៅមានភាពយឺតយ៉ាវ និងការលំបាក (សំណូមពរសុំឱ្យបង់នៅសាខាពន្ធដារខណ្ឌ ឬគួរមានភ្នាក់ងារពន្ធដារនៅអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ)។**<br><br>**ដំណើររឿង ៖** ចំពោះការស្នើសុំសេវាផ្ទេរកម្មសិទ្ធិបណ្ណសម្គាល់(ប្លង់រឹង) និងការស្នើសុំសេវាផ្ទេរកម្មសិទ្ធិអចលទ្រព្យដែលពុំទាន់ចុះបញ្ជី នៅពេលមន្ត្រីបច្ចេកទេសបានពិនិត្យរួចរាល់ហើយ តម្រូវឱ្យអ្នកស្នើសុំសេវាកាន់ឯកសារទៅបង់ពន្ធប្រថាប់ត្រា៤%នៅសាខាពន្ធដារ ឬអគ្គនាយកដ្ឋានពន្ធដារ។ អ្នកស្នើសុំសេវាត្រូវធ្វើដំណើរទៅមកៗច្រើនលើកដើម្បីបង់ពន្ធ និងត្រូវកាន់ឯកសារទៅបង់ពន្ធដោយខ្លួនឯង។ ជាមួយគ្នានេះ អត្រាពន្ធក៏មានភាពមិនច្បាស់លាស់ គឺអាស្រ័យទៅតាមការកំណត់របស់មន្ត្រីពន្ធដារ។<br><br>**ដំណោះស្រាយ៖**<br><br>– អ្នកជាប់ពន្ធ ឬអ្នកតំណាង អាចស្នើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ឬតាមអនឡាញ កម្មវិធីរដ្ឋបាលអេឡិចត្រូនិចពន្ធដារ (GDT e-Administration) ដែលអគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យអនុវត្តតាំងពីដើមឆ្នាំ២០២៤។ ករណីដែលឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់ ការបង់ពន្ធប្រថាប់ត្រានឹងរួចរាល់ក្នុងរយៈពេលពី ៤-៨ថ្ងៃនៃថ្ងៃធ្វើការ<br>– ចាប់តាំងពីឆ្នាំ២០១៦មក ការបង់ពន្ធប្រថាប់ត្រានៅទូទាំងប្រទេស ត្រូវប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យ ដែលមូលដ្ឋានគិតពន្ធជាតម្លៃអចលនទ្រព្យ(ដីនិងសំណង់) កំណត់តាមឧបសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លក្ខខណ្ឌលើកលែងឬអនុគ្រោះពន្ធ និងការគណនាប្រាក់ពន្ធជាស្វ័យប្រវត្តិក្នុងប្រព័ន្ធ។ ករណីម្ចាស់អចលនទ្រព្យមានចម្ងល់ពីតម្លៃមូលដ្ឋានគិតពន្ធ អាចពិនិត្យលើឧបសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសៀវភៅណែនាំស្តីពីពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមានជាឧទាហរណ៍អំពីរបៀបពិនិត្យតម្លៃដីនិងសំណង់ និងរបៀបគណនាប្រាក់ពន្ធ ដែលមាននៅក្នុងគេហទំព័រ និង Facebook Page ផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ឬទំនាក់ទំនងសួរមក Call Center តាមរយៈលេខ ១២៧៧ (មិនគិតថ្លៃ) ឬ GDT Live Chat។ បន្ថែមពីនេះ អ្នកជាប់ពន្ធឬអ្នកតំណាងអាចប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ GDT Check and Track App ដើម្បីតាមដានវឌ្ឍនភាពនៃឯកសាររបស់ខ្លួន និង |

| | |
|---|---|
| | ត្រួតពិនិត្យផ្ទៀងផ្ទាត់សុក្រឹត្យភាពនៃឯកសារគតិយុត្តនានាដែលចេញដោយរដ្ឋបាលសារពើពន្ធ ថាតើឯកសារពិត ឬក្លែងក្លាយ ដោយមានបង្ហាញប្រាក់ពន្ធត្រូវបង់ទៀតផង<br>– ចាប់តាំងពីឆ្នាំ២០១៦នេះដែរ អគ្គនាយកដ្ឋានពន្ធដារបានចាត់បញ្ជូនមន្ត្រីដើម្បីប្រចាំការនៅរដ្ឋបាលខណ្ឌសម្រាប់ផ្តល់សេវាពាក់ព័ន្ធការបង់ពន្ធនេះ ហើយនៅតាមបណ្តាស្រុកនានានៃខេត្តក៏មានមន្ត្រីពន្ធដារនៃការិយាល័យស្រុក ដើម្បីសហការផ្តល់សេវានេះដែរ<br>– យ៉ាងណាក៏ដោយ យោងមាត្រា១៦៣ នៃច្បាប់ស្តីពីសារពើពន្ធ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ មិនត្រូវបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ករណីដែលអ្នកជាប់ពន្ធមិនទាន់បានបង់ពន្ធប្រថាប់ត្រា។ ដូចនេះ សូមអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ពង្រឹងនិងសហការបញ្ជូនសំណុំឯកសារមកបង់ពន្ធប្រថាប់ត្រាឱ្យបានត្រឹមត្រូវ ចៀសវាងប្រជាពលរដ្ឋដែលកាន់កាប់ចុងក្រោយត្រូវរងការបង់ពន្ធច្រើនតំណ<br>– អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយអំពីសេវាកម្មរបស់អគ្គនាយកដ្ឋានពន្ធដារដែលបានដាក់ឱ្យដំណើការ រួមមាន កម្មវិធីរដ្ឋបាលអេឡិចត្រូនិចពន្ធដារ (GDT e-Administration) និងកម្មវិធីទូរស័ព្ទដៃ GDT Check and Track App ដែលមានជាសេចក្តីជូនដំណឹង និងវីដេអូឃ្លីបណែនាំផងដែរ។ |
| ២៨ | – **ស្នើសុំឱ្យមានការផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិភ្ជាប់ទៅនឹងមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលរាជធានី ខេត្ត (វិស័យសុខាភិបាល និងសង្គមកិច្ច) និង ក្រុង ស្រុក ខណ្ឌ (វិស័យទាំង២០) ដើម្បីឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភាពម្ចាស់ការក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។**<br>**ដំណើររឿង** ៖ យោងអនុក្រឹត្យលេខ១៩៣ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារ និងផ្តល់សេវាសុខាភិបាលទៅរដ្ឋបាលរាជធានី ខេត្ត និងអនុក្រឹត្យ៣៤ អំពីការផ្ទេរមុខងារវិស័យសង្គមកិច្ច ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា បានផ្ទេរបុគ្គលិកសុខាភិបាល និងធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋរាជធានី ខេត្តរួចហើយ។ ដោយឡែក ចំពោះទ្រព្យសម្បត្តិដែលត្រូវប្រើប្រាស់សម្រាប់អនុវត្តមុខងារក្នុងវិស័យទាំងពីរនេះ ពុំទាន់បានផ្ទេរជាផ្លូវការទៅឱ្យរដ្ឋបាលរាជធានី ខេត្តនៅឡើយ។ ដូចគ្នានេះដែរ បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យជំនាញឱ្យទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ |

ឆ្នាំ២០១៩ គិតរហូតដល់ពេលនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធនៅមិនទាន់ការផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិភ្ជាប់ជាមួយនឹងមុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរមកឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌនៅឡើយ។

**ដំណោះស្រាយ ៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ ០០១ សហវ.សរ.អទច ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ ស្តីពីការផ្ទេរសិទ្ធិកាន់កាន់ និងប្រើប្រាស់លើទ្រព្យសម្បត្តិរដ្ឋដោយមានចែងលម្អិតអំពីយន្តការ និងនីតិវិធីនៃការផ្ទេរ បូករួមទាំងការផ្ទេរទ្រព្យសម្បត្តិរដ្ឋក្នុងក្របខ័ណ្ឌនៃការគាំទ្រការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដើម្បីជំរុញការអនុវត្តសារាចរនេះ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការផ្សព្វផ្សាយសារាចរណែនាំនេះជាបន្តបន្ទាប់ លើកចុងក្រោយគឺនៅខែវិច្ឆិកា ឆ្នាំ២០២៤ នៅក្នុងសិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនៅខេត្តព្រះសីហនុ
- ជំរុញការអនុវត្តដោយបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអនុវត្តសារាចរនេះ នៅមុនដំណាច់ត្រឹមត្រីមាសទី១ ឆ្នាំ២០២៥។

* * * * *

- **នីតិវិធីនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋមានភាពស្មុគស្មាញ និងប្រើប្រាស់ពេលវេលាច្រើន ស្នើសុំថ្នាក់ជាតិពិនិត្យមើលឡើងវិញនូវនីតិវិធី និងពន្លឿនការជម្រះបញ្ជី។**

**ដំណើររឿង ៖** យោងអនុក្រឹត្យលេខ៦៦ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានកំណត់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវស្នើសុំគោលការណ៍សម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងធ្វើការជម្រះបញ្ជីទ្រព្យសម្បត្តិចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ វិធាន និងនីតីវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះយ៉ាងនេះក្តី រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជួបការលំបាកក្នុងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តទាំងនេះ។

| | |
|---|---|
| | **ដំណោះស្រាយ៖**<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ០០២ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ស្តីពីនីតិវិធីលម្អិតនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយមានចែងលម្អិតអំពីយន្តការ និងនីតិវិធី។ ប្រកាសនេះ គឺជួយឱ្យអ្នកអនុវត្តស្វែងយល់ច្បាស់អំពីនីតិវិធី និងសម្រួលដល់ការអនុវត្ត<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តការផ្សព្វផ្សាយនីតិវិធីបច្ចេកទេសលម្អិត ដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ពិសេសដល់មន្ត្រីទទួលបន្ទុកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>– ជំរុញអាជ្ញាធរគ្រប់គ្រង និងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋឱ្យបន្តពង្រឹងកិច្ចសហការ ដើម្បីពន្លឿនការជំរុញអនុវត្តនីតិវិធីនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ |
| ២៩ | – **ទំហំថវិការបស់រដ្ឋបាលខេត្តមួយចំនួន មិនទាន់ឆ្លើយតបទៅនឹងតម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍរបស់ខេត្ត។**<br>**ដំណើររឿង** ៖ យោងតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន (ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ) ចំណាយគុណប្រយោជន៍ និងចំណាយរដ្ឋបាលរបស់រដ្ឋបាលខេត្តត្រូវរ៉ាប់រងទាំងស្រុងដោយចំណូលផ្ទៃក្នុងរបស់រដ្ឋបាលខេត្តសាមី លើកលែងតែចំណាយសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានប្រគល់ដោយថ្នាក់ជាតិដែលត្រូវរ៉ាប់រងដោយការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ។ ពាក់ព័ន្ធបញ្ហានេះ រដ្ឋបាលខេត្តមួយចំនួនមានបញ្ហាប្រឈមក្នុងការប្រមូលចំណូលផ្ទាល់របស់ខ្លួន ដោយសារប្រភពចំណូលក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមិនសូវមានសក្តានុពល។<br>**ដំណោះស្រាយ៖**<br>– ទំហំថវិការបស់រដ្ឋបាលខេត្តនីមួយៗទទួលបានតាមរយៈសក្តានុពលនៃការប្រមូលចំណូលនៅមូលដ្ឋានផ្ទាល់ ដែលរួមមានចំណូលមិនមែនសារពើពន្ធ និងសារពើពន្ធ |

| | |
|---|---|
| | – កន្លងមកដោយសក្តានុពលនៃការប្រមូលចំណូលរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ មានគម្លាតទំហំចំណូល ទើបមានការបែងចែកចំណូលពីរដ្ឋបាលរាជធានី ខេត្តដែលមានទំហំចំណូលច្រើន ទៅរដ្ឋបាលខេត្តដែលមានទំហំចំណូលតិច ដើម្បីធានាសមធម៌ និងបន្ថយគម្លាតអភិវឌ្ឍន៍ពីខេត្តមួយទៅខេត្តមួយ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំឱ្យមានយន្តការនៃការឧបត្ថម្ភធនប្រចាំឆ្នាំ ជូនរដ្ឋបាលខេត្ត។ ប្រភពធនធាននេះ រួមមានចំណូលពីខេត្តដែលមានសក្តានុពលប្រមូលចំណូល និងបែងចែកជូនរដ្ឋបាលខេត្តដែលមានប្រភពចំណូលខ្សត់ខ្សោយ។ ការផ្ទេរនេះ ត្រូវបានកំណត់ដោយរូបមន្តច្បាស់លាស់ ដើម្បីធានាសមធម៌ ព្រមទាំងគិតគូរផងដែរពីតម្រូវការជាក់ស្តែងរបស់រដ្ឋបាលខេត្ត មួយចំនួនដែលមានលក្ខណៈចាំបាច់បន្ទាន់ និងដែលមានការចង្អុលបង្ហាញដោយផ្ទាល់ពីរាជរដ្ឋាភិបាល<br>– លើសពីនេះ ក៏មានការបែងចែកថវិកាពី មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ (អតិរេកថវិការាជធានី ខេត្ត បន្ថែមជូនរដ្ឋបាលរាជធានី ខេត្តផងដែរ) ប៉ុន្តែប្រភពពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនេះ ដែលជាអតិរេកថវិកាមានការប្រែប្រួលមិនទៀងទាត់ អាស្រ័យលើការអនុវត្តចំណូល ចំណាយថវិកាប្រចាំឆ្នាំជាក់ស្តែង ឧទាហរណ៍ ឆ្នាំ២០២២ មានចំនួន ១២៤ ៤៨៥,៦លានរៀល យោងទៅច្បាប់ឆ្នាំ២០២៤ និងឆ្នាំ២០២៣មានចំនួន ១៥ ៧០០លានរៀល យោងទៅច្បាប់ឆ្នាំ២០២៥<br>– អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសិក្សាលទ្ធភាពនៃការកំណត់ប៉ារ៉ាម៉ែត្រនៃការវិភាជន៍ឧបត្ថម្ភធនជូនរដ្ឋបាលរាជធានីខេត្តតាមរូបមន្ត រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានការបែងចែកចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន តាមរយៈយន្តការ "មូលនិធិភាតរភាព" និងទទួលបានពីធនធានបន្ថែមពី Capital Gain Tax ពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យផងដែរ។<br><br>* * * * *<br><br>– **ការចំណាយផ្នែកប្រតិបត្តិការរដ្ឋបាល ជាពិសេសចំណាយបេសកកម្មមានតម្រូវការច្រើន ផ្អែកទៅលើទំហំការងារ មុខងារ និងការទទួលខុសត្រូវដែលបានផ្ទេរកាន់តែច្រើនឡើងៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ប្រតិភូកម្ម និងប្រគល់) កិច្ចប្រជុំនៅថ្នាក់ជាតិ និងការចុះគាំទ្ររដ្ឋបាលមូលដ្ឋាន (ក្រុង ស្រុក ឃុំ សង្កាត់) ដែលថវិការដ្ឋបាលខេត្តមានកម្រិត មិនអាចទូទាត់បានគ្រប់គ្រាន់ អាស្រ័យហេតុនេះស្នើសុំឱ្យមានការពិចារណាក្នុងការបង្កើនចំណាយផ្នែកប្រតិបត្តិការរដ្ឋបាលឱ្យបានសមស្រប។** |

**ដំណើររឿង ៖** មុខងារសំខាន់ៗមួយចំនួនត្រូវបានផ្ទេរជាបណ្ដើរៗទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ ប្រការនេះបានធ្វើឱ្យបន្ទុកការងារ ការទទួលខុសត្រូវ និងការចំណាយរបស់រដ្ឋបាលរាជធានី ខេត្តសម្រាប់រ៉ាប់រងលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះមានការកើនឡើងជាលំដាប់ផងដែរ ដែលជាហេតុធ្វើឱ្យរដ្ឋបាលរាជធានី ខេត្តខ្វះថវិកាសម្រាប់គាំទ្រផ្នែកប្រតិបត្តិការ។

**ដំណោះស្រាយ៖**

- តាមគោលការណ៍របស់រាជរដ្ឋាភិបាល ចំណាយប្រតិបត្តិការរដ្ឋបាលជាមុខសញ្ញាចំណាយដែលត្រូវមានការគិតគូរក្នុងស្មារតីសន្សំសំចៃ
- លើកទឹកចិត្តដល់រដ្ឋបាលរាជធានី ខេត្តផ្ដល់អាទិភាពដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន និងការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធនានានៅមូលដ្ឋាន
- កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតឱ្យមានការគ្រោងកើនថវិកាចំណាយប្រតិបត្តិការរដ្ឋបាល ក្នុងរង្វង់ ៣% ផងដែរ ប្រសិនបើមានតម្រូវការចាំបាច់ គាំទ្រការអនុវត្តសកម្មភាពថ្មីៗ ក្នុងការផ្ដល់សេវាសាធារណៈ ឧទាហរណ៍ តម្រូវការចំណាយ កាត់ឯកសណ្ឋានបេសកកម្ម អគ្គិសនី ទឹក...
- ក្នុងស្មារតីសន្សំសំចៃ រដ្ឋបាលរាជធានី ខេត្តត្រូវគិតគូរផ្ដល់អាទិភាពដល់មុខសញ្ញាចំណាយប្រតិបត្តិការរដ្ឋបាល ដែលឆ្លើយតបទៅនឹងសកម្មភាពការងារ និងតម្រូវការចាំបាច់នៃការផ្ដល់សេវានៅមូលដ្ឋាន។

* * * * *

- **ការចំណាយថវិកាសម្រាប់ចុះតាមមូលដ្ឋានរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺទទួលបានចាប់ពីការធ្វើដំណើរលើសពី២០គីឡូម៉ែត្រ ក្រោម២០គីឡូម៉ែត្រគឺមិនទទួលបានឡើយ និងសំណូមពរជួយផ្ដល់នូវធនធានហិរញ្ញវត្ថុសម្រាប់ចម្ងាយក្រោម២០គីឡូម៉ែត្រ (ប្រេង)**

**ដំណើររឿង ៖** យោងប្រកាសលេខ៥៥៩ ឆ្នាំ២០២២ ស្ដីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ បានកំណត់ថា ប្រាក់បេសកកម្មត្រូវផ្ដល់ជូនមន្ត្រីរាជការសាធារណៈ ដែលចុះធ្វើសកម្មភាពចេញពីរង្វង់ដែនដីរាជធានី ឬរង្វង់ដែនដីនៃឃុំ/សង្កាត់នៃក្រុង ស្រុកសាមី ដែលមានចម្ងាយចាប់ពី២០គីឡូម៉ែត្រឡើងទៅ។ ពាក់ព័ន្ធនឹងបញ្ហានេះ ផ្អែកតាមស្ថានភាពភូមិសាស្ត្រ

ជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានលក្ខណៈខុសគ្នា ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្ថានភាពភូមិសាស្ត្រធំទូលាយ ស្នើសុំឱ្យមានការពិចារណាក្នុងការផ្តល់ប្រាក់បេសកកម្មសម្រាប់ការធ្វើសកម្មភាពក្រោម២០គីឡូម៉ែត្រចេញពីរង្វង់ដែនដីរបស់ខ្លួន។

**ដំណោះស្រាយ៖** ប្រកាសលេខ ៥៥៩ សហវ.អហក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ស្តីពីរបិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងស្មារតីសន្សំសំចៃថវិកា និងបានកំណត់៖

- ការបម្លាស់ទីក្នុងគោលដៅបេសកកម្មចេញពីដែនដីនៃឃុំ សង្កាត់មួយទៅដែនដីឃុំ សង្កាត់មួយផ្សេងៗទៀត ទទួលប្រាក់បេសកកម្ម (លើកលែងបម្លាស់ទីក្នុងរង្វង់រាជធានីភ្នំពេញ)
- សោហ៊ុយធ្វើដំណើរដោយមធ្យោបាយរដ្ឋ ឬផ្ទាល់ខ្លួន (រថយន្ត ១០០គីឡូម៉ែត្រ= ៨ម៉ឺនរៀល, ទោចក្រយានយន្ត ១០០គីឡូម៉ែត្រ= ២,៥ម៉ឺនរៀល, ការទូទាត់តាមសមាមាត្រនៃចំងាយផ្លូវជាក់ស្តែង)។ សោហ៊ុយធ្វើដំណើរដោយមធ្យោបាយសាធារណៈ ដូចជា រថយន្តក្រុង រថយន្តឈ្នួល កាណូត ឬកប៉ាល់ ត្រូវទូទាត់តាមវិក្កយបត្រជាក់ស្តែង
- សម្រាប់ការបម្លាស់ទីដែលមានចម្ងាយក្រោម ២០គ.ម ឆ្លងឃុំ មានការផ្តល់ជូនប្រាក់ហោប៉ៅ (ទទួលបានយ៉ាងតិច ១៦.០០០ រៀល ដល់ ២៤.០០០ រៀល ទៅតាមឋានៈ)
- ផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងសោហ៊ុយធ្វើដំណើរសម្រាប់ការបម្លាស់ទីដែលមានចម្ងាយចាប់ពី ២០គ.ម និងផ្តល់ជូនបន្ថែមប្រាក់ស្នាក់នៅសម្រាប់ការបម្លាស់ទីចម្ងាយលើសពី ៤០គ.ម
- គួរបន្តអនុវត្តទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន (មិនផ្តល់ជូនប្រាក់បេសកកម្មសម្រាប់ការធ្វើដំណើរនៅក្នុងឃុំ ទោះមានចម្ងាយផ្លូវ ២០គ.ម ក៏ដោយ)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តពង្រឹងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**តារាងឧបសម្ព័ន្ធទី៧.៤. (ស្ថានភាពទី៤)**

# បញ្ហាប្រឈម សំណើសំណូមពរចំនួន៧ ដែលពុំទាន់មានគ្រោងជាសកម្មភាពនៅក្នុងផែនការ ឬកម្មវិធីណាមួយ និងត្រូវបានដាក់ចេញនូវវិធានការដោះស្រាយក្នុងកិច្ចប្រជុំ គ.ជ.អ.ប. កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ និងដំណោះស្រាយ |
|---|---|
| ១ | **– រដ្ឋបាលក្រុង ស្រុកភាគច្រើនខ្វះមន្ត្រីជំនាញតាមវិស័យមួយចំនួន (កសិកម្ម ធនធានទឹក បរិស្ថាននិងអនាម័យ អភិវឌ្ឍន៍ជនបទ សាធារណការ និងធនធានធម្មជាតិ....) និងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់លើការកសាងផែនការ ការសិក្សា រៀបចំ និងអនុវត្តគម្រោងឃុំ សង្កាត់...**<br>**– មន្ត្រីរបស់រដ្ឋបាលក្រុង ស្រុកដែលមានស្រាប់ពុំទាន់មានជំនាញបច្ចេកទេសច្បាស់លាស់តាមវិស័យ ដែលស្នើសុំឱ្យមានការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពជំនាញ។**<br><br>**ដំណើររឿង៖** ផ្អែកតាមអនុក្រឹត្យលេខ១៨២ និងលេខ១៨៤ ឆ្នាំ២០១៩ បុគ្គលិករបស់ការិយាល័យជំនាញតាមវិស័យនានាត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។ ទោះយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពបច្ចុប្បន្ន បុគ្គលិកដែលបានផ្ទេរទាំងនោះ ក្នុងវិស័យមួយចំនួនមានបុគ្គលិកតិចឬពុំមានបុគ្គលិក បុគ្គលិកមួយចំនួនពុំមានជំនាញបច្ចេកទេស បុគ្គលិកខ្លះមានអាយុច្រើន និងចូលនិវត្តន៍ជាបណ្តើរៗ **(បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុង២០វិស័យរួមទាំងក្រសួងមហាផ្ទៃផងក្នុងឆ្នាំ២០២០មានចំនួន១៣.០៧៤នាក់ រហូតដល់បច្ចុប្បន្នគិតត្រឹមតែកក្កដា ឆ្នាំ២០២៤មានចំនួន១០.០២៤នាក់ ដូច្នេះមានការថយចុះចំនួន២.៩៥០នាក់)**។ ជាមួយគ្នានេះក្នុងអំឡុងពេលប៉ុន្មានឆ្នាំក្រោយមកនេះ រាជរដ្ឋាភិបាលបានផ្អាកការជ្រើសរើសបុគ្គលិកក្របខ័ណ្ឌរដ្ឋថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ជំនួសអ្នកដែលចូលនិវត្តន៍...) អាស្រ័យហេតុនេះធ្វើឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុកជួបបញ្ហាប្រឈមពាក់ព័ន្ធនឹងការខ្វះបុគ្គលិកជំនាញសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យ។ |

| | |
|---|---|
| | **ដំណោះស្រាយ ៖**<br>(១). ក្រសួងមុខងារសាធារណៈសហការជាមួយនឹងក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ពន្លឿនការផ្សព្វផ្សាយអនុក្រឹត្យលេខ៧៦ ស្ដីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុកមានមូលដ្ឋានក្នុងការកំណត់ប្រភេទមុខតំណែងវិជ្ជាជីវៈ និងចំនួនបុគ្គលិកតាមមុខតំណែងវិជ្ជាជីវៈនីមួយៗដែលត្រូវការជាក់ស្ដែងពិតប្រាកដផ្អែកលើមុខងារជាក់លាក់ ទំហំការងារ តម្រូវការសេវា និងសក្ដានុពលសេដ្ឋកិច្ចនៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗ ព្រមទាំងរៀបចំផែនការបុគ្គលិកឱ្យបានច្បាស់លាស់។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវរួមគ្នាធ្វើការសិក្សា និងពិនិត្យមើលឡើងវិញនូវស្ថានភាពនិងតម្រូវការមន្ត្រីជាក់ស្ដែង ផ្អែកទៅតាមមុខងារជាក់លាក់ និងជាវិធានការចំពោះមុខ ត្រូវពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីដែលមានស្រាប់ ដើម្បីបំពេញការងារជាមួយនឹងការពង្រឹងសមត្ថភាពដល់មន្ត្រីទាំងនោះ។<br>(២). ចំពោះការបណ្ដុះបណ្ដាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្នើឱ្យមានកិច្ចសហការគ្នារវាងសាលាភូមិន្ទរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ដើម្បីពិភាក្សាគ្នាអំពីវិធីសាស្ត្រ និងកម្មវិធីបណ្ដុះបណ្ដាលដល់មន្ត្រីជំនាញនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>******<br>• **ខ្វះមន្ត្រីនៅតាមទីចាត់ការមួយចំនួន និងខ្វះមន្ត្រីបច្ចេកទេស (ជំនាញសំណង់ស៊ីវិល និងវិស្វករ) សម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់លើការងារសិក្សា រៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម និងការរៀបចំផែនការអភិវឌ្ឍន៍...។**<br>**ដំណើររឿង ៖** ធនធានឆន្ទានុសិទ្ធិ ជាពិសេសមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក ដើម្បីប្រើប្រាស់សម្រាប់រៀបចំ និងអនុវត្តគម្រោងនានា រួមមានទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសេវាកម្មដែលឃុំ សង្កាត់ និងក្រុង ស្រុកនីមួយៗ ត្រូវរៀបចំ និងអនុវត្តក្នុងឆ្នាំនីមួយៗ។ ការរៀបចំ និងអនុវត្តគម្រោងទាំងនេះចាំបាច់ត្រូវមានការសិក្សាលទ្ធភាពគម្រោង ការសិក្សាផលប៉ះពាល់បរិស្ថាននិងសង្គម ការរៀបចំប្លង់គម្រោង និងការសិក្សាលក្ខណៈបច្ចេកទេសលើចំណុចសំខាន់ៗជាច្រើនផ្សេងទៀត។ ផ្អែកតាមតម្រូវការជាក់ស្ដែង បើប្រៀបធៀបទៅនឹងសមត្ថភាព និងលទ្ធភាពគាំទ្រផ្នែកបច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្ត គឺនៅមិនទាន់ |

| | |
|---|---|
| | ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកដែលត្រូវការរៀបចំ និងអនុវត្តគម្រោងតាមឆ្នាំនីមួយៗ ប្រកបដោយប្រសិទ្ធភាពបានឡើយ ដោយសារកង្វះមន្ត្រីបច្ចេកទេស និងសមត្ថភាពគាំទ្របច្ចេកទេសពីរដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ នៅតាមទីចាត់ការមួយចំនួនក៏មានការខ្វះមន្ត្រីមួយចំនួនបើធៀបទៅនឹងទំហំការងារ និងតួនាទីភារកិច្ចរបស់ទីចាត់ការនីមួយៗ។<br><br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានគ.ជ.អ.ប. រួមគ្នាសិក្សា និងកំណត់អំពីមុខតំណែងវិជ្ជាជីវៈឱ្យបានច្បាស់លាស់តាមអង្គភាពនីមួយៗនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីមានមូលដ្ឋានកំណត់អំពីតម្រូវការធនធានមនុស្សជាក់ស្តែងឆ្លើយតបទៅនឹងមុខងារនិងតួនាទីភារកិច្ចរបស់អង្គភាពនីមួយៗ។ ជាវិធានការចំពោះមុខត្រូវពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីដែលមានស្រាប់ ដើម្បីបំពេញការងារជាមួយនឹងការពង្រឹងសមត្ថភាពដល់មន្ត្រីទាំងនោះ។ |
| ២ | **រដ្ឋបាលថ្នាក់ក្រោមជាតិស្នើសុំឱ្យមានប្រព័ន្ធលើកទឹកចិត្តដល់សមាជិកក្រុមប្រឹក្សា៖**<br>▪ **ប្រាក់សោធននិវត្តន៍សម្រាប់សមាជិកក្រុមប្រឹក្សាដែលបានជាប់ឆ្នោតលើសពី៣ អាណត្តិឡើង**<br>▪ **ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សាជាស្ត្រី។**<br><br>**ដំណើររឿង** ៖ ការស្នើសុំឱ្យមានប្រព័ន្ធលើកទឹកចិត្តនេះ គឺដើម្បីឱ្យសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនមែនជាអតីតមន្ត្រីរាជការ គឺជាប្រជាពលរដ្ឋសុទ្ធសាធដែលបានជាប់ការបោះឆ្នោតជាសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនអាណត្តិ(៣អាណត្តិ) ដើម្បីឱ្យទទួលបានប្រាក់គាំពារសង្គម និងប្រាក់លើកទឹកចិត្តនៅពេលដែលបញ្ចប់ការងារដោយសារហេតុផលសុខភាព ចាស់ជរា ឬដោយសារមូលហេតុផ្សេងទៀត។ ករណីនេះ ចំពោះបុគ្គលិកដែលបម្រើការងារនៅតាមវិស័យផ្សេងៗសុទ្ធតែមានការគិតគូរអំពីការឧបត្ថម្ភគាំទ្រសង្គមនៅពេលបាត់បង់ការងារ ដូចជាកម្មករបម្រើការងាររោងចក្រ និងតាមសិប្បកម្មវិស័យឯកជនជាដើម។ ជាមួយគ្នានេះ បទពិសោធន៍នៃប្រទេសនានាដូចជាប្រទេសឥណ្ឌូនេស៊ីក៏ត្រូវបានផ្តល់ការឧបត្ថម្ភគាំទ្រសង្គមនេះ ចំពោះសមាជិកក្រុមប្រឹក្សាណាដែលបំពេញការងារបាន១អាណត្តិផងដែរ។<br><br>**ដំណោះស្រាយ៖**<br><br>– ឯកភាពជាគោលការណ៍។ ស្នើឱ្យមានការសិក្សាឱ្យបានម៉ត់ចត់ ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ រួមទាំងក្រសួងសេដ្ឋកិច្ចនិង |

| | |
|---|---|
| | ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិនិត្យលទ្ធភាព និងសុំគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាលដើម្បីចាប់ផ្ដើមអនុវត្តចាប់ពីឆ្នាំ២០២៧។ លើសពីនេះ ក៏ត្រូវមានការគិតគូរប្រៀបធៀបជាមួយគោលការណ៍ប្រាក់សោធននិវត្តន៍របស់មន្ត្រីរាជការស៊ីវិល និងបន្ទុកចំណាយថវិការដ្ឋ<br>• សម្រាប់មន្ត្រីរាជការ អតីតភាពការងារលើសពី៣០ឆ្នាំ ស្មើនឹង៨០% និងលើសពី២០ឆ្នាំ ស្មើនឹង៦០%<br>• ឃុំ សង្កាត់មានចំនួនសរុប**១.៦៥២** និងមានក្រុមប្រឹក្សាសរុប**ចំនួន១១.៦២២នាក់** ក្នុងនោះ៖<br>+ ជាមន្ត្រីរាជការ ទទួលបានប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា<br>+ ជាអតីតមន្ត្រីរាជការចូលនិវត្តន៍ ទទួលបានប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា<br>+ ជាប្រជាពលរដ្ឋ ទទួលបានប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាសុទ្ធសាធ<br>– ត្រូវសិក្សាបន្ថែមអំពីចំនួនក្រុមប្រឹក្សាដែលជាប្រជាពលរដ្ឋ ដើម្បីពិនិត្យលទ្ធភាពថវិកាដោយសិក្សារួម ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (**សរុបរួម១៥.៨២២រូប**)ផងដែរ<br>– ឯកភាពជាគោលការណ៍លើសំណើផ្ដល់ប្រាក់លំហែមាតុភាពសម្រាប់សមាជិកក្រុមប្រឹក្សាជាស្ត្រី។ ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវធ្វើការសិក្សាអំពីបញ្ហានេះ ដោយមានកិច្ចសហការជាមួយស្ថាប័ន/អង្គភាពពាក់ព័ន្ធ ដើម្បីលើកយោបល់អំពីលទ្ធភាពនៃការចាប់ផ្ដើមអនុវត្តពីឆ្នាំ២០២៥នេះ ឬដើមឆ្នាំ២០២៦។ |
| ៣ | – **ស្នើសុំពិនិត្យ និងកែសម្រួលគោលការណ៍ នីតិវិធី និងលក្ខណៈសម្បត្តិនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិ។**<br>– **ស្នើសុំដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែដល់មេភូមិ អនុភូមិ និងជំនួយការភូមិ។**<br>**ដំណើររឿង ៖**<br>– ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំភូមិត្រូវអនុវត្តតាមសេចក្ដីណែនាំលេខ០០៤ ស.ណ.ន. ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ក្នុងនោះ មេភូមិត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងចំណោមបេក្ខជនឈរឈ្មោះ ដែលស្នើឡើងដោយមេឃុំ ចៅសង្កាត់ ចៅសង្កាត់រង និងជំទប់ ហើយអនុប្រធានភូមិ និងសមាជិកភូមិត្រូវបានបោះឆ្នោតជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងចំណោម |

បេក្ខជនឈរឈ្មោះដែលស្នើដាក់ឡើងដោយមេភូមិ និងមេឃុំ ឬចៅសង្កាត់។ ផ្អែកតាមសេចក្តីណែនាំ ថ្នាក់ដឹកនាំភូមិទាំង៣រូបនេះ ត្រូវបានកំណត់លក្ខណសម្បត្តិត្រឹមតែចេះអាន និងសរសេរ និងពុំមានកំណត់អាយុ ឬអាណត្តិការងារនោះទេ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការផ្លាស់ប្តូរថ្នាក់ដឹកនាំភូមិ ជាពិសេសថ្នាក់ដឹកនាំភូមិ ភាគច្រើនមានវ័យចំណាស់ និងសមត្ថភាពធ្វើការងារមានកម្រិត។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងការធ្វើគណនេយ្យភាពរបស់ថ្នាក់ដឹកនាំភូមិចំពោះប្រជាពលរដ្ឋ ឃុំ សង្កាត់មួយចំនួនបានស្នើសុំកែសម្រួលគោលការណ៍ នីតិវិធី និងលក្ខណសម្បត្តិនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិដូចខាងលើ និងស្នើសុំពិចារណាការដំឡើងប្រាក់ឧបត្ថម្ភដល់ថ្នាក់ដឹកនាំភូមិផងដែរ

- ពាក់ព័ន្ធនឹងប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិនេះ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ ប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិឆ្នាំ២០២៥នេះមានការកើនឡើងដូចជា ប្រាក់ឧបត្ថម្ភមេភូមិ កើន៣២,៥% អនុប្រធានភូមិ កើន៤៣% និងសមាជិកភូមិ កើន៤៨%។ ជារួម ចំនួនសមាជិកភូមិនៅទូទាំងប្រទេសសរុប ៤៣.៧៤៣នាក់ និងទទួលបានការដំឡើងប្រាក់ឧបត្ថម្ភជាបន្តបន្ទាប់រៀងរាល់ឆ្នាំ ក្នុងកម្រិតមួយសមស្រប តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ដំណោះស្រាយ ៖**

- ក្រសួងមហាផ្ទៃនឹងធ្វើការសិក្សាពិនិត្យមើលឡើងវិញលើគោលការណ៍ លក្ខណៈសម្បត្តិ និងនីតិវិធីនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋានគ.ជ.អ.ប. នឹងសិក្សាលើលទ្ធភាពនៃការដំឡើងប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិ ដោយកំណត់យកពិដាននៃប្រាក់ឧបត្ថម្ភមេភូមិ ប្រហាក់ប្រហែលនឹងបុគ្គលិកជាប់កិច្ចសន្យា (បច្ចុប្បន្នស្មើនឹង ៧៩០.០០០ រៀល) ហើយអនុប្រធានភូមិ និងសមាជិកភូមិ ត្រូវគិតគូរក្នុងគម្លាតពីមេភូមិក្នុងកម្រិតសមស្របណាមួយ។ ជាមួយគ្នានេះ ត្រូវគិតគូរអំពីរយៈពេលនៃការបង្កើនប្រាក់ឧបត្ថម្ភមេភូមិឱ្យស្មើពិដានបុគ្គលិកកិច្ចសន្យាក្នុងរយៈពេលណាមួយសមស្រប (៣ឆ្នាំទៅ៥ឆ្នាំ) ដែលអាចនឹងចាប់ផ្តើមអនុវត្តពីឆ្នាំ២០២៦ ទៅដល់ឆ្នាំ២០២៨ ឬពីឆ្នាំ២០២៧ ទៅដល់ឆ្នាំ២០៣០។ ជាមួយគ្នានេះ ក៏ត្រូវគិតអំពីលទ្ធភាពនៃការបង្កើនថវិការបស់ឃុំ សង្កាត់ដែរ ដើម្បីរ៉ាប់រងលើការចំណាយប្រាក់ឧបត្ថម្ភនេះ។

| ៤ | – **ថវិកាអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក មិនទាន់ឆ្លើយតបបានសមស្របនឹងតម្រូវការជាអាទិភាពជាច្រើនរបស់ប្រជាពលរដ្ឋ ដូចនេះ ស្នើសុំថ្នាក់ជាតិពិនិត្យលទ្ធភាពបង្កើនធនធានថវិកាផ្នែកអភិវឌ្ឍន៍ និងសេវាសង្គម...។** |
|---|---|

**ចំណើររឿង** ៖ ទោះបីថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកត្រូវបានបង្កើនជាបន្តបន្ទាប់ក៏ដោយ (ឧ. ក្នុងឆ្នាំ២០០២ ឃុំ សង្កាត់នីមួយៗទទួលបានថវិកាផ្នែកអភិវឌ្ឍន៍ជាមធ្យមប្រមាណ២.៧០០ដុល្លារ និងក្នុងឆ្នាំ២០២៤នេះ មានការកើនរហូតដល់ប្រមាណជាង ១០ម៉ឺនដុល្លារក៏ដោយ ប៉ុន្តែតម្រូវការអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននៅតែមានចំនួនច្រើន លើសពីលទ្ធភាពថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុក (ផ្អែកតាមគម្រោងអាទិភាពបានលើកឡើងក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។

**បច្ចុប្បន្ន ចំណាយអភិវឌ្ឍន៍រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវបានបង្កើនរៀងរាល់ឆ្នាំ៖**

- កញ្ចប់ថវិកាក្រុង ស្រុកនីមួយៗសរុបជាមធ្យមក្នុង១ឆ្នាំ

| **បរិយាយ** | **ឆ្នាំ២០២៣** | **ឆ្នាំ២០២៤** | **ឆ្នាំ២០២៥** | **២៥/២៤** |
|---|---|---|---|---|
| **ថវិកាក្រុង ស្រុកនីមួយៗ ជាមធ្យមក្នុង១ឆ្នាំ (ដុល្លារ)** | **៤៩២ ៥០០** | **៥៨៦ ០០០** | **៦៦៤ ០០០** | **១៣,៣%** |
| *បន្ទុកបុគ្គលិក* | ២១០ ២០០ | ២៣១ ០០០ | ២២៥ ០០០ | -២,៦% |
| *រដ្ឋបាល* | ៧៤ ៣០០ | ៩៦ ០០០ | ៩៦ ០០០ | ០ |
| *សេវាសង្គម និងបរិស្ថាន* | | ២៥ ០០០ | ២៥ ០០០ | ០ |
| *ចំណាយអភិវឌ្ឍន៍ជាមធ្យម* | ២០៨ ០០០ | ២៣៤ ០០០ | ៣១៨ ០០០ | ៣៥,៨% |

- កញ្ចប់ថវិកាឃុំ សង្កាត់នីមួយៗសរុប ជាមធ្យម ក្នុង១ឆ្នាំ

| **បរិយាយ (ដុល្លារ)** | **ឆ្នាំ២០២៣** | **ឆ្នាំ២០២៤** | **ឆ្នាំ២០២៥** | **២៥/២៤** |
|---|---|---|---|---|
| **ថវិកាឃុំ សង្កាត់នីមួយៗ ជាមធ្យម ក្នុង ១ឆ្នាំ (ដុល្លារ)** | **១៥៦ ០០០** | **១៨៨ ០០០** | **២១០ ០០០** | **១១,៧%** |
| *បន្ទុកបុគ្គលិក* | ៥៥ ៥០០ | ៥៩ ០០០ | ៦១ ៧០០ | ៤,៥% |

| | | | | |
|---|---|---|---|---|
| *រដ្ឋបាល* | ១២ ៥០០ | ១៦ ៣០០ | ១៩ ៧០០ | ២០,៨% |
| *សេវាអនាម័យ-បរិស្ថាន* | | ៩ ៧០០ | ១៦ ០០០ | ៦៤,៩% |
| *ចំណាយអភិវឌ្ឍន៍ជាមធ្យម* | ៨៨ ០០០ | ១០៣ ០០០ | ១១២ ៦០០ | ៩,៣% |

- **រដ្ឋបាលក្រុង ស្រុក៖** បង្កើនថវិកាមូលនិធិក្រុង ស្រុក តាមរយៈការកើនឡើងនៃចំណូលចរន្តថវិកាជាតិ ពីមួយឆ្នាំទៅមួយឆ្នាំ (១,៦%), ការផ្តល់ចំណូលពីចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្តជូនរដ្ឋបាលក្រុង ស្រុក (៤%) ដែលនាំឱ្យរដ្ឋបាល ក្រុង ស្រុកបច្ចុប្បន្ននេះមានថវិកាចំណាយអភិវឌ្ឍន៍ប្រមាណជាមធ្យម **៣១៨.០០០ដុល្លារអាមេរិក**
- **រដ្ឋបាលឃុំ សង្កាត់៖** បង្កើនថវិកាមូលនិធិឃុំ សង្កាត់ តាមរយៈការកើនឡើងនៃចំណូលចរន្តថវិកាជាតិ ពីមួយឆ្នាំទៅមួយឆ្នាំ (៣,៥%), ធនធានបន្ថែមនៃចំណូលចរន្តថវិកាជាតិសម្រាប់អភិវឌ្ឍន៍ (១%) ការបង្កើនចំណូលពីចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលរាជធានីខេត្តជូនរដ្ឋបាលឃុំ សង្កាត់រៀងរាល់ឆ្នាំ (៦%) ដែលនាំឱ្យរដ្ឋបាលឃុំ សង្កាត់បច្ចុប្បន្ននេះមានថវិកាចំណាយអភិវឌ្ឍន៍ប្រមាណជាមធ្យម **១១២.៦០០ដុល្លារអាមេរិក។**

**ដំណោះស្រាយ ៖**

- រក្សាអត្រាវិភាជន៍ពីថវិការដ្ឋទៅមូលនិធិក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ តាមស្មារតីនៃអនុក្រឹត្យដែលបានកំណត់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨។ អត្រានេះនឹងត្រូវគិតគូរឡើងវិញនៅចាប់ពីឆ្នាំ២០២៩
- ទន្ទឹមនឹងនេះ នៅពេលឆាប់ៗខាងមុខនេះ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នឹងទទួលបានធនធានបន្ថែមពីយន្តការមូលនិធិភាតរភាព ដែលប្រភពចំណូលសំខាន់ពីការផ្ទេរចំណូលពីសេវាសាធារណៈ (១៥%) និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន។ **បច្ចុប្បន្ន សេចក្តីព្រាងអនុក្រឹត្យស្តីពីមូលនិធិភាតរភាព ត្រូវបានរៀបចំរួច គ្រោងប្រជុំពិភាក្សាជាមួយក្រសួងមហាផ្ទៃ និងដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៥**
- ជាមួយគ្នានេះផងដែរ រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នឹងត្រូវបន្ថែមនូវអត្រា០,៥% ពីការបែងចែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានីខេត្តនៅពេលដែលរដ្ឋបាលរាជធានី ខេត្ត នឹងទទួលបានប្រភពចំណូលសំខាន់ថ្មីមួយគឺពន្ធលើប្រាក់ចំណេញមូលធន (Capital Gain Tax)។

* * * * *

| | |
|---|---|
| | – **រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្តពុំមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយតប និងដោះស្រាយតម្រូវការជាអាទិភាពជាច្រើនរបស់ប្រជាពលរដ្ឋដែលបានលើកឡើងតាមរយៈវេទិកាសាធារណៈនានា ដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងាររាជរដ្ឋាភិបាល។**<br>**ដំណើររឿង** ៖ ការរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងាររាជរដ្ឋាភិបាល គឺជាយន្តការដ៏មានសារៈសំខាន់ក្នុងការផ្តល់ព័ត៌មាន ការស្តាប់មតិយោបល់ បញ្ហាប្រឈមនិងសំណើសំណូមពរនានា ព្រមទាំងការឆ្លើយតបចំពោះតម្រូវការអាទិភាពនានា និងដោះស្រាយបញ្ហាប្រឈមជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ក្នុងការអនុវត្តជាក់ស្តែង មានសំណើសំណូមពរជាច្រើនត្រូវបានលើកឡើង ប៉ុន្តែលទ្ធភាពហិរញ្ញវត្ថុ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតដែលមិនអាចឆ្លើយតបទៅនឹងសំណើ និងសំណូមពរដ៏ច្រើនរបស់ប្រជាពលរដ្ឋបានទេ។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣ថ្នាក់ស្នើសុំក្រសួង ស្ថាប័នពិនិត្យលទ្ធភាពជួយគាំទ្រ និងដោះស្រាយសំណើសំណូមពរជាអាទិភាពនានា។<br>**ដំណោះស្រាយ**៖ គួររៀបចំជាការសេចក្តីណែនាំរួមមួយក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល ដើម្បីពង្រឹងការរៀបចំ និងបញ្ចូលគម្រោងទាំងនេះ ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល/ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី ដើម្បីធ្វើអាទិភាវូបនីយកម្មគម្រោងដែលជាតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋដែលបានស្នើ។ |
| ៥ | **រដ្ឋបាលស្រុកមួយចំនួនពុំទាន់មានអគាររដ្ឋបាលសមរម្យនៅឡើយ។**<br>**ដំណើររឿង** ៖ បច្ចុប្បន្ន មានរដ្ឋបាលក្រុង ស្រុកសរុប១៩៦ ក្នុងនោះរដ្ឋបាលក្រុង ស្រុកគ្មានអគារចំនួន៧ អគារទ្រុឌទ្រោមចំនួន២៨ អគារមធ្យមចំនួន៦២ អគារល្អចំនួន៥០ និងអគារថ្មីចំនួន៤៨។<br>**ដំណោះស្រាយ** ៖ ក្រសួងមហាផ្ទៃសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំផែនការសាងសង់អគាររដ្ឋបាលស្រុកឱ្យបានសមស្រប។ |
| ៦ | – **រដ្ឋបាលខេត្តមួយចំនួនពុំទាន់មានប្លង់រៀបចំនគរូបនីយកម្ម និងប្លង់ប្រើប្រាស់ដីធ្លី**<br>– **ស្នើសុំឱ្យមានប្លង់គោលប្រើប្រាស់ដីធ្លីថ្នាក់ក្រុង ស្រុក។** |

| | |
|---|---|
| | **ដំណើររឿង** ៖ ការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មនេះ គឺស្ថិតក្រោមសមត្ថកិច្ចគណៈកម្មាធិការអន្តរក្រសួង ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។ បច្ចុប្បន្ន រដ្ឋបាលខេត្តចំនួន៣គឺខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងខេត្តមណ្ឌលគិរី មានផែនការរៀបចំដែនដីខេត្តរួចហើយ។ ក្រៅពីនេះ ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ប្លង់គោលប្រើប្រាស់ដីខណ្ឌចំនួន៨ គឺខណ្ឌជ្រោយចង្វារ, ខណ្ឌសែនសុខ, ខណ្ឌដូនពេញ, ខណ្ឌ៧មករា, ខណ្ឌព្រែកព្នៅ, ខណ្ឌទួលគោក, ខណ្ឌឫស្សីកែវ និងខណ្ឌមានជ័យ ប្លង់គោលប្រើប្រាស់ដីក្រុងចំនួន១៦គឺ ក្រុងព្រះសីហនុ, ក្រុងកែប, ក្រុងកំពត, ក្រុងខេមរភូមិន្ទ, ក្រុងបូកគោ, ក្រុងសៀមរាប, ក្រុងបាត់ដំបង, ក្រុងតាខ្មៅ, ក្រុងស្ទឹងត្រែង, ក្រុងបាវិត, ក្រុងសួង, ក្រុងប៉ោយប៉ែត, ក្រុងដូនកែវ, ក្រុងព្រះវិហារ, ក្រុងកំពង់ចាម និងក្រុងកោះរ៉ុង ប្លង់គោលប្រើប្រាស់ដីស្រុកចំនួន១ គឺ ស្រុកបរិបូណ៌ និងប្លង់គោលប្រើប្រាស់ដីទីប្រជុំជនចំនួន២ គឺទីប្រជុំជនត្បូងឃ្មុំ និងទីប្រជុំជនជ្រៃធំ ក៏ត្រូវបានរៀបចំរួចហើយផងដែរ។ ផ្អែកតាមស្ថានភាពនេះ រដ្ឋបាលខេត្ត ក្រុង ស្រុកមួយចំនួនធំនៅពុំទាន់មានផែនការរៀបចំដែនដី និងប្លង់គោលប្រើប្រាស់ដីនៅឡើយ។<br><br>**ដំណោះស្រាយ** ៖ គណៈកម្មាធិការអន្តរក្រសួងនឹងពន្លឿនការរៀបចំប្លង់រៀបចំនគរូបនីយកម្ម និងប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោលប្រើប្រាស់ដីធ្លីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៧ | **ការភ្ជាប់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំជាមួយនឹងរដ្ឋបាលក្រុង ស្រុក។**<br><br>**ដំណើររឿង** ៖ រដ្ឋបាលក្រុង ស្រុកត្រូវបានចាត់ទុកថាជាថ្នាក់រដ្ឋបាលដែលមានតួនាទី ភារកិច្ច មុខងារ និងមន្ត្រីជំនាញតាមវិស័យនានាសម្រាប់ការគាំទ្រ និងផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសជូនដល់ប្រជាពលរដ្ឋ។ នាពេលបច្ចុប្បន្ននេះ រដ្ឋបាលក្រុង ស្រុក បាននិងកំពុងជួបបញ្ហាប្រឈម គឺការខ្វះមន្ត្រីជំនាញសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យ ជាពិសេសការិយាល័យកសិកម្មក្រុង ស្រុកកំពុងមានតម្រូវការចាំបាច់នូវមន្ត្រីជំនាញដូចជា ជំនាញក្សេត្រសាស្ត្រ បសុព្យាបាល ផ្សព្វផ្សាយកសិកម្ម គ្រឿងយន្តកសិកម្មជាដើម ដើម្បីធានាឱ្យការិយាល័យនេះអាចបំពេញតួនាទីគាំទ្រដល់កសិករនៅតាមភូមិ ឃុំក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបាននិងកំពុងជ្រើសរើស និងពង្រាយមន្ត្រីកសិកម្មនៅតាមឃុំ សង្កាត់នីមួយៗ។ ក្នុងន័យនេះ ដើម្បីធានាដល់ |

| | |
|---|---|
| | ប្រសិទ្ធភាពនៃការគ្រប់គ្រង ការគាំទ្រ និងការប្រើប្រាស់មន្ត្រីកសិកម្មទាំងនេះ និងដោះស្រាយនូវបញ្ហាកង្វះមន្ត្រីជំនាញកសិកម្មនៅថ្នាក់ក្រុង ស្រុក រដ្ឋបាលក្រុង ស្រុកបានស្នើសុំឱ្យពិចារណាភ្ជាប់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកសិកម្មឃុំជាមួយនឹងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាននៃរដ្ឋបាលក្រុង ស្រុក ដើម្បីងាយស្រួលក្នុងការសម្របសម្រួលផ្តល់ការគាំទ្រ និងការផ្សព្វផ្សាយបច្ចេកទេសកសិកម្មជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសន្សំសំចៃ។<br><br>**ដំណោះស្រាយ** ៖ ពាក់ព័ន្ធនឹងសំណើនេះ ក្រសួងមុខងារសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរួមគ្នាសិក្សា និងលើកយោបល់អំពីការរៀបចំឱ្យមានប្រព័ន្ធការងារមួយដែលផ្សារភ្ជាប់គ្នារវាងមន្ត្រីកសិកម្មឃុំ ជាមួយនឹងការិយាល័យកសិកម្ម ធនធានធម្មជាតិ រដ្ឋបាលស្រុក និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម ដើម្បីមានមូលដ្ឋានក្នុងការលើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ |

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខ៖ ........................................./គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពសម្រាប់អនុវត្តវិធានការដោះស្រាយបញ្ហាប្រឈម សំណើសំណូមពររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០

| ល.រ | សកម្មភាព | សូចនាករ | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|
| ១ | ការរៀបចំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរ អង្គភាពពាក់ព័ន្ធអំពីខ្លឹមសារនៃអនុក្រឹត្យ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈ | ចំនួនវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ត្រីមាសទី២ ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈ និងក្រសួងអប់រំ យុវជន និងកីឡា<br><br>**ស្ថាប័នចូលរួម៖** ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ | អនុក្រឹត្យ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំងនាយកសាលាបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈត្រូវបានដាក់ចេញកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៥ |
| ២ | ការជ្រើសរើសមន្ត្រីសុខាភិបាលបន្ថែមតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក | ១.៣១៧នាក់ | ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈនិងក្រសួងសុខាភិបាល | កំពុងជ្រើសរើស |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការផ្សព្វផ្សាយប្រកាសអន្តរក្រសួងស្តីពីនីតិវិធីសម្រាប់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋសម្រាប់គម្រោងវិនិយោគក្រោម៥លានដុល្លារអាមេរិក | ចំនួន២៥ រាជធានី ខេត្តត្រូវបានផ្សព្វផ្សាយ | ត្រីមាសទី ២-៣ ឆ្នាំ ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានដាក់ចេញកាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៥ |
| ៤ | ការពិនិត្យមើលឡើងវិញអំពីក្របខ័ណ្ឌពេលវេលានៃការរៀបចំ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យទាន់ប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែលកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគិតគូរនៅក្នុងក្របខ័ណ្ឌនៃការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធវិនិយោគសាធារណៈ ២០២៦-២០៣០ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងផែនការ | |
| ៥ | ការពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត | សៀវភៅណែនាំ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | បាននិងកំពុងពិនិត្យ និងកែសម្រួល |

| | | | | | |
|---|---|---|---|---|---|
| ៦ | ការកំណត់អំពីមុខងារជាកាតព្វកិច្ច នីតិវិធី និងស្តង់ដាសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** លេខាធិការដ្ឋាន គ.ជ.អ.ប.<br>**ស្ថាប័នចូលរួម៖** ក្រសួងពាក់ព័ន្ធ | |
| ៧ | ការរៀបចំប្រកាសប្រតិភូកម្ម សេចក្តីណែនាំបច្ចេកទេស និងការបណ្តុះបណ្តាលដល់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពជំនាញលើការគ្រប់គ្រង និងការចុះបញ្ជីគម្រោងវិនិយោគក្រោម៥លានដុល្លារអាមេរិក | លិខិតបទដ្ឋានគតិយុត្ត និងវត្ថុបណ្តុះបណ្តាល | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងបរិស្ថាន/ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍/ក្រសួងសាធារណការនិងដឹកជញ្ជូន / ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ/ក្រសួងធនធានទឹកនិងឧតុនិយម/ក្រសួងពាណិជ្ជកម្ម/ ក្រសួងទេសចរណ៍/ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍/ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | – ក្រសួងចំនួន១០បានដាក់ចេញប្រកាសប្រតិភូកម្ម<br>– ក្រសួងចំនួន១បានដាក់ចេញសេចក្តីណែនាំ<br>– ក្រសួងមិនទាន់បានផ្តល់ការបណ្តុះបណ្តាលនៅឡើយ |
| ៨ | ការរៀបចំ និងដាក់ចេញសៀវភៅណែនាំស្តីពីនីតិវិធីនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | សៀវភៅណែនាំ និងវត្ថុបណ្តុះបណ្តាល | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន) និងក្រសួងយុត្តិធម៌ | បាននិងកំពុងរៀបចំ |

| | | | | | |
|---|---|---|---|---|---|
| ៩ | ការរៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ<br>**ស្ថាប័នចូលរួម៖** ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសុខាភិបាល | កំពុងអនុវត្តសាកល្បងនៅសង្កាត់ចំនួន៦នៃរាជធានីភ្នំពេញ |
| ១០ | ការសិក្សា និងធ្វើបច្ចុប្បន្នភាពកម្រងសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | បញ្ជីកម្រងសេវារដ្ឋបាល | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ<br>**ស្ថាប័នចូលរួម៖** ក្រសួងពាក់ព័ន្ធ | បាននិងកំពុងសិក្សា |
| ១១ | ការរៀបចំគោលការណ៍ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងសម្រាប់រដ្ឋបាលក្រុង ស្រុក | សេចក្តីណែនាំ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងរៀបចំសេចក្តីព្រាង |
| ១២ | ការសិក្សាអំពីធនធានថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ថវិកាសម្រាប់អនុវត្តមុខងារត្រូវបានផ្ទេរ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.<br>**ស្ថាប័នចូលរួម៖** ក្រសួងពាក់ព័ន្ធ | បានសិក្សារួចរាល់ និងកំពុងបូកសរុបរបាយការណ៍ |
| ១៣ | ការរៀបចំសេចក្តីណែនាំស្តីពីនីតិវិធីចំណាយ និងមុខសញ្ញាចំណាយសម្រាប់សេវាសង្គម | សេចក្តីណែនាំ | ត្រីមាសទី១ ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | បាននិងកំពុងរៀបចំសេចក្តីព្រាង |

| | | | | | |
|---|---|---|---|---|---|
| ១៤ | ការធ្វើសន្ធានកម្មរវាងប្រព័ន្ធគ្រប់គ្រងចំណូល NRMIS និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ FMIS | ប្រព័ន្ធទាំងពីរត្រូវបានធ្វើសន្ធានកម្ម | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | បាននិងកំពុងអនុវត្ត |
| ១៥ | ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធទូទាត់អេឡិចត្រូនិច | ប្រព័ន្ធទូទាត់អេឡិចត្រូនិច | ២០២៥-២០២៧ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| ១៦ | ការរៀបចំអនុក្រឹត្យស្ដីពីមូលនិធិភាតរភាព | អនុក្រឹត្យ | ត្រីមាសទី២ ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>**ស្ថាប័នចូលរួម៖** ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | បានរៀបចំសេចក្ដីព្រាង |
| ១៧ | ការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីកំណត់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័នក្នុងការធ្វើសវនកម្ម និងអធិការកិច្ច អភិក្រមនៃការធ្វើអធិការកិច្ច ព្រមទាំងវិធាននិងនីតិវិធីប្រតិបត្តិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>**ស្ថាប័នចូលរួម៖** ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ | បាននិងកំពុងរៀបចំ |
| ១៨ | ការសិក្សា និងការកំណត់ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ នីមួយៗដោយផ្អែកលើកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្រ | អនុក្រឹត្យ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | |

| | | | | | |
|---|---|---|---|---|---|
| ១៩ | ការសិក្សាពីលទ្ធភាពនៃការបង្កើតឱ្យមានការិយាល័យ ឬផ្នែកមួយចំនួននៅតាមរដ្ឋបាលឃុំ សង្កាត់នីមួយៗ | របាយការណ៍ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | |
| ២០ | ការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការរៀបចំរដ្ឋបាលសង្កាត់ចំណុះស្រុក | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | បាននិងកំពុងសិក្សា |
| ២១ | ការពិនិត្យនិងកែសម្រួលសៀវភៅកិច្ចការរដ្ឋបាលឃុំ សង្កាត់ | សៀវភៅណែនាំ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | បាននិងកំពុងសិក្សា |
| ២២ | ការកំណត់លក្ខណៈវិនិច្ឆ័យនៃការរៀបចំរដ្ឋបាលក្រុង | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | បាននិងកំពុងសិក្សា |
| ២៣ | ការសិក្សា និងពិនិត្យមើលឡើងវិញលើការរៀបចំរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. **ស្ថាប័នចូលរួម៖** ក្រសួងពាក់ព័ន្ធ | បាននិងកំពុងសិក្សា |
| ២៤ | ការសិក្សាពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ **ស្ថាប័នចូលរួម៖** ក្រសួងពាក់ព័ន្ធ | បាននិងកំពុងសិក្សា |

| | | | | | |
|---|---|---|---|---|---|
| ២៥ | ការសិក្សាពីលទ្ធភាពនៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពបរិវត្តកម្មឌីជីថលសម្រាប់រដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | បាននិងកំពុងសិក្សា |
| ២៦ | ការកំណត់មុខងារជាក់លាក់សម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងធនធានធម្មជាតិ | បញ្ជីមុខងារ | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ | បាននិងកំពុងសិក្សា |
| ២៧ | ការរៀបចំយន្តការ គោលការណ៍ និងនីតិវិធីនៃការប្រឡងប្រជែងជើងឯកផ្តល់សេវាសាធារណៈ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ<br>**ស្ថាប័នចូលរួម៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងពាក់ព័ន្ធ | បាននិងកំពុងរៀបចំ |
| ២៨ | ការរៀបចំ និងដាក់ឱ្យអនុវត្តសេចក្តីណែនាំបច្ចេកទេស និងការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរ | សេចក្តីណែនាំ និងវគ្គបណ្តុះបណ្តាល | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងផ្ទេរមុខងារ | បាននិងកំពុងរៀបចំ |

| | | | | | |
|---|---|---|---|---|---|
| ២៩ | ការសិក្សា និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាវិស័យសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងសិក្សាអំពីលទ្ធភាពនៃការធ្វើប្រតិភូកម្មមុខងារសមស្របមួយចំនួនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និង ក្រសួងសុខាភិបាល | បាន និងកំពុងរៀបចំវាយតម្លៃ |
| ៣០ | ការសិក្សា និងពិនិត្យមើលអំពីលទ្ធភាពនៃការផ្ទេរមុខងារគ្រប់គ្រងសត្តឃាតដ្ឋានទៅឱ្យរដ្ឋបាលក្រុង ស្រុក | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | |
| ៣១ | ការសិក្សាអំពីបន្ទុកការងាររបស់ឃុំ សង្កាត់ ដើម្បីកំណត់អំពីតម្រូវការបុគ្គលិក និងលទ្ធភាពបង្កើនថវិកាបន្ទុកបុគ្គលិកនៅថ្នាក់ឃុំ សង្កាត់ | របាយការណ៍ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងមុខងារសាធារណៈ | |
| ៣២ | ការសិក្សាអំពីតម្រូវការនៃការបណ្តុះបណ្តាលដល់ស្មៀនឃុំ សង្កាត់ ការរៀបចំកម្មវិធីសិក្សាជាក់លាក់សម្រាប់អភិវឌ្ឍសមត្ថភាពដល់ស្មៀនឃុំ សង្កាត់ដែលត្រូវធ្វើឡើងជាប្រចាំ ព្រមទាំងគិតគូរអំពីវិធីសាស្ត្រសមស្របដើម្បីផ្តល់ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាទាំងថ្មី និងចាស់យ៉ាងហោចណាស់មួយដងក្នុង១អាណត្តិ | របាយការណ៍ និងវគ្គបណ្តុះបណ្តាល | ឆ្នាំ២០២៥-២០២៧ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន)<br>**ស្ថាប័នចូលរួម៖** ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ | |

| | | | | | |
|---|---|---|---|---|---|
| ៣៣ | ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងសមត្ថភាព និងលទ្ធភាពរបស់ទីចាត់ការគ្រប់គ្រងធនធានមនុស្សថ្នាក់រាជធានីខេត្ត តាមរយៈការរៀបចំឱ្យមានក្រុមគ្រូបង្គោលដើម្បីរួមចំណែកដល់ការផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | វគ្គបណ្តុះបណ្តាល | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន)<br>**ស្ថាប័នចូលរួម៖** ក្រសួងមុខងារសាធារណៈ និងក្រសួងពាក់ព័ន្ធ | |
| ៣៤ | ការផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងចំណូលសេវាសាធារណការជូនរដ្ឋបាលរាជធានី ខេត្តលើមុខងារដែលបានផ្ទេរប្រតិភូកម្ម | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងមហាផ្ទៃ | |
| ៣៥ | ការផ្តល់ព័ត៌មាន និងការពិគ្រោះយោបល់អំពីការរៀបចំគម្រោងអភិវឌ្ឍន៍ និងគម្រោងវិនិយោគសាធារណៈរបស់ក្រសួងសាមីនីមួយៗដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | | ជាប្រចាំ | **ស្ថាប័នដឹកនាំ៖** ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | |
| ៣៦ | ការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំកាតគ្រីម៉ូតូ និងការចុះបញ្ជីស្លាកលេខ និងប័ណ្ណសម្គាល់ទោចក្រយានយន្ត | | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ និងក្រសួងសាធារណការ និងដឹកជញ្ជូន | |

| | | | | | |
|---|---|---|---|---|---|
| ៣៧ | ការសិក្សា និងពិនិត្យមើលអំពីលទ្ធភាពនៃការអនុញ្ញាតឱ្យរដ្ឋបាលក្រុង ស្រុកទទួលបានចំណូលសួយសារពីធនធានរ៉ែដែលរដ្ឋបាលក្រុង ស្រុកបានផ្តល់អាជ្ញាប័ណ្ណ | របាយការណ៍ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងរ៉ែ និងថាមពល ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| ៣៨ | ការដាក់ចេញប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃសេវាក្នុងវិស័យរ៉ែដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក | ប្រកាសអន្តរក្រសួង | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល និងក្រសួងមហាផ្ទៃ | |
| ៣៩ | ការពិនិត្យមើលឡើងវិញអំពីគោលការណ៍ នីតិវិធី និងសំណុំឯកសារភ្ជាប់ពាក់ព័ន្ធនឹងសេវាសុរិយោដី និងសំណង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | |
| ៤០ | ការធ្វើសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនជាមួយកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបានធ្វើសន្ទានកម្ម | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងមហាផ្ទៃ | បាននិងកំពុងរៀបចំ |
| ៤១ | ការពិនិត្យ ពិភាក្សា និងដោះស្រាយបញ្ហាលើប្រភេទសេវារដ្ឋបាលដែលបានធ្វើប្រតិភូកម្មទៅឱ្យរាជធានី ខេត្ត រួមមាន (១).ការចុះបញ្ជីយានយន្ត (វិស័យសាធារណការ) (២). ការចុះបញ្ជីបង្កើតសិប្បកម្មដែលគ្មានហានិភ័យដើមទុនតិចជាង ឬស្មើ២មុឺនដុល្លារ (វិស័យឧស្សាហកម្ម) | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | |

| | | | | | |
|---|---|---|---|---|---|
| | (៣).ការផ្តល់វិញ្ញាបនបត្រដំណើរការសិប្បកម្មគ្មានហានិភ័យដើមទុនតិចជាង ឬស្មើ២ម៉ឺនដុល្លារ (វិស័យឧស្សាហកម្ម) ដើម្បីឱ្យរដ្ឋបាលរាជធានី ខេត្តអាចអនុវត្តបាន | | | | |
| ៤២ | ការរៀបចំការផ្តល់សេវាជាកញ្ចប់នៅការិយាល័យ/អង្គភាពច្រកចេញចូលតែមួយ និងផ្តល់សេវាអនឡាញ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ<br>**ស្ថាប័នចូលរួម៖** ក្រសួងពាក់ព័ន្ធ | កំពុងសិក្សា និងអនុវត្តសាកល្បង |
| ៤៣ | ការណែនាំអំពីការពង្រឹងការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | សេចក្តីណែនាំ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត | |
| ៤៤ | ការសិក្សា និងពិនិត្យមើលអំពីមុខងារសវនកម្មផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | |
| ៤៥ | ការសិក្សា និងរៀបចំកំណត់លក្ខណៈវិនិច្ឆ័យនៃការបង្កើតភូមិថ្មី ការបង្រួម និងការរំសាយភូមិ ស្របតាមស្ថានភាពវិវឌ្ឍន៍នៃសេដ្ឋកិច្ច-សង្គម ប្រជាសាស្ត្រ និងភូមិសាស្ត្របច្ចុប្បន្ន | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | |

| | | | | | |
|---|---|---|---|---|---|
| ៤៦ | ការរៀបចំកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | |
| ៤៧ | ការសិក្សាអំពីជម្រើសនានាក្នុងការរៀបចំប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីបំពេញការងារនៅរដ្ឋបាលក្រុង ស្រុក ជាពិសេសនៅស្រុកជនបទ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | |
| ៤៨ | ការរៀបចំប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្មសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងពាក់ព័ន្ធ | |
| ៤៩ | ការរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ជាតិ | ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ | |
| ៥០ | ការសិក្សា និងពិនិត្យមើលឡើងវិញលើសមាសភាគវិភាជន៍ថវិកាឱ្យបានសមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច | របាយការណ៍ | ឆ្នាំ២០២៨ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | |

| | | | | | |
|---|---|---|---|---|---|
| ៥១ | ការសិក្សាអំពីលទ្ធភាពថវិកាសម្រាប់ការអនុវត្តមុខងារជាភ្នាក់ងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់ | របាយការណ៍ | ឆ្នាំ២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | |
| ៥២ | ការពិនិត្យមើលឡើងវិញពីក្របខ័ណ្ឌពេលវេលារៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | |
| ៥៣ | ការរៀបចំគោលការណ៍ណែនាំអំពីការគ្រោងកញ្ចប់ថវិកាសម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលសាមីនីមួយៗ | សេចក្តីណែនាំ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | |
| ៥៤ | ការរៀបចំឱ្យមានយន្តការងាយស្រួល និងឆាប់រហ័សសម្រាប់ការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិដីធ្លីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | |
| ៥៥ | ការផ្ទេរជាផ្លូវការនូវទ្រព្យសម្បត្តិភ្ជាប់ទៅនឹងមុខងារដែលបានផ្ទេរមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងពាក់ព័ន្ធ និង លេខាធិការដ្ឋាន គ.ជ.អ.ប. | |
| ៥៦ | ការផ្សព្វផ្សាយអំពីនីតិវិធីនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងការពន្លឿនការអនុវត្តនីតិវិធីនៃការជម្រះបញ្ជីសារពើពន្ធទ្រព្យសម្បត្តិរដ្ឋ | វគ្គផ្សព្វផ្សាយ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |

| | | | | | |
|---|---|---|---|---|---|
| ៥៧ | ការសិក្សាលទ្ធភាពនៃការកំណត់ប៉ារ៉ាម៉ែត្រនៃការវិភាជឧបត្ថម្ភធនជូនរដ្ឋបាលរាជធានី ខេត្តតាមរូបមន្ត និងការបង្កើនការបែងចែកចំណូលមិនមែនសារពើពន្ធតាមរយៈយន្តការមូលនិធិភាគរភាព និងធនធានបន្ថែមពី Capital Gain Taxes ពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | កំពុងសិក្សា និងរៀបចំ |
| ៥៨ | ការផ្សព្វផ្សាយអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ ដើម្បីមានមូលដ្ឋានក្នុងការកំណត់ប្រភេទមុខតំណែងវិជ្ជាជីវៈនិងចំនួនបុគ្គលិកតាមមុខតំណែងវិជ្ជាជីវៈនីមួយៗ | ចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានកំណត់មុខតំណែងវិជ្ជាជីវៈ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. | បានអនុវត្តសាកល្បងនៅខេត្តសៀមរាប |
| ៥៩ | ការរៀបចំវិធីសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីជំនាញនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយមានកិច្ចសហការរវាងសាលាជាតិរដ្ឋបាលមូលដ្ឋាន និងសាលាភូមិន្ទរដ្ឋបាល | វិធីសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាល | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ (សាលាជាតិរដ្ឋបាលមូលដ្ឋាន) និងក្រសួងមុខងារសាធារណៈ (សាលាភូមិន្ទរដ្ឋបាល) | |
| ៦០ | ការកំណត់អំពីមុខតំណែងវិជ្ជាជីវៈនៅតាមអង្គភាពនីមួយៗនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីមានមូលដ្ឋានកំណត់អំពីតម្រូវការធនធានមនុស្សជាក់ស្តែង | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋានគ.ជ.អ.ប. | |

| | | | | | |
|---|---|---|---|---|---|
| | ឆ្លើយតបទៅនឹងមុខងារនិងតួនាទីភារកិច្ចរបស់អង្គភាពនីមួយៗ | | | | |
| ៦១ | ការសិក្សាអំពីលទ្ធភាព ក្របខ័ណ្ឌពេលវេលា និងជម្រើសនានាសម្រាប់ការផ្តល់ប្រាក់សោធននិវត្តន៍ដល់សមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងប្រាក់លំហែមាតុភាពសម្រាប់ក្រុមប្រឹក្សាជាស្ត្រី ព្រមទាំងការបង្កើនប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិ | លិខិតបទដ្ឋានគតិយុត្ត | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ<br>**ស្ថាប័នចូលរួម៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គម | |
| ៦២ | ការពិនិត្យមើលឡើងវិញអំពីគោលការណ៍ លក្ខណសម្បត្តិ និងនីតិវិធីនៃការជ្រើសរើសថ្នាក់ដឹកនាំភូមិ | របាយការណ៍ | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ | |
| ៦៣ | ការពិនិត្យមើលឡើងវិញនូវអត្រាវិភាជន៍ថវិកាទៅមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ និងលទ្ធភាពបន្ថែមថវិកាទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់តាមរយៈយន្តការមូលនិធិភាតរភាព | របាយការណ៍ | ឆ្នាំ២០២៥-២០២៨ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | |
| ៦៤ | ការរៀបចំសេចក្តីណែនាំ ដើម្បីពង្រឹងការរៀបចំ និងបញ្ចូលគម្រោងអាទិភាពនានាដែលស្នើឡើងតាមរយៈវេទិកាសាធារណៈទៅក្នុងកម្មវិធីវិនិយោគពីរឆ្នាំរំកិល/ | សេចក្តីណែនាំ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. |  |

| | | | | | |
|---|---|---|---|---|---|
| | ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | |
| ៦៥ | ការរៀបចំផែនការសាងសង់អគាររដ្ឋបាលស្រុកឱ្យបានសមស្រប | ផែនការ | ឆ្នាំ២០២៥-២០២៦ | **ស្ថាប័នដឹកនាំ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | |
| ៦៦ | ការរៀបចំប្លង់រៀបចំនគរូបនីយកម្ម និងប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោលប្រើប្រាស់ដីធ្លីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | គ្រប់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ឆ្នាំ២០២៥-២០២៨ | **ស្ថាប័នដឹកនាំ៖** ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | |
| ៦៧ | ការសិក្សា និងលើកយោបល់អំពីការរៀបចំឱ្យមានប្រព័ន្ធការងារមួយដែលផ្សារភ្ជាប់គ្នារវាងមន្ត្រីកសិកម្មឃុំ ជាមួយនឹងការិយាល័យកសិកម្ម ធនធានធម្មជាតិ រដ្ឋបាលក្រុង ស្រុក និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម | របាយការណ៍ | ឆ្នាំ២០២៥ | **ស្ថាប័នដឹកនាំ៖** ក្រសួងមុខងារសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងមហាផ្ទៃ | |

បោះពុម្ពដោយលេខាធិការដ្ឋាន គ.ជ.អ.ប

លេខាធិការដ្ឋាន គ.ជ.អ.ប.
NCDD Secretariat
ក្រសួងមហាផ្ទៃ (លេខាធិការដ្ឋាន គ.ជ.អ.ប), មហាវិថីព្រះនរោត្តម,
សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ
Ministry of Interior's Compound (NCDDs), Norodom Boulevard,
Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh, 12301, Cambodia

លេខាធិការដ្ឋាន គ.ជ.អ.ប.
F facebook.com/ncdds
W www.ncdd.gov.kh
@ info@ncdd.gov.kh
@NCDDSecretariat

ទាញយករបាយការណ៍នេះ